# អារម្ភកថា

សេចក្តីប្រកាសសហស្សវត្សរ៍ ត្រូវបានអនុម័តដោយប្រទេសសមាជិកចំនួន ១៨៩ នាមហាសន្និបាតអង្គការសហប្រជាជាតិកាលពីខែកញ្ញា ឆ្នាំ២០០០ ដោយនៅពេលនោះ មេដឹកនាំពិភពលោកទាំងអស់បានព្រមព្រៀងគ្នាលើគោលដៅ និងចំនុចដៅមួយចំនួនដែលមានកំនត់ពេលវេលាច្បាស់លាស់ និងអាចវាស់បាន ដើម្បីប្រយុទ្ធនឹងភាពក្រីក្រធ្ងន់ធ្ងរ ភាពអត់ឃ្លាន ជំងឺនានា អនក្ខរកម្ម ភាពរិចរឹលនៃបរិស្ថាន និងការរើសអើងចំពោះស្ត្រី។ គោលដៅទាំងនេះ គឺជាផ្នែកមួយនៃទិសដៅអភិវឌ្ឍន៍សកល ដែលត្រូវបានប្រទេសជាសមាជិកអង្គការសហប្រជាជាតិអនុម័តកាលពីប៉ុន្មានឆ្នាំមុន ហើយបច្ចុប្បន្ននេះត្រូវបានហៅថាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs)។

រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តយ៉ាងម៉ឹងម៉ាត់ ដើម្បីបំពេញគំលាតរវាងការប្តេជ្ញាចិត្តរបស់ពិភពលោកនិងការរីកចំរើនរបស់ជាតិ រវាងលទ្ធផលនៃការអភិវឌ្ឍន៍ថ្នាក់ជាតិ និងភាពខុសគ្នានៅមូលដ្ឋានទៅតាមទីតាំងភូមិសាស្ត្រ និងស្ថានភាពយេនឌ័រ។ ក្រោយថ្ងៃ ៧ មករា ឆ្នាំ១៩៧៩ កម្ពុជាបានផ្តួចផ្តើមអោយមានដំណើរការអភិវឌ្ឍន៍ជាបន្តបន្ទាប់ ដែលទទួលបានលទ្ធផលគួរអោយកត់សំគាល់។ បន្ទាប់ពីការបោះឆ្នោតជាតិ ឆ្នាំ១៩៩៣ ដោយកសាងបន្ថែមទៅលើសមិទ្ធិផលទាំងនោះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តជំរុញការងារអភិវឌ្ឍន៍អោយកាន់តែខ្លាំងក្លាថែមទៀត លើកកំពស់សមត្ថភាពដឹកនាំ ដើម្បីអោយទទួលបានលទ្ធផលល្អប្រសើរនៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៃសង្គម បង្កើតភាពជាដៃគូដែលទុកចិត្តបាន បង្កើនការកៀរគរធនធានអភិវឌ្ឍន៍ទាំងក្នុងស្រុក និងពីអន្តរជាតិ និងលើកកំពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនេះ ដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ អោយបានដល់ប្រជាជនកម្ពុជាទូទៅ។

តាមពិត កម្ពុជាមានបញ្ហាប្រឈមមួយចំនួន ដែលត្រូវដោះស្រាយនៅលើមាគ៌ាឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ទោះបីជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ មានកំណើនសេដ្ឋកិច្ចក៏ដោយក៏ប៉ុន្តែ ភាពក្រីក្ររបស់ប្រជាជននៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់។ ការរីកចំរើននៅជនបទតាមមិនទាន់កំណើនប្រជាជន ហើយភាពគ្មានការងារធ្វើគឺជាបញ្ហាប្រឈមដ៏ចំបងមួយ។ ស្ថានភាពសុខភាព និងអនាម័យរបស់ប្រជាជនមួយចំនួននៅតែចោទជាបញ្ហានៅឡើយ។ អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ ហាក់ដូចជាមានការកើនឡើងបន្តិចក្នុងទសវត្សរ៍កន្លងទៅ ហើយការកាត់បន្ថយអត្រាមរណភាពមាតាមានការរីកចំរើនបន្តិចបន្តួចប៉ុណ្ណោះ។ ធនធានធម្មជាតិនៅកម្ពុជា ទាមទារអោយយកចិត្តទុកដាក់ជាអាទិភាព ប្រសិនបើយើងចង់រក្សាកេរ្តិ៍ដំណែលធនធានដ៏ស្តុកស្តម្ភនេះ អោយបានគង់វង្សទុកសំរាប់កូនចៅជំនាន់ក្រោយ។ បញ្ហាប្រឈមទាំងអស់នេះមានទំហំធំធេងណាស់។ ទោះបីជាយ៉ាងនេះក៏ដោយ យើងនៅតែអាចសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍បានប្រសិនបើយើងទាំងអស់គ្នាខិតខំប្រឹងប្រែងអោយអស់ពីកំលាំងកាយចិត្ត និងប្រាជ្ញាស្មារតីសំរេចអោយបាននូវសក្តានុពលនៃការអភិវឌ្ឍន៍របស់កម្ពុជា។

នេះជារបាយការណ៍ទីពីរ ស្តីពីស្ថានភាពគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ របាយការណ៍ទីមួយ ក្នុងឆ្នាំ២០០១ ដែលជាមូលដ្ឋានគ្រឹះសំរាប់ធ្វើរបាយការណ៍នានានៅពេលអនាគត និងផ្សព្វផ្សាយការយល់ដឹងដ៏ទូលំ

ទូលាយដល់គ្រប់ភាគីពាក់ព័ន្ធនានា ត្រូវបានរៀបចំឡើងដោយមានការសំរបសំរួលពីក្រុមអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា។ របាយការណ៏ភាពជឿនលឿននៃគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏ឆ្នាំ២០០៣នេះ ត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏សង្គមកិច្ច ដោយមានការចូលរួមពីគ្រប់ភាគីអភិវឌ្ឍន៏សំខាន់ៗជាច្រើន។ នៅក្នុងរបាយការណ៏នេះ បានអធិប្បាយអំពីការធ្វើមូលដ្ឋានីយកម្មនៃគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏សកល ឱ្យទៅជាគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា ដើម្បីឆ្លុះបញ្ចាំងអោយឃើញពីតថភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។ របាយការណ៏ក៏ផ្តល់ផងដែរនូវការវិភាគអំពីគោលនយោបាយ និងកម្មវិធីសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលរួមចំណែកដល់ការសំរេចគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជានីមួយៗ ហើយក៏កំណត់អំពីបញ្ហាប្រឈមចំបងៗ ដើម្បីឈានទៅសំរេចអោយបានគោលដៅទាំងនេះ និងបានដាក់ចេញនូវក្របខ័ណ្ឌការងារមួយ ដើម្បីដោះស្រាយរាល់បញ្ហាប្រឈមទាំងនោះផងដែរ។ របាយការណ៏នេះជាការងារមួយកំពុងដំណើរការ ហើយនឹងអាចកែលំអជាបន្តទៀតក្នុងពេលអនាគត ពោលគឺនៅពេលដែលកម្ពុជាមានសមត្ថភាពរឹងមាំខាងការវិភាគស្ថិតិ និងវិភាគគោលនយោបាយ។

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសំរាប់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៏របស់យើង។ ដោយមានការចងក្រងកត់ត្រានូវសកម្មភាពនានា ភាពជោគជ័យ បទពិសោធន៏ និងបញ្ហាប្រឈមនានាចំពោះមុខ របាយការណ៏នេះបានបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់យើង និងជំរុញអោយភាគីទាំងអស់បង្កើតភាពជាដៃគូអោយបានរឹងមាំ ដើម្បីអភិវឌ្ឍន៏ប្រទេសកម្ពុជា។



**ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា**

# ទីតាំងភូមិសាស្ត្រ និងស្ថានភាពប្រទេសកម្ពុជានៅតំបន់អាស៊ីអគ្នេយ៍

ប្រទេសកម្ពុជា ជាផ្នែកមួយនៃឧបទ្វីបអាស៊ីអគ្នេយ៍ ដែលមានផ្ទៃដីសរុប ១៨១០៣៥ គម$^{២}$ គឺធំជាងបន្តិចនៃពាក់កណ្តាលប្រទេសវៀតណាម ហើយប្រហែលជាមួយភាគបីនៃប្រទេសថៃ។ រយៈពេលជាង ២០ឆ្នាំ ចុងក្រោយនេះ ប្រទេសកម្ពុជា ត្រូវបានស្ថិតនៅឯកោពីសហគមន៍អន្តរជាតិដោយសារសង្គ្រាម និងទុក្ខវេទនាផ្ទៃក្នុងដែលបានចាប់ផ្តើមតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០ ហើយជាលទ្ធផល គឺការបាត់បង់ជីវិតមនុស្សជាច្រើន ក៏ដូចជាការបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ចទាំងស្រុង។ គួរកត់សំគាល់ថាបញ្ហាប្រឈមដ៏ធំមួយចំពោះការអភិវឌ្ឍន៍នៅកម្ពុជា គឺលទ្ធផលដែលបន្សល់ទុកដោយសារសង្គ្រាម។ ជាលើកទីមួយ នៅក្នុងរយៈពេលជិតបីទសវត្សរ៍ ជាមួយការត្រឡប់មកវិញនូវសន្តិភាព និងការស្តារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បន្ទាប់ពីការបោះឆ្នោតឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាបច្ចុប្បន្ន មានកាលានុវត្តភាពក្នុងការធ្វើកំណែទំរង់យ៉ាងច្រើន ដើម្បីសំរេចបានគ្រប់វិស័យទាំងអស់នៃជីវភាពសង្គម និងសេដ្ឋកិច្ច។ តាមលក្ខណៈរដ្ឋបាល ប្រទេសកម្ពុជាត្រូវបានបែងចែកជា ២៤ ខេត្ត/ក្រុង ១៨៥ ស្រុក/ខ័ណ្ឌ ១៦២១ ឃុំ/សង្កាត់ និង ១៣៧០៧ ភូមិ ( ឯកសារ គ.ជ.ប ២០០៣) ។



## តារាងសង្ខេប ស្តីអំពីសូចនាករអភិវឌ្ឍន៍សំខាន់ៗ

| សូចនាករ | កម្ពុជា | ឡាវ | ថៃ | វៀតណាម | ភូមា | ម៉ាឡេស៊ី |
|---|---|---|---|---|---|---|
| លំដាប់នៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស | ១៣០ | ១៣៥ | ៧៤ | ១០៩ | ១៣១ | ៥៨ |
| សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០១ | ០,៥៥៦ | ០,៥២៥ | ០,៧៦៨ | ០,៦៨៨ | ០,៥៤៩ | ០,៧៩០ |
| សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ | ០,៥៥១ | ០,៥១៨ | ០,៧៦៦ | ០,៦៨៧ | គ្មាន | ០,៧៨៤ |
| សន្ទស្សន៍ Gini ក្នុងប្រាក់ចំណូល/ចំណាយប្រើប្រាស់ | ៤០,៤ | ៣៧ | ៤៣,២ | ៣៦,១ | គ្មាន | ៤៩,២ |
| សន្ទស្សន៍ការអប់រំ | ០,៦៤ | ០,៦៣ | ០,៨៨ | ០,៨៣ | ០,៧២ | ០,៨៣ |
| ចំនួនប្រជាជន (គិតជាលាននាក់) ឆ្នាំ២០០១ | ១៣ ,៥ | ៥,៤ | ៦១,៦ | ៧៩,២ | ៤៨,២ | ២៣,៥ |
| អត្រាកំណើនប្រជាជន ឆ្នាំ២០០១ | ២,៥ | ២,២ | ១,៥ | ១,៩ | ១,៨ | ២,៥ |
| អត្រាលទ្ធភាពបង្កកំនើតសរុប | ៤,៨ | ៤,៨ | ១,៩ | ២,៣ | ២,៩ | ២,៩ |
| ផលិតផលក្នុងស្រុកសរុបសំរាប់មនុស្សម្នាក់ ឆ្នាំ២០០១ | ២៧៨ | ៣២៦ | ១៨៧៤ | ៤១១ | គ្មាន | ៣៦៩៩ |
| អាំងស៊ីដង់ភាពក្រីក្រ ឆ្នាំ២០០០ (%) | ៣៦,១ | ៣៨,៦ | ១៣,១ | គ្មាន | គ្មាន | គ្មាន |
| អាយុកាលមធ្យមគិតពីកំណើត ឆ្នាំ២០០១ | ៥៧,៤ | ៥៣,៩ | ៦៨,៩ | ៦៨,៦ | ៥៧,០ | ៧២,៨ |
| លទ្ធភាពទទួលបានទឹកស្អាតនៅជនបទ ឆ្នាំ២០០០ (%) | ២៦ | ២៩ | ៨១ | ៧២ | ៦៦ | ៩៤ |
| អត្រាប្រេវ៉ាឡង់មេរោគអេដស៏ក្នុងចំណោមមនុស្សពេញវ័យ ឆ្នាំ២០០១[១] | ២,៧ | < ០,១ | ១,៨ | ០,៣ | គ្មាន | ០,៤ |
| ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ឆ្នាំ២០០០ | ៥២,៩ | ៥៤,៤ | ២៨,៩ | ៣០,២ | ៥២,៣ | ៥៨,៧ |

ប្រភព: របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០៣, UNDP ។

[១] http://www.unaids.org ។

# មាតិកា


អារម្ភកថា i

ទីតាំងភូមិសាស្ត្រប្រទេសកម្ពុជានៅក្នុងអាស៊ីអគ្នេយ៍ iii

តារាងសង្ខេប ស្តីអំពីសូចនាករអភិវឌ្ឍន៍សំខាន់ៗ iv

មាតិកា v

សូចនាករ និងចំណុចដៅ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក) xi

ស្ថានភាពនៃ គអសក សង្ខេប xvii

សន្ទស្សន៍រួមរបស់ គអសក តាមខេត្ត/ក្រុង xx

សេចក្តីសង្ខេប xxii

បញ្ជីអក្សរកាត់ xxvii

សេចក្តីផ្តើម ១

**ផ្នែកទី១: បរិបទអភិវឌ្ឍន៍ និងដំណើរការ គអស នៅក្នុងប្រទេសកម្ពុជា** ២

១.១ លក្ខណៈរចនាសម្ព័ន្ធ និងប្រវត្តិសាស្ត្រថ្មីៗ របស់កម្ពុជា ៣

១.២ ភាពអំណោយផលសំរាប់ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ៤

១.៣ បញ្ហាប្រឈម និងការអនុវត្តន៍នៃកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចក្នុងរយៈពេលមួយទសវត្សរ៍មុន ៦

១.៣.១ កំនើនសេដ្ឋកិច្ច ៧

១.៣.២ វិសមភាព ៨

១.៣.៣ ចំនួនប្រជាជន ៨

១.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលកម្ពុជា ១០

១.៥ ដំណើរការរៀបចំ គអសក ១១

**ផ្នែកទី២: គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា: បញ្ហាប្រឈម និងក្របខ័ណ្ឌការងារ** ១៣

២ សេចក្តីផ្តើម ១៤

២.១ គោលដៅទី១: លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ ១៤

២.១.១ សូចនាករ និងចំណុចដៅរបស់ គអសក១ ១៤

២.១.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក១ ១៦

២.១.៣ គោលនយោបាយ និងកម្មវិធីបច្ចុប្បន្នសំខាន់ៗដែលរួមចំណែកដល់ គអសក១ ១៨

២.១.៤ បញ្ហាប្រឈមជាគន្លឹះៗ ក្នុងការសំរេចចំណុចដៅនៃ គអសក១ ១៩

២.១.៥ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃ គអសក១ ២០

២.១.៦ ភាពខុសគ្នាតាមតំបន់ ក្នុងការសំរេចចំណុចដៅនៃ គអសក១ ២៣

២.២ គោលដៅទី២: សំរេចឱ្យបានជាទូទៅការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ ២៥
២.២.១ សូចនាករ និងចំណុចដៅនៃ គអសក២ ២៥
២.២.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក២ ២៦
២.២.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្នដែលរួមចំណែកដល់ គអសក២ ៣២
២.២.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក២ ៣៣
២.២.៥ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃ គអសក២ ៣៤
២.២.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក២ ៣៥
២.៣ គោលដៅទី៣: លើកតំកើងសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ៣៨
២.៣.១ សូចនាករ និងចំណុចដៅនៃ គអសក៣ ៣៨
២.៣.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៣ ៤០
២.៣.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក៣ ៤២
២.៣.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៣ ៤៤
២.៣.៥ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៣ ៤៤
២.៣.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៣ ៤៦
២.៤ គោលដៅទី៤: កាត់បន្ថយមរណភាពកុមារ ៤៨
២.៤.១ សូចនាករ និងចំណុចដៅនៃ គអសក៤ ៤៨
២.៤.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៤ ៤៩
២.៤.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក៤ ៥០
២.៤.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៤ ៥១
២.៤.៥ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៤ ៥២
២.៤.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៤ ៥២
២.៥ គោលដៅទី៥: លើកកំពស់សុខភាពមាតា ៥៥
២.៥.១ សូចនាករ និងចំណុចដៅនៃ គអសក៥ ៥៥
២.៥.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៥ ៥៦
២.៥.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្នដែលរួមចំណែកដល់ គអសក៥ ៥៨
២.៥.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៥ ៥៩
២.៥.៥ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៥ ៥៩
២.៥.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៥ ៦០
២.៦ គោលដៅទី៦: ប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺដទៃទៀត ៦២
២.៦.១ សូចនាករ និងចំណុចដៅនៃ គអសក៦ ៦២
២.៦.២ មេរោគអេដស៍/ជំងឺអេដស៍ ៦៤
២.៦.២.១ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៦ ស្តីពីមេរោគ អេដស៍/ជំងឺអេដស៍ ៦៤

២.៦.២.២ គោលនយោបាយ និងកម្មវិធីសំខាន់ៗនាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់មេរោគអេដស៍/ជម្ងឺអេដស៍ ៦៦
២.៦.២.៣ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃមេរោគអេដស៍/ជម្ងឺអេដស៍ ៦៧
២.៦.២.៤ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃមេរោគអេដស៍/ជម្ងឺអេដស៍ ៦៨
២.៦.៣ ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម ៦៩
២.៦.៣.១ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៦ ស្តីពីជំងឺគ្រុនចាញ់ និងគ្រុនឈាម ៦៩
២.៦.៣.២ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ជម្ងឺគ្រុនចាញ់ និងគ្រុនឈាម ៦៩
២.៦.៣.៣ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺគ្រុនចាញ់ និងគ្រុនឈាម ៧១
២.៦.៣.៤ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺគ្រុនចាញ់ និងគ្រុនឈាម ៧២
២.៦.៤ ជំងឺរបេង ៧៣
២.៦.៤.១ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៦ ស្តីពីជំងឺរបេង ៧៣
២.៦.៤.២ គោលនយោបាយ និងកម្មវិធីសំខាន់ៗនាពេលបច្ចុប្បន្នដែលរួមចំណែកដល់ជម្ងឺរបេង ៧៣
២.៦.៤.៣ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចបាននូវចំណុចដៅនៃជម្ងឺរបេង ៧៤
២.៦.៤.៤ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺរបេង ៧៥
២.៦.៥ ភាពខុសគ្នាតាមតំបន់ ក្នុងការសំរេចចំណុចដៅនៃ គអសក៦ ៧៥
២.៧ គោលដៅទី៧: ធានាចីរភាពបរិស្ថាន ៧៨
២.៧.១ សូចនាករ និងចំណុចដៅនៃ គអសក៧ ៧៨
២.៧.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៧ ៨០
២.៧.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗនាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក៧ ៨២
២.៧.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៧ ៨៣
២.៧.៥ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៧ ៨៥
២.៧.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៧ ៨៦
២.៨ គោលដៅទី៨: បង្កើតភាពជាដៃគូជាសកលសំរាប់កិច្ចអភិវឌ្ឍន៍ ៨៨
- ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ៨៩
- បច្ចេកវិទ្យា គមនាគមន៍ ពតិមានវិទ្យា (ICT) ៩១

- ភាពជាដៃគូ ដើម្បីនិរន្តភាពនៃការអភិវឌ្ឍន៍នៅកម្ពុជា ៩២
- លទ្ធភាពរកទីផ្សារ/ពាណិជ្ជកម្ម ៩៣
- បំណុល ៩៤
២.៩ គោលដៅទី៩: ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ ៩៥
២.៩.១ ចំណុចដៅ និងសូចនាករ គអសក៩ ៩៥
២.៩.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៩ ៩៥
២.៩.៣ គោលនយោបាយ និងកម្មវិធីបច្ចុប្បន្នសំខាន់ៗ ដែលរួមចំណែកដល់ គអសក៩ ៩៧
២.៩.៤ បញ្ហាប្រឈមជាគន្លឹះ ក្នុងការសំរេចចំណុចដៅនៃ គអសក៩ ៩៨
២.៩.៥ ក្របខ័ណ្ឌការងារឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ក្នុងការសំរេចបាន គអសក៩ ៩៩
២.៩.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៩ ១០០

**ផ្នែកទី៣: វិធីសាស្ត្រតាមដាន និងការវាយតំលៃលើភាពជឿនលឿនរបស់ គអសក** ១០២
៣.១ ការតាមដានលើភាពជឿនលឿននៃ គអសក ១០៣
៣.២ ការវាយតំលៃជំរើសខាងគោលនយោបាយ ដើម្បីសំរេចបាន គអសក ១០៤
៣.៣ ក្របខ័ណ្ឌស្ថាប័ន ដើម្បីតាមដាន និងវាយតំលៃលើ គអសក ១០៥
៣.៤ ប្រព័ន្ធគ្រប់គ្រងពត៌មានភាពក្រីក្រកម្ពុជា ១០៦

**ឯកសារយោង** ១០៨
ឧបសម្ព័ន្ធ ក : សន្ទានុក្រមពាក្យបច្ចេកទេស ១១២
ឧបសម្ព័ន្ធ ខ : វិធីសាស្ត្រ ១២២
ឧបសម្ព័ន្ធ គ : វិធីសាស្ត្រគណនាសន្ទស្សន៍រួមនៃ គអសក ១២៥

**បញ្ជីតារាង**

តារាង ១.១: សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចថ្មីៗ សំរាប់កម្ពុជា ៩
តារាង ២.១.១: មូលដ្ឋានីយកម្មនៃ គអស១ ឱ្យទៅជា គអសក១ ១៤
តារាង ២.១.២: ឆ្នាំជាមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក១ តាមលំដាប់ឆ្នាំ ១៥
តារាង ២.១.៣: សន្ទស្សន៍រួមនៃ គអសក១ តាមខេត្ត/ក្រុង ២៤
តារាង ២.២.១: មូលដ្ឋានីយកម្មនៃ គអស២ ទៅជា គអសក២ ២៥
តារាង ២.២.២: ឆ្នាំជាមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក២ តាមលំដាប់ឆ្នាំ ២៦
តារាង ២.២.៣: សន្ទស្សន៍រួមនៃ គអសក២ តាមខេត្ត/ក្រុង ៣៧
តារាង ២.៣.១: មូលដ្ឋានីយកម្មនៃ គអស៣ ទៅជា គអសក៣ ៣៨
តារាង ២.៣.២: ឆ្នាំជាមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក៣ តាមលំដាប់ឆ្នាំ ៣៩

តារាង ២.៣.៣: សន្ទស្សន៍រួមនៃ គអសក៣ តាមខេត្ត/ក្រុង ៤៧
តារាង ២.៤.១: មូលដ្ឋានីយកម្មនៃ គអស៤ ទៅជា គអសក៤ ៤៨
តារាង ២.៤.២: ឆ្នាំជាមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក៤ តាមលំដាប់ឆ្នាំ ៤៨
តារាង ២.៤.៣: សន្ទស្សន៍រួមនៃ គអសក៤ តាមខេត្ត/ក្រុង ៥៤
តារាង ២.៥.១: មូលដ្ឋានីយកម្មនៃ គអស៥ ទៅជា គអសក៥ ៥៥
តារាង ២.៥.២: ឆ្នាំជាមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក៤ តាមលំដាប់ឆ្នាំ ៥៦
តារាង ២.៥.៣: សន្ទស្សន៍រួមនៃ គអសក៥ តាមខេត្ត/ក្រុង ៦១
តារាង ២.៦.១: មូលដ្ឋានីយកម្មនៃ គអស៦ ទៅជា គអសក៦ ៦២
តារាង ២.៦.២: ឆ្នាំជាមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក៦ តាមលំដាប់ឆ្នាំ ៦៣
តារាង ២.៦.៣: សន្ទស្សន៍រួមនៃ គអសក៦ តាមខេត្ត/ក្រុង ៧៧
តារាង ២.៧.១: មូលដ្ឋានីយកម្មនៃ គអស៧ ទៅជា គអសក៧ ៧៨
តារាង ២.៧.២: ឆ្នាំជាមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក៧ តាមលំដាប់ឆ្នាំ ៧៩
តារាង ២.៧.៣: សន្ទស្សន៍រួមនៃ គអសក៧ តាមខេត្ត/ក្រុង ៨៧
តារាង ២.៨.១: ចំណុចដៅ និងសូចនាករជាសកលនៃ គអស៨ ៨៨
តារាង ២.៩.១: ឆ្នាំជាមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក៩ តាមលំដាប់ឆ្នាំ ៩៥
តារាង ២.៩.២: សន្ទស្សន៍រួមនៃ គអសក៩ តាមខេត្ត/ក្រុង ១០១
តារាង ៣.១: សមត្ថភាពតាមដាន និងធ្វើរបាយការណ៍ពីភាពជឿនលឿននៃ គអសក ១០៥

**បញ្ជីរូប**

រូប ២.១.១: និន្នាការ និងចំណុចដៅនៃសមាមាត្រប្រជាជន ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ថ្នាក់ជាតិ ១៦
រូប ២.១.២: និន្នាការ និងចំណុចដៅនៃសមាមាត្រប្រជាជន ដែលក្រជាងគេបំផុត ២០% ក្នុងការប្រើប្រាស់ចំណាយថ្នាក់ជាតិ ១៧
រូប ២.១.៣: និន្នាការ និងចំណុចដៅនៃសមាមាត្រប្រជាជន ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ ១៧
រូប ២.១.៤: សន្ទស្សន៍រួមនៃ គអសក១ តាមខេត្ត/ក្រុង ២៣
រូប ២.២.១: និន្នាការ និងចំណុចដៅនៃអត្រាពិតចូលរៀនថ្មី ២៧
រូប ២.២.២: និន្នាការ និងចំណុចដៅនៃអត្រាពិតនៃការសិក្សានៅបឋមសិក្សា ២៧
រូប ២.២.២.១: និន្នាការ និងចំណុចដៅនៃអត្រាពិតនៃការសិក្សានៅបឋមសិក្សា តាមភេទ ២៨
រូប ២.២.៣: និន្នាការ និងចំណុចដៅនៃអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ២៨
រូប ២.២.៣.១: និន្នាការ និងចំណុចដៅនៃអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ តាមភេទ ២៩
រូប ២.២.៤: និន្នាការ និងចំណុចដៅនៃសមាមាត្រកុមារអាយុពី ៦-១៤ឆ្នាំ ដែលមិនបានចូលរៀន ២៩
រូប ២.២.៥: និន្នាការ និងចំណុចដៅនៃអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ទី៥ ៣០
រូប ២.២.៦: និន្នាការ និងចំណុចដៅនៃអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ទី៦ ៣០

រូប ២.២.៧: និន្នាការ និងចំណុចដៅនៃអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ទី៩ ៣១
រូប ២.២.៨: និន្នាការ និងចំណុចដៅនៃអត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី ១៥ ទៅ២៤ឆ្នាំ ៣១
រូប ២.២.៩: និន្នាការ និងចំណុចដៅនៃផលធៀបចំនួនកុមារីជាមួយកុមារា ដែលរៀននៅបឋមសិក្សា ៣២
រូប ២.២.១០: និន្នាការនិងចំណុចដៅនៃផលធៀបចំនួនកុមារីជាមួយកុមារាដែលរៀននៅមធ្យមសិក្សាបឋមភូមិ ៣២
រូប ២.២.១១: សន្ទស្សន៍រួមនៃ គអសក២ តាមខេត្ត/ក្រុង ៣៦
រូប ២.៣.១: និន្នាការ និងចំណុចដៅនៃផលធៀបរវាងសិស្សស្រី និងប្រុសនៅកំរិតមធ្យមសិក្សាទុតិយភូមិ ៤០
រូប ២.៣.២: និន្នាការ និងចំណុចដៅនៃផលធៀបរវាងនិស្សិតស្រី និងប្រុសនៅឧត្តមសិក្សា ៤១
រូប ២.៣.៣: និន្នាការ និងចំណុចដៅនៃសមាមាត្រអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ ៤២
រូប ២.៣.៤: សន្ទស្សន៍រួមនៃ គអសក៣ តាមខេត្ត/ក្រុង ៤៦
រូប ២.៤.១: និន្នាការនៃអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ ៤៩
រូប ២.៤.២: និន្នាការនៃអត្រាមរណភាពទារក ៥០
រូប ២.៤.៣: សន្ទស្សន៍រួមនៃ គអសក៤ តាមខេត្ត/ក្រុង ៥៣
រូប ២.៥.១: និន្នាការ និងចំណុចដៅនៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ ៥៧
រូប ២.៥.២: សន្ទស្សន៍រួមនៃ គអសក៥ តាមខេត្ត/ក្រុង ៦០
រូប ២.៦.១: និន្នាការ និងចំណុចដៅនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥-៤៩ឆ្នាំ ៦៤
រូប ២.៦.២: និន្នាការ និងចំណុចដៅ នៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមស្ត្រីអាយុពី ១៥-២៤ឆ្នាំ បានពិនិត្យផ្ទៃពោះមុនពេលសំរាល ៦៥
រូប ២.៦.៣: សន្ទស្សន៍រួមនៃ គអសក៦ តាមខេត្ត/ក្រុង ៧៦
រូប ២.៧.១: និន្នាការ និងចំនុចដៅស្តីពីគំរបព្រៃឈើកម្ពុជា គិតជាភាគរយធៀបនឹងផ្ទៃដីប្រទេស ៨០
រូប ២.៧.២: និន្នាការ និងចំនុចដៅ ស្តីពីសមាមាត្រប្រជាជនមានទឹកស្អាតប្រើប្រាស់នៅជនបទ និងទីក្រុង/ប្រជុំជន ៨១
រូប ២.៧.៣: និន្នាការ និងចំនុចដៅស្តីពីភាគរយប្រជាជនជនបទ និងទីក្រុង/ប្រជុំជន ដែលមានប្រព័ន្ធអនាម័យប្រសើរឡើង ៨២
រូប ២.៧.៤: សន្ទស្សន៍រួមនៃ គអសក៧ តាមខេត្ត/ក្រុង ៨៦
រូប ២.៩.១: និន្នាការ និងចំណុចដៅនៃចំនួនជនស៊ីវិលរងគ្រោះដែលបានកត់ត្រា (មិនរាប់បញ្ចូលយោធា) ៩៦
រូប ២.៩.២: និន្នាការ និងចំណុចដៅនៃភាគរយផ្ទៃដីដែលបានដោះមីនលើផ្ទៃដីដែលបានសង្ស័យក្នុងកំរិតធ្ងន់ ខ្ពស់ មធ្យម និងទាប ៩៧
រូប ២.៩.៣: សន្ទស្សន៍រួមនៃ គអសក៩ តាមខេត្ត/ក្រុង ១០១
រូប ៣.១: ការបង្កើតស្ថាប័ន សំរាប់តាមដាន និងវិភាគភាពក្រីក្រនៅកម្ពុជា ១០៥
រូប ៣.២: ការបង្កើតស្ថាប័នប្រព័ន្ធគ្រប់គ្រងពតិមានភាពក្រីក្រកម្ពុជា ១០៧

## សូចនាករ និងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក)

| |
|---|
| **គអសក១: លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន** |
| **ចំណុចដៅរួមទី ១: កាត់បន្ថយឱ្យបានពាក់កណ្តាល រវាងឆ្នាំ១៩៩៣ និង២០១៥ នូវសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ** |
| ចំណុចដៅ ១.១: កាត់បន្ថយសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិពី ៣៩% នៅឆ្នាំ១៩៩៣ ទៅ១៩,៥% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ១.២: បង្កើនបមាណភាគរបស់ប្រជាជន ដែលក្រជាងគេបំផុត ២០% ក្នុងការប្រើប្រាស់ចំណាយថ្នាក់ជាតិពី ៧,៤% នៅឆ្នាំ ១៩៩៣ ទៅ១១% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ១.៣: កាត់បន្ថយសមាមាត្រកុមារធ្វើការងារ ដែលមានអាយុពី ៥-១៧ឆ្នាំ ពី១៦,៥% នៅឆ្នាំ១៩៩៩ ទៅ៨% នៅឆ្នាំ២០១៥ |
| **ចំណុចដៅរួមទី ២: កាត់បន្ថយឱ្យបានពាក់កណ្តាល រវាងឆ្នាំ១៩៩៣ និង២០១៥ នូវសមាមាត្រប្រជាជន ដែលទទួលរងនូវភាពអត់ឃ្លាន** |
| ចំណុចដៅ ១.៤: កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទំងន់ (ទំងន់ធៀបនឹងអាយុ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ ពី ៤៥,២% នៅឆ្នាំ២000 ទៅ២២% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ១.៥: កាត់បន្ថយសមាមាត្រប្រជាជន ដែលស្ថិតនៅក្រោមខ្សែបន្ទាត់ម្ហូបអាហារ ពី២០% នៅឆ្នាំ១៩៩៣ ទៅ១០% នៅឆ្នាំ ២០១៥ |
| ចំណុចដៅ ១.៦: កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃកុមារក្រិន (កំពស់ធៀបនឹងអាយុ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ ពី៤៤,៦% នៅឆ្នាំ២000 ទៅ២២% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ១.៧: កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃកុមារស្គម (ទំងន់ធៀបនឹងកំពស់ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ ពី១៥% នៅឆ្នាំ២000 ទៅ៩% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ១.៨: បង្កើនសមាមាត្រគ្រួសារ ដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ ពី១៤% នៅឆ្នាំ២000 ទៅ៩០% នៅឆ្នាំ២០១៥ |
| **គអសក២: សំរេចឱ្យបានជាទូទៅការអប់រំមូលដ្ឋានរយៈពេល ៩ ឆ្នាំ** |
| **ចំណុចដៅរួមទី ៣: ធានាឱ្យកុមារទាំងអស់បានបញ្ចប់ការសិក្សាកំរិតបឋមសិក្សា នៅមុនដំណាច់ឆ្នាំ២០១០ និងការសិក្សាកំរិតមូលដ្ឋាន រយៈពេល ៩ ឆ្នាំ នៅមុនដំណាច់ឆ្នាំ២០១៥** |
| ចំណុចដៅ ២.១: បង្កើនអត្រាពិតចូលរៀនថ្មី ពី៨១% នៅឆ្នាំ២០០១ ឱ្យឡើងដល់ ១០០% នៅឆ្នាំ២០១០ |
| ចំណុចដៅ ២.២: បង្កើនអត្រាពិតនៃការសិក្សានៅបឋមសិក្សា ពី៨៧% នៅឆ្នាំ២០០១ ឱ្យឡើងដល់ ១០០% នៅឆ្នាំ២០១០ |
| ចំណុចដៅ ២.៣: បង្កើនអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ពី១៩% នៅឆ្នាំ២០០១ ឱ្យឡើងដល់ ១០០% នៅឆ្នាំ ២០១៥ |
| ចំណុចដៅ ២.៤: កាត់បន្ថយសមាមាត្រកុមារអាយុពី ៦ ទៅ ១៤ឆ្នាំ ដែលមិនបានចូលរៀននៅសាលា ពី៣៥% នៅឆ្នាំ១៩៩៩ ឱ្យចុះដល់ 0% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ២.៥: បង្កើនអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៥ ពី៥៨% នៅឆ្នាំ២០០១ ឱ្យឡើងដល់ ១០០% នៅឆ្នាំ២០១០ |
| ចំណុចដៅ ២.៦: បង្កើនអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ (ថ្នាក់ចុងក្រោយនៃការសិក្សាកំរិតបឋមសិក្សា) ពី៥១% នៅឆ្នាំ២០០១ ឱ្យឡើងដល់ ១០០% នៅឆ្នាំ២០១០ |
| ចំណុចដៅ ២.៧: បង្កើនអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៩ (ថ្នាក់ចុងក្រោយនៃការសិក្សាកំរិតមូលដ្ឋាន) ពី៣៣% នៅឆ្នាំ២០០១ ឱ្យឡើងដល់ ១០០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ២.៨: បង្កើនអត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី ១៥-២៤ឆ្នាំ ពី៨២% នៅឆ្នាំ១៩៩៩ ឱ្យឡើងដល់១០០% នៅឆ្នាំ២០១៥ |
| **ចំណុចដៅរួមទី ៤: លុបបំបាត់វិសមភាពយេនឌ័រក្នុងការអប់រំកំរិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ ឱ្យបានមុនដំណាច់ឆ្នាំ២០១០** |
| ចំណុចដៅ ២.៩: បង្កើនផលធៀបចំនួនកុមារីជាមួយចំនួនកុមារា ដែលរៀននៅបឋមសិក្សា ពី៨៧% នៅឆ្នាំ២០០១ ឱ្យឡើងដល់ |

| |
|---|
| ១០០% នៅឆ្នាំ២០១០ |
| ចំណុចដៅ ២.១០: បង្កើនផលធៀបចំនួនកុមារីជាមួយចំនួនកុមារា ដែលរៀននៅមធ្យមសិក្សាបឋមភូមិ ពី៦៣% នៅឆ្នាំ ២០០១ ឱ្យឡើងដល់ ១០០% នៅឆ្នាំ២០១០ |
| **គអសកក៣: លើកកំពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី** |
| **ចំណុចដៅរួមទី ៥: កាត់បន្ថយគំលាតយេនឌ័រ នៅកំរិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា** |
| ចំណុចដៅ ៣.១: បង្កើនផលធៀបរវាងសិស្សស្រី និងសិស្សប្រុសនៅកំរិតមធ្យមសិក្សាទុតិយភូមិ ពី៤៨% នៅឆ្នាំ២០០១ ទៅ១០០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.២ : បង្កើនផលធៀបរវាងនិស្សិតស្រី និងនិស្សិតប្រុសនៅឧត្តមសិក្សា ពី៣៨% នៅឆ្នាំ២០០១ ដល់៨៥% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.៣: បង្កើនផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរសអាយុ ១៥-២៤ឆ្នាំ ពី៨៧% នៅឆ្នាំ១៩៩៨ ដល់១០០% នៅឆ្នាំ២០១០ |
| ចំណុចដៅ ៣.៤: បង្កើនផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរសអាយុ ២៥-៤៤ឆ្នាំ ពី៧៨% នៅឆ្នាំ១៩៩៨ ដល់១០០% នៅឆ្នាំ២០១០ |
| **ចំណុចដៅរួមទី ៦: លុបបំបាត់គំលាតយេនឌ័រ សំរាប់ការងារមានប្រៀវត្សរ៍នៅគ្រប់វិស័យសេដ្ឋកិច្ច** |
| ចំណុចដៅ ៣.៥: បង្កើនសមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យកសិកម្ម ( ប្រភេទវិស័យទី១) ពី៣៥% នៅឆ្នាំ១៩៩៨ ដល់៥០% នៅឆ្នាំ២០០៥ |
| ចំណុចដៅ ៣.៦: បង្កើនសមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យឧស្សាហកម្ម ( ប្រភេទវិស័យទី ២) ពី៤៤% នៅឆ្នាំ ១៩៩៨ ដល់៥០% នៅឆ្នាំ២០០៥ |
| ចំណុចដៅ ៣.៧: បង្កើនសមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យសេវាកម្ម ( ប្រភេទវិស័យទី ៣) ពី២១% នៅឆ្នាំ១៩៩៨ ដល់៥០% នៅឆ្នាំ២០១៥ |
| **ចំណុចដៅរួមទី ៧: លុបបំបាត់គំលាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ** |
| ចំណុចដៅ ៣.៨: បង្កើនសមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ ពី១២% នៅឆ្នាំ២០០៣ ដល់៣០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.៩: បង្កើនសមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងព្រឹទ្ធសភា ពី១៣% នៅឆ្នាំ២០០៣ ដល់៣០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.១០: បង្កើនសមាមាត្រនៃស្ត្រីជារដ្ឋមន្ត្រី ពី៨% នៅឆ្នាំ២០០៣ ដល់១៥% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.១១: បង្កើនសមាមាត្រនៃស្ត្រីជារដ្ឋលេខាធិការ ពី៦% នៅឆ្នាំ២០០៣ ដល់១៨% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.១២: បង្កើនសមាមាត្រនៃស្ត្រីជាអនុរដ្ឋលេខាធិការ ពី៥% នៅឆ្នាំ២០០៣ ដល់២០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.១៣: បង្កើនសមាមាត្រនៃស្ត្រីជាអភិបាលខេត្ត ពី០% នៅឆ្នាំ២០០៣ ដល់១០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.១៤: បង្កើនសមាមាត្រនៃស្ត្រីជាអភិបាលខេត្តរង ពី ១% នៅឆ្នាំ ២០០៣ ដល់១៥% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.១៥: បង្កើនសមាមាត្រនៃស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ពី៨% នៅឆ្នាំ២០០៣ ដល់២៥% នៅឆ្នាំ២០១៥ |
| **ចំណុចដៅរួមទី ៨: កាត់បន្ថយរាល់គ្រប់ទំរង់នៃអំពើហិង្សាចំពោះស្ត្រី និងកុមារ** |
| ចំណុចដៅ ៣.១៦: បង្កើនចំនួនករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានពិគ្រោះយោបល់ដោយបុគ្គលិកដែលមានជំនាញ អោយបាន ១០០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.១៧: បង្កើនភាគរយនៃប្រជាជនឱ្យយល់ដឹងពីអំពើហិង្សាចំពោះស្ត្រី គឺជាអកប្បកិរិយាខុសឆ្គង និងជាអំពើឧក្រិដ្ឋអោយបាន១០០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៣.១៨: តាក់តែង និងអនុវត្តច្បាប់ទាំងឡាយប្រឆាំងនឹងរាល់គ្រប់ទំរង់នៃអំពើហិង្សាចំពោះស្ត្រី និងកុមារទៅតាមល័ក្ខខ័ណ្ឌ និងនិយាមអន្តរជាតិឱ្យបាននៅឆ្នាំ២០០៥ |
| ចំណុចដៅ ៣.១៩: ប្រមូលទិន្នន័យស្ថិតិប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យអំពើហិង្សាចំពោះស្ត្រីឱ្យបាននៅឆ្នាំ២០០៥ |
| ចំណុចដៅ ៣.២០: តាក់តែង និងអនុវត្តផែនការទប់ស្កាត់អំពើហិង្សាឱ្យបាននៅឆ្នាំ២០០៥ |

| **គអសក៤: កាត់បន្ថយអត្រាមរណភាពកុមារ** |
|---|
| **ចំណុចដៅរួមទី ៩: បន្ថយអត្រាមរណភាពកុមារក្រោមអាយុ ៥ ឆ្នាំ** |
| ចំណុចដៅ ៤.១: កាត់បន្ថយអត្រាមរណភាពកុមារក្រោមអាយុ ៥ ឆ្នាំ ក្នុង១០០០ កំណើតរស់ ពី១២៤ នៅឆ្នាំ១៩៩៨ ទៅ៦៥ នៅឆ្នាំ ២០១៥ |
| ចំណុចដៅ ៤.២: កាត់បន្ថយអត្រាមរណភាពទារក ក្នុង១០០០ កំណើតរស់ ពី៩៥ នៅឆ្នាំ១៩៩៨ ទៅ៥០ នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៤.៣: បង្កើនសមាមាត្រនៃកុមារអាយុក្រោម ១ ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺកញ្ជ្រិល ពី៤១% នៅឆ្នាំ២០០០ ទៅ ៩០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៤.៤: បង្កើនសមាមាត្រនៃកុមារអាយុ ៦-៥៩ខែ បានទទួលថ្នាំវីតាមីនអា ពី២៨% នៅឆ្នាំ២០០០ ទៅ៩០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៤.៥: បង្កើនសមាមាត្រនៃកុមារអាយុក្រោម ១ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស ពី៤៣% នៅឆ្នាំ២០០០ ទៅ៩០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៤.៦: បង្កើនសមាមាត្រនៃទារកត្រូវបានបំបៅដោះ ដល់អាយុ ៦ខែ ពី១១.៤% នៅឆ្នាំ២០០០ ទៅ៤៩% នៅ ឆ្នាំ២០១៥ |
| ចំណុចដៅ ៤.៧: បង្កើនសមាមាត្រនៃម្តាយ ដែលចាប់ផ្តើមបំបៅដោះទារកទើបនឹងកើត ក្នុងរយៈពេល ១ ម៉ោងនៃកំណើត ពី១១% នៅឆ្នាំ២០០០ ទៅ៦២% នៅឆ្នាំ២០១៥ |
| **គអសក៥: លើកកំពស់សុខភាពមាតា** |
| **ចំណុចដៅរួមទី ១០: បន្ថយផលធៀបមរណភាពមាតា** |
| ចំណុចដៅ ៥.១: កាត់បន្ថយផលធៀបមរណភាពមាតា ក្នុង១០០០០០ កំណើតកូន ពី៤៣៧ នៅឆ្នាំ១៩៩៧ ទៅ១៤០ នៅឆ្នាំ ២០១៥ |
| ចំណុចដៅ ៥.២: កាត់បន្ថយអត្រាលទ្ធភាពផ្តល់កំណើតសរុប ពី ៤នាក់ នៅឆ្នាំ១៩៩៨ ទៅ៣នាក់ នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៥.៣: បង្កើនសមាមាត្រនៃការសំរាលកូន ដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ ពី៣២% នៅឆ្នាំ២០០០ ទៅ៨០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៥.៤: បង្កើនសមាមាត្រនៃស្ត្រីរៀបការដែលប្រើវិធីពន្យារកំណើតទំនើប ពី១៨.៥% នៅឆ្នាំ២០០០ ទៅ៦០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៥.៥: បង្កើនភាគរយនៃស្ត្រីមានផ្ទៃពោះ ដែលបានទទួលការពិគ្រោះមុនពេលសំរាលបានពីរដង ឬច្រើនជាង ជាមួយបុគ្គលិកសុខាភិបាលដែលមានជំនាញ ពី៣០% នៅឆ្នាំ២០០០ ទៅ៩០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៥.៦: កាត់បន្ថយសមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក ពី ៦៦% នៅឆ្នាំ២០០០ ទៅ៣៣% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៥.៧: កាត់បន្ថយសមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលមានផលធៀបទំងន់ទៅនឹងកំពស់ក្រោម ១៨.៥ គីឡូក្រាម/ម៉ែត្រការ៉េ ពី ២១% នៅឆ្នាំ២០០០ ទៅ៨% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៥.៨: កាត់បន្ថយសមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក ពី៥៨% នៅឆ្នាំ២០០០ ទៅ១៩% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៥.៩: បង្កើនសមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលសំរាលកូនដោយការវះកាត់ ពី០.៨% នៅឆ្នាំ២០០០ ទៅ៤% នៅឆ្នាំ២០១៥ |
| **គអសក៦: ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺដទៃទៀត** |
| **ចំណុចដៅរួមទី ១១: បន្ថយការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍** |
| ចំណុចដៅ ៦.១: កាត់បន្ថយអត្រាប្រេវ៉ាឡង់ នៃមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥-៤៩ឆ្នាំ ពី២.៦% នៅឆ្នាំ ២០០២ មក១.៨% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.២: កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ ក្នុងចំណោមស្ត្រីមានផ្ទៃពោះ ដែលមានអាយុពី ១៥-២៤ឆ្នាំ បានពិនិត្យផ្ទៃពោះមុនសំរាល ពី២.៧% នៅឆ្នាំ២០០២ មក១.៥% នៅឆ្នាំ២០១៥ |

| |
|---|
| ចំណុចដៅ ៦.៣: បង្កើនអត្រាប្រើស្រោមអនាម័យក្នុងចំណោមអ្នករកស៊ីផ្លូវភេទ ក្នុងពេលរួមភេទចុងក្រោយ ពី៩១% នៅឆ្នាំ២០០២ ទៅ៩៨% នៅឆ្នាំ២០០៥ |
| ចំណុចដៅ ៦.៤: បង្កើនភាគរយនៃយុវជនអាយុពី ១៥-២៤ឆ្នាំ ដែលបានរាយការណ៍ ពីការប្រើស្រោមអនាម័យ ក្នុងពេលរួមភេទជាមួយដៃគូមិនទៀងទាត់ ពី៨២% នៅឆ្នាំ២០០២ ទៅ៩៥% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.៥: បង្កើនសមាមាត្រនៃការប្រើស្រោមអនាម័យ ដែលបានរាយការណ៍ដោយស្ត្រីរៀបការ ដែលដឹងថាខ្លួន ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ពី១% នៅឆ្នាំ២០០០ ទៅ១០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.៦: បង្កើនភាគរយនៃស្ត្រីពិនិត្យផ្ទៃពោះមុនសំរាលដែលមានផ្ទុកមេរោគអេដស៍ ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្តាយទៅកូន ពី២,៧% នៅឆ្នាំ២០០២ ទៅ៥០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.៧: បង្កើនភាគរយនៃអ្នកជំងឺអេដស៍ ដែលបានទទួលថ្នាំប្រឆាំងនឹងមេរោគអេដស៍ ពី ៣% នៅឆ្នាំ២០០២ ទៅ៧៥% នៅឆ្នាំ២០១៥ |
| **ចំណុចដៅរួមទី ១២: បន្ថយការរីករាលដាល នៃជម្ងឺគ្រុនចាញ់ ជម្ងឺគ្រុនឈាម និងជម្ងឺរបេង** |
| ចំណុចដៅ ៦.៨: កាត់បន្ថយអត្រាស្លាប់ដោយសារជម្ងឺគ្រុនចាញ់ ដែលបានរាយការណ៍ ដោយវិស័យសុខាភិបាលសាធារណៈ ពី០,៤% នៅឆ្នាំ២០០០ ទៅ០,១% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.៩: បង្កើនសមាមាត្រនៃប្រជាជននៅតំបន់មានជម្ងឺគ្រុនចាញ់ខ្ពស់ ដែលប្រើមុងជ្រលក់ថ្នាំកាលពីយប់កន្លងមក ពី៩៧% នៅឆ្នាំ២០០២ ទៅ៩៨% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.១០: កាត់បន្ថយចំនួនអ្នកជំងឺគ្រុនចាញ់ដែលបានទទួលការព្យាបាល នៅក្នុងផ្នែកសុខាភិបាលសាធារណៈ ក្នុងប្រជាជន ១០០០នាក់ ពី១១,៤ នៅឆ្នាំ២០០០ ទៅ៤ នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.១១: បង្កើនសមាមាត្រនៃសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់ពីរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់ ៩៥% តាមរូបមន្តជាតិ ពី៦០% នៅឆ្នាំ២០០២ ទៅ៩៥% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.១២: កាត់បន្ថយចំនួនអ្នកជម្ងឺគ្រុនឈាម ដែលបានទទួលការព្យាបាលនៅក្នុងផ្នែកសុខាភិបាលសាធារណៈ ក្នុងប្រជាជន ១០០០នាក់ ពី១ នៅឆ្នាំ២០០១ ទៅ០,៤ នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.១៣: កាត់បន្ថយអត្រាស្លាប់ដោយសារជម្ងឺគ្រុនឈាមដែលបានរាយការណ៍ ពីផ្នែកសុខាភិបាលសាធារណៈ ពី១,៥% នៅឆ្នាំ២០០៣ ទៅ០,៣% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.១៤: កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជម្ងឺរបេងស្លួតវិជ្ជមាន BK ក្នុងប្រជាជន ១០០០០០នាក់ ពី៤២៨ នៅឆ្នាំ១៩៩៧ ទៅ ១៣៥ នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៦.១៥: កាត់បន្ថយអត្រាស្លាប់ដោយសារជម្ងឺរបេងក្នុងប្រជាជន ១០០០០០នាក់ ពី៩០ នៅឆ្នាំ១៩៩៧ ទៅ៣២ នៅឆ្នាំ ២០១៥ |
| ចំណុចដៅ ៦.១៦: បង្កើនសមាមាត្រនៃអ្នកដែលបានប៉ាន់ស្មានថាមានករណីជម្ងឺរបេងស្លួតវិជ្ជមាន BK ថ្មី បានរកឃើញក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) ពី៥៧% នៅឆ្នាំ២០០២ អោយលើសពី៧០% នៅឆ្នាំ២០១០ និងឆ្នាំ២០១៥ |
| ចំណុចដៅ ៦.១៧: រក្សាសមាមាត្រនៃអ្នកជម្ងឺរបេងស្លួតវិជ្ជមាន BK ដែលបានកត់ត្រាហើយបានព្យាបាលប្រកបដោយជោគជ័យក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) អោយនៅលើ៨៥% ចាប់ពីឆ្នាំ២០០៥ ទៅមុខ |
| **គអសកក៧: ធានាចីរភាពបរិស្ថាន** |
| **ចំណុចដៅរួមទី ១៣: បញ្ចូលគោលការណ៍អភិវឌ្ឍន៍ចីរភាព ទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន** |
| ចំណុចដៅ ៧.១: រក្សានូវគម្របព្រៃឈើក្នុងកំរិត ៦០% លើផ្ទៃដីសរុប នៅឆ្នាំ២០០០ អោយនៅថេរដល់ឆ្នាំ២០១៥ |

| |
|---|
| ចំណុចដៅ ៧.២: រក្សានូវផ្ទៃដីតំបន់ការពារដែលមានចំនួន ២៣ ក្នុងកំរិត ៣,៣ លានហិកតា នៅឆ្នាំ១៩៩៣ អោយនៅថេរដល់ ឆ្នាំ ២០១៥ |
| ចំណុចដៅ ៧.៣: រក្សានូវតំបន់អភិរក្សព្រៃឈើថ្មីទាំង៦ ក្នុងកំរិតបច្ចុប្បន្ន ១,៣៥ លានហិកតា អោយនៅថេរដល់ឆ្នាំ២០១៥ |
| ចំណុចដៅ ៧.៤: បង្កើនចំនួនអ្នកអភិរក្សតំបន់ការពារពី ៦០០នាក់ នៅឆ្នាំ២០០០ អោយដល់១២០០នាក់ នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៧.៥: រក្សាចំនួនអ្នកអភិរក្សក្នុងតំបន់អភិរក្សព្រៃឈើ នៅកំរិត ៥០០នាក់ រហូតដល់ឆ្នាំ ២០១៥ |
| ចំណុចដៅ ៧.៦: បង្កើនសមាមាត្រឡូត៍នេសាទដែលប្រគល់ជូនសហគមន៍មូលដ្ឋាន ពី៥៦% នៅឆ្នាំ១៩៩៨ អោយដល់៦០% នៅឆ្នាំ ២០១៥ |
| ចំណុចដៅ ៧.៧: បង្កើនចំនួនសហគមន៍នេសាទមូលដ្ឋាន ពី២៦៤ នៅឆ្នាំ២០០០ ឱ្យដល់៥៨៩ នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៧.៨: បង្កើនផ្ទៃទីជំរកសុវត្ថិភាពរបស់មច្ឆា ពី២៦៤៥០០ហិកតា ឆ្នាំ២០០០ ឱ្យដល់៥៨០៨០០ ហិកតា នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៧.៩: កាត់បន្ថយការពឹងផ្អែកលើអុសដុតរបស់គ្រួសារ ពី៩២% នៅឆ្នាំ១៩៩៣ មកត្រឹម៥២% នៅឆ្នាំ២០១៥ |
| **ចំណុចដៅរួមទី ១៤: កាត់បន្ថយឱ្យបានពាក់កណ្តាល សមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់ទឹកស្អាតជាប្រចាំ មុនដំណាច់ឆ្នាំ ២០១៥** |
| ចំណុចដៅ ៧.១០: បង្កើនសមាមាត្រប្រជាជនជនបទ ដែលមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាត ពី២៤% នៅឆ្នាំ១៩៩៨ ឱ្យដល់៥០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៧.១១: បង្កើនសមាមាត្រប្រជាជនទីក្រុង/ប្រជុំជន ដែលមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាត ពី៦០% នៅឆ្នាំ១៩៩៨ ឱ្យដល់៨០% នៅឆ្នាំ២០១៥ |
| **ចំណុចដៅរួមទី ១៥: កាត់បន្ថយឱ្យបានពាក់កណ្តាល សមាមាត្រប្រជាជន ដែលគ្មានលទ្ធភាពប្រើប្រាស់អនាម័យប្រសើរជាងមុនជាប្រចាំ នៅមុនដំណាច់ឆ្នាំ២០១៥** |
| ចំណុចដៅ ៧.១២: បង្កើនសមាមាត្រប្រជាជនជនបទ ដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង ពី៨.៦% នៅឆ្នាំ ១៩៩៦ ឱ្យដល់៣០% នៅឆ្នាំ២០១៥ |
| ចំណុចដៅ ៧.១៣: បង្កើនសមាមាត្រប្រជាជនទីក្រុង/ប្រជុំជន ដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង ពី៤៩% នៅឆ្នាំ១៩៩៨ ឱ្យដល់៧៤% នៅឆ្នាំ២០១៥ |
| **ចំណុចដៅរួមទី ១៦: បង្កើនអត្រានៃប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ នៅមុនដំណាច់ឆ្នាំ២០១៥** |
| ចំណុចដៅ ៧.១៤: បង្កើនអត្រានៃប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ ពី១៥% នៅឆ្នាំ២០០០ ដល់ ៦៥% នៅឆ្នាំ២០១៥ |
| **គអសស៨: បង្កើតភាពជាដៃគូជាសកលសំរាប់កិច្ចអភិវឌ្ឍន៍[2]** |
| **ចំណុចដៅរួមទី ១៧: បង្កើតថែមទៀតការបើកចំហប្រព័ន្ធពាណិជ្ជកម្ម និងហិរញ្ញវត្ថុប្រកប ដោយមូលដ្ឋានច្បាប់អាចប៉ាន់ស្មានបាន និង មិនមានការរើសអើង** |
| សូចនាករ ៨.១: ODA សុទ្ធ ជាភាគរយនៃកិច្ចអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (DAC) ចំនូលជាតិសរុប (GNI) របស់ម្ចាស់ជំនួយ [ចំណុចដៅសរុប ០.៧% និង ០.៥% សំរាប់ប្រទេសក្រីក្របំផុត (LDC)] |
| សូចនាករ ៨.២: សមាមាត្រនៃ ODA ធៀបជាមួយសេវាសង្គមជាមូលដ្ឋាន (ការអប់រំមូលដ្ឋាន ការថែទាំសុខភាពបឋម អាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ) |

[2] ការធ្វើមូលដ្ឋានីយកម្ម គអសស៨ ទៅជា គអសកម៨ នឹងត្រូវបញ្ចូល នៅពេលខាងមុខដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

| |
|---|
| **ចំណុចដៅរួមទី ១៨: កំណត់ពីតម្រូវការពិសេសរបស់ LDCs រួមមានការរួចពន្ធលើទំនិញ នាំចេញឬនាំចូល និងកូតាដល់ការនាំចេញរបស់ LDC ជំរុញកម្មវិធីសំរាល បំណុលដល់បណ្តាប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ (HIPC) និងការទុកជាមោឃនូវបំណុលទ្វេភាគី ផ្លូវការ ដល់បណ្តាប្រទេសដែលប្តេជ្ញាក្នុងការកាត់បន្ថយភាពក្រីក្រ** |
| សូចនាករ ៨.៣: សមាមាត្រនៃ ODA ឥតសំណង |
| សូចនាករ ៨.៤: សមាមាត្រនៃ ODA សំរាប់ផ្នែកបរិស្ថាន នៅក្នុងបណ្តារដ្ឋដែនដីកោះតូចៗ |
| សូចនាករ ៨.៥: សមាមាត្រនៃ ODA សំរាប់ផ្នែកដឹកជញ្ជូន នៅក្នុងបណ្តាប្រទេសមិនជាប់សមុទ្រ |
| សូចនាករ ៨.៦: សមាមាត្រនៃការនាំចេញ (គិតជាតំលៃមិនបញ្ចូលអាវុធ) ដោយការរួចពន្ធ និងកូតា |
| សូចនាករ ៨.៧: កំរិតជាមធ្យមពន្ធលើទំនិញនាំចេញឬនាំចូល និងកូតាលើផលិតផលកសិកម្ម និងវាយនភ័ណ្ឌ និងសំលៀកបំពាក់ |
| **ចំណុចដៅរួមទី ១៩: កំណត់តម្រូវការពិសេសរបស់បណ្តាប្រទេសមិនជាប់សមុទ្រ និងបណ្តារដ្ឋ ដែនកោះតូចៗ (តាមរយៈកម្មវិធី Barbados និងបទបញ្ញត្តិរបស់មហាសន្និបាតសហប្រជាជាតិលើកទី ២២)** |
| សូចនាករ ៨.៨: ឧបត្ថម្ភធននៅក្នុងស្រុក និងការនាំចេញផលិតផលកសិកម្មនៅក្នុង បណ្តាប្រទេសនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) |
| សូចនាករ ៨.៩: សមាមាត្រនៃ ODA ដែលផ្តល់ឱ្យដើម្បីជួយបង្កើនសមត្ថភាពពាណិជ្ជកម្ម |
| **ចំណុចដៅរួមទី ២០: ដោះស្រាយបញ្ហាបំណុលនៃប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈវិធានការជាតិ និងអន្តរជាតិនានា ដើម្បីធ្វើឱ្យបំណុលមានចីរភាពក្នុងរយៈពេលវែង** |
| សូចនាករ ៨.១០: សមាមាត្រនៃបំណុលទ្វេភាគីផ្លូវការរបស់ HIPC ដែលបានលុបចោល |
| សូចនាករ ៨.១១: សេវាបំណុលជាភាគរយនៃការនាំចេញទំនិញនិងសេវាកម្ម |
| សូចនាករ ៨.១២: សមាមាត្រនៃ ODA ដែលបានផ្តល់ឱ្យជាការសំរាលបំណុល |
| សូចនាករ ៨.១៣: ចំនួនប្រទេសដែលទទួលបានការសំរេចចិត្តជា HIPC និងការបំពេញល័ក្ខខ័ណ្ឌនានា |
| **ចំណុចដៅរួមទី ២១: សហការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រសំរាប់ការងារសមរម្យ និងប្រកបដោយផលិតភាពសំរាប់យុវជន** |
| សូចនាករ ៨.១៤: អត្រាអត់ការងារធ្វើនៃអ្នកដែលមានអាយុ ១៥-២៤ ឆ្នាំ |
| **ចំណុចដៅរួមទី ២២: សហការជាមួយក្រុមហ៊ុនឱសថ ដើម្បីផ្តល់លទ្ធភាពអាចទទួលបានឱសថសារវ័ន្ត នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍** |
| សូចនាករ ៨.១៥: សមាមាត្រប្រជាជនអាចទទួលបានឱសថសារវ័ន្តឈរលើមូលដ្ឋានប្រកបដោយចីរភាព |
| **ចំណុចដៅរួមទី ២៣: សហការជាមួយផ្នែកឯកជន ដើម្បីធ្វើឱ្យមានអត្ថប្រយោជន៍នៃបច្ចេកវិទ្យាថ្មីៗ ជាពិសេសផ្នែកពត៌មាន និង ទូរគមនាគមន៍** |
| សូចនាករ ៨.១៦: ចំនួនខ្សែទូរស័ព្ទក្នុងមនុស្ស ១០០០ នាក់ |
| សូចនាករ ៨.១៧: ចំនួនកុំព្យូទ័រផ្ទាល់ខ្លួនក្នុងមនុស្ស ១០០០នាក់ សូចនាករដទៃទៀតនឹងត្រូវបង្កើតឡើង |
| **គអសក៩: ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ**[៣] |
| **ចំណុចដៅរួមទី ២៤: ឆ្ពោះទៅរកអត្រាគ្រោះថ្នាក់សូន្យដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ នៅឆ្នាំ២០១២** |
| ចំណុចដៅ ៩.១: កាត់បន្ថយចំនួនជនស៊ីវិលរងគ្រោះដោយសារមីនឱ្យដល់សូន្យនៅត្រឹមឆ្នាំ២០១២ |
| ចំណុចដៅ ៩.២: បោសសំអាតតំបន់ដែលសង្ស័យថាមានមីនកំរិតធ្ងន់ ខ្ពស់ មធ្យម និងទាប ឱ្យអស់នៅត្រឹមឆ្នាំ២០១២ |
| **ចំណុចដៅរួមទី ២៥: លុបបំបាត់ផលប៉ះពាល់ជាអវិជ្ជមានដល់មនុស្សជាតិ និងសេដ្ឋកិច្ច សង្គមកិច្ច ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ ត្រឹមឆ្នាំ២០២៥** |
| ចំណុចដៅ ៩.៣: បង្កើតក្របខ័ណ្ឌការងារជំនួយដ៏ទូលំទូលាយមួយដល់ជនរងគ្រោះ មុនឆ្នាំ២០០៥ ហើយត្រូវអនុវត្ត |
| ចំណុចដៅ ៩.៤: បង្កើនកញ្ចប់ជំនួយ និងធ្វើសមាហរណកម្មទៅក្នុងសង្គមដល់ជនរងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ |

[៣] គោលដៅទី ៩ នេះត្រូវបានស្នើឡើងដោយរាជរដ្ឋាភិបាល។

## ស្ថានភាពសង្ខេបនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

| ចំណុចដៅរួម | តើអាចនឹងសំរេចចំណុចដៅរួមនេះដែរឬទេ? | | | | បរិយាកាសគាំទ្រ | | | |
|---|---|---|---|---|---|---|---|---|
| | អាចធ្វើបាន | មានសក្តានុពល | មិនទំនង | គ្មានទិន្នន័យ | ខ្លាំង | មធ្យម | ខ្សោយតែកំពុងកែលំអ | ខ្សោយ |
| **ចំណុចដៅរួមទី ១:** កាត់បន្ថយឱ្យបានពាក់កណ្តាល រវាងឆ្នាំ១៩៩៣ និង២០១៥ នូវសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | | √ | | | | √ | | |
| **ចំណុចដៅរួមទី ២:** កាត់បន្ថយឱ្យបានពាក់កណ្តាល រវាងឆ្នាំ១៩៩៣ និង២០១៥ នូវសមាមាត្រប្រជាជន ដែលទទួលរងនូវភាពអត់ឃ្លាន | | √ | | | | √ | | |
| **ចំណុចដៅរួមទី ៣:** ធានាឱ្យកុមារទាំងអស់បានបញ្ចប់ការសិក្សាកំរិតបឋមសិក្សានៅមុនដំណាច់ឆ្នាំ២០១០និងការសិក្សាកំរិតមូលដ្ឋានរយៈពេល ៩ឆ្នាំ នៅមុនដំណាច់ឆ្នាំ២០១៥ | | √ | | | | √ | | |
| **ចំណុចដៅរួមទី ៤:** លុបបំបាត់វិសមភាពយេនឌ័រ ក្នុងការអប់រំកំរិតមូលដ្ឋានរយៈពេល ៩ឆ្នាំ ឱ្យបានមុនដំណាច់ឆ្នាំ២០១០ | | √ | | | | √ | | |
| **ចំណុចដៅរួមទី ៥:** កាត់បន្ថយគំលាតយេនឌ័រនៅកំរិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា | | | √ | | | | √ | |
| **ចំណុចដៅរួមទី ៦:** លុបបំបាត់គំលាតយេនឌ័រសំរាប់ការងារមានប្រាក់បៀវត្សរ៍ នៅគ្រប់វិស័យសេដ្ឋកិច្ច | | √ | | | | √ | | |
| **ចំណុចដៅរួមទី ៧:** លុបបំបាត់គំលាតយេនឌ័រនៅក្នុងកិច្ចការរដ្ឋាភិបាល | | | √ | | | √ | | |
| **ចំណុចដៅរួមទី ៨:** កាត់បន្ថយរាល់គ្រប់ទំរង់នៃអំពើហិង្សាចំពោះស្ត្រី និងកុមារ | | | | √ | | | √ | |
| **ចំណុចដៅរួមទី ៩:** បន្ថយអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ | | | √ | | | √ | | |
| **ចំណុចដៅរួមទី ១០:** បន្ថយផលធៀបមរណភាពមាតា | | | √ | | | √ | | |
| **ចំណុចដៅរួមទី ១១:** បន្ថយការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ | √ | | | | √ | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ចំណុចដៅរូមទី ១២:** បន្ថយការរីករាលដាលនៃជម្ងឺគ្រុនចាញ់ ជម្ងឺគ្រុនឈាម និងជម្ងឺរបេង | | √ | | | | √ | | |
| **ចំណុចដៅរូមទី ១៣:** បញ្ចូលគោលការណ៍អភិវឌ្ឍន៍ចីរភាព ទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន | √ | | | | | √ | | |
| **ចំណុចដៅរូមទី ១៤:** កាត់បន្ថយឱ្យបានពាក់កណ្តាលនូវសមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់ទឹកស្អាតជាប្រចាំ នៅមុនដំណាច់ឆ្នាំ២០១៥ | | √ | | | √ | | | |
| **ចំណុចដៅរូមទី ១៥:** កាត់បន្ថយឱ្យបានពាក់កណ្តាលនូវសមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់អនាម័យប្រសើរជាងមុនជាប្រចាំ នៅមុនដំណាច់ឆ្នាំ២០១៥ | | √ | | | √ | | | |
| **ចំណុចដៅរូមទី ១៦:** បង្កើនឱ្យបានច្រើននូវសមាមាត្រប្រជាជនដែលមានលទ្ធភាពទទួលបានកម្មសិទ្ធិដីធ្លី ដែលមានសុវត្ថិភាព នៅមុនដំណាច់ឆ្នាំ២០១៥ | √ | | | | √ | | | |
| **ចំណុចដៅរូមទី ១៧:** បង្កើតថែមទៀតការបើកចំហនូវប្រព័ន្ធពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ប្រកបដោយមូលដ្ឋានច្បាប់អាចប៉ាន់ស្មានបាន និងមិនមានការរើសអើងដោយរួម មានការប្តេជ្ញាឱ្យមានអភិបាលកិច្ចល្អ កិច្ចអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រទាំងថ្នាក់ជាតិ និងអន្តរជាតិ | | | | | | | | |
| **ចំណុចដៅរូមទី ១៨:** កំណត់ពីតំរូវការពិសេសរបស់ LDCs រួមមាន ការរួចពន្ធលើទំនិញនាំចេញ ឬនាំចូល និងកូតាដល់ការនាំចេញរបស់ LDC ជំរុញកម្មវិធីសំរាលបំណុលដល់បណ្តាប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ (HIPC) និងការទុកជាមោឃនូវបំណុលទ្វេភាគីផ្លូវការ ដល់បណ្តាប្រទេសដែលប្តេជ្ញាក្នុងការកាត់បន្ថយភាពក្រីក្រ | | | | | | | | |
| **ចំណុចដៅរូមទី ១៩:** កំណត់តំរូវការពិសេសរបស់បណ្តាប្រទេសមិនជាប់សមុទ្រនិងបណ្តារដ្ឋដែនកោះតូចៗ (តាមរយៈកម្មវិធី Barbados និងបទបញ្ញត្តិរបស់មហាសន្និបាតសហប្រជាជាតិលើកទី ២២) | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ចំណុចដៅរូមទី ២០:** ដោះស្រាយបញ្ហាបំណុលនៃប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈវិធានការជាតិ និងអន្តរជាតិនានា ដើម្បីធ្វើឱ្យបំណុលមានចីរភាពក្នុងរយៈពេលវែង | | | | | | | | |
| **ចំណុចដៅរូមទី ២១:** សហការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រសំរាប់ការងារសមរម្យ និងប្រកបដោយផលិតភាពសំរាប់យុវជន | | | | | | | | |
| **ចំណុចដៅរូមទី ២២:** សហការជាមួយក្រុមហ៊ុនឱសថ ដើម្បីផ្តល់លទ្ធភាពអាចទទួលបានឱសថសារវ័ន្តនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ | | | | | | | | |
| **ចំណុចដៅរូមទី ២៣:** សហការជាមួយផ្នែកឯកជន ដើម្បីធ្វើឱ្យមានអត្ថប្រយោជន៍នៃបច្ចេកវិទ្យាថ្មីៗ ជាពិសេសផ្នែកពត៌មាន និងទូរគមនាគមន៍ | | | | | | | | |
| **ចំណុចដៅរូមទី ២៤:** ឆ្ពោះទៅរកអត្រាសូន្យនៃផលប៉ះពាល់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះត្រឹមឆ្នាំ២០១២ | | | √ | | √ | | | |
| **ចំណុចដៅរូមទី ២៥:** លុបបំបាត់ផលប៉ះពាល់ជាអវិជ្ជមានដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះលើមនុស្សជាតិ និងសេដ្ឋកិច្ច សង្គមកិច្ច ត្រឹមឆ្នាំ២០២៥ | √ | | | | √ | | | |

## សន្ទស្សន៍រួមនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា តាមខេត្ត-ក្រុង[៤]




[៤] ឧបសម្ព័ន្ធ គ បង្ហាញពីវិធីសាស្ត្រគណនាសន្ទស្សន៍ គអសក។ សន្ទស្សន៍រួមនេះ គឺជាមធ្យមភាគនៃគ្រប់សន្ទស្សន៍ គអសក ទាំងអស់។

## សន្ទស្សន៍រួមនៃ គអសក តាមគោលដៅ

| លេខកូដ | ខេត្ត/ក្រុង | គអសក១ | គអសក២ | គអសក៣ | គអសក៤ | គអសក៥ | គអសក៦ | គអសក៧ | គអសក៨ | គអសករួម |
|---|---|---|---|---|---|---|---|---|---|---|
| ១២ | ភ្នំពេញ | ០,៧៨៤ | ០,៩៦២ | ០,៨២៥ | ០,៨២៧ | ០,៧៨៦ | ០,៧៩ | ០,៩៨៩ | ០,៩៩៩ | ០,៨៧០ |
| ០៨ | កណ្ដាល | ០,៦៩២ | ០,៧៧៩ | ០,៦២៧ | ០,៤៧ | ០,៤៣៧ | ០,៨០៧ | ០,៤០៩ | ០,៩៨៥ | ០,៦៥១ |
| ២០ | ស្វាយរៀង | ០,៥៧៣ | ០,៦៨៣ | ០,៦៣១ | ០,៥៣៣ | ០,៤៣៥ | ០,៧២៧ | ០,៤៦៧ | ០,៩៦៤ | ០,៦២៧ |
| ១៨ | ក្រុងព្រះសីហនុ | ០,៧៨៣ | ០,៧០២ | ០,៦០៣ | ០,៣២៧ | ០,៥៣៩ | ០,៦៥៧ | ០,៣៧៦ | ០,៩៩៨ | ០,៦២៣ |
| ២៣ | ក្រុងកែប | ០,៧៩២ | ០,៦៥៥ | ០,៧១ | ០,៣២៧ | ០,៥៣៩ | ០,៥៩១ | ០,៣៥ | ០,៩៩៦ | ០,៦១៥ |
| ០៧ | កំពត | ០,៧៩ | ០,៧៦៧ | ០,៧១៦ | ០,៣២៧ | ០,៥៣៩ | ០,៥៩៦ | ០,២៣១ | ០,៩១៥ | ០,៦១០ |
| ១០ | ក្រចេះ | ០,៦០៣ | ០,៦៣៥ | ០,៧៣៥ | ០,៤៤២ | ០,៣១១ | ០,៦១២ | ០,៣៧ | ០,៩៧០ | ០,៥៨៥ |
| ០៣ | កំពង់ចាម | ០,៦៤៣ | ០,៧២២ | ០,៥៥៥ | ០,៣៨៧ | ០,៣២៦ | ០,៧៣៥ | ០,៣៤ | ០,៨៩៧ | ០,៥៧៦ |
| ១៤ | ព្រៃវែង | ០,៣៩ | ០,៦១១ | ០,៥៣៤ | ០,៣៣២ | ០,៣៩៩ | ០,៧៩៥ | ០,៤៥៩ | ១,០០០ | ០,៥៦៥ |
| ២១ | តាកែវ | ០,៧២៣ | ០,៧៧១ | ០,៤៩៣ | ០,៥៤៩ | ០,៣២៣ | ០,៥៦ | ០,១១៩ | ០,៩៧៣ | ០,៥៦៤ |
| ០៦ | កំពង់ធំ | ០,៤៣៥ | ០,៦៥១ | ០,៦៨៦ | ០,៥៦៩ | ០,២៩២ | ០,៧៣៨ | ០,២៣១ | ០,៨៩៥ | ០,៥៦២ |
| ០៤ | កំពង់ឆ្នាំង | ០,៥៥៧ | ០,៦៨៣ | ០,៤៨៤ | ០,៤២២ | ០,២៧៩ | ០,៦៨២ | ០,៣១ | ០,៩៩២ | ០,៥៥១ |
| ០១ | បន្ទាយមានជ័យ | ០,៧៤៣ | ០,៦៥ | ០,៥១៧ | ០,៧៣៩ | ០,៤៦២ | ០,៥៥២ | ០,១០៨ | ០,៦៤១ | ០,៥៥១ |
| ០៥ | កំពង់ស្ពឺ | ០,៦៧៥ | ០,៦០២ | ០,៤៤១ | ០,៨០៦ | ០,២០៨ | ០,៥៥៥ | ០,១៧ | ០,៩៤០ | ០,៥៥០ |
| ០៩ | កោះកុង | ០,៦៨៥ | ០,៤០៨ | ០,៣០៦ | ០,៥៤៩ | ០,៥៤៥ | ០,៦៧៥ | ០,៣៥១ | ០,៨៧៣ | ០,៥៤៩ |
| ០២ | បាត់តំបង | ០,៦៩៧ | ០,៦៩៣ | ០,៦០៤ | ០,៣៨ | ០,៧៤៦ | ០,៦៦៧ | ០,៣៤ | ០,០០០ | ០,៥១៦ |
| ២៤ | ក្រុងប៉ៃលិន | ០,៦១២ | ០,៥៤៤ | ០,៤១៨ | ០,៣៨ | ០,៧៤៦ | ០,២២៣ | ០,៤១៦ | ០,៧៨៥ | ០,៥១៦ |
| ១៣ | ព្រះវិហារ | ០,៦០៤ | ០,៣៦២ | ០,៤៥៨ | ០,៤៤២ | ០,៣១១ | ០,៨៦៨ | ០,២២៨ | ០,៨៥៦ | ០,៥១៦ |
| ១៩ | ស្ទឹងត្រែង | ០,៦៧៤ | ០,៣៩៧ | ០,៤១៧ | ០,៤៤២ | ០,៣១១ | ០,៧០១ | ០,២៤៣ | ០,៨៩៩ | ០,៥១១ |
| ១៥ | ពោធិ៍សាត់ | ០,៦៤៤ | ០,៦៥៤ | ០,៦៣៧ | ០,២៣៨ | ០,៣៣៤ | ០,៧៣៥ | ០,២៩ | ០,៥៤៧ | ០,៥១០ |
| ១៧ | សៀមរាប | ០,៥៣២ | ០,៥៩៥ | ០,៤៨៦ | ០,៣៨៦ | ០,១៨៩ | ០,៥០៤ | ០,១៦៥ | ០,៥៥៣ | ០,៤២៦ |
| ២២ | ឧត្តរមានជ័យ | ០,៥៩៨ | ០,៣២៧ | ០,១៩១ | ០,៣៨៦ | ០,១៨៩ | ០,៩៣៨ | ០,០០៤ | ០,៦៤២ | ០,៤០៩ |
| ១១ | មណ្ឌលគិរី | ០,៣៦៣ | ០,១៤៩ | ០,២៩៩ | ០,២៥៤ | ០,០៩៧ | ០,៨១៩ | ០,២៥ | ០,៩៩៣ | ០,៤០៣ |
| ១៦ | រតនគិរី | ០,៣០៨ | ០,១៥៣ | ០,៣០៩ | ០,២៥៤ | ០,០៩៧ | ០,៥៧៤ | ០,១១៧ | ០,៩៥៧ | ០,៣៤៦ |

# សេចក្តីសង្ខេប

១. រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើសេចក្តីប្រកាសសហស្សវត្សរ៍ និងបានប្តេជ្ញាចិត្តចំពោះដំណើរការគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ រាជរដ្ឋាភិបាលកម្ពុជា មានបំណងវាស់វែងនូវការអនុវត្តន៍ជាក់ស្តែងនៃការអភិវឌ្ឍន៍របស់ជាតិដោយអនុឡោមតាម គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងដើម្បីរៀបចំនូវរបាយការណ៍ ស្តីពីភាពជឿនលឿននៃគោលដៅអភិវឌ្ឍន៍ហស្សវត្សរ៍កម្ពុជា អោយបានជាទៀងទាត់។

២. ប្រទេសកម្ពុជា បានធ្វើឱ្យមានការរីកចំរើន ឆ្ពោះទៅសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ប៉ុន្តែនឹងត្រូវមានការខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងទសវត្សរ៍បន្ត។ ចាប់តាំងពីឆ្នាំ១៩៩៩មក ប្រទេសកម្ពុជាបានបន្ត និងធ្វើឱ្យមានការរីកចំរើនសំខាន់ៗជាច្រើន នៅក្នុងការអនុវត្តន៍ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលមានទិសដៅសំរេចឱ្យបាននូវកំនើនសេដ្ឋកិច្ចយូរអង្វែង និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ប្រទេសកម្ពុជាក៏បានបោះជំហានទៅមុខគួរឱ្យចាប់អារម្មណ៍ សំដៅពង្រឹងស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច។ ការគ្រប់គ្រងសេដ្ឋកិច្ចដែលមានលក្ខណៈសមស្រប ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំនើនសេដ្ឋកិច្ចប្រកបដោយចីរភាព គឺជាតម្រូវការចាំបាច់សំរាប់ការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព និងសំរាប់ឱ្យប្រទេសកម្ពុជាសំរេចបាន នូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួន។

៣. ទោះបីជាកំនើនសេដ្ឋកិច្ចដែលមានលក្ខណៈថេរ ក្នុងកំឡុងមួយទសវត្សរ៍កន្លងមកក៏ដោយ ក៏ភាពក្រីក្រមានការថយចុះតែពី ៣៩% ទៅ៣៦% ក្នុងរវាងឆ្នាំ១៩៩៤ និង១៩៩៩ ប៉ុណ្ណោះ។ ការរីកចំរើននៅតំបន់ជនបទតាមមិនទាន់កំនើនប្រជាជន ហើយក៏មាននិន្នាការគួរឱ្យព្រួយបារម្ភនៃការកើនឡើង នូវភាពគ្មានការងារធ្វើនៅជនបទ ហើយនិងកង្វះការរីកចំរើននៅក្នុងការងារក្រៅពីវិស័យកសិកម្ម។ ប្រសិនបើនិន្នាការកន្លងមកនៅតែបន្ត អាំងស៊ីដង់ភាពក្រីក្រនឹងថយចុះដល់ ២៨% មុនដំណាច់ឆ្នាំ២០១៥។ ជាការច្បាស់លាស់ ការថយចុះនៃភាពក្រីក្រនេះ គឺមិនបានដល់ចំនុចដៅដែលបានដាក់ចេញ ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យមកនៅត្រឹម១៩.៥% នោះទេ។ ការសំរេចបានចំនុចដៅនៃ គអសក នឹងទាមទារឱ្យមានកំនើនសេដ្ឋកិច្ចលឿនជាងមុន និងកាត់បន្ថយភាពក្រីក្រឱ្យបានច្រើនជាមួយកំនើននោះ។

៤. នៅក្នុងវិស័យសង្គមកិច្ច កំនើនមានលក្ខណៈយឺតហើយមិនស្មើភាព។ ថ្វីត្បិតតែលទ្ធភាពទទួលបានការអប់រំនៅថ្នាក់បឋម មានការកែលំអយ៉ាងច្រើនក្នុងទសវត្សរ៍ចុងក្រោយក៏ដោយ ក៏ប្រទេសកម្ពុជាហាក់ដូចជាមិនអាចសំរេចនូវចំនុចដៅរបស់ខ្លួន ចំពោះការទទួលយកនូវការអប់រំថ្នាក់មធ្យមសិក្សាបឋមភូមិនោះឡើយ។

៥. សមភាពយេនឌ័រ នៅតែជាបញ្ហាដ៏ចំបងក្នុងផ្នែកជាច្រើននៃជីវភាពសង្គមកិច្ច សេដ្ឋកិច្ច ទោះបីជាមានការប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់របស់រាជរដ្ឋាភិបាលចំពោះការផ្តល់សិទ្ធិអំណាចទៅឱ្យស្ត្រីក៏ដោយ។ ជាការឆាប់ពេកក្នុងការវាយតំលៃ ថាតើយើងនឹងអាចសំរេចបាននូវចំនុចដៅនោះដែរឬទេ។ ម៉្យាងទៀតបញ្ហាប្រឈមមានលក្ខណៈគួរអោយកត់សំគាល់ បើទោះជាមានការបញ្ជ្រាបនូវ បញ្ហាយេនឌ័រនាពេលថ្មីៗនេះនៅក្នុងដំណើរការគោលនយោបាយ ហើយការផ្លាស់ប្តូរឥរិយាបទ និងអាកប្បកិរិយា ដែលចាំបាច់ក្នុងការសំរេចបាននូវចំនុចដៅទាំងនោះមុនដំណាច់ឆ្នាំ២០១៥ ក៏ដោយ។

**៦.** ស្ថានភាពសុខភាព និងអនាម័យរបស់ប្រជាជនមួយចំនួនធំនៅតែមានកំរិតមិនអាចទទួលយកបាន។ អត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ ទំនងជាកើនឡើងបន្តិចនៅក្នុងកំឡុងទសវត្សរ៍ក្រោយនេះ។ ប្រទេសកម្ពុជា មិនទំនងជាអាចសំរេចនូវចំនុចដៅរបស់ខ្លួន ក្នុងការកាត់បន្ថយនូវមរណភាពកុមារអាយុក្រោម ៥ឆ្នាំ ឱ្យនៅត្រឹម ៦៥នាក់ ក្នុងចំណោមកុមារ ១០០០នាក់ មុនដំណាច់ឆ្នាំ២០១៥ នោះ។

**៧.** ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជារីកចំរើននៅមានកំរិតនៅឡើយ ក្នុងការកាត់បន្ថយនូវមរណភាពមាតា។ តាមទិន្នន័យថ្មីៗបំផុត ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ បានបង្ហាញនូវផលធៀបមរណភាពមាតាខ្ពស់ខ្លាំងគឺ ៤៣៧នាក់ ក្នុងកំណើតកូន ១០០០០០នាក់។ មានគំលាតគួរអោយកត់សំគាល់រវាងកំរិតទាំងនេះ និងចំនុចដៅនៃ គអសក ដែលមានទិសដៅកាត់បន្ថយផលធៀបមរណភាពមាតាឱ្យចុះមកដល់ ១៤០នាក់ ក្នុងកំណើតកូន ១០០០០០នាក់ នៅមុនដំណាច់ឆ្នាំ២០១៥។

**៨.** អត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមប្រជាជនពេញវ័យអាយុ ១៥-៤៩ឆ្នាំ បានថយចុះពី ៣,៣% មក២,៦% រវាងឆ្នាំ១៩៩៧ និងឆ្នាំ២០០២។ ការធ្វើចំណោលទៅមុខយោងតាមនិន្នាការកន្លងមក បានបង្ហាញថា ប្រទេសកម្ពុជានឹងសំរេចចំនុចដៅ គអសក ដែលបានកំណត់ត្រឹម ១,៨% នៅឆ្នាំ២០១៥។ ក៏ដូចជាក្នុងផ្នែកដទៃទៀតនៅក្នុងឯកសារនេះដែរ ការធ្វើចំណោលយោងតាមនិន្នាការកន្លងមក គួរតែមានការប្រុងប្រយ័ត្ន ដោយសារកត្តាជាច្រើនអាចនឹងមានការផ្លាស់ប្តូរដូចជា ជីវិតរបស់អ្នកដែលឆ្លងមេរោគអេដស៍ និងទំរង់អាកប្បកិរិយារបស់គេ។

**៩.** ធនធានធម្មជាតិកម្ពុជា កំពុងតែមានភាពរិចរឹលនៅក្នុងល្បឿនមួយយ៉ាងលឿន។ គម្របព្រៃឈើបានធ្លាក់ចុះរហូតដល់ ៥៨,៧% នៃផ្ទៃដីសរុបរបស់កម្ពុជា នៅមុនដំណាច់ឆ្នាំ១៩៩៧ ទោះបីជា មានការដាំដើមឈើជាថ្មីរហូតដល់ ១១១២៥ហិកតា រវាងឆ្នាំ១៩៨៥ និងឆ្នាំ២០០២ ក៏ដោយ។ ការថយចុះនៃគម្របព្រៃឈើរវាងទសវត្សរ៍ឆ្នាំ១៩៦០ និងឆ្នាំ១៩៩៧ គឺមានចំនួនជិត ២លានហិកតា ដែលតំណាងឱ្យអត្រាថយចុះប្រហែលជាកន្លះភាគរយក្នុងមួយឆ្នាំ។ នៅប្រទេសកម្ពុជា អត្រានេះនឹងធ្លាក់មកនៅក្រោមចំនុចដៅ គអសក ដែលត្រូវជា ៦០% ពីឆ្នាំ២០០៥ រហូតដល់ឆ្នាំ២០១៥។

**១០.** ដោយសារមីនផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានដល់ជីវភាពរស់នៅរបស់អ្នកជនបទ ការបោសសំអាតមីន គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពចំបង៧សំរាប់ការស្តារ និងអភិវឌ្ឍន៍ប្រទេស។ ទោះបីជាមានការថយចុះនូវចំនួនជនស៊ីវិលរងគ្រោះដោយសារមីនក៏ដោយ ក៏នៅតែមានជនស៊ីវិលរាប់រយនាក់ត្រូវបានរងគ្រោះថ្នាក់ជារៀងរាល់ឆ្នាំ ហើយទាំងនេះជាបន្ទុកដ៏ធ្ងន់តាំងពីអតីតកាល ក៏ដូចជាទៅអនាគត។ បើសិនជាកម្ពុជាត្រូវតែបំពេញតាមចំណុចដៅដែលបានកំណត់ នោះត្រូវតែមានការប្តេជ្ញាយ៉ាងមុតមាំ និងរយៈពេលវែងពីសំណាក់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយទាំងឡាយ។

**១១.** ក្នុងចំណោមខេត្តនីមួយៗ មានភាពខុសគ្នាគួរអោយកត់សំគាល់ចំពោះភាពជឿនលឿន ឆ្ពោះទៅរកចំនុចដៅ គអសក។ ស្ថានភាពមានលក្ខណៈខុសប្លែកគ្នាពីគោលដៅមួយទៅគោលដៅមួយទៀត។ លើសពីនេះទៀត តំបន់ឆ្នេរ និងបណ្តាខេត្តភាគខាងកើត ដែលមានព្រំប្រទល់ជាប់ប្រទេសវៀតណាម ជាខេត្ត/ក្រុង ដែលស្ថិតនៅចំណាត់ថ្នាក់ល្អប្រសើរ។

**១២.** បញ្ហាប្រឈមទីមួយក្នុងការអភិវឌ្ឍន៍ គឺការរក្សាឱ្យបាននូវអត្រាកំនើនសេដ្ឋកិច្ចខ្ពស់ ដើម្បីបង្កើតការងារធ្វើ និងឱកាសរកប្រាក់ចំនូលសំរាប់ប្រជាជន ដែលមានចំនួនកាន់តែកើនឡើង។ ពាណិជ្ជកម្មជាកត្តាមួយប្រកបដោយសក្តានុពល ដើម្បីឱ្យក្លាយទៅជាក្បាលម៉ាស៊ីននៃកំនើននេះ ដោយសារតែមានការបើកទូលាយនូវឱកាសទីផ្សារក្នុងសេដ្ឋកិច្ចពិភពលោកនៃសកលភាវូបនីយកម្ម។ ពាណិជ្ជកម្មក៏អាចដើរតួនាំមុខគេនៅក្នុងការផ្តួចផ្តើមកំណែទំរង់ និងកែប្រែគោលនយោបាយ នៅក្នុងវិស័យដទៃទៀតរួមមាន កំនែទំរង់ច្បាប់ដើម្បីស្របទៅតាមនិយាមអន្តរជាតិ និងដើម្បីធានាឱ្យបាននូវបរិយាកាសដែលមានលក្ខណៈអំណោយផលដល់ការវិនិយោគទុនបរទេស កំនែទំរង់វិស័យសាធារណៈ ដើម្បីកាត់បន្ថយនូវនីតិវិធីរដ្ឋបាលដែលមិនចាំបាច់ និងអំពើពុករលួយ កំនែទំរង់វិស័យអប់រំ ដើម្បីបណ្តុះបណ្តាលយុវជននៅក្នុងវិស័យផ្សេងៗទៀត ដែលប្រទេសកម្ពុជាមានឧត្តមភាពប្រៀបធៀប ហើយនិងការវិនិយោគទុនក្នុងហេដ្ឋារចនាសម្ព័ន្ធជនបទ និងទីក្រុងដើម្បីកាត់បន្ថយចំណាយប្រតិបត្តិ សំរាប់វិស័យឯកជន និងដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែងជាងមុន។

**១៣.** បញ្ហាប្រឈមទីពីរក្នុងការអភិវឌ្ឍន៍ គឺការបន្តអនុវត្តទៅតាមយុទ្ធសាស្ត្រកំនើនសេដ្ឋកិច្ច ដែលនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់។ យើងត្រូវយកចិត្តទុកដាក់បន្ថែមទៀត ដល់គោលនយោបាយកំនើនសេដ្ឋកិច្ចគាំទ្រដល់អ្នកក្រីក្រ តាមរយៈការវិនិយោគទុននៅក្នុងវិស័យនានា ដែលមានអ្នកក្រីក្រចូលរួមច្រើន និងអាចរកការងារដែលមាននិរន្តរភាព។ លើសពីនេះទៅទៀត កំនើនសេដ្ឋកិច្ចគួរតែបានបង្កើនចំណូលថវិការដ្ឋ ដែលមួយផ្នែកនៃប្រាក់ចំនូលនេះ គួរតែត្រូវបានបែងចែកទៅឱ្យកម្មវិធីការពារផ្នែកសង្គម សំរាប់ប្រជាជនទាំងឡាយណាដែលពុំមានឱកាសទទួលបានពីកំណើនសេដ្ឋកិច្ចនោះ។

**១៤.** ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) គឺជាបញ្ហាពហុវិស័យមួយ ដោយយោងទៅលើវិស័យជាច្រើននៅក្នុងសង្គម។ សមត្ថភាពរបស់ប្រទេសកម្ពុជានៅមានកំរិត ក្នុងការផ្តល់ហិរញ្ញប្បទានដល់កម្មវិធីសាធារណៈ ដែលចាំបាច់ដើម្បីបង្កើនសន្ទុះការអភិវឌ្ឍន៍។ ថវិកាសាធារណៈសរុបមានតិចតួច ហើយចំនែកដែលបែងចែកសំរាប់កម្មវិធីអភិវឌ្ឍន៍មានកំរិតស្តួចស្តើង បើប្រៀបធៀបទៅនឹងតំរូវការរបស់ប្រជាជនដែលមានចំនួនកាន់តែច្រើន ហើយនឹងគំលាតដែលត្រូវបំពេញឱ្យបានមុនដំណាច់ឆ្នាំ២០១៥ នោះ។ ដូច្នេះ ជំនួយអភិវឌ្ឍន៍ផ្លូវការដែលមានកំរិតច្រើនជាង ១០០% នៃថវិកាជាតិនោះ នឹងត្រូវដើរតួចំបង ប្រសិនប្រទេសកម្ពុជាត្រូវការសំរេច គអសក របស់ខ្លួនឱ្យបាន។ ជំនួយដែលមានប្រសិទ្ធភាព និងបានកំនត់ចំនុចដៅល្អជាងមុន និងសម្របទៅតាមអាទិភាពរបស់ជាតិ គឺជាល័ក្ខខ័ណ្ឌដ៏សំខាន់បំផុតសំរាប់ប្រទេសកម្ពុជាដើម្បីសំរេចឱ្យបាននូវចំនុចដៅរបស់ខ្លួន។ ម្ចាស់ជំនួយមានការទទួលខុសត្រូវដ៏ចំបងក្នុងការជួយរាជរដ្ឋាភិបាលកម្ពុជាឱ្យសំរេចបាននូវគោលដៅរបស់ខ្លួន។ រាជរដ្ឋាភិបាលនឹងមានសេចក្តីរីករាយ ក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិសំរាប់ជោគជ័យទាំងនេះ ហើយក៏ជាអ្នកចូលរួមទទួលខុសត្រូវផងដែរក្នុងករណីដែលមានការបរាជ័យ។

**១៥.** ការសំរេចបាននូវចំនុចដៅ គអសក គឺទំនងជាត្រូវបានបង្កើនសន្ទុះតាមរយៈការបង្កើនការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធជាច្រើននៅក្នុងដំណើរការអភិវឌ្ឍន៍ និងការចូលរួមកាន់តែច្រើនក្នុងដំណើរការធ្វើការសំរេចចិត្តដូចជា ដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម។ ឧទាហរណ៍ ការចូលរួមពីសំណាក់មាតាបិតាកាន់តែច្រើនឡើងក្នុងការគ្រប់គ្រងសាលារៀន តាមរយៈសមាគមមាតាបិតាសិស្ស និងគ្រូបង្រៀនដែលធ្វើឱ្យមានសក្តានុពល

ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន គុណភាពនៃការអប់រំ ហើយនិងលទ្ធផលនៃការអប់រំផងដែរ។ មូលហេតុនេះក៏អាចយកទៅប្រើជាមួយសេវាថែទាំសុខភាពបឋម និងការគ្រប់គ្រងធនធានធម្មជាតិ តាមរយៈគំនិតផ្តួចផ្តើមគ្រប់គ្រងដោយផ្អែកលើសហគមន៍ផងដែរ។ ជាទូទៅដំណើរការប្រកបដោយប្រសិទ្ធភាពនៃវិមជ្ឈការ ដែលបានធ្វើឱ្យអ្នកផ្តល់សេវាខិតទៅជិតអ្នកប្រើប្រាស់ ជាហេតុធ្វើឱ្យមានសក្តានុពល ក្នុងការបង្កើននូវតំលាភាព ប្រសិទ្ធភាព និងគុណភាពនៃសេវាដែលបានផ្តល់។

**១៦.** ការពង្រឹងស្ថាប័នត្រូវតែដោះស្រាយបញ្ហាបី ដែលធ្វើឱ្យរាំងស្ទះដល់ការសំរេច គអសក ពោលគឺៈ (i) អង្គការសង្គមស៊ីវិល ដែលមានប្រសិទ្ធភាពមានចំនួនតិចពេក (ii)ការសម្របសម្រួល និងការគ្រប់គ្រងជាមួយវិស័យសាធារណៈនៅមានលក្ខណៈទន់ខ្សោយ និង (iii) សមត្ថភាពធនធានមនុស្សនៅមានកំរិត។

**១៧.** បើទោះបីជាមានអង្គការមិនមែនរដ្ឋាភិបាលជាតិជាច្រើន មានសកម្មភាពសស្រាក់សស្រាំនៅក្នុងវិស័យមួយចំនួនធំដែលផ្តល់វិភាគទានដល់ការអភិវឌ្ឍន៍នៅមូលដ្ឋានក៏ដោយ ក៏យើងត្រូវការកែលំអនូវការបំពេញការងាររបស់ពួកគេក្នុងផ្នែកប្រសិទ្ធភាព និងផលិតភាពផងដែរ។ លើសពីនេះ វិស័យឯកជនពុំសូវមានសកម្មភាពច្រើនឡើយ ហើយមានការប្រមូលផ្តុំនៅក្នុងប្រតិបត្តិការក្រៅផ្លូវការ ដែលមានទ្រង់ទ្រាយតូច លើកលែងតែឧស្សាហកម្មកាត់ដេរ។

**១៨.** ការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានការអនុវត្តន៍ និងការប្រតិបត្តិកម្មវិធី និងគំរោងទាំងឡាយ ដែលតំរង់ឆ្ពោះទៅរកការកែលំអជីវភាពរស់នៅរបស់ប្រជាជនក្រីក្របំផុត។ នៅក្នុងបរិបទមួយដែលធនធានមនុស្ស ហើយសមត្ថភាពវិស័យសាធារណៈនៅមានកំរិត ការទាមទារខ្ពស់ ហើយជួនកាលមានការខ្វែងគំនិតគ្នា និងតំរូវការរបស់ម្ចាស់ជំនួយអាចឱ្យខូចប្រយោជន៍ ដោយធ្វើឱ្យមានការថយចុះនូវធនធានដែលចេញពីការអនុវត្តន៍សកម្មភាពអភិវឌ្ឍន៍ជាក់ស្តែង។ បញ្ហាប្រឈមទីមួយរបស់រាជរដ្ឋាភិបាល គឺត្រូវកែលំអការធ្វើផែនការយុទ្ធសាស្ត្រក្នុងការប្រើប្រាស់នូវធនធានរបស់ខ្លួន និងការលើកកំពស់ការសំរបសំរួល រវាងដៃគូនានា។ បញ្ហាប្រឈមទីពីរ គឺការបង្កើតនូវប្រព័ន្ធប្រកបដោយប្រសិទ្ធភាពមួយ សំរាប់តាមដាន និងវាយតំលៃទៅលើគោលនយោបាយ និងកម្មវិធីនានា។

**១៩.** មានតំរូវការរួមក្នុងការធ្វើអោយប្រសើរឡើងនូវសមត្ថភាពមនុស្ស ដើម្បីបង្កើនធនធានសំរាប់ប្រើក្នុងការសំរេចឱ្យបាននូវ គអសក។ លើសពីនេះទៀត នៅក្នុងរយៈពេលយូរអង្វែង ការបង្កើនជំនាញ និងកំរិតអប់រំរបស់ប្រជាជន នឹងក្លាយជាការចាំបាច់ដើម្បីធ្វើអោយប្រទេសស្ថិតនៅលើមាគ៌ាកំនើន ដែលមានលក្ខណៈរឹងមាំ និងចំរុះជាងមុន។

**២០.** វិសមភាពមានទំរង់ប្លែកៗពីគ្នានៅក្នុងប្រទេសកម្ពុជា។ វិសមភាពយេនឌ័រគួរឱ្យកត់សំគាល់នៅក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ដែលត្រូវបានគូសបញ្ជាក់នៅក្នុងការពិភាក្សាស្តីអំពី គអសក៣។ វិសមភាពក៏មានលក្ខណៈគួរអោយកត់សំគាល់ដែរ រវាងសហគមន៍ជនបទ និងទីក្រុង/ប្រជុំជន ជាពិសេសនៅទីក្រុងភ្នំពេញ។ ជីវភាពរស់នៅ និងឱកាសរកប្រាក់ចំនួលនៅទីក្រុង ជាទូទៅមានកំរិតខ្ពស់ច្រើនជាងនៅតំបន់ជនបទ។ វិសមភាពក៏មានលក្ខណៈគួរអោយកត់សំគាល់ផងដែរនៅតំបន់ជនបទ ជាធម្មតានៅតំបន់ណាដែលមានជនជាតិភាគតិចប្រមូលផ្តុំ។ ការធ្វើឱ្យមានភាពជឿនលឿនឆ្ពោះទៅរកចំនុចដៅ គអសក ក្នុងទសវត្សរ៍ក្រោយនេះ

ទាមទារបង្កើនការវិនិយោគទុន ឱ្យបានច្រើនថែមទៀតនៅក្នុងធនធានរូបវន្ត និងធនធានមនុស្សដែលតំរង់ឆ្ពោះទៅរកតំបន់ណាដែលមានលក្ខណៈអន់ថយជាងតំបន់ដទៃ។

**២១.** កំនើនប្រជាជនខ្ពស់មានឥទ្ធិពលទៅលើ គអសក ទាំងអស់ ហើយក៏បង្ហាញអោយឃើញជាបញ្ហាប្រឈមដ៏ធំមួយសំរាប់ប្រទេសកម្ពុជាផងដែរ។ គោលនយោបាយប្រជាជនប្រកបដោយប្រសិទ្ធភាពមួយ ដែលស្របទៅតាមបរិបទសង្គម និងវប្បធម៌កម្ពុជា ហើយដោះស្រាយបញ្ហាដូចជា ការអប់រំស្ត្រី និងលទ្ធភាពទទួលបានការពន្យារកំណើត គឺជាតម្រូវការសំរាប់កម្ពុជា ដើម្បីទប់ស្កាត់និន្នាការនៃភាពរិចរិលធនធាន និងភាពក្រីក្រ។

**២២.** បើទោះបីជាយើងត្រូវជំនះទៅនឹងបញ្ហាប្រឈមធំៗ នៅទសវត្សរ៍ក្រោយនេះក៏ដោយ ក៏កម្ពុជាមានសង្ឃឹមថានឹងអាចសំរេចបាននូវចំនុចដៅ គអស របស់ខ្លួនបានល្អដែរ។ ជាលើកទីមួយ នៅក្នុងរយៈពេលជិតបីទសវត្សរ៍ ជាមួយការត្រឡប់មកវិញនូវសន្តិភាព និងការស្តារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បន្ទាប់ពីការបោះឆ្នោត ឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាបច្ចុប្បន្នមានឱកាសក្នុងការធ្វើកំនែទំរង់យ៉ាងច្រើន ដើម្បីសំរេចបានគ្រប់ផ្នែកទាំងអស់នៃជីវភាពសេដ្ឋកិច្ច និងសង្គមកិច្ច។ ភារកិច្ចមានទំហំធំធេង ហើយនឹងត្រូវការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ពីភាគីទាំងអស់ ដើម្បីធ្វើការសម្របសម្រួលជាមួយទិសដៅរួមនៃការរីកចំរើនឆ្ពោះទៅរកចំនុចដៅ គអសក។

**២៣.** ការវាស់វែងភាពជឿនលឿនឆ្ពោះទៅ គអសក ទាមទារឱ្យមានប្រព័ន្ធតាមដាន និងវាយតំលៃប្រកបដោយប្រសិទ្ធភាព ដែលមាននៅក្នុងប្រព័ន្ធស្ថាប័នដ៏សមស្របមួយ។ ការតាមដានកម្មវិធី និងគំរោងរបស់វិស័យនានា នឹងត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធ និងស្ថាប័នអនុវត្តដទៃទៀត។ ក្រសួងពាក់ព័ន្ធទាំងនោះ នឹងផ្តោតការយកចិត្តទុកដាក់លើបណ្តាសូចនាករធនធាន សូចនាករដំណើរការ និងសូចនាករលទ្ធផល។ ភារកិច្ចចំបងរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច និងក្រុមបច្ចេកទេសដែលជាអង្គភាពបច្ចេកទេសតាមដាន និងវិភាគភាពក្រីក្រ គឺត្រូវផ្តោតការយកចិត្តទុកដាក់លើការតាមដាន និងការវាយតំលៃផលប៉ះពាល់អោយមានប្រសិទ្ធភាព។ ដើម្បីសំរេចបានការឯកភាពគ្នា ស្ថាប័នទាំងអស់នឹងត្រូវដើរតួជាដៃគូនៅក្នុងប្រព័ន្ធនេះ។ ការទទួលខុសត្រូវរួមនៅក៏រិតតាក់តែងគោលនយោបាយ ស្ថិតនៅលើក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច។

**២៤.** នាពេលបច្ចុប្បន្ន សកម្មភាពជាច្រើនក្នុងការតាមដាន និងវាយតំលៃកំពុងត្រូវបានដំណើរការដោយមិនមានការសម្របសម្រួលល្អ និងពត៌មានដែលបានផលិតមានលក្ខណៈរាយប៉ាយនៅតាមបណ្តាស្ថាប័នរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងៗទៀត។ ដើម្បីដោះស្រាយស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើសមាហរណកម្មនៃការតាមដាន គអសក ជាមួយនឹងប្រព័ន្ធតាមដាន និងវាយតំលៃផលប៉ះពាល់នៃភាពក្រីក្រមួយ។ សមាសធាតុដ៏សំខាន់នៃប្រព័ន្ធនេះ ជាប្រព័ន្ធពត៌មានដែលងាយស្រួលប្រើ ដើម្បីជួយសំរួលដល់ការរក្សាទុក ការគ្រប់គ្រង និងការផ្សព្វផ្សាយពត៌មាន។ កម្ពុជាបានសំរេចបង្កើតប្រព័ន្ធគ្រប់គ្រងពត៌មានភាពក្រីក្រ (PMIS) ដែលមានទំរង់ជាឃ្លាំងទិន្នន័យជាតិមួយ (National Data Warehouse) ហើយនឹងត្រូវដាក់បញ្ចូលគ្នាឱ្យបានល្អជាមួយនឹងរចនាសម្ព័ន្ធថ្នាក់ជាតិដែលមានស្រាប់។

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ANC | ការពិនិត្យផ្ទៃពោះមុនពេលសំរាល |
| ARV | ថ្នាំព្យាបាលប្រឆាំងនឹងមេរោគអេដស៍ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ |
| BMC | មជ្ឈមណ្ឌលគ្រប់គ្រងថវិកា |
| BMI | សន្ទស្សន៍កំពស់ និងម៉ាស់មាឌនៃខ្លួនមនុស្ស |
| BSS | ការអង្កេតតាមដានការប្រព្រឹត្ត |
| CCA | ការវាយតំលៃប្រទេសរួម |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CEDAW | កត្តិកាសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងចំពោះស្ត្រី |
| CENAT | មជ្ឈមណ្ឌលជាតិកំចាត់ជំងឺរបេង និងហង់សិន |
| CFR | អត្រាមរណភាព |
| CG | ការប្រជុំពិគ្រោះយោបល់ |
| CHDR | របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជា |
| CMAA | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការ |
| CMAC | មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា រឺ គអសក |
| CMVIS | ប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីននៅកម្ពុជា |
| CNCW | ក្រុមប្រឹក្សាជាតិស្ត្រីកម្ពុជា |
| CNIP | ផែនការវិនិយោគអាហារូបត្ថម្ភកម្ពុជា |
| CNM/NMC | មជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ |
| CPMAS | ប្រព័ន្ធតាមដាន និងវិភាគភាពក្រីក្រកម្ពុជា |
| CPMIS | ប្រព័ន្ធគ្រប់គ្រងពត៌មានភាពក្រីក្រកម្ពុជា |
| CRC | កាកបាទក្រហមកម្ពុជា |
| CSD | ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច |
| CSES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា |
| CSOs | អង្គការសង្គមស៊ីវិលកម្ពុជា |
| CSWs | អ្នករកស៊ីផ្លូវភេទ |
| DAC | ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការ |
| DAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | |
|---|---|
| D(H)F | ជំងឺគ្រុនឈាម/ជំងឺគ្រុនឈាមធ្ងន់ធ្ងរ |
| DOTS | ការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ |
| DPT | ខាន់ស្លាក់ ក្អកមាន់ តេតាណូស |
| EFA | ការអប់រំសំរាប់ទាំងអស់គ្នា |
| EMIS | ប្រព័ន្ធពត៌មានគ្រប់គ្រងការអប់រំ |
| ESI | ស្ថិតិ និងសូចនាករអប់រំ |
| ESP | ផែនការយុទ្ធសាស្ត្រអប់រំ |
| ESSP | កម្មវិធីគាំទ្រវិស័យអប់រំ |
| FAO | អង្គការស្បៀងអាហារ និងកសិកម្មនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| FDI | ការវិនិយោគទុនបរទេស |
| FPL | ខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ |
| FYMAP | ផែនការសកម្មភាពមីនសំរាប់រយៈពេល ៥ឆ្នាំ |
| GAP | ផែនការសកម្មភាពអភិបាលកិច្ច |
| GDI | សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GNI | ចំណូលជាតិសរុប |
| GNP | ផលិតផលជាតិសរុប |
| GSCSD | អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច |
| GSNA | អគ្គលេខាធិការដ្ឋាននៃរដ្ឋសភាជាតិ |
| GSP | ប្រព័ន្ធអនុគ្រោះពន្ធ |
| GTZ | សហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ |
| HALO Trust | អង្គការកម្ពុជាត្រាស្ត |
| HC | មណ្ឌលសុខភាព |
| HDI | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស |
| HI | អង្គការជនពិការអន្តរជាតិ |
| HIV/AIDS | មេរោគអេដស៍/ជំងឺអេដស៍ |
| HP | ប៉ុស្តិ៍សុខភាព |
| HPI | សន្ទស្សន៍ភាពក្រីក្ររបស់មនុស្ស |
| HSS | អង្កេតតាមដានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ |
| ICORC | គណៈកម្មាធិការអន្តរជាតិស្តីពីការកសាងកម្ពុជាឡើងវិញ |
| ICT | ពត៌មាន និងបច្ចេកវិទ្យាទំនាក់ទំនង |

| | |
|---|---|
| IDA | ជំងឺខ្វះឈាមក្រហម |
| IEC | ពត៌មាន អប់រំ និងទំនាក់ទំនង |
| ISIC | និយាមអន្តរជាតិនៃចំណាត់ថ្នាក់តាមវិស័យ |
| ITN | មុងជ្រលក់ថ្នាំ |
| IUCN | សហព័ន្ធអភិរក្សធម្មជាតិពិភពលោក |
| LDC | ប្រទេសអភិវឌ្ឍន៍តិចតួច |
| LFS | អង្កេតកំលាំងពលកម្ម |
| LMAP | គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី |
| MAG | ក្រុមប្រឹក្សាសកម្មភាពមីន |
| LMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| M&E | តាមដាន និងវាយតំលៃ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MFN | ប្រទេសដែលទទួលបានការអនុគ្រោះពន្ធ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MOE | ក្រសួងបរិស្ថាន |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | ក្រសួងសុខាភិបាល |
| MOI | ក្រសួងមហាផ្ទៃ |
| MOP | ក្រសួងផែនការ |
| MOSALVY | ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា |
| MOWVA | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MTCT | ការឆ្លងពីម្តាយទៅកូន |
| MTEF | ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម |
| MTEP | ផែនការចំណាយរយៈពេលមធ្យម |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| NARG1 | អត្រាពិតចូលរៀនថ្មីនៅថ្នាក់ទីមួយ |
| NDCP | កម្មវិធីគ្រប់គ្រងជំងឺគ្រុនឈាម |
| NDFC | មជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនឈាម |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ សើរស្បែក និងកាមរោគ |

| | |
|---|---|
| NEC | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) |
| NERLSE | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ |
| NERPE | អត្រាពិតនៃការសិក្សានៅបឋមសិក្សា |
| NFE | ការអប់រំក្រៅប្រព័ន្ធ |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| NHS | អង្កេតសុខភាពជាតិ |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NPF | វេទិកាជាតិស្តីពីភាពក្រីក្រ |
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| NTP | កម្មវិធីជាតិកំចាត់ជំងឺរបេង |
| OD | ស្រុកប្រតិបត្តិ |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| OECD | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| PAP | កម្មវិធីសកម្មភាពអាទិភាព |
| PC6-14OS | សមាមាត្រកុមារអាយុពី ៦ ទៅ ១៤ឆ្នាំ ដែលមិនបានចូលរៀន |
| PGER | អត្រារួមនៃការសិក្សានៅបឋមសិក្សា |
| PLWHA | អ្នករស់នៅដោយផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ |
| PMA | ការតាមដាន និងវិភាគភាពក្រីក្រ |
| PMATU | អង្គភាពបច្ចេកទេសតាមដាន និងវិភាគភាពក្រីក្រ |
| PMIS | ប្រព័ន្ធគ្រប់គ្រងពត៌មានភាពក្រីក្រ |
| PVI | សូចនាករភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព |
| RCAF | កងយោធពលខេមរភូមិន្ទ |
| RGBLSE | ផលធៀបចំនួនកុមារី ជាមួយចំនួនកុមារា ដែលរៀននៅមធ្យមសិក្សាបឋមភូមិ |
| RGBPE | ផលធៀបចំនួនកុមារី ជាមួយចំនួនកុមារា ដែលរៀននៅបឋមសិក្សា |
| RGBUSE | ផលធៀបចំនួនកុមារី ជាមួយចំនួនកុមារា ដែលរៀននៅមធ្យមសិក្សាទុតិយភូមិ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RLFM | ផលធៀបនៃអក្ខរកម្មស្ត្រី និងបុរស |
| RWSS | យុទ្ធសាស្ត្រទឹក និងអនាម័យជនបទ |
| SAC | ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិតិ |
| SCC | គណៈកម្មាធិការសំរបសំរួលស្ថិតិ |
| SEDPII | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទីពីរ |

| | |
|---|---|
| SPQ | ការប្រើប្រាស់ចំណាយរបស់ប្រជាជនដែលក្រីក្រជាងគេបំផុត ២០% |
| SRG1-5 | អត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ ទី៥ |
| SRG1-6 | អត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ ទី៦ ដែលជាថ្នាក់ចុងក្រោយនៅកំរិតអប់រំបឋមសិក្សា |
| SRG1-9 | អត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ ទី៩ ដែលជាថ្នាក់ចុងក្រោយនៅកំរិតអប់រំមូលដ្ឋាន |
| STDs or STI | ជំងឺកាមរោគ |
| SWAP | វិធីសាស្រ្តទូលំទូលាយតាមវិស័យ |
| SWOT | ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង |
| TB | ជំងឺរបេង |
| TBA | ឆ្មបបូរាណ |
| TTC | សាលាបណ្តុះបណ្តាលគ្រូ |
| TVET | ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| TWG | ក្រុមការងារបច្ចេកទេស |
| UNCT | ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNDAF | ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ |
| UNESCO | អង្គការ ការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌ សហប្រជាជាតិ |
| UNGASS | សម័យប្រជុំពិសេស នៃមហាសន្និបាតអង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិសហប្រជាជាតិសំរាប់កុមារ |
| UNMAS | សេវាសកម្មភាពមីនសហប្រជាជាតិ |
| USAID | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក |
| UXO | យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ( គ្រាប់មិនទាន់ផ្ទុះ) |
| VCT | ការពិគ្រោះ និងការធ្វើតេស្តដោយស្ម័គ្រចិត្ត |
| WATSAN | ទឹក និងអនាម័យ |
| WB | ធនាគារពិភពលោក |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |
| WG | ក្រុមការងារ |
| WHO | អង្គការសុខភាពពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |
| YLR | អត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី ១៥ ទៅ ២៤ឆ្នាំ |

# សេចក្តីផ្តើម

សេចក្តីប្រកាសសហស្សវត្សរ៍ដែលរាជរដ្ឋាភិបាលកម្ពុជា ជាហត្ថលេខីនោះ ជាឯកសារមួយដែលមានសារៈសំខាន់ក្រៃលែង។ សេចក្តីប្រកាសនេះ បញ្ជាក់នូវការប្តូរផ្តាច់របស់ប្រទេសកម្ពុជាក្នុងការសំរេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (គអស)។ គអស ទាំងនេះ បានផ្តោតការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែង ក្នុងការសំរេចឱ្យបាននូវលទ្ធផលជាគន្លឹះអប្បបរមាមួយចំនួន។ រាជរដ្ឋាភិបាលកម្ពុជា មានការប្តូរផ្តាច់យ៉ាងច្បាស់លាស់ក្នុងការដើរតួជាអ្នកដឹកនាំ និងអ្នកសម្របសម្រួលក្នុងការសំរេច ឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក)។ ភាគីពាក់ព័ន្ធខាងការអភិវឌ្ឍន៍ទាំងអស់នៅក្នុងប្រទេសកម្ពុជារួមទាំង តំណាងរបស់រាជរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ហើយនិងសហគមន៍ផ្តល់ជំនួយ មានការប្តូរផ្តាច់ក្នុងការធ្វើការរួមគ្នាដើម្បីឈានឆ្ពោះទៅរក គអស។

របាយការណ៍នេះ គឺជារបាយការណ៍ទីពីរស្តីអំពី គអសក។ របាយការណ៍ទីមួយដែលបានផលិត នៅឆ្នាំ ២០០១ ត្រូវបានរៀបចំឡើងក្រោមការដឹកនាំ របស់ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស។ របាយការណ៍នេះមានគុណសម្បត្តិក្នុងការណែនាំប្រទេសកម្ពុជាឱ្យយល់អំពី គអស និងលើកកំពស់ការយល់ដឹង នៅក្នុងចំណោមភាគីពាក់ព័ន្ធលើការងារអភិវឌ្ឍន៍ទាំងអស់ អំពីសារៈសំខាន់នៃការសំរេចគោលដៅទាំងនោះ។

របាយការណ៍ស្តីពីភាពជឿនលឿននៃ គអសក ឆ្នាំ២០០៣ បានបង្កើតនូវទិដ្ឋភាពថ្មីៗជាច្រើន។ ទីមួយ ហើយដែលសំខាន់ជាងគេបំផុតនោះ គឺរបាយការណ៍នេះត្រូវបានរៀបចំក្រោមការដឹកនាំ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចដោយមានការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធអភិវឌ្ឍន៍សំខាន់ៗមួយចំនួន។ ទីពីរ របាយការណ៍នេះបានពាក់ព័ន្ធទៅនឹងមូលដ្ឋានីយកម្មនៃ គអស ដែលឥឡូវនេះហៅថា គអសក ដើម្បីឆ្លុះបញ្ចាំងអំពីការពិតនៅកម្ពុជាឱ្យបានប្រសើរជាងមុន។ ទីបី របាយការណ៍នេះ បានផ្តល់នូវការវិនិច្ឆ័យស៊ីជំរៅជាងមុន អំពីស្ថានភាពរបស់ប្រទេស។ ទីបួន គោលនយោបាយ និងកម្មវិធីចំបងៗ ដែលរួមចំនែកដល់ គអសក ត្រូវបានកំនត់ និងពិពណ៌នា។ ទីប្រាំ របាយការណ៍នេះ បានកំនត់នូវបញ្ហាចំបងមួយចំនួននៅក្នុងការអនុវត្តន៍ គអសក ហើយក៏បានដាក់ចេញនូវក្របខ័ណ្ឌការងារ ដើម្បីជំនះនូវបញ្ហាប្រឈមនានា និងសំរេចឱ្យបាននូវគោលដៅទាំងនោះ។ ទីប្រាំមួយ របាយការណ៍នេះ ក៏បានគូសបញ្ជាក់អំពីការផ្សារភ្ជាប់ រវាងទំនាក់ទំនងយ៉ាងសំខាន់ក្នុងចំណោម គអសក ទាំងឡាយ។ ជាចុងក្រោយ របាយការណ៍នេះ បង្ហាញពីផែនការតំរង់ទិសសំរាប់ឱ្យមានការវាយតំលៃ និងតាមដានប្រកបដោយប្រសិទ្ធភាពនៃភាពជឿនលឿនលើ គអសក។

របាយការណ៍ស្តីពីភាពជឿនលឿននៃ គអសក ឆ្នាំ២០០៣ ត្រូវបានបែងចែកជាបីផ្នែកធំៗ។ ផ្នែកទីមួយណែនាំឱ្យស្គាល់អំពីបរិបទអភិវឌ្ឍន៍នៅប្រទេសកម្ពុជា។ ផ្នែកទីពីរ បានបង្ហាញ (i)សូចនាករ និងចំនុចដៅរបស់ គអសក (ii)ស្ថានភាពបច្ចុប្បន្ន និន្នាការកន្លងមក និងអនាគត ក៏ដូចជាគំលាតរវាងចំនុចដៅ និងនិន្នាការ (iii) គោលនយោបាយ និងកម្មវិធីបច្ចុប្បន្នសំខាន់ៗ ដែលចូលរួមចំនែកដល់ គអសក (iv)បញ្ហាប្រឈមចំបងៗ ក្នុងការបំពេញនូវចំនុចដៅ គអសក ហើយនិង (v)ក្របខ័ណ្ឌការងារ ដើម្បីជំនះនឹងបញ្ហាប្រឈមចំបងៗ និងឈានទៅសំរេចបានចំនុចដៅ គអសក ទាំងនោះ។ ផ្នែកទីបី គូសបញ្ជាក់អំពីវិធីសាស្ត្រតាមដាន និងវាយតំលៃលើភាពជឿនលឿនរបស់ គអសក។ របាយការណ៍នេះ ក៏ភ្ជាប់នូវឧបសម្ព័ន្ធមួយចំនួន ដោយរាប់បញ្ចូលទាំងសន្ទានុក្រមនៃពាក្យបច្ចេកទេស និងការពិភាក្សាអំពីវិធីសាស្ត្រគណនា។

# ផ្នែកទី១

# បរិបទអភិវឌ្ឍន៍នៅប្រទេសកម្ពុជា

## ១.១ លក្ខណៈរចនាសម្ព័ន្ធ និងប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសកម្ពុជា

ប្រទេសកម្ពុជា ស្ថិតនៅផ្នែកនិរតីនៃឧបទ្វីបឥណ្ឌូចិន ក្នុងតំបន់អាស៊ីអគ្នេយ៍ ដែលមានផ្ទៃដីសរុប ១៨១០៣៥គ.ម[២] ។ ប្រទេសកម្ពុជាធំជាងពាក់កណ្ដាលនៃប្រទេសវៀតណាមបន្តិច និងប្រហែលជាមួយភាគបី នៃប្រទេសថៃ។ ប្រទេសកម្ពុជា មានព្រំប្រទល់ជាប់នឹងប្រទេសថៃនៅភាគខាងលិច និងភាគពាយ័ព្យ ជាប់នឹងប្រទេសសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅភាគខាងជើង ជាប់នឹងប្រទេសវៀតណាម នៅទិសបូពិ និងអគ្នេយ៍ ហើយជាប់នឹងឈូងសមុទ្រថៃ នៅភាគខាងត្បូង និងភាគនិរតី។ កម្ពុជាភាគច្រើនមានដីទំនាបដែលហូរកាត់ដោយទន្លេរ និងស្ទឹងជាច្រើនដែលហូរចាក់ទៅក្នុងទន្លេរមេគង្គ និងបឹងទន្លេសាប។ មានជួរភ្នំទាបៗជាច្រើននៅក្នុងផ្នែកនិរតីនៃប្រទេស និងនៅតាមព្រំដែនភាគខាងជើងជាមួយប្រទេសថៃ រីឯនៅភាគឦសាន គឺជាខ្ពង់រាបដែលសំបូរទៅដោយព្រៃ ដែលមានរយៈកំពស់ខ្ពស់ជាងតំបន់វាលទំនាបកណ្ដាល។ កំពស់ទឹកភ្លៀង គឺមានលក្ខណៈខុសៗគ្នាទៅតាមតំបន់ក្នុងប្រទេស ហើយក៏មានលក្ខណៈខុសៗគ្នាពីមួយឆ្នាំទៅមួយឆ្នាំផងដែរ។ កំពស់ទឹកភ្លៀងនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈមិនស្មើគ្នា ហើយមិនទៀងទាត់ដែលបណ្ដាលឱ្យមានភាពរាំងស្ងួត ឬក៏ទឹកជំនន់ដែលជួនកាលកើតឡើងដំណាលគ្នានៅតំបន់ផ្សេងៗនៃប្រទេស។ រយៈពេលនៃការធ្លាក់ភ្លៀងខ្លាំងច្រើនតែអាក់ខានដែលគេហៅថារដូវរាំងស្ងួតរយៈពេលខ្លី (កូនរដូវប្រាំង) ជាធម្មតាក្នុងកំឡុងពេល ១ ឬ ២ សប្ដាហ៍ ដែលមានទឹកភ្លៀងតិចជាងមុន ឬក៏អត់ទឹកភ្លៀងតែម្ដង នៅក្នុងខែមិថុនា និងខែកក្កដា។ រយៈពេលនេះ ជារយៈពេលដែលមានលក្ខណៈសំខាន់យ៉ាងខ្លាំងសំរាប់ការបង្កបង្កើនផលស្រូវ។

គួររំលឹកថាក្នុងរយៈពេលជិត ២០ឆ្នាំ ប្រទេសកម្ពុជាត្រូវបាននៅឯកោពីសហគមន៍អន្តរជាតិ ដោយសារសង្គ្រាម និងសេចក្ដីវេទនា។ ជំលោះផ្ទៃក្នុងដែលបានចាប់ផ្ដើមនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ បានបង្កឱ្យបាត់បង់ជីវិតមនុស្ស និងធនធានមនុស្សយ៉ាងសំបើម ក៏ដូចជាមានការបំផ្លិចបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមផងដែរ។ នៅក្នុងកិរិតណាមួយនោះ ការប្រឈមខាងសេដ្ឋកិច្ច-សង្គមកិច្ច ដ៏សន្ធឹកសន្ធាប់ដែលប្រទេសកម្ពុជាកំពុងតែជួបប្រទះនោះ គឺជាមរតកនៃយុគសម័យនេះឯង។

ជាលើកទីមួយ ក្នុងរយៈពេលជិតបីទសវត្សរ៍ ដែលមានការវិលត្រឡប់មកវិញនូវសន្តិភាព និងការស្ដារស្ថិរភាពខាងម៉ាក្រូសេដ្ឋកិច្ច បន្ទាប់ពីមានការបោះឆ្នោត ឆ្នាំ១៩៩៣ ប្រទេសកម្ពុជាមានឱកាសធ្វើកំនែទំរង់ ដែលមានឥទ្ធិពលយ៉ាងធំធេងនៅក្នុងផ្នែកសេដ្ឋកិច្ច និងសង្គម។ គោលបំណងនេះ គឺសំដៅលើកកំពស់ផលិតភាព និងជីវភាពរស់នៅ ហើយជាចុងក្រោយគឺកាត់បន្ថយភាពក្រីក្រ នៅក្នុងបរិបទនៃប្រទេសមួយក្នុងចំណោមប្រទេស ដែលមានប្រាក់ចំណូលប្រចាំឆ្នាំទាបជាងគេបំផុតនៅក្នុងពិភពលោក។ បន្ទាប់ពីមានអស្ថិរភាពអស់រយៈពេលជិតបីទសវត្សរ៍ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា កំពុងស្វែងរកមធ្យោបាយដោះស្រាយទៅនឹងបញ្ហាសេដ្ឋកិច្ចដែលកំពុងជួបប្រទះដោយសារកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច។

ស្ថានភាពប្រជាសាស្ត្រនៃប្រទេសកម្ពុជា ក៏បានឆ្លុះបញ្ចាំងនូវកេរ្តិ៍ដំណែល ដែលបានទទួលនូវការរងទុក្ខ និងការតស៊ូអស់រយៈពេលដ៏យូរអង្វែង។ យោងតាមជំរឿន ឆ្នាំ១៩៩៨ ប្រជាជនកម្ពុជាមានចំនួនជាង ១១,៤លាននាក់ ដែលក្នុងនោះបុរសមានចំនួន ៥,៥លាននាក់ និងស្ត្រីមានចំនួន ៥,៩លាននាក់។ អត្រាកំនើនប្រជាជនគឺ ២,៥% ក្នុងមួយឆ្នាំ។ ជិត៨៥% នៃប្រជាជនរស់នៅតំបន់ជនបទ។ ប្រជាជនវ័យក្មេងអាយុតិចជាង ១៥ឆ្នាំ មានចំនួនជិត

៤៣% នៅឆ្នាំ១៩៩៨[៥] ។ របបខ្មែរក្រហមបានធ្វើឱ្យមានការប្រែប្រួលដល់រចនាសម្ព័ន្ធអាយុ និងយេនឌ័រ នៅក្នុងចំណោមប្រជាជន។ សមាសភាពភេទជារួម ក្នុងស្ត្រី ១០០នាក់ មានបុរសតែ ៩៣នាក់ ប៉ុណ្ណោះ ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវភាពមិនប្រក្រតីនៃសមាមាត្របុរស ដោយសារតែមានការបាត់បង់បុរសអាយុ ២០ឆ្នាំ ឬក៏លើសពីនេះ នៅក្នុងសម័យខ្មែរក្រហមចាប់ពី ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

## ១.២ ភាពអំណោយផលសំរាប់ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ

សេចក្តីប្រកាសប្រចាំសហស្សវត្សរ៍ គឺជាការប្តូរផ្តាច់ចំពោះសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ សន្តិភាព សន្តិសុខ និងអភិបាលកិច្ចល្អ។ សេចក្តីប្រកាសនេះ បានទទួលស្គាល់នូវសារៈសំខាន់នៃ បរិយាកាសអំណោយផលក្នុងការសំរេចឱ្យបាននូវការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកនីតិរដ្ឋ និងគោលការណ៍អភិបាលកិច្ចល្អ ដូចជាតំលាភាព ការប្រមើលទុកជាមុន ការទទួលខុសត្រូវ និងការចូលរួមជាល័ក្ខខ័ណ្ឌចាំបាច់ដំបូង ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយចីរភាព យុត្តិធម៌សង្គម និងការកាត់បន្ថយភាពក្រីក្រ។

បន្ទាប់ពីរយៈពេល ២៥ឆ្នាំ នៃអស្ថិរភាព និងសង្គ្រាមស៊ីវិលដែលបាននាំទៅដល់ការដួលរលំស្ទើរតែទាំងស្រុងនៃស្ថាប័ន និងប្រព័ន្ធអភិបាលកិច្ចនៅក្នុងប្រទេសនេះដែលឥឡូវ កម្ពុជាគឺជាដែនដីមួយដែលមានសន្តិភាព និងបើកទូលាយចំពោះពិភពលោក។ ប្រទេសកម្ពុជាបានទទួលយកនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សការគោរពសិទ្ធិមនុស្ស សហគ្រាសសេរី និងសេដ្ឋកិច្ចទីផ្សារ ហើយនិងការធ្វើសមាហរណកម្មយ៉ាងពេញលេញ ទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កម្ពុជាកំពុងតែស្ថិតនៅក្នុងដំណាក់កាលដំបូងនៅក្នុងមាគ៌ាមួយដ៏វែងឆ្ងាយ ដែលបានត្រួសត្រាយដោយការរំពឹងទុកខ្ពស់ ចំពោះធនធានដ៏មានកំរិត។ ការផ្លាស់ប្តូរកម្មវិធីដូចមានរំលេចនៅក្នុងឯកសារផ្លូវការរួមមាន គអសក ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី២ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រជាតំរូវការចាំបាច់។ ជោគជ័យនេះនឹងអាស្រ័យទៅលើវិសាលភាពថាតើគោលការណ៍នៃអភិបាលកិច្ចល្អ ដែលចូលរួមចំណែកនោះ ត្រូវបានគោរពកំរិតណា។

របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០០ បានចែងថា "ជីវភាពរស់នៅសមរម្យ អាហារូបត្ថម្ភគ្រប់គ្រាន់ការគាំពារសុខភាព និងការអប់រំ មិនមែនត្រឹមតែជាគោលដៅអភិវឌ្ឍន៍ប៉ុណ្ណោះទេ តែវាគឺជាសិទ្ធិមនុស្សផងដែរ" (ទំព័រទី៨)។ ប្រទេសកម្ពុជា គឺជាភាគីមួយដែលបានផ្តល់សច្ចាប័នលើឯកសារច្បាប់ទាំងប្រាំមួយស្តីអំពីសិទ្ធិមនុស្សអន្តរជាតិរួមមាន អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងពូជសាសន៍ នៅឆ្នាំ១៩៨៣ អនុសញ្ញាអន្តរជាតិស៊ីវិល និងសិទ្ធិខាងនយោបាយ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងចំពោះស្ត្រី អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬធ្វើទណ្ឌកម្មឃោរឃៅអមនុស្សធម៌ ឬធ្វើឱ្យអាប់អោនកិត្តិយសដល់អ្នកដទៃ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅឆ្នាំ១៩៩២។ បទបញ្ញត្តិទាំងអស់នេះបានពង្រឹង និងបំពេញបន្ថែមលើ គអសក ដោយផ្តោតទៅលើបញ្ហាជាច្រើន ដែលស្ថិតនៅចំណុចស្នូលនៃ គអស ពោលគឺៈ ភាពក្រីក្រ ភាពអត់ឃ្លាន តំបន់ក្រីក្រក្នុងទីក្រុង ការអប់រំ វិសមភាព

[៥] ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជា ឆ្នាំ១៩៩៨: របាយការណ៍វិភាគលទ្ធផលជំរឿនទី៦: ការប៉ាន់ស្មានប្រជាជន ឆ្នាំ២០០១-២០២១។ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ភ្នំពេញ។

យេនឌ័រ និងការមិនផ្ដល់សិទ្ធិអំណាចដល់ស្ត្រី មរណភាពកុមារ សុខភាពទន់ខ្សោយរបស់ម្ដាយ មេរោគអេដស៍/ជំងឺអេដស៍ និងជំងឺឆ្លងដទៃទៀត និងតំរូវការឱ្យមានចីរភាពខាងបរិស្ថាន ដោយរួមបញ្ចូលទាំងទឹកស្អាតផងដែរ ។

គោលនយោបាយ និងកម្មវិធីសំខាន់ៗបច្ចុប្បន្ន ដែលប្រទេសកម្ពុជាកំពុងអនុវត្តន៍ ហើយត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ គអសក រួមចំណែកក្នុងការសំរេចបាននូវសិទ្ធិមនុស្ស ជាពិសេសបង្ហាញនូវភាពស៊ីសង្វាក់គ្នារវាងវិធានការដែលត្រូវបានដាក់ចេញ ទៅនឹងខ្លឹមសារនៃសេចក្ដីប្ដេជ្ញាចិត្តរបស់កម្ពុជា ចំពោះសិទ្ធិមនុស្សអន្តរជាតិ។ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីបំពេញចំណុចដៅ គអសក បានក្លាយទៅជាជំហានដ៏សំខាន់ ឆ្ពោះទៅរកការបំពេញនូវកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិមួយចំនួន ។

ផែនការសកម្មភាពអភិបាលកិច្ចត្រូវបានតាក់តែងឡើង តាមរយៈការពិភាក្សាថ្នាក់ជាតិ ជាបន្តបន្ទាប់ ហើយត្រូវបានអនុម័តនៅខែមីនា ឆ្នាំ២០០១។ ផែនការនេះដែលដើរតួជាផែនការតំរង់ទិសរបស់រាជរដ្ឋាភិបាល ដើម្បីជាមគ្គុទេសក៍ និងការសម្របសម្រួលគំនិតផ្ដួចផ្ដើមកំនែទំរង់អភិបាលកិច្ចចំបងនានា គឺក្ដោបលើផ្នែកជាអាទិភាពចំនួនប្រាំបីរួមមាន (១)កំនែទំរង់ច្បាប់ និងតុលាការ (២)កំនែទំរង់រដ្ឋបាល និងវិសហមជ្ឈការ (៣)វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន (៤)កំនែទំរង់ហិរញ្ញវត្ថុសាធារណៈ (៥)ការប្រឆាំងអំពើពុករលួយ (៦)សមធមិយេនឌ័រ (៧)ការរំសាយទ័ព និងកំនែទំរង់កងកំលាំងប្រដាប់អាវុធ និង(៨)កំនែទំរង់នៃការគ្រប់គ្រងធនធានធម្មជាតិ (ដី ព្រៃឈើ និងជលផល)។ គំនិតផ្ដួចផ្ដើមភាគច្រើនដែលបានជ្រើសរើសធ្វើជាអាទិភាពដំបូងនោះត្រូវបានបញ្ចប់សព្វគ្រប់ ហើយគំនិតផ្ដួចផ្ដើមរយៈពេលមធ្យមក៏កំពុងដំណើរការទៅមុខដែរ ។ ផែនការនេះត្រូវបានធ្វើអោយមានបច្ចុប្បន្នភាព និងកត់ត្រានូវភាពជឿនលឿន បន្ទាប់ពីរយៈពេលពីរឆ្នាំនៃការអនុវត្តន៍ ហើយដាក់ចេញនូវអាទិភាពនានា សំរាប់រយៈពេលបីឆ្នាំបន្ទាប់។ ផែនការនេះក៏កំពុងតែត្រូវបានគេពង្រីក ដោយយកចិត្តទុកដាក់លើកិច្ចអភិវឌ្ឍន៍សង្គមឱ្យបានកាន់តែប្រសើរជាងមុន ។

ដើម្បីឱ្យរាជរដ្ឋាភិបាលបានជិតស្និទ្ធជាមួយនឹងប្រជាជនជាងមុននោះ រាជរដ្ឋាភិបាលកម្ពុជាបានបោះជំហានដំបូងឆ្ពោះទៅការធ្វើវិមជ្ឈការ ដោយបានដាក់ចេញនូវច្បាប់ជាមូលដ្ឋានសំខាន់ពីរ គឺច្បាប់ស្ដីពីវិមជ្ឈការ និងការបោះឆ្នោតឃុំ/សង្កាត់ ឆ្នាំ២០០១។ ការរៀបចំប្រកបដោយជោគជ័យនៃការបោះឆ្នោះឃុំ/សង្កាត់ ឆ្នាំ២០០២ ហើយការបោះឆ្នោតថ្នាក់ជាតិ នៅខែកក្កដា ឆ្នាំ២០០៣ គឺជាសាក្សីបញ្ជាក់ពីគោលបំណងរបស់កម្ពុជា ក្នុងការកសាងនូវសង្គមប្រជាធិបតេយ្យពិតប្រាកដ ។

ទិដ្ឋភាពជាគន្លឹះនៃអភិបាលកិច្ច ដែលសំខាន់ចំពោះការសំរេចបាននូវ គអសក គឺការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងទិដ្ឋភាពផ្សេងៗ នៃការតាក់តែង និងការអនុវត្តន៍គោលនយោបាយ ។ ការលើកកំពស់ការចូលរួម គឺមានលក្ខណៈសំខាន់ខ្លាំងណាស់ចំពោះការធ្វើអោយប្រសើរឡើងនូវតំលាភាព និងការទទួលខុសត្រូវ ដោយធានាអោយបានភាពជាម្ចាស់នៅថ្នាក់មូលដ្ឋាន និងការគាំទ្រតាមរយៈការចូលរួមឱ្យបានកុះករ និងសកម្មពីសំណាក់ប្រជាជននៅក្នុងដំណើរការអភិវឌ្ឍន៍។ ដំណើរការនៃកំណើនការចូលរួមរបស់ប្រជាជន មានឥទ្ធិពលជាសារវ័ន្ត និងយូរអង្វែងជាងមុន ដើម្បីឆ្ពោះទៅសំរេច គអសក។ ដំណើរការនេះ ក៏បានជំរុញឱ្យមានការចូលរួមពីប្រជាជនច្រើនជាងមុន លើកកំពស់នូវការយល់ដឹងរបស់ប្រជាជន ស្ដីអំពីសិទ្ធិសេដ្ឋកិច្ច-សង្គមកិច្ច ហើយក៏បានចូលរួមវិភាគទានដល់ការចាក់គ្រឹះនៃដំណើរការលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាផងដែរ ។

ដំណើរការប្រកបដោយប្រសិទ្ធភាពនៃវិមជ្ឈការ ដែលធ្វើឱ្យអ្នកផ្តល់សេវាកម្មបានខិតទៅជិតអ្នកប្រើប្រាស់ជាងមុននោះ គឺការបង្កើននូវតំលាភាពផលិតភាព និងគុណភាពនៃសេវាកម្មដែលបានផ្តល់។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីឱ្យការអនុវត្តន៏វិមជ្ឈការប្រកបដោយប្រសិទ្ធភាព អាចនឹងចូលរួមចំណែកគួរឱ្យកត់សំគាល់ដល់ការសំរេចបាននូវ គអសក នោះ គឺយើងត្រូវធ្វើការដោះស្រាយទៅលើបញ្ហាជាសារវន្តមួយចំនួន នៅក្នុងវិស័យផ្សេងៗគ្នា។ ជាពិសេសតំរូវអោយមានយុទ្ធសាស្ត្រផ្ទាល់ខ្លួនច្បាស់លាស់ និងរលូន សំរាប់ការអនុវត្តន៏កំនែទំរង់វិមជ្ឈការនានា ដោយរាប់បញ្ចូលទាំងការចាត់តាំងនូវមុខងារ និងតួនាទីជាក់លាក់ទៅឱ្យឃុំ/សង្កាត់ និងរដ្ឋបាលតាមលំដាប់ថ្នាក់ផ្សេងៗគ្នា ក្នុងការផ្តល់សេវាកម្មការអនុវត្តន៏ ដោយមានប្រាក់ចំណូលស្របគ្នា វចនាសម្ព័ន្ធអចិន្ត្រៃយ៏ និងយន្តការសំរាប់ការគាំទ្រ និងត្រួតពិនិត្យទៅលើក្រុមប្រឹក្សាឃុំ/សង្កាត់ និងសម្របសម្រួលគំនិតផ្តួចផ្តើមនានា ក្នុងចំណោមក្រសួងទាំងឡាយ ដើម្បីធ្វើវិសហមជ្ឈការ នៃការផ្តល់សេវាកម្មនៅក្នុងកំរិតមួយដ៏សមស្រប។

ការពង្រឹងស្ថាប័នសាធារណៈ ដើម្បីផ្តល់លទ្ធផលនានា គឺមិនត្រឹមតែទាមទារឱ្យមានការកសាងសមត្ថភាពមនុស្សប៉ុណ្ណោះទេ ថែមទាំងត្រូវដោះស្រាយការរៀបចំនូវប្រព័ន្ធលើកទឹកចិត្តជាសារវន្ត ដើម្បីជំរុញឱ្យសេវាកម្មស៊ីវិលធ្វើការជ្រើសរើស និងរក្សាទុកនូវមន្ត្រីដែលមានសមត្ថភាពខ្ពស់។ ដូច្នេះការកែលំអប្រាក់បៀវត្សរ៍ និងការងារវិស័យសាធារណៈ នៅក្នុងបរិបទនៃក្របខ័ណ្ឌការងារ ការទទួលខុសត្រូវជាសាធារណៈ គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះការសំរេច គអសក។

ស្ថាប័ននីតិបញ្ញត្តិ និងតុលាការនៅមានភាពទន់ខ្សោយនៅឡើយ បើប្រៀបធៀបទៅនឹងស្ថាប័នប្រតិបត្តិ។ ជាលទ្ធផល ការត្រួតពិនិត្យ និងតុល្យភាពខ្សែទទឹងគឺនៅមានកំរិត។ ការទទួលខុសត្រូវរបស់ស្ថាប័នទាំងពីរនេះត្រូវតែពង្រឹង ដើម្បីធានាការបំពេញនូវតួនាទីឱ្យបានត្រឹមត្រូវ នៅក្នុងការតាក់តែងគោលនយោបាយ និងនៅក្នុងសកម្មភាពតាមដាន និងការអនុវត្តន៏ផ្សេងៗ។ ស្ថាប័នរាជរដ្ឋាភិបាលដែលមានដំណើរការ មានប្រសិទ្ធភាព មានការទទួលខុសត្រូវ និងសង្គមស៊ីវិលដ៏រស់រវើកមានសារៈសំខាន់ណាស់ ក្នុងការសំរេចនូវលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ដែលបានឆ្លុះបញ្ចាំងនៅក្នុង គអសក។

**១.៣ បញ្ហាប្រឈម និងការអនុវត្តន៏នៃកិច្ចអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គមកិច្ចក្នុងរយៈពេលមួយទសវត្សរ៍មុន**

ឆ្នាំ១៩៩០ ជាឆ្នាំទី១នៃរបាយការណ៏អភិវឌ្ឍន៏មនុស្ស សន្ទស្សន៏នៃការអភិវឌ្ឍន៏មនុស្សនៅកម្ពុជាបង្ហាញត្រឹមតែ ០,៥១២ ប៉ុណ្ណោះដែលធ្វើឱ្យប្រទេសនេះស្ថិតនៅក្នុងលំដាប់ "ការអភិវឌ្ឍន៏មនុស្សកំរិតទាប"។ នៅឆ្នាំ ២០០១ សន្ទស្សន៏អភិវឌ្ឍន៏មនុស្សរបស់កម្ពុជាមានកំរិត ០,៥៥៦ បានធ្វើឱ្យកម្ពុជាឡើងមួយកំរិតទៅដល់លំដាប់ "ការអភិវឌ្ឍន៏មនុស្សកំរិតមធ្យម" ហើយបានធ្វើឱ្យប្រទេសកម្ពុជាស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ១៣០ ក្នុងចំណោមប្រទេសចំនួន ១៧៥។ នេះបានសំដែងឱ្យឃើញនូវការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅក្នុងការអភិវឌ្ឍន៏សង្គម។ ទោះបីជាយ៉ាងណាក៏ដោយ ភាពក្រីក្រនៅប្រទេសកម្ពុជានៅតែជាបញ្ហា ដែលត្រូវយកចិត្តទុកដាក់នៅឡើយ។ ប្រជាជនកម្ពុជា ៣៦% រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ។ ភាពក្រីក្រនៅកម្ពុជាបណ្តាលមកពីកត្តាជាច្រើនរួមមាន កំនើនប្រជាជនខ្ពស់ កង្វះកាលានុវត្តភាព សមត្ថភាពនៅមានកំរិត អសន្តិសុខ ភាពឯកោ និងភាពងាយរងគ្រោះ។

### ១.៣.១ កំនើនសេដ្ឋកិច្ច

រូបមន្តរបស់រាជរដ្ឋាភិបាល សំរាប់ឱ្យមានការគ្រប់គ្រងសេដ្ឋកិច្ចដ៏សមស្របមួយ គឺជាការគួបផ្សំដ៏ប្រសើរវាំងគោលនយោបាយស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងកំនែទំរង់ផ្នែកមីក្រូសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩ ប្រទេសកម្ពុជាបានអនុវត្ត និងធ្វើឱ្យមានភាពជឿនលឿនដ៏សំខាន់ នៅក្នុងការអនុវត្តន៏ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលសំដៅសំរេចឱ្យបាន នូវកំនើនសេដ្ឋកិច្ចរយៈពេលវែងប្រកបដោយសមធម៌ និងការអភិវឌ្ឍន៏ប្រកបដោយចីរភាព។ ក្របខ័ណ្ឌការងារនេះ ផ្តោតជាសំខាន់ទៅលើការរក្សាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ពង្រឹងស្ថាប័នធនាគារ និងហិរញ្ញវត្ថុ ការអនុវត្តន៏ វិធានការកំនែទំរង់ហិរញ្ញវត្ថុ ដោយធានាឱ្យមានការគ្រប់គ្រងដ៏សមស្របទៅលើសម្បត្តិសាធារណៈ ការបង្កើនវិនិយោគសាធារណៈ ដើម្បីអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម និងធនធានមនុស្ស។ កម្ពុជាបានបោះជំហានគួរឱ្យកត់សំគាល់ នៅក្នុងការពង្រឹងស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៏អន្តរជាតិ។

ចាប់តាំងពីមានការបង្កើតរាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ២០០២ កំនើនផលិតផលសរុបក្នុងស្រុកជាមធ្យមគឺមាន ៥,៥%។ កសិកម្មមានចំនួន ៣៣,៤% នៃផលិតផលក្នុងស្រុកសរុប ហើយក៏បានផ្តល់ការងារ ៧០,៧% នៃកំលាំងពលកម្ម។ វិស័យនេះកំពុងតែមានការរីកចំរើនជាមធ្យម ៣,៦% ក៏ប៉ុន្តែ ទិន្នផលកសិកម្មមានការប្រែប្រួលយ៉ាងច្រើន ពីមួយឆ្នាំទៅមួយឆ្នាំ ដោយឆ្លុះបញ្ចាំងឱ្យឃើញនូវការវិនិយោគមិនគ្រប់គ្រាន់នៅក្នុងវិស័យនេះ ការធ្វើអាជីវកម្មហួសហេតុលើធនធានធម្មជាតិ និងល័ក្ខខ័ណ្ឌអាកាសធាតុមិនអំណោយផល។

វិស័យឧស្សាហកម្មបានក្លាយទៅជាក្បាលម៉ាស៊ីននៃកំនើនដ៏ចំបង ដោយមានកំណើនក្នុងមួយឆ្នាំៗជាមធ្យម ១៧,៧%។ វិស័យនេះមានផ្នែកកម្មន្តសាល (៧៨,៥%) និងផ្នែកសំណង់ (១៨,៨%)។ ផ្នែកវាយនភ័ណ្ឌ និងសំលៀកបំពាក់បាននាំមកនូវការរីកលូតលាស់ ដែលមានសន្ទុះយ៉ាងខ្លាំងក្នុងការនាំចេញនូវផលិតផលរបស់ខ្លួនរយៈពេលបួនឆ្នាំកន្លងមក បន្ទាប់ពីមានការផ្តល់ពីសហរដ្ឋអាមេរិកនូវឋានៈជាប្រទេសអនុគ្រោះបំផុត (MFN) នៅឆ្នាំ១៩៩៦ និងប្រព័ន្ធអនុគ្រោះពន្ធ (GSP) នៅឆ្នាំ១៩៩៧។ ចំណែកទិន្នផលវិស័យសេវាកម្ម គឺមានការចុះថយនៅពេលដែលវិស័យឧស្សាហកម្មមានការពង្រីកខ្លួននោះ។ វិស័យសេវាកម្មបានចុះពី ៣៩% នៃផលិតផលសរុបក្នុងស្រុក នៅឆ្នាំ១៩៩៣ ទៅដល់ ៣៤,២% នៅឆ្នាំ២០០២។

ក្នុងរយៈពេល ២-៣ឆ្នាំកន្លងមកនេះ ផ្នែកទេសចរណ៏បានផ្តល់វិភាគទានដ៏សំខាន់ដល់កំនើនសេដ្ឋកិច្ចតាមរយៈការទាក់ទាញវិនិយោគទុនបរទេស ការបង្កើតការងារ និងប្រាក់ចំណូលសំរាប់ប្រជាជនមូលដ្ឋាន។ ផ្នែកនេះបង្កើតប្រាក់ចំណូលក្នុងមួយឆ្នាំៗចំនួន ២០០លានដុល្លាអាមេរិក ដែលបង្កើតបានប្រហែលជា ១០ម៉ឺនការងារ។ ដូច្នេះ ផ្នែកទេសចរណ៏បានចូលរួមវិភាគទានយ៉ាងសំខាន់គួរឱ្យកត់សំគាល់ ទៅនឹងការអភិវឌ្ឍន៏សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ នេះគឺជាវិស័យមួយដែលអាចនឹងទទួលបានជោគជ័យ ហើយដែលមានសក្តានុពលភាពក្នុងការរួមវិភាគទានចំពោះការងារ និងការរីកលូតលាស់។

### ១.៣.២ វិសមភាព

វិសមភាពមានសណ្ឋានផ្សេងៗពីគ្នានៅប្រទេសកម្ពុជាដូចជា វិសមភាពយេនឌ័រនៅក្នុងជីវភាពសង្គមសេដ្ឋកិច្ច និងនយោបាយ ដូចមានពិភាក្សាក្នុង គអសក៣។ វិសមភាពក៏មានលក្ខណៈសំខាន់គួរឱ្យយកចិត្តទុកដាក់វាំងសហគមន៏ជនបទ និងទីក្រុង/ទីប្រជុំជន ជាពិសេសនៅទីក្រុងភ្នំពេញ។ ជីវភាពរស់នៅ និងឱកាសក្នុងការរក

ប្រាក់ចំណូលជាទូទៅ គឺមានកំរិតខ្ពស់ភាគច្រើននៅក្នុងតំបន់ទីក្រុងជាងនៅតំបន់ជនបទ។ វិសមភាពមានលក្ខណៈសំខាន់គួរឱ្យចាប់អារម្មណ៏ផងដែរនៅក្នុងតំបន់ជនបទជាពិសេស តំបន់ដែលមានជនជាតិភាគតិចប្រមូលផ្តុំ។ ការធ្វើឱ្យមានភាពជឿនលឿនឆ្ពោះទៅរកចំណុចដៅ គអសក ក្នុងរយៈពេលមួយទសវត្សរ៍ក្រោយនេះ គឺទាមទារឱ្យមានការបង្កើនការវិនិយោគជាធនធានរូបវន្ត និងមនុស្សនៅក្នុងតំបន់ណាដែលមានលក្ខណៈអន់ថយជាងគេ។

**១.៣.៣ ប្រជាជន**

កំនើនប្រជាជនខ្ពស់មានឥទ្ធិពលទៅលើ គអសក ទាំងស្រុងតែម្តង។ ទី១ កំនើននេះមានផលប៉ះពាល់ទៅលើភាពក្រីក្រ ដោយសារការកើនឡើងចំនួនអ្នកនៅក្នុងបន្ទុក លើអ្នករកប្រាក់ចំណូលក្នុងគ្រួសារ ដោយបង្កើនចំនួនការងារមិនពេញលេញ ភាពគ្មានការងារ និងធ្វើអោយធ្លាក់ចុះនូវប្រាក់កំរៃការងារ ប្រសិនបើកំលាំងពលកម្មមិនត្រូវបានស្រូបទាញបានច្រើនដោយផ្នែកសេដ្ឋកិច្ចនោះទេ។ ទី២ កំនើនប្រជាជនក៏មានផលប៉ះពាល់ទៅលើលទ្ធផលការអប់រំ ដោយបង្កើនសំពាធទៅលើការផ្តល់សេវាសាធារណៈ នៅក្នុងវិស័យអប់រំ។ ទី៣ ជាញឹកញយវាបានឆ្លុះបញ្ចាំងឱ្យឃើញនូវវិសមភាពយេនឌ័រខ្លាំង ដោយសារតែស្ត្រីមិនមានជំរើសខាងបន្តពូជ ហើយក៏ទទួលរងនូវទំនៀមទំលាប់ប្រពៃណីអំពីបញ្ហាផ្លូវភេទរបស់ស្ត្រី។ ទី៤ មរណភាពទារក និងកុមារ មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងការពន្យារកំណើត និងអាយុរបស់មាតានៅពេលសំរាលកូន ដែលកត្តាទាំងពីរនេះទទួលរងឥទ្ធិពលអវិជ្ជមាន ដោយសារកំនើនប្រជាជនខ្ពស់ និងគុណភាពនៃការផ្តល់ការគាំពារសុខភាព។ បញ្ហាដូចគ្នានេះក៏កើតមានចំពោះអត្រាមរណភាពមាតាផងដែរ។ លើសពីនេះទៅទៀត ប្រជាជនវ័យក្មេងដែលកំពុងតែកើនឡើង ហើយរស់នៅក្នុងស្ថានភាពដែលមានអនាម័យកំរិតទាប ជាសំពាធដ៏ធ្ងន់ទៅលើប្រព័ន្ធគាំពារសុខភាព ដែលមិនអាចឆ្លើយតបទៅនឹងតំរូវការឱ្យមានប្រសិទ្ធភាពនោះឡើយ។ ទី៥ តំរូវការខ្ពស់សំរាប់សេវាកម្មសង្គមបានធ្វើឱ្យមានសំពាធទៅលើហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និងគំរាមកំហែងដល់តុល្យភាពម៉ាក្រូសេដ្ឋកិច្ច ។ ទី៦ កំណើនប្រជាជនយ៉ាងឆាប់រហ័សនៅតំបន់ជនបទនាំឱ្យមានការកាប់បំផ្លាញព្រៃឈើ ការរិចរិលដី ការបំផ្លាញធនធានទឹក និងការថយចុះនូវជីវសាស្ត្រចំរុះ។ នៅក្នុងតំបន់ទីក្រុង/ទីប្រជុំជន ប្រការនេះបានដាក់សំពាធទៅលើការផ្គត់ផ្គង់ទឹក និងអនាម័យ ហើយក៏មានផលប៉ះពាល់លើការបំពុលបរិយាកាសផងដែរ។ លើសពីនេះទៀត កំនើនប្រជាជនខ្ពស់មានការជាប់ទាក់ទងជាមួយនឹងជំលោះ ដែលមានចំនួនកាន់តែច្រើនឡើងៗ លើដីធ្លីនៅតាមតំបន់ជនបទ និងជំងឺសង្គមនៅក្នុងតំបន់ទីក្រុងផងដែរដូចជា ការរស់នៅកកកុញ ការរាលដាលនៃជំងឺឆ្លង និងការប្រព្រឹត្តិបទល្មើសផ្សេងៗ។ បញ្ហាប្រឈមនោះ គឺត្រូវអនុវត្តគោលនយោបាយប្រជាជនដ៏មានប្រសិទ្ធភាពស្របទៅតាមបរិបទសង្គម និងវប្បធម៌កម្ពុជាដោយយកការអប់រំជាមូលដ្ឋាន ក្នុងការដោះស្រាយបញ្ហាផ្សេងៗ។

តាមរយៈគោលនយោបាយប្រជាជន រាជរដ្ឋាភិបាលសូមធ្វើការបញ្ជាក់ជាថ្មីម្តងទៀត អំពីការទទួលស្គាល់និងការគាំទ្រចំពោះសិទ្ធិរបស់គូស្វាមី ភរិយា និងបុគ្គលទាំងអស់ ឱ្យមានសិទ្ធិជាមូលដ្ឋានក្នុងការសំរេចចិត្តដោយសេរី និងដោយទទួលខុសត្រូវលើចំនួនកូន និងការពន្យារកំណើត និងឱ្យមានលទ្ធភាពទទួលបាននូវព័ត៌មាន ការអប់រំ សេវា និងមធ្យោបាយដើម្បីធ្វើការងារនេះ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងសិក្សាពីសក្តានុពលធនធាននៅក្នុងប្រទេសកម្ពុជា ថាតើធនធានអាចផ្គត់ផ្គង់ប្រជាជនបានចំនួនប៉ុន្មាន។

## តារាង ១.១: សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចថ្មីៗ សំរាប់ប្រទេសកម្ពុជា[៦]

| សូចនាករ | តំលៃ |
|---|---|
| ផលិតផលក្នុងស្រុកសរុប (ផសស) សំរាប់មនុស្សម្នាក់ ឆ្នាំ២០០២ (ដុល្លាអាមេរិក) | ២៩៧ |
| អត្រាកំណើន ផសស ប្រចាំឆ្នាំ១៩៩៣-២០០២ (គិតជាភាគរយ) | ៥.៥ |
| ចំណែកនៃ ផសស តាមវិស័យ ឆ្នាំ២០០២ (គិតជាភាគរយ) | |
| វិស័យកសិកម្ម | ៣៣.៤ |
| វិស័យឧស្សាហកម្ម | ២៦.៣ |
| វិស័យសេវាកម្ម | ៣៤.២ |
| ការងារគិតតាមវិស័យ នៅឆ្នាំ២០០២ (គិតជាភាគរយ) | |
| វិស័យកសិកម្ម | ៧០.៧ |
| វិស័យឧស្សាហកម្ម | ១០.៥ |
| វិស័យសេវាកម្ម | ១៩.៥ |
| ចំនួនប្រជាជន (ចំណោលប្រជាសាស្ត្រ ឆ្នាំ២០០១) | ១៣០៩៩៤៧២ |
| អត្រាចំនួនប្រជាជនប្រចាំឆ្នាំ (តាមជំរឿន ឆ្នាំ១៩៩៨ គិតជាភាគរយ) | ២.៤៩ |
| ចំនួនប្រជាជននៅក្នុងតំបន់ជនបទ (ឆ្នាំ១៩៩៨ គិតជាភាគរយ) | ៨៤.៣ |
| លំដាប់នៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០១ | ១៣០ |
| សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០១ | ០.៥៥៦ |
| សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រនៅ ឆ្នាំ២០០១ | ០.៥៥១ |
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា ឆ្នាំ២០០១ | ៨៧ |
| អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ឆ្នាំ២០០១ | ១៩ |
| អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០០១ | ៧.៤ |
| អត្រាអក្ខរកម្មមនុស្សពេញវ័យ ឆ្នាំ១៩៩៨ | ៧១ |
| អត្រាមរណភាពទារក ឆ្នាំ១៩៩៥-២០០០ (ក្នុង ១០០០ កំណើតរស់) | ៩៥ |
| ផលធៀបមរណភាពមាតា ឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០០ (ក្នុង ១០០,០០០ កំណើតកូន) | ៤៣៧ |
| អាយុកាលមធ្យមនៅ ឆ្នាំ១៩៩៨ (គិតជាឆ្នាំ) | ៥៤ |
| កុមារដែលមិនគ្រប់ទំងន់ក្រោមអាយុ ៥ឆ្នាំ នៅឆ្នាំ២០០០ (គិតជាភាគរយ) | ៤៥.២ |
| លទ្ធភាពទទួលបានទឹកស្អាតនៅ ឆ្នាំ១៩៩៨ (គិតជាភាគរយ) | ២៩ |
| ចំនួនប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ នៅឆ្នាំ១៩៩៩ (គិតជាភាគរយ) | ៣៦ |
| ការផ្តល់អាហារូបត្ថម្ភខាងថាមពលប្រូតេអ៊ីន នៅឆ្នាំ២០០០ (ភាគរយនៃកុមារមានអាយុពី ៦-៥៩ ខែ) | ៤៥ |
| ភាពខុសគ្នារវាងអនក្ខរជនបុរស និងស្ត្រី ឆ្នាំ១៩៩៨ (គិតជាភាគរយ) | ២៨.៣ |
| ចំនួនមនុស្សក្នុងវេជ្ជបណ្ឌិតម្នាក់ នៅឆ្នាំ១៩៩៨ | ៦៨០៨ |
| ចំនួនមនុស្ស ក្នុងបុគ្គលិកសុខាភិបាលម្នាក់ នៅឆ្នាំ១៩៩៨ | ៥៩៨ |

[៦] ប្រភព: - វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០១: "អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០០"។
- វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ១៩៩៩: "ជំរឿនប្រជាជនកម្ពុជាទូទៅ ឆ្នាំ១៩៩៨ និងលទ្ធផលជំរឿនចុងក្រោយ"។
- ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ឆ្នាំ២០០២: "យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ ឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥"។
- រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០២: "ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី២ ឆ្នាំ២០០១ ដល់ឆ្នាំ២០០៥"។
- ក្រសួងសុខាភិបាល នាយកដ្ឋានផែនការ និងពតិមានសុខភាព ឆ្នាំ១៩៩៩: "ឯកសារស្តីអំពីគោលជំហរក្រុមពិគ្រោះយោបល់"។
- វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៣: "គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០២"។
- វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៣: "កំរងស្ថិតិ ឆ្នាំ២០០២"។
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ឆ្នាំ២០០៣: "សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០១"។

## ១.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា

សំរាប់រាជរដ្ឋាភិបាលកម្ពុជា កំនើនគឺជាអាវុធដ៏មានឥទ្ធិពលបំផុតនៅក្នុងការប្រយុទ្ធនឹងភាពក្រីក្រ ហើយរាជរដ្ឋាភិបាលក៏ប្តូរផ្តាច់ក្នុងការអនុវត្តន៏គោលនយោបាយ លើកទឹកចិត្តដល់ស្ថិរភាពខាងម៉ាក្រូសេដ្ឋកិច្ច និងការបង្វែរធនធានទៅលើវិស័យនានាអោយកាន់តែមានប្រសិទ្ធភាពថែមទៀត និងជំរុញការធ្វើសមាហរណកម្មនៅក្នុងសេដ្ឋកិច្ចសកលលោក។ ការមានស្ថិរភាពនយោបាយឡើងវិញ សន្តិសុខមានកំរិតល្អប្រសើរជាងមុននៅក្នុងប្រទេសជិតខាង និងសណ្ឋាននៃការប្រសើរឡើងវិញនៃសេដ្ឋកិច្ចក្នុងតំបន់ បានធ្វើឱ្យប្រទេសកម្ពុជាពង្រឹង និងពង្រីក ហើយធ្វើឱ្យកាន់តែស៊ីជំរៅនូវកំនែទំរង់របស់ខ្លួន ដែលកំពុងតែដំណើរការ ហើយជួយរក្សានូវកំលាំងចលករ សំរាប់ឱ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយចីរភាពនោះ។ ចក្ខុវិស័យយូរអង្វែងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺចង់ឱ្យកម្ពុជាជាប្រទេសមួយ ដែលមានលក្ខណៈសង្គមស្ថិតរមួត ជឿនលឿនខាងការអប់រំ និងរស់រវើកខាងវប្បធម៌ ដែលគ្មានភាពក្រីក្រ អនក្ខរកម្ម និងសុខភាពទន់ខ្សោយ ដែលតាមរយៈនេះប្រជាជនកម្ពុជា អាចរស់នៅក្នុងភាពចុះសម្រុងនឹងគ្នា ដោយគ្មានភាពអត់ឃ្លាន វិសមធម៌ ភាពឯកោ ភាពងាយទទួលរងគ្រោះ។ នៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការបញ្ចេញការប្រឹងប្រែងយ៉ាងខ្លាំង និងប្រកបដោយចីរភាព ដើម្បីរំដោះប្រទេសកម្ពុជា ឱ្យរួចផុតពីនឹមនៃភាពក្រីក្រ។ ដូច្នេះប្រជាជនកម្ពុជាទាំងអស់ អាចនឹងទទួលបាននូវផលប្រយោជន៏នៃកំនើនសេដ្ឋកិច្ច និងចូលរួមនៅក្នុងដំណើរការអភិវឌ្ឍន៍។ ដើម្បីដោះស្រាយទៅលើបុព្វហេតុនៃភាពក្រីក្រ ដែលបានលើកឡើងខាងលើនោះ គោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានចែងនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ មានគោលបំណង: (១)បង្កើតនូវកាលានុវត្តភាព (២)បង្កើនសន្តិសុខ (៣)ពង្រឹងសមត្ថភាព (៤)ផ្តល់សិទ្ធិអំណាចទៅឱ្យអ្នកក្រីក្រ។

ដើម្បីពង្រឹងស្ថាប័ន និងកែលំអអភិបាលកិច្ច នៅក្នុងការគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ មានវិស័យបួនសំខាន់ៗ ដែលត្រូវយកចិត្តទុកដាក់ខ្លាំង (១)ប្រព័ន្ធយុត្តិធម៌ ដែលគាំទ្រដល់ការអភិវឌ្ឍន៍ និងសិទ្ធិផ្សេងៗ (២)ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ដែលផ្តល់សិទ្ធិអំណាចដល់ប្រជាជន និងសហគមន៍ (៣)រដ្ឋបាលមួយដែលជាអ្នកផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងជាដៃគូដែលគួរឱ្យទុកចិត្តបាន សំរាប់ការអភិវឌ្ឍន៍ (៤)បរិយាកាសមួយដែលអំពើពុករលួយមិនអាចធ្វើឱ្យរាំស្ទះដល់ការអភិវឌ្ឍន៍ និងយុត្តិធម៌សង្គម។ កំនែទំរង់ទាំងនេះមានរយៈពេលវែង។ យើងនឹងត្រូវការរយៈពេលដើម្បីឱ្យផលប៉ះពាល់ និងលទ្ធផលចេញជារូបរាង។ ដូច្នេះអភិក្រមទូទៅ គឺដើម្បីកសាងនូវមូលដ្ឋានគ្រឹះសំរាប់ចីរភាព និងដោះស្រាយនូវបញ្ហាពាក់ព័ន្ធជាបន្ទាន់ជាងគេបំផុត និងជាផលប្រយោជន៏ដល់ប្រជាជន។

សេចក្តីប្រកាសសហស្សវត្សរ៏ត្រូវបានចុះហត្ថលេខា ដោយប្រទេសកម្ពុជា ដោយសារតែសេចក្តីប្រកាសនោះមានលក្ខណៈស៊ីសង្វាក់ជាមួយនិងការប្តេជ្ញាចិត្តយូរអង្វែង របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកែលំអជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រដែលបានលើកឡើងផងដែរ នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចទី២ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិរបស់ខ្លួន។

## ១.៥ ដំណើរការរៀបចំគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

ដំណើរការនៃការជ្រើសរើសសូចនាករ និងចំណុចដៅ គអសក មានការចូលរួមទូលំទូលាយ និងមានបំណងសំរួល គអស អោយស្របទៅនឹងបរិបទកម្ពុជា។ ដំណើរការនេះក៏មានការពិគ្រោះយោបល់ជាច្រើនលើកក្នុងចំណោមភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដោយភាគីពាក់ព័ន្ធទាំងអស់នោះ បានទទួលពត៌មានអំពីការវិភាគលំអិតនៃស្ថានភាពថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ដំណើរការនេះជាទិដ្ឋភាព ដែលមានលក្ខណៈសំខាន់យ៉ាងខ្លាំង ដើម្បីបញ្ចេញនូវកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិពិតប្រាកដ ឱ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច (CSD) និងអគ្គលេខាធិការដ្ឋានរបស់ខ្លួន (GSCSD) បានផ្តល់នូវការណែនាំជារួម។ ក្រសួងពាក់ព័ន្ធដែលមានជំនាញរៀងៗខ្លួន គឺជាការចាំបាច់ក្នុងការផ្តល់ការណែនាំជាក់លាក់ទៅតាមវិស័យផ្សេងៗគ្នា។ ក្រុមស្រាវជ្រាវរបស់ CSD/GSCSD គឺជាអង្គភាពបច្ចេកទេសតាមដាន និងវិភាគភាពក្រីក្រ (PMATU) ត្រូវបានចាត់តាំងឱ្យបំពេញភារៈកិច្ចនេះ ដើម្បីជួយសម្រួលនូវដំណើរការពិគ្រោះយោបល់គ្នា ដែលមានការចូលរួមដ៏ទូលំទូលាយ និងតំលាភាព ដើម្បីចាប់យកនូវទិដ្ឋភាព ទស្សនៈ និងបទពិសោធន៍ពីកម្ពុជាឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

ដំណើរការនេះ ត្រូវបានបែងចែកជាពីរដំណាក់កាល។ ការវាយតំលៃដំបូងនៃនិន្នាការកន្លងមកសំរាប់ គអស ចំបងៗ ត្រូវបានធ្វើឡើងដោយ PMATU។ នោះមានបំណងរក្សាអោយមានជាមូលដ្ឋានសំរាប់ការពិភាក្សានៅក្នុងការពិគ្រោះយោបល់ ការវាយតំលៃដំបូងទាំងនោះ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងការកសាងសមត្ថភាពអ្នកវិជ្ជាជីវៈថ្នាក់ជាតិរបស់ PMATU។ ដូច្នេះ ការវាយតំលៃនេះបានដើរតួក្នុងគោលបំណងពីរគឺៈ ស្វែងយល់ឱ្យបានស៊ីជំរៅលើបញ្ហាជាឫសគល់នៃប្រទេសកម្ពុជា ដើម្បីសំរេចឱ្យបាននូវ គអស និងមួយទៀតគឺបង្កើននូវចំណេះដឹង និងសមត្ថភាពនៃអ្នកវិជ្ជាជីវៈថ្នាក់ជាតិ។ ការវាយតំលៃដំបូងត្រូវបានពិភាក្សានៅក្នុងវេទិកាជាតិស្តីអំពីភាពក្រីក្រ ដោយមានការចូលរួមយ៉ាងទូលំទូលាយ។

ដំណើរការទី២ មានការពិគ្រោះយោបល់ស៊ីជំរៅ។ ការពិគ្រោះយោបល់នេះត្រូវបានផ្តួចផ្តើម តាមរយៈសិក្ខាសាលាមួយដែលមានការចូលរួមពីក្រសួងពាក់ព័ន្ធ អ្នកផ្តល់ជំនួយ និង NGOs។ ការពិគ្រោះយោបល់អន្តរក្រសួងត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ ដោយមានការចូលរួមពីទីភ្នាក់ងារសំខាន់ៗ ដែលនៅក្រៅរដ្ឋាភិបាល។ សំណើរឱ្យមានសូចនាករដែលត្រូវតាមកាលៈទេសៈ និងចំណុចដៅដែលសមស្របត្រូវបានពិនិត្យមើលឡើងវិញ និងពិភាក្សានៅក្នុងការប្រជុំជាច្រើនលើក ដែលសម្របសម្រួលដោយអ្នកវិជ្ជាជីវៈថ្នាក់ជាតិនៃក្រុម PMATU។ អ្នកវិជ្ជាជីវៈក៏បានធ្វើទស្សនៈកិច្ចនៅខេត្តបី ដើម្បីមានការពិគ្រោះយោបល់ថ្នាក់មូលដ្ឋានផងដែរ[៧]។ ក្នុងកំឡុងពេលទស្សនៈកិច្ចទាំងអស់នេះ ការពិភាក្សាត្រូវបានធ្វើឡើងជាមួយមន្ត្រីថ្នាក់ខេត្ត ក្រុមប្រឹក្សាឃុំ/សង្កាត់ អង្គការមិនមែន

[៧] ខេត្តដែលបានធ្វើទស្សនៈកិច្ចនោះគឺ មណ្ឌលគិរី កោះកុង និងកណ្តាល។

រដ្ឋាភិបាល ដែលមានមូលដ្ឋាននៅក្នុងសហគមន៍ ក៏ដូចជាគ្រួសារផ្សេងៗ ដែលបានផ្ដល់នូវយោបល់ឆ្លើយតបសំរាប់កំណត់ចំណុចដៅចុងក្រោយ ។

បន្ទាប់ពីមានការពិគ្រោះយោបល់ក្នុងជុំទី១ សេចក្ដីព្រាងរបាយការណ៍ ដោយរាប់បញ្ចូលនូវសូចនាករ និងចំណុចដៅដែលបានស្នើរផងដែរ សំរាប់ប្រទេសកម្ពុជានោះ គឺត្រូវបានតាក់តែងឡើង។ សេចក្ដីព្រាងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុង និងក្រៅរដ្ឋាភិបាល ហើយបន្ទាប់មកក៏បានពិភាក្សានៅលើវេទិកាជាតិស្ដីអំពីភាពក្រីក្រ មុនពេលត្រូវបានបញ្ចប់សព្វគ្រប់ ហើយនឹងដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។

ដោយស្របទៅនឹងដំណើរការធ្វើមូលដ្ឋានីយកម្មរបស់ គអស យុទ្ធនាការលើកកំពស់ការយល់ដឹងមួយត្រូវបានរៀបចំឡើង។ នៅក្នុងបរិបទនៃការអនុវត្តន៍ និងការតាមដានយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររាជរដ្ឋាភិបាលកម្ពុជាបានសំរេចចិត្តអនុវត្ត នូវយុទ្ធនាការលើកកំពស់ការយល់ដឹងទូលំទូលាយជាតិ ស្ដីអំពី គអស។ ក្នុងដំណើរការនេះ រាជរដ្ឋាភិបាលកម្ពុជាបានកសាងបន្ថែមទៅលើការងារពីមុនៗមក ដែលក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសបានធ្វើឡើងនូវការផ្សព្វផ្សាយ គអស (ខែមីនា-មិថុនា ឆ្នាំ២០០២) និងដំណាក់កាលទីមួយនៃយុទ្ធនាការ គអស នៅខេត្តចំនួនប្រាំពីរ នៅក្នុងប្រទេសកម្ពុជា (ខែសីហា-ធ្នូ ឆ្នាំ២០០២)។ របាយការណ៍ គអសក (ឆ្នាំ២០០១) និងរបាយការណ៍បច្ចេកទេសស្ដីអំពី គអស (PMATU/GSCSD) ឆ្នាំ២០០៣ ត្រូវបានប្រើជាឧបករណ៍ចំបងដែលធ្វើឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន នៅថ្នាក់មូលដ្ឋាន នៅក្នុងសិក្ខាសាលា សំរាប់ភាគីពាក់ព័ន្ធទាំងអស់ដែលនឹងត្រូវធ្វើឡើងនៅទូទាំងប្រទេស។ ស្ថាប័នពាក់ព័ន្ធ គអស ដែលត្រូវបានគេពង្រឹងបែបនេះនឹងផ្ដល់នូវឱកាសដ៏ច្រើនបន្ថែមទៀត សំរាប់ឱ្យមាននូវស្ថាប័នភាវូបនីយកម្ម នៃការចូលរួមពីថ្នាក់មូលដ្ឋាន ក្នុងការអភិវឌ្ឍន៍ការអនុវត្តន៍ និងការតាមដានយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ យុទ្ធនាការត្រូវបានរៀបចំនៅក្នុងលក្ខណៈជាសិក្ខាសាលា ការសន្ទនាតាមវិទ្យុ តាមទូរស័ព្ទ កម្មវិធីជជែកកំសាន្តតាមទូរទស្សន៍ និងការប្រកួតប្រជែងគំនូរជាមួយនិងសិស្សវិទ្យាល័យទូទាំងប្រទេស។

# ផ្នែកទី២

# គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

# បញ្ហាប្រឈម និងក្របខ័ណ្ឌការងារ

## ២ សេចក្តីផ្តើម

នៅក្នុងផ្នែកនេះ គអសក ទីមួយៗត្រូវបានពិភាក្សាតាមលំដាប់លំដោយពី គអសក១-៩ ដោយឡែក គអសក៨ កំពុងដំណើរការដោយ CDC ហើយចំណុចខាងក្រោមត្រូវបានត្រួតពិនិត្យឡើងវិញ:

- សូចនាករ និងចំណុចដៅ គអស ត្រូវបានធ្វើមូលដ្ឋានីយកម្ម ដើម្បីឆ្លុះបញ្ចាំងអំពីការពិតរបស់កម្ពុជា។
- និន្នាការកន្លងមក និងសូចនាករដែលបានជ្រើសរើស ត្រូវបានត្រួតពិនិត្យ ហើយគំលាតរវាង គអសក និងតំលៃនិន្នាការទាំងនោះត្រូវបានវិភាគ។
- គោលនយោបាយ និងកម្មវិធីបច្ចុប្បន្នចំបងៗ ដែលរួមចំណែកដល់ គអសក ត្រូវបានរាយការណ៍ ដើម្បីចាប់យកខ្លឹមសារនៃកិច្ចខិតខំប្រឹងប្រែង ខាងគោលនយោបាយដែលមានស្រាប់។
- ការប្រឈមចំបងៗក្នុងការសំរេចឱ្យបាននូវចំណុចដៅ គអសក ត្រូវបានកំនត់ ដើម្បីទាញការយកចិត្តទុកដាក់ពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ទៅលើអាទិភាពផ្សេងៗ។
- ក្របខ័ណ្ឌការងារសំរាប់ដោះស្រាយបញ្ហាប្រឈមទាំងនោះ ត្រូវបានស្នើឡើង ដោយកសាងបន្ថែមទៅលើយុទ្ធសាស្រ្ត និងផែនការជាតិទៅតាមវិស័យដែលមានស្រាប់ ដើម្បីធ្វើជាគំរោងការតំរង់ទិសគោលនយោបាយ ដែលមានសារៈសំខាន់ខ្លាំងនៅក្នុងគោលបំណងសំរេចឱ្យបាននូវ គអសក។
- ជាចុងក្រោយសន្ទស្សន៍រួមនៃ គអសក ត្រូវបានគណនា ដើម្បីចាប់យកខ្លឹមសាររួមក្នុងចំណោមខេត្ត/ក្រុងផ្សេងៗ។

## ២.១ គោលដៅទី១: លុបបំបាត់នូវភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន

គោលដៅទី ១ មានទិសដៅកាត់បន្ថយសមាមាត្រប្រជាជនដែលមានកំរិតប្រើប្រាស់ចំណាយ/ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ក៏ដូចជាដើម្បីកាត់បន្ថយនូវភាពអត់ឃ្លាន និងការខ្វះអាហារូបត្ថម្ភផងដែរ។

### ២.១.១ សូចនាករ និងចំណុចដៅ គអសក១

តារាង ២.១.១ បានបង្ហាញឱ្យឃើញនៅក្នុងជួរឈរខាងឆ្វេង គឺជាចំណុចដៅ និងសូចនាករ ដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ រីឯជួរឈរខាងស្តាំ បង្ហាញពីចំណុចដៅ និងសូចនាករ ដែលបានជ្រើសរើសដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗរួចមក។

**តារាង ២.១.១: មូលដ្ឋានីយកម្ម គអស១ ឱ្យទៅជា គអសក១**

| គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលទី១ | គអសក១ |
|---|---|
| **ចំណុចដៅទី១:** កាត់បន្ថយឱ្យបានពាក់កណ្តាល រវាងឆ្នាំ១៩៩០ និងឆ្នាំ២០១៥ នូវសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាង ១ដុល្លា ក្នុងមួយថ្ងៃ | **ចំណុចដៅរួមទី១:** កាត់បន្ថយឱ្យបានពាក់កណ្តាល រវាងឆ្នាំ១៩៩៣ និងឆ្នាំ២០១៥ នូវសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ |
| **សូចនាករ១:** សមាមាត្រប្រជាជននៅក្រោម ១ដុល្លា ក្នុងមួយថ្ងៃ | **សូចនាករ១.១:** សមាមាត្រប្រជាជនដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ |
| **សូចនាករ២:** ផលធៀបគំលាតភាពក្រីក្រ | |

| | |
|---|---|
| **សូចនាករ៣:** បមាណភាគរបស់ប្រជាជនដែលក្រជាងគេបំផុត ២០% ក្នុងការប្រើប្រាស់ចំណាយថ្នាក់ជាតិ | **សូចនាករ១.២:** បមាណភាគរបស់ប្រជាជនដែលក្រជាងគេបំផុត ២០% ក្នុងការប្រើប្រាស់ចំណាយថ្នាក់ជាតិ |
| | **សូចនាករ១.៣:** សមាមាត្រកុមារធ្វើការងារ ដែលមានអាយុពី ៥-១៧ឆ្នាំ |
| **ចំណុចដៅទី២:** កាត់បន្ថយឱ្យបានពាក់កណ្តាលរវាងឆ្នាំ១៩៩០ និងឆ្នាំ២០១៥ នូវសមាមាត្រប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន | **ចំណុចដៅរួមទី ២:** កាត់បន្ថយឱ្យបានពាក់កណ្តាលរវាងឆ្នាំ១៩៩៣ និង២០១៥ នូវសមាមាត្រប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន |
| **សូចនាករ៤:** អត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទំងន់ ដែលមានអាយុក្រោម ៥ឆ្នាំ | **សូចនាករ១.៤:** អត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទំងន់ (ទំងន់ធៀបនឹងអាយុ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ |
| **សូចនាករ៥:** សមាមាត្រប្រជាជនដែលស្ថិតនៅក្រោមការប្រើប្រាស់ថាមពលអាហារអប្បបរមា | **សូចនាករ១.៥:** សមាមាត្រប្រជាជនដែលស្ថិតនៅក្រោមខ្សែបន្ទាត់ក្រីក្រម្ហូបអាហារ |
| | **សូចនាករ១.៦:** អត្រាប្រេវ៉ាឡង់នៃកុមារក្រិន (កំពស់ធៀបនឹងអាយុ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ |
| | **សូចនាករ១.៧:** អត្រាប្រេវ៉ាឡង់នៃកុមារស្គម (ទំងន់ធៀបនឹងកំពស់ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ |
| | **សូចនាករ១.៨:** សមាមាត្រគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ |

តារាង ២.១.២ បង្ហាញនូវតំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក១ តាមលំដាប់ឆ្នាំ។ តំលៃឆ្នាំមូលដ្ឋាននេះមានការប្រែប្រួលទៅតាមទិន្នន័យដែលមាន។

**តារាង ២.១.២: តំលៃទិន្នន័យមូលដ្ឋាន និងចំណុចដៅសំរាប់សូចនាករ គអសក១**

| សូចនាករ | ទិន្នន័យមូលដ្ឋាន | | ចំណុចដៅ | | |
|---|---|---|---|---|---|
| | តំលៃ | ឆ្នាំ | ២០០៥ | ២០១០ | ២០១៥ |
| ១.១ សមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ | ៣៩ | ១៩៩៣ | ៣១ | ២៥ | ១៩.៥ |
| ១.២ បមាណភាគរបស់ប្រជាជន ដែលក្រជាងគេបំផុត ២០% ក្នុងការប្រើប្រាស់ចំណាយថ្នាក់ជាតិ | ៧.៤ | ១៩៩៣ | ៩ | ១០ | ១១ |
| ១.៣ សមាមាត្រកុមារធ្វើការងារដែលមានអាយុពី ៥-១៧ឆ្នាំ (១) | ១៦.៥ | ១៩៩៩ | ១៣ | ១០.៦ | ៨ |
| ១.៤ អត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទំងន់ (ទំងន់ធៀបនឹងអាយុ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ (២) | ៤៥.២ | ២០០០ | ៣៦ | ២៩ | ២២.៦ |
| ១.៥ សមាមាត្រប្រជាជន ដែលស្ថិតក្រោមបន្ទាត់ខ្សែភាពក្រីក្រម្ហូបអាហារ | ២០ | ១៩៩៣ | ១៦ | ១៣ | ១០ |
| ១.៦ អត្រាប្រេវ៉ាឡង់នៃកុមារក្រិន (កំពស់ធៀបនឹងអាយុ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ | ៤៤.៦ | ២០០០ | ៣៥ | ២៨ | ២២ |
| ១.៧ អត្រាប្រេវ៉ាឡង់នៃកុមារស្គម (ទំងន់ធៀបនឹងកំពស់ <2SD) ដែលមានអាយុក្រោម ៥ឆ្នាំ | ១៥ | ២០០០ | ១៣ | ១០ | ៩ |
| ១.៨ សមាមាត្រគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ | ១៤ | ២០០០ | ៨០ | ៩០ | ៩០ |

(១) គណនាដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយប្រើ CSES 1999 ។

(២) គំលាតគំរូ (Standard Deviation) ។

## ២.១.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក១

ភាពក្រីក្រលើចំណាយប្រើប្រាស់ នៅតែមានការរីករាលដាលនៅក្នុងប្រទេសកម្ពុជា ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយក៏ដោយ។ តួលេខជាផ្លូវការបានបង្ហាញថា សន្ទស្សន៍ភាពក្រីក្ររាប់តាមចំនួនមនុស្សនៅថ្នាក់ជាតិ មានការថយចុះបន្តិចពី ៣៩% មក ៣៥.៩% រវាងឆ្នាំ១៩៩៣ និងឆ្នាំ១៩៩៩។ មានគ្រួសារមួយចំនួនស្ថិតនៅជិតខ្សែបន្ទាត់ភាពក្រីក្រងាយនឹងធ្លាក់ទៅក្នុងភាពក្រីក្រ។

**រូប ២.១.១: និន្នាការ និងចំណុចដៅនៃសមាមាត្រប្រជាជន ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ**




ប្រភព: ក្រសួងផែនការ ឆ្នាំ១៩៩៩។

អត្រានៃការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ទីក្រុង/ប្រជុំជន ខ្ពស់ជាងនៅតំបន់ជនបទ ដែលសន្ទស្សន៍នៃចំនួនអ្នកក្រមានកំរិតថេរដដែល ពោលគឺ ៤០% ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ លើសពីនេះទៀតមានភាពខុសគ្នាខ្លាំងរវាងខេត្ត និងខេត្តឬក្រុង។ អត្រាភាពក្រីក្រប្រែប្រួលពី ៨% នៅខេត្តកោះកុង ទៅ ៩៧% នៅក្រុងប៉ៃលិន។ សូចនាករដទៃទៀតដូចជា សន្ទស្សន៍គំលាតភាពក្រីក្រ និងសន្ទស្សន៍ភាពក្រីក្រធ្ងន់ធ្ងរ បង្ហាញនូវនិន្នាការ និងភាពខុសគ្នាប្រហាក់ប្រហែលតាមតំបន់ និងខេត្ត/ក្រុងនានា។

ប្រសិនបើនិន្នាការកន្លងមកនៅបន្ត កំរិតភាពក្រីក្រនឹងអាចថយចុះដល់ ២៨% នៅឆ្នាំ២០១៥។ និន្នាការនេះមិនអាចឈានទៅសំរេចបានគោលដៅនៃការកាត់បន្ថយភាពក្រីក្រដែលបានកំណត់ ១៩.៥% បានទេ។ ដូច្នេះ ដើម្បីសំរេចបានចំណុចដៅ គអសក១ ទាមទារឱ្យមានកំនើនសេដ្ឋកិច្ចលឿនជាងមុន និងការកាត់បន្ថយភាពក្រីក្រឱ្យបានច្រើនជាងមុន ពាក់ព័ន្ធទៅនឹងកំនើននេះ។

បមាណភាគរបស់ប្រជាជនដែលក្រជាងគេបំផុត ២០% នៅក្នុងការប្រើប្រាស់ចំណាយថ្នាក់ជាតិបានកើនពី ៧.៤% នៅឆ្នាំ១៩៩៣ ដល់ ៨.៩% នៅឆ្នាំ១៩៩៩។ តាមរយៈការគណនាពីនិន្នាការកន្លងមក សូចនាករនេះនឹងអាចឈានដល់ ១៣% នៅឆ្នាំ២០១៥ គឺលើសពីចំណុចដៅបន្តិចដែលបានកំណត់ ១១%។

### រូប ២.១.២: និន្នាការ និងចំណុចដៅនៃបមាណភាគរបស់ប្រជាជន ដែលក្រជាងគេបំផុត ២០% ក្នុងការប្រើប្រាស់ចំណាយថ្នាក់ជាតិ




ប្រភព: ក្រសួងផែនការ ១៩៩៥ ១៩៩៨ ២០០០។

ចំណុចដៅសំរាប់សមាមាត្រកុមារធ្វើការដែលមានអាយុពី ៥-១៧ឆ្នាំ បានបង្ហាញនៅក្នុងតារាង ២.១.២។ ដោយគ្មានទិន្នន័យតាមលំដាប់ឆ្នាំកន្លងមក យើងមិនអាចធ្វើការប៉ាន់ស្មាននូវនិន្នាការបានទេ។ សមាមាត្រកុមារធ្វើការងារមាន ១៦,៥% នៅឆ្នាំ១៩៩៩ (អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៩) ដែលរាជរដ្ឋាភិបាលមានបំណងចង់សំរេចឱ្យបាននូវអត្រា ៨% នៅឆ្នាំ២០១៥។

រូប ២.១.៣ បង្ហាញនូវនិន្នាការ និងចំណុចដៅសមាមាត្រប្រជាជន ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ។ បើសិននិន្នាការកន្លងមកនៅតែបន្ត និន្នាការនេះនឹងធ្លាក់ដល់ចំណុច ០,១៦% នៅឆ្នាំ២០០៧ ។ ដោយផ្អែកលើនិន្នាការនេះ កម្ពុជាងាយនឹងសំរេចបានគោលដៅរបស់ខ្លួន។ ដោយយោងទៅតាមចំណុចដៅដែលបានកំណត់ ប្រទេសកម្ពុជារំពឹងថានឹងសំរេចនូវចំណុចដៅរបស់ខ្លួន ដែលបានកំណត់ ១០% នៅឆ្នាំ២០១៥។

### រូប ២.១.៣: និន្នាការ និងចំណុចដៅនៃសមាមាត្រប្រជាជន ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ




ប្រភព: ក្រសួងផែនការ ១៩៩៧ ១៩៩៩។

សូចនាករសំរាប់អត្រាប្រេវ៉ាឡង់កុមារមិនគ្រប់ទំងន់អាយុក្រោម ៥ឆ្នាំ អត្រាប្រេវ៉ាឡង់កុមារក្រិន អត្រាប្រេវ៉ាឡង់កុមារស្គម អាយុក្រោម ៥ឆ្នាំ និងសូចនាករសំរាប់សមាមាត្រគ្រួសារ ដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ បាន

បង្ហាញនៅក្នុងតារាង ២.១.២។ ដោយពុំមានទិន្នន័យតាមលំដាប់ឆ្នាំកន្លងមក សូចនាករទាំងនេះមិនអាចធ្វើការប៉ាន់ស្មាននូវនិន្នាការបានទេ។

ចំពោះអត្រាប្រេវ៉ាឡង់កុមារមិនគ្រប់ទំងន់អាយុក្រោម ៥ឆ្នាំ មានកំរិតខ្ពស់ខ្លាំងនៅក្នុងប្រទេសកម្ពុជា ដែលមានប្រហែលជា ៤៥.២% នៅឆ្នាំ២០០០។ រាជរដ្ឋាភិបាលមានបំណងសំរេចឱ្យបានអត្រា ២២.៦% នៅឆ្នាំ២០១៥។ អត្រាប្រេវ៉ាឡង់កុមារក្រិន មានការរីករាលដាលខ្លាំងដែរ នៅក្នុងប្រទេសកម្ពុជា ដែលមានប្រហែលជា ៤៤.៦% នៃកុមារដែលមានអាយុក្រោម ៥ឆ្នាំ នៅឆ្នាំ២០០០។ រាជរដ្ឋាភិបាលមានបំណងសំរេចឱ្យបាននូវចំណុចដៅ ២២% នៅឆ្នាំ២០១៥។ ចំពោះអត្រាប្រេវ៉ាឡង់កុមារស្គម ១៥% នៅឆ្នាំ២០០០ (ក្រសួងផែនការ និងក្រសួងសុខាភិបាល ឆ្នាំ២០០១) រាជរដ្ឋាភិបាលមានបំណងសំរេចឱ្យបាននូវអត្រា ៩% នៅឆ្នាំ២០១៥ ។ ចំណុចដៅសមាមាត្រគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ ១៤% នៅឆ្នាំ២០០០ (ក្រសួងផែនការ និងក្រសួងសុខាភិបាល ឆ្នាំ២០០១) រាជរដ្ឋាភិបាលមានបំណងសំរេចឱ្យបាននូវចំណុចដៅ ៩០% នៅឆ្នាំ២០១៥។

## ២.១.៣ គោលនយោបាយ និងកម្មវិធីបច្ចុប្បន្នសំខាន់ៗ ដែលរួមចំណែកដល់ គអសក១

ក្រៅពីផែនការសកម្មភាពតាមវិស័យ មានឯកសារយោងសំខាន់ៗពីរ ដែលគូសបញ្ជាក់អំពីយុទ្ធសាស្ត្ររបស់កម្ពុជា ដើម្បីលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្ររួមមាន ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទីពីរ (SEDPII, 2001-2005) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣-២០០៥ (NPRS)។ NPRS បានផ្តើមចេញពីឯកសារ SEDPII ប៉ុន្តែបានផ្តោតការយកចិត្តទុកដាក់ទៅលើភាពក្រីក្រសំរាប់រយៈពេលបីឆ្នាំខាងមុខ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ត្រូវបានចាត់ទុកជាក្របខ័ណ្ឌការងារដ៏ទូលំទូលាយមួយ ដែលមានគោលដៅរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាការលើកស្ទួយគោលនយោបាយគាំទ្រអ្នកក្រីក្រ ដើម្បីលើកកំពស់កំរិតជីវភាពរស់នៅតាមជនបទ បង្កើនឱកាសការងារ ធានាអោយបានប្រសើរជាងមុននូវសុខភាព អាហារូបត្ថម្ភ និងការអប់រំ កាត់បន្ថយភាពងាយរងគ្រោះ ពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ច លើកតំកើងសមធមិយេនឌ័រ និងផ្តោតការយកចិត្តទុកដាក់ទៅលើកង្វល់របស់ប្រជាជន។

SEDPII ជាយុទ្ធសាស្ត្ររបស់ជាតិគូសបញ្ជាក់អំពីគោលនយោបាយ និងកម្មវិធីដែលជំរុញឱ្យមានកំនើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅក្នុងរយៈពេលយូរអង្វែង។ SEDPII ជំរុញឱ្យមានកំនើនសេដ្ឋកិច្ចទូលំទូលាយប្រកបដោយសមធមិ និងចីរភាព។ ផែនការនេះលើកស្ទួយការអភិវឌ្ឍន៍សង្គមវប្បធម៌ ដោយកែលំអលទ្ធភាពរបស់ប្រជាជនក្រីក្រក្នុងការទទួលបានការអប់រំសុខភាព ទឹកស្អាត និងអនាម័យ ថាមពល ឥណទាន ទីផ្សារ និងការប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថាន និងដើម្បីកែលំអអភិបាលកិច្ច តាមរយៈការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាពអភិបាលកិច្ច។ សន្តិសុខស្បៀងនៅតំបន់ជនបទ និងការពង្រឹងក្របខ័ណ្ឌច្បាប់ (ឧទាហរណ៍ ច្បាប់ភូមិបាល ច្បាប់ព្រៃឈើ និងច្បាប់ជលផល) ដើម្បីបង្កើនសន្តិសុខ គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះផែនការសកម្មភាពនេះ។

យុទ្ធសាស្ត្រទាំងពីរនេះ មានលក្ខណៈពិសេសរួមដែលគួរឱ្យកត់សំគាល់ ហើយមានគោលដៅជំរុញឱ្យមានដំណើរការអភិវឌ្ឍន៍ដ៏ទូលំទូលាយ តាមរយៈកំនើនសេដ្ឋកិច្ចគាំទ្រដល់អ្នកក្រីក្រ ការអភិវឌ្ឍន៍ធនធានមនុស្ស ការលើកស្ទួយកសិកម្ម និងសហគ្រាសខ្នាតតូច និងមធ្យម នៅតំបន់ជនបទ និងអភិបាលកិច្ចល្អដែលផ្តោតជាសំខាន់ទៅលើការប្រយុទ្ធនឹងអំពើពុករលួយ ។

## ២.១.៤ បញ្ហាប្រឈមជាគន្លឹះ ក្នុងការសំរេចចំណុចដៅនៃ គអសក១

ភាពក្រីក្របានចុះថយបន្តិច ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក នៅក្នុងប្រទេសកម្ពុជា។ ទោះបីជានិន្នាការនេះ មានការលើកទឹកចិត្តដល់យើងក៏ដោយ ក៏យើងត្រូវការដោះស្រាយនូវបញ្ហាប្រឈមមួយចំនួន នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ តាមលក្ខណៈសេដ្ឋកិច្ច យើងត្រូវការធានាថា ដំណើរការកំនើន បានគាំទ្រដល់អ្នកក្រីក្រកាន់តែខ្លាំងឡើង ដោយបង្កើតបាននូវផលប្រយោជន៍ដល់អ្នកក្រីក្របំផុត។ តាមលក្ខណៈនយោបាយកំនែទំរង់ប្រជាធិបតេយ្យ ត្រូវតែអនុវត្តអោយស្របទៅតាមដំណើរការវិមជ្ឈការ។ បើនិយាយពីវិស័យសង្គមវិញ វិធានការការពារសង្គមប្រកបដោយប្រសិទ្ធភាពត្រូវតែពង្រឹង ហើយសមត្ថភាពមនុស្សត្រូវតែបង្កើន និងពង្រឹងផងដែរ។ ជាងនេះទៀត ការផ្លាស់ប្តូរស្ថាប័នត្រូវតែបានអនុវត្ត ដើម្បីពង្រឹងនូវតួនាទីសង្គមស៊ីវិល និងផ្នែកឯកជននៅក្នុងដំណើរការអភិវឌ្ឍន៍ និងអភិបាលកិច្ចល្អ ដែលបានបញ្ជ្រាបយ៉ាងមានប្រសិទ្ធភាព ចូលទៅក្នុងជីវភាពសាធារណៈ។ វាជាការច្បាស់ដែលថា ការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានទាមទារនូវការឆ្លើយតបជាពហុវិស័យ រួមទាំងបញ្ហាសេដ្ឋកិច្ច សង្គម និងនយោបាយ ក៏ដូចជាបញ្ហាដែលទាក់ទងទៅនឹងយេនឌ័រ និងបរិស្ថានផងដែរ។ ការពិភាក្សាខាងក្រោមនេះ មានការទាក់ទងទៅនឹងទិដ្ឋភាព នៃការកាត់បន្ថយភាពក្រីក្រទាំងនោះ ដែលត្រូវបានលើកឡើងនៅក្នុង គអស ជាក់លាក់ដទៃទៀត ឬនៅក្នុងផ្នែកស្តីអំពីបញ្ហារួម។

រីឯខាងវិស័យម៉ាក្រូសេដ្ឋកិច្ចវិញ ប្រទេសកម្ពុជានឹងមានបញ្ហាប្រឈមក្នុងការរក្សាឱ្យបាននូវស្ថិរភាពខាងម៉ាក្រូសេដ្ឋកិច្ច ដោយក្នុងពេលដំណាលគ្នានោះ ត្រូវលើកស្ទួយកំនើនសេដ្ឋកិច្ចប្រកបដោយសមធម៌អោយបានទូលំទូលាយជាងមុន។ មានបញ្ហាប្រឈមមួយចំនួន ដែលទាក់ទងទៅនឹងហិរញ្ញវត្ថុសាធារណៈដូចជា ការពឹងផ្អែកហួសហេតុទៅលើជំនួយអភិវឌ្ឍន៍ជាផ្លូវការ (ODA) មូលដ្ឋានពន្ធដារ ដែលមានលក្ខណៈតូចចង្អៀត និងការគ្រប់គ្រងចំណាយដែលមានលក្ខណៈទន់ខ្សោយ។ ជាទូទៅ មានវិសាលភាពសំរាប់ការកែលំអ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតំរូវឱ្យមានការតំរង់ទិសធនធានឡើងវិញ ឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ ដោយលើកតំកើងនូវការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពជាងមុន។

លក្ខណៈនៃភាពក្រីក្រ បានបង្ហាញនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួន នៅក្នុងកំរិតមីក្រូសេដ្ឋកិច្ច។ នៅប្រទេសកម្ពុជា ភាពក្រីក្រច្រើនតែកើតមាននៅតាមតំបន់ជនបទ ដោយទាក់ទងទៅនឹងភាពគ្មានដីធ្លី ឬដីកសិដ្ឋានមានទំហំតូច សកម្មភាពសេដ្ឋកិច្ចពុំសូវមានលក្ខណៈចំរុះ គ្រួសារមានសមាជិកច្រើន ហើយការអប់រំក្នុងប្រព័ន្ធនៅមានកំរិតនៅឡើយ។ សមាសធាតុដ៏សំខាន់នៃការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព គឺការបង្កើនផលិតកម្មកសិកម្ម និងការងារក្នុងគោលបំណងបង្កើននូវការប្រើប្រាស់ស្បៀងអាហារជាមូលដ្ឋាន និងការចាំបាច់

ផ្សេងៗទៀត។ វាក៏ជាប្រការសំខាន់ផងដែរ ក្នុងការធ្វើឱ្យអ្នកដែលមានដីធ្លីតូចៗ នៅតំបន់ជនបទធ្វើសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈចំរុះ ដើម្បីឱ្យខ្លួនអាចប្រឈមជាមួយនឹងភាពតក់ស្លុត និងភាពតានតឹងពីខាងក្រៅផ្សេងៗ។ បញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលរួមមាន ការកែលំអនូវផលិតភាព តាមរយៈការផ្តល់នូវលទ្ធភាពទទួលបាននូវបច្ចេកវិទ្យាកសិកម្ម និងទ្រព្យធនដែលប្រកបដោយផលិតភាពខ្ពស់ និងជំរុញសកម្មភាពនានាក្រៅពីកសិកម្មនៅជនបទ។

បន្ថែមពីលើភាពក្រីក្ររ៉ាំរ៉ៃ ក៏មានបញ្ហាប្រឈមចំបងៗ ដែលពាក់ព័ន្ធទៅនឹងភាពងាយរងគ្រោះ និងអសន្តិសុខជាពិសេស អសន្តិសុខស្បៀង និងភាពងាយរងគ្រោះដោយសារទឹកជំនន់ និងភាពរាំងស្ងួត។ ភាពងាយរងគ្រោះជាចំណុចស្នូលនៃជីវភាពរស់នៅរបស់អ្នកក្រីក្រ ហើយក៏មានការអំពាវនាវឱ្យមានវិធានការកាត់បន្ថយឥទ្ធិពលនៃការភ័យរន្ធត់ ក៏ដូចជាបង្កើននូវសមត្ថភាពរបស់ពួកគាត់ ដើម្បីទប់ស្កាត់នឹងសេចក្តីភ័យរន្ធត់ទាំងនោះ។ យើងត្រូវការបង្កើនសមត្ថភាពរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងនូវគ្រោះធម្មជាតិ ហើយជាងនេះទៀតផ្តល់កិច្ចការពារខាងសង្គមឱ្យបានទូលំទូលាយជាងមុន ដល់ជនទាំងឡាយណាដែលក្រីក្រជាងគេ។ បញ្ហាប្រឈមទាំងនេះវាស្ថិតនៅក្នុងការស្វែងរកឱ្យឃើញនូវវិធីថ្មីៗ ដែលបំពេញបន្ថែមទៅនឹងយុទ្ធសាស្ត្រដោះស្រាយរបស់ប្រជាជននៅជនបទ ដើម្បីធានាថាកម្មវិធីជំនួយសង្គម ត្រូវបានគេតំរង់ទិសទៅរកអ្នកដែលក្រីក្រជាងគេ ដែលមិនអាចចូលរួមក្នុងជីវភាពខាងសេដ្ឋកិច្ចបាន។

នៅក្នុងប្រទេសកម្ពុជា អត្រាខ្ពស់នៃកង្វះអាហារូបត្ថម្ភ មិនត្រឹមតែបណ្តាលមកពីការបរិភោគអាហារមិនគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែមកពីកង្វះនូវការអនុវត្តនៃការផ្តល់ម្ហូបអាហារ និងចំណីអាហារ ដែលមានគុណភាពអន់។ បញ្ហាប្រឈមទៅនឹងការកាត់បន្ថយនូវកង្វះអាហារូបត្ថម្ភនេះ គឺត្រូវបង្កើនចំណេះដឹងស្តីអំពីបញ្ហាអាហារូបត្ថម្ភ និងលទ្ធភាពទទួលបាននូវស្បៀងអាហារសំរាប់អ្នកទាំងឡាយណា ដែលមិនមានប្រាក់គ្រប់គ្រាន់ ដើម្បីទិញស្បៀងអាហារទាំងនោះ។

### ២.១.៥ ក្របខ័ណ្ឌការងារ ដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅ គអសក១

ទិសដៅជាយុទ្ធសាស្ត្រដ៏ចំបងៗ ដើម្បីកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លានមាន ៣ ផ្នែក ដូចខាងក្រោមៈ

### ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

កត្តាគន្លឹះក្នុងការសំរេចឱ្យបាននូវចំណុចដៅ ឆ្នាំ២០១៥ គឺសមត្ថភាពនៃសេដ្ឋកិច្ចកម្ពុជាក្នុងការទប់ទល់ទៅនឹងភាពវឹកវរនៃសេដ្ឋកិច្ច ដែលបណ្តាលមកពីកត្តាខាងក្នុង និងខាងក្រៅ។ រាជរដ្ឋាភិបាលមានបំណងពង្រឹងនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយផ្អែកយ៉ាងសំខាន់តាមរយៈគោលនយោបាយសារពើពន្ធ និងការអនុវត្តន៍នូវកំណែទំរង់រចនាសម្ព័ន្ធ ដោយធានាថាគោលនយោបាយ និងកម្មវិធីទាំងអស់នេះ នឹងគាំទ្រដល់អ្នកក្រីក្រ។ លើសពីនេះទៀតរាជរដ្ឋាភិបាលមានគោលបំណងកែលំអនូវការគ្រប់គ្រងវិស័យសាធារណៈ និងសមត្ថភាពរបស់ជាតិទៅលើការរៀបចំថវិកាដោយផ្អែកលើសកម្មភាព ធ្វើផែនការជាយុទ្ធសាស្ត្រ និងការគ្រប់គ្រងហិរញ្ញវត្ថុ។

ស្ថិរភាពសេដ្ឋកិច្ច ត្រូវដើរទន្ទឹមនឹងស្ថិរភាពនយោបាយ ។ រាជរដ្ឋាភិបាលនឹងបង្កើនល្បឿនដំណើរការវិមជ្ឈការ នៅក្នុងប៉ុន្មានឆ្នាំក្រោយនេះ ដោយមានទស្សនៈលើកកំពស់គុណភាពទំនិញ និងសេវាសាធារណៈ នៅក្នុងតំបន់ដែលប្រមូលផ្តុំទៅដោយភាពក្រីក្រ ។ វិធានការបែបនេះទំនងជារួមវិភាគទាន ក្នុងការកាត់បន្ថយភាពក្រីក្រ និងសំរេចឱ្យបាននូវ គអស ដទៃទៀត ក្នុងស្ថានភាពដែលមិនមានការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ឱ្យបានគ្រប់គ្រាន់នៅក្នុងតំបន់ក្រីក្រ និងតំបន់ដាច់ស្រយាល ។

**ស្ថានភាពមីក្រូសេដ្ឋកិច្ច**

រាជរដ្ឋាភិបាលនឹងត្រូវការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន នៅផ្នែកបន្តបន្ទាប់ ដើម្បីសំរេចនូវចំណុចដៅទាំងឡាយនៃ គអសក ឱ្យមានប្រសិទ្ធភាព:

- ជំរុញការប្រើបច្ចេកវិទ្យាទំនើប ជាពិសេសបច្ចេកទេសផលិត ដើម្បីអាចបង្កើននូវទិន្នផល វិធានការចំរុះថែទាំដំណាំ (IPM) ប្រព័ន្ធកសិកម្មចំរុះ ការធ្វើឱ្យប្រសើរឡើងនូវពូជ និងបច្ចេកវិទ្យាកាត់បន្ថយភាពមានគ្រោះថ្នាក់ ដើម្បីទប់ស្កាត់ផលប៉ះពាល់ពីគ្រោះធម្មជាតិ ។
- ជំរុញការអភិវឌ្ឍន៍ផ្នែកកសិឧស្សាហកម្ម និងទីផ្សារ និងកែលំអនូវការគ្រប់គ្រងគុណភាពខាងផលិតកម្មកសិកម្ម ។
- ការវិនិយោគក្នុងវិស័យ ដែលមានសក្តានុពលក្នុងការបង្កើននូវកំនើនខ្ពស់ ដែលអាចឱ្យប្រទេសកម្ពុជាទទួលបាននូវឧត្តមភាពប្រៀបធៀប ហើយប្រជាជនក្រីក្រភាគច្រើននឹងអាចទទួលបានការងារធ្វើដូចជា ក្នុងវិស័យឧស្សាហកម្មកាត់ដេរ វិស័យជលផល ការធ្វើសូត្រជាដើម ។ល ។
- សំរបសំរួលដល់ការពង្រីកសេវាហិរញ្ញវត្ថុខ្នាតតូច ដោយរាប់បញ្ចូលទាំងឥណទាន ការសន្សំ ការធានារ៉ាប់រង និងសេវាមិនមែនទៅលើហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់សកម្មភាពរកប្រាក់ចំណូល និងសហគ្រាសតូចៗ ។
- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលជួយទ្រទ្រង់ដល់អ្នកក្រីក្រដូចជា ធារាសាស្ត្រខ្នាតតូច ផ្លូវដែលអាចប្រើបានគ្រប់រដូវ ការផ្តល់អគ្គិសនីនៅតាមជនបទ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ដើម្បីបង្កើនសន្ទុះផលិតកម្ម លើកកំពស់ផលិតភាព និងជួយសំរួលដល់ផ្នែកពាណិជ្ជកម្ម និងចលនាកំលាំងពលកម្ម ។ ការវិនិយោគទាំងនេះត្រូវតែមានការចូលរួមពីអ្នកនៅតាមមូលដ្ឋាន ក្នុងការជ្រើសរើសគំរោងការសាងសង់ និងការថែទាំ ។
- ពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី និងទីផ្សារដី ព្រមទាំងទប់ស្កាត់ និងដោះស្រាយទំនាស់ដីធ្លី តាមរយៈយន្តការក្រៅប្រព័ន្ធតុលាការ រៀបចំដែនដី និងគ្រប់គ្រងធម្មជាតិ ដោយសមធម៌ ចីរភាព និងប្រសិទ្ធភាព និងបែងចែកដីដោយសមធម៌ ។
- កែលំអនូវផ្នែកទីផ្សារ ដើម្បីលើកកំពស់នូវការនាំចេញផលិតផលកសិកម្ម និងជួយសំរួលដល់ការផ្លាស់ប្តូរគ្នាទៅវិញទៅមកខាងសេដ្ឋកិច្ចនៅក្នុងតំបន់ និងរវាងតំបន់ជនបទ និងទីក្រុងផងដែរ ។
- ពង្រឹងវិធានការ ដើម្បីលើកកំពស់ការចូលរួមពីសហគមន៍ក្នុងការផ្តល់សេវា និងសកម្មភាពផលិតភាពដោយផ្ទាល់ព្រមទាំងពង្រឹងនូវដំណើរការវិមជ្ឈការផងដែរ ។

**ការគាំពារសង្គម និងការកាត់បន្ថយហានិយភ័យ**

មានរបាយការណ៍ជាច្រើន បញ្ជាក់ពីភាពងាយទទួលរងគ្រោះ ដែលទាមទារឱ្យមានការឆ្លើយតបជាគោលនយោបាយសមាហរណកម្ម។ រាជរដ្ឋាភិបាលនឹងពង្រឹងនូវវិធានការរបស់ខ្លួន ដើម្បីប្រយុទ្ធនឹងភាពងាយរងគ្រោះទៅតាមមធ្យោបាយដូចខាងក្រោម:

- បង្កើតប្រព័ន្ធផែនទីអសន្តិសុខស្បៀង ភាពងាយរងគ្រោះ និងពតិមាន។
- បង្កើតនូវផែនការយុទ្ធសាស្ត្រ និងពង្រីកកម្មវិធីពិសេសរបស់ជាតិ សំរាប់សន្តិសុខស្បៀងដែលមានចំណាយប្រកបដោយប្រសិទ្ធភាព និងប្រើប្រាស់នូវបច្ចេកវិទ្យាសមស្រប។
- ពង្រឹងយន្តការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ តាមរយៈគណៈកម្មាការសុរិយោដី។ ការខ្វះប័ណ្ណកម្មសិទ្ធិដីធ្លីធ្វើឱ្យអ្នកក្រីក្រត្រូវប្រឈមនឹងការរំលោភយកដី និងទំនាស់ដីធ្លី។ នៅពេលដែលយន្តការនេះ ត្រូវបានពង្រឹង ប្រជាពលរដ្ឋ ពិសេសភោគីក្រីក្រ នឹងមានលទ្ធភាពប្រើប្រាស់យន្តការនេះក្នុងការដោះស្រាយវិវាទដីធ្លី ដោយចំណាយពេលវេលា និងថវិកាក្នុងកំរិតទាប។
- បង្កើនការគាំពារផ្នែកសង្គមដល់ក្រុមដែលសកម្មសេដ្ឋកិច្ច តាមរយៈសេវានីតិសម្បទាន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឱកាសការងារដោយផ្អែកតាមសហគមន៍។
- ពង្រឹងនូវជំនួយសង្គមសំរាប់ប្រជាជនណាដែលអាចចូលរួមនៅក្នុងវិស័យសេដ្ឋកិច្ចដូចជា ចាស់ជរា និងជនពិការ និងដើម្បីជួយដល់កុមារកំព្រា និងកុមារអនាថារស់នៅតាមចិញ្ចើមថ្នល់។
- ពង្រឹងវិធានការ ដើម្បីបង្កើននូវកិច្ចគាំពារកុមារនៅកន្លែងការងារតាមរយៈការអនុវត្តន៍ និងការត្រួតពិនិត្យកម្មវិធីការពារពលកម្មកុមារ ដែលរួមមានវិធានការគាំទ្រខាងអាហារូបត្ថម្ភ គាំទ្រផ្លូវច្បាប់ ការលើកកំពស់ការយល់ដឹង ការអប់រំ ការត្រួតពិនិត្យទៅលើពលកម្មកុមារ ព្រមជាមួយនិងការផ្តល់នូវជំរើសផ្សេងៗក្នុងការរកទទួលទាន។
- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងគ្រោះធម្មជាតិ តាមរយៈការបង្កើនការសម្របសម្រួលនៅក្នុងចំណោមអ្នកពាក់ព័ន្ធដ៏សំខាន់ៗ និងត្រៀមខ្លួនឱ្យបានប្រសើរជាងមុន ដើម្បីទប់ទល់នឹងគ្រោះធម្មជាតិផ្សេងៗ នៅពេលអនាគត។
- ជំរុញការអនុវត្តន៍កម្មវិធីសម្បទានដី សង្គមកិច្ច ដល់ប្រជាជនដែលខ្វះដីសំរាប់លំនៅស្ថាន និងសំរាប់ធ្វើកសិកម្មចិញ្ចឹមជីវិតជាលក្ខណៈគ្រួសារដែលមានប្រមាណ ១៣% នៃប្រជាជនទូទាំងប្រទេស។ ភាពក្រីក្រផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងភាពគ្មានដីធ្លី ដូច្នេះ ការបែងចែកដីធ្លីនឹងនាំទៅរកការកាត់បន្ថយភាពក្រីក្រ ដោយការផ្តល់ឱ្យអ្នកក្រីក្រនូវទ្រព្យដែលមានផលិតភាព និងល័ក្ខខ័ណ្ឌអនុគ្រោះផ្សេងៗទៀត។

## ២.១.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក១

រូប ២.១.៣ បានបង្ហាញពីការបែងចែកតាមតំបន់នៃសូចនាករ គអសក១ តាមខេត្ត/ក្រុង។ តំលៃនីមួយៗ តំណាងឱ្យសន្ទស្សន៍ដែលមានទំងន់មធ្យមស្មើគ្នា (equally weighted index) នៃសូចនាករដែលមានទិន្នន័យទាំងអស់របស់ គអសក១។ សន្ទស្សន៏រួមនៃ គអសក១ បង្ហាញនូវរូបភាពនៃការបែងចែកស្ថានភាពរបស់ប្រទេស ទាក់ទងទៅនឹងភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន។ លទ្ធផលទាំងនេះអនុញ្ញាតិឱ្យយើងធ្វើការបែងចែកខេត្ត/ក្រុង ជាបីលំដាប់ថ្នាក់ អាស្រ័យទៅតាមលំដាប់សន្ទស្សន៏របស់ខ្លួន។ ខេត្ត/ក្រុងណាដែលមានពណ៌បៃតង គឺជាខេត្ត/ក្រុង ដែលមានលទ្ធភាពប្រសើរជាងគេក្នុងការសំរេចចំណុចដៅ ចំណែកពណ៌លឿង និងពណ៌ក្រហម គឺជាខេត្ត/ក្រុងទាំងឡាយណាដែលមានលទ្ធភាពមធ្យម និងអន់ជាងគេតាមលំដាប់ក្នុងការសំរេចចំណុចដៅ នៅឆ្នាំ២០១៥[៨]។ បណ្តាខេត្ត/ក្រុងដែលមានពណ៌ក្រហម គឺច្រើនតែស្ថិតនៅតំបន់ប៉ែកពាយ័ព្យ ឦសាន និងអគ្នេយ៏នៃប្រទេស។

**រូប ២.១.៤: សន្ទស្សន៏រួមនៃ គអសក១ តាមខេត្ត/ក្រុង**




សំគាល់: សន្ទស្សន៏ គអសក១ គឺជាមធ្យមភាគដែលមានទំងន់ស្មើគ្នាទៅតាមលំដាប់ខេត្ត/ក្រុងនីមួយៗនៃតំលៃសូចនាករចំនួន ៦ របស់ គអសក១។

[៨] សន្ទស្សន៏ត្រូវបានគណនាដោយយោងទៅតាមរូបមន្តដែលបង្ហាញក្នុងឧបសម្ព័ន្ធ គ។

## តារាង ២.១.៣: សន្ទស្សន៍រួមនៃ គអសក១ តាមខេត្ត/ក្រុង

| លេខកូដ | ខេត្ត-ក្រុង | សន្ទស្សន៍ ១.១ | សន្ទស្សន៍ ១.៣ | សន្ទស្សន៍ ១.៤ | សន្ទស្សន៍ ១.៦ | សន្ទស្សន៍ ១.៧ | សន្ទស្សន៍ ១.៨ | សន្ទស្សន៍ គអសក១ |
|---|---|---|---|---|---|---|---|---|
| ០៧ | កំពត | 0,៨៨២ | 0,៧៩៣ | 0,៧៨0 | 0,៣៩៥ | 0,៩៩៣ | 0,៨៩៦ | **0,៧៩0** |
| ១២ | ភ្នំពេញ | 0,៩៥៨ | 0,៩២៨ | ១,000 | ១,000 | 0,៤១៣ | 0,៤0៧ | **0,៧៨៤** |
| ១៨ | ក្រុងព្រះសីហនុ | 0,៧0៩ | 0,៩២៨ | 0,៧៨0 | 0,៣៩៥ | 0,៩៩៣ | 0,៨៩៦ | **0,៧៨៣** |
| ២៣ | ក្រុងកែប | 0,៥៤២ | 0,៩0៦ | 0,៧៨0 | 0,៣៩៥ | 0,៩៩៣ | 0,៨៩៦ | **0,៧៥២** |
| 0១ | បន្ទាយមានជ័យ | 0,៦៣៣ | 0,៨២៦ | 0,៧៩៤ | 0,៨៨៨ | 0,៣៣៣ | 0,៩៨៤ | **0,៧៤៣** |
| ២១ | តាកែវ | 0,៩២១ | 0,៨៣៧ | 0,៧៧៥ | 0,៤៣៩ | 0,៤៨៧ | 0,៨៧៩ | **0,៧២៣** |
| 0២ | បាត់ដំបង | 0,៧៩៥ | 0,៦៤២ | 0,៩៣៦ | 0,៦៣៦ | 0,២២៧ | 0,៩៤៤ | **0,៦៩៧** |
| 0៨ | កណ្ដាល | 0,៨៨៥ | 0,៨២៤ | 0,៣៩៤ | 0,២៩៩ | 0,៨៤៧ | 0,៩0៥ | **0,៦៩២** |
| 0៩ | កោះកុង | ១,000 | 0,៨៣៧ | 0,៦៤៧ | 0,000 | 0,៦៥៣ | 0,៩៧១ | **0,៦៨៥** |
| 0៥ | កំពង់ស្ពឺ | 0,៨៨៨ | 0,៧១៣ | 0,៥៨៧ | 0,៣៥៧ | 0,៥0៧ | ១,000 | **0,៦៧៥** |
| ១៩ | ស្ទឹងត្រែង | 0,៩0៨ | ១,000 | 0,៤៥0 | 0,១៣៦ | 0,៩0៧ | 0,៦៤២ | **0,៦៧៤** |
| ១៥ | ពោធិ៍សាត់ | 0,៦៣៤ | 0,៧៨៨ | 0,៤៨២ | 0,២៩៦ | 0,៧៤0 | 0,៩២២ | **0,៦៤៤** |
| 0៣ | កំពង់ចាម | 0,៩៥៦ | 0,៧២៧ | 0,៤១៣ | 0,២៣១ | 0,៥៩៣ | 0,៩៣៨ | **0,៦៤៣** |
| ២៤ | ក្រុងប៉ៃលិន | 0,000 | 0,៩២៨ | 0,៩៣៦ | 0,៦៣៦ | 0,២២៧ | 0,៩៤៤ | **0,៦១២** |
| ១៣ | ព្រះវិហារ | 0,៧៦៥ | 0,៧២៥ | 0,៤៥0 | 0,១៣៦ | 0,៩0៧ | 0,៦៤២ | **0,៦0៤** |
| ១0 | ក្រចេះ | 0,៦៥៨ | 0,៨២៤ | 0,៤៥0 | 0,១៣៦ | 0,៩0៧ | 0,៦៤២ | **0,៦0៣** |
| ២២ | ឧត្ដរមានជ័យ | 0,៦៥៣ | 0,៥៨៧ | 0,៣១៧ | 0,១៤៦ | 0,៩២៧ | 0,៩៥៩ | **0,៥៩៨** |
| ២0 | ស្វាយរៀង | 0,៦0៣ | 0,៩0៩ | 0,៥00 | 0,១២៦ | 0,៧៦៧ | 0,៥៣៤ | **0,៥៧៣** |
| 0៤ | កំពង់ឆ្នាំង | 0,៥៩១ | 0,000 | 0,៤៩១ | 0,៣១0 | ១,000 | 0,៩៥១ | **0,៥៥៧** |
| ១៧ | សៀមរាប | 0,៤៨៨ | 0,៣៥៥ | 0,៣១៧ | 0,១៤៦ | 0,៩២៧ | 0,៩៥៩ | **0,៥៣២** |
| 0៦ | កំពង់ធំ | 0,៧៦៥ | 0,២៥៩ | 0,៣៣៩ | 0,២៦៥ | 0,000 | 0,៩៧៩ | **0,៤៣៥** |
| ១៤ | ព្រៃវែង | 0,៤៩៥ | 0,២២៦ | 0,000 | 0,១២៩ | 0,៦២៧ | 0,៨៦៤ | **0,៣៩0** |
| ១១ | មណ្ឌលគីរី | 0,៨៦៩ | 0,៥៦២ | 0,១២៨ | 0,000 | 0,៦២0 | 0,000 | **0,៣៦៣** |
| ១៦ | រតនៈគីរី | 0,៩៩៣ | 0,១0៥ | 0,១២៨ | 0,000 | 0,៦២0 | 0,000 | **0,៣0៨** |

សំគាល់: គណនាដោយប្រើទិន្នន័យពីកម្មវិធីស្បៀងអាហារពិភពលោក (២00២) "ការប៉ាន់ស្មានទៅលើអត្រាភាពក្រីក្រនៅថ្នាក់ឃុំនៅក្នុងប្រទេសកម្ពុជា" អង្កេត សេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៩ និងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២000។

## ២.២ គោលដៅទី២: សំរេចឱ្យបានជាទូទៅការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ

គោលដៅទី២ មានគោលបំណងធានាឱ្យកុមារទាំងអស់មានលទ្ធភាពបញ្ចប់វគ្គសិក្សាកំរិតអប់រំមូលដ្ឋានឱ្យបានពេញលេញ។

### ២.២.១ សូចនាករ និងចំណុចដៅនៃ គអសក២

តារាង ២.២.១ បានបង្ហាញឱ្យឃើញនៅក្នុងជួរឈរខាងឆ្វេង គឺជាចំណុចដៅ និងសូចនាករដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ រីឯជួរឈរខាងស្តាំ បង្ហាញពីចំណុចដៅ និងសូចនាករដែលបានជ្រើសរើសដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗរួចមក។

**តារាង ២.២.១: មូលដ្ឋានីយកម្ម គអស២ ទៅជា គអសក២**

| គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលទី២ | គអសក២ |
|---|---|
| **ចំណុចដៅទី៣:** ធានាឱ្យកុមារទាំងអស់បានបញ្ចប់ការសិក្សាកំរិតបឋមសិក្សា នៅមុនដំណាច់ឆ្នាំ២០១៥ | **ចំណុចដៅរួមទី៣:** ធានាឱ្យកុមារទាំងអស់បានបញ្ចប់ការសិក្សាកំរិតបឋមសិក្សា នៅមុនដំណាច់ឆ្នាំ២០១០ និងការសិក្សាកំរិតមូលដ្ឋានរយៈពេល ៩ឆ្នាំ នៅមុនដំណាច់ឆ្នាំ២០១៥ |
| **សូចនាករ៦:** អត្រាពិតនៃការសិក្សានៅបឋមសិក្សា | **សូចនាករ២.១:** អត្រាពិតចូលរៀនថ្មី |
| | **សូចនាករ២.២:** អត្រាពិតនៃការសិក្សានៅបឋមសិក្សា |
| | **សូចនាករ២.៣:** អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ |
| | **សូចនាករ២.៤:** សមាមាត្រកុមារអាយុពី៦ ទៅ១៤ឆ្នាំ ដែលមិនបានចូលរៀន |
| **សូចនាករ៧:** សមាមាត្រនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៥ | **សូចនាករ២.៥:** អត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៥ |
| | **សូចនាករ២.៦:** អត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ (ថ្នាក់ចុងក្រោយនៃការសិក្សាកំរិតបឋមសិក្សា) |
| | **សូចនាករ២.៧:** អត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៩ (ថ្នាក់ចុងក្រោយនៃការសិក្សាកំរិតមូលដ្ឋាន) |
| **សូចនាករ៨:** អត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី១៥ ទៅ ២៤ឆ្នាំ | **សូចនាករ២.៨:** អត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី១៥ ទៅ ២៤ឆ្នាំ |
| **ចំណុចដៅទី៤:** លុបបំបាត់វិសមភាពយេនឌ័រក្នុងការអប់រំកំរិតបឋមសិក្សា និងមធ្យមសិក្សា ឱ្យបានមុនដំណាច់ឆ្នាំ ២០០៥ និងនៅគ្រប់កំរិតសិក្សាមិនឱ្យហួសពីឆ្នាំ២០១៥ | **ចំណុចដៅរួមទី៤:** លុបបំបាត់វិសមភាពយេនឌ័រក្នុងការអប់រំកំរិតមូលដ្ឋាន រយៈពេល ៩ឆ្នាំ ឱ្យបានមុនដំណាច់ឆ្នាំ២០១០ |
| **សូចនាករ៩:** ផលធៀបចំនួនកុមារីជាមួយចំនួនកុមារាដែលរៀននៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា (១) | **សូចនាករ២.៩:** ផលធៀបចំនួនកុមារីជាមួយចំនួនកុមារា ដែលរៀននៅបឋមសិក្សា |
| | **សូចនាករ២.១០:** ផលធៀបចំនួនកុមារីជាមួយចំនួនកុមារា ដែលរៀននៅមធ្យមសិក្សាបឋមភូមិ |

(១)សូចនាករ៩ ដែលមាននៅក្នុងបញ្ជី គអស ត្រូវបានភ្ជាប់ទៅនឹងគោលដៅទី៣ ។ ប៉ុន្តែអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច បានសំរេចដាក់ផ្នែកខ្លះនៃចំណុចដៅទី៤ និងសូចនាករ៩ ដែលពាក់ព័ន្ធទៅនឹងការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិឱ្យមកនៅជាមួយ គអសក២ វិញ ដោយសារគោលដៅនេះមានការពាក់ព័ន្ធនិងមានលក្ខណៈរួមទៅនឹងគោលដៅដែលទាក់ទងនឹងយេនឌ័រ។

តារាង ២.២.២ បង្ហាញនូវតំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក២ តាមលំដាប់ឆ្នាំ។ ទិន្នន័យមូលដ្ឋាន ជាឆ្នាំកន្លងទៅថ្មីៗដែលមានទិន្នន័យ ហើយតំលៃនៃឆ្នាំមូលដ្ឋានមាននៅឆ្នាំ១៩៩៩ រឺឆ្នាំ២០០១។ ការកំនត់តំលៃចំនុចដៅ ត្រូវបានផ្អែកទៅលើរបាយការណ៍បំពេញការងារវិស័យអប់រំ (ការពិនិត្យឡើងវិញនូវកម្មវិធីគាំទ្រវិស័យអប់រំ ឆ្នាំ២០០៣) ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០០៥ និងការពិគ្រោះយោបល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា។

**តារាង ២.២.២: តំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករនៃ គអសក២ តាមលំដាប់ឆ្នាំ**

| សូចនាករ | ទិន្នន័យមូលដ្ឋាន | | ចំណុចដៅ | | |
|---|---|---|---|---|---|
| | តំលៃ | ឆ្នាំ | ២០០៥ | ២០១០ | ២០១៥ |
| ២.១ អត្រាពិតចូលរៀនថ្មី | ៨១[ក] | ២០០១ | ៩៥ | ១០០ | ១០០ |
| ២.២ អត្រាពិតនៃការសិក្សានៅបឋមសិក្សា | ៨៧[ក] | ២០០១ | ៩៥ | ១០០ | ១០០ |
| ១. កុមារា | ៩០[គ] | ២០០១ | ៩៦ | ១០០ | ១០០ |
| ២. កុមារី | ៨៤[ក] | ២០០១ | ៩៤ | ១០០ | ១០០ |
| ២.៣ អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ១៩[ក] | ២០០១ | ៥០ | ៧៥ | ១០០ |
| ១. កុមារា | ២១[គ] | ២០០១ | ៥១ | ៧៥ | ១០០ |
| ២. កុមារី | ១៦[ក] | ២០០១ | ៤៩ | ៧៥ | ១០០ |
| ២.៤ សមាមាត្រកុមារអាយុពី ៦ ទៅ ១៤ឆ្នាំ ដែលមិនបានចូលរៀន | ៣៥[ខ] | ១៩៩៩ | ២២ | ១១ | ០ |
| ២.៥ អត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ ទី៥ | ៥៨[គ] | ២០០១ | ៧៧ | ១០០ | ១០០ |
| ២.៦ អត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ ទី៦ (ថ្នាក់ចុងក្រោយនៃការសិក្សាកំរិតបឋមសិក្សា) | ៥១[គ] | ២០០១ | ៧៣ | ១០០ | ១០០ |
| ២.៧ អត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ ទី៩ (ថ្នាក់ចុងក្រោយនៃការសិក្សាកំរិតមូលដ្ឋាន) | ៣៣[គ] | ២០០១ | ៥២ | ៧៦ | ១០០ |
| ២.៨ អត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី ១៥ ទៅ ២៤ឆ្នាំ | ៨២[ខ] | ១៩៩៩ | ៩០ | ៩៥ | ១០០ |
| ២.៩ ផលធៀបចំនួនកុមារី ជាមួយកុមារា ដែលរៀននៅបឋមសិក្សា | ៨៧[គ] | ២០០១ | ៩៨ | ១០០ | ១០០ |
| ២.១០ ផលធៀបចំនួនកុមារី ជាមួយកុមារា ដែលរៀននៅមធ្យមសិក្សាបឋមភូមិ | ៦៣[គ] | ២០០១ | ៩៦ | ១០០ | ១០០ |

ប្រភព: [ក] - ក្រសួងអប់រំ យុវជន និង កីឡា ២០០២ក។

[ខ] - ទិន្នន័យមូលដ្ឋាននៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៩។

[គ] - ទិន្នន័យមូលដ្ឋាននៃស្ថិតិ និងអាំងឌីការទ័រអប់រំ ឆ្នាំ២០០១/២០០២។

## ២.២.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក២

លទ្ធភាពទទួលបានការអប់រំមូលដ្ឋាន អាចត្រូវបានវាស់ស្ទង់ដោយអត្រាពិតចូលរៀនថ្មី អត្រាពិតនៃការសិក្សានៅបឋមសិក្សា អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងសមាមាត្រកុមារអាយុពី ៦ ទៅ ១៤ឆ្នាំ ដែលមិនបានចូលរៀន។ អត្រាពិតចូលរៀនថ្មីគឺមាន ៨១% នៅឆ្នាំ២០០១។ អត្រានេះបានកើនឡើងយ៉ាង

ខ្លាំងក្នុងចន្លោះឆ្នាំ១៩៩៧ ទៅឆ្នាំ២០០១។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជាទំនងជានឹងឈានដល់ចំណុចដៅរបស់ខ្លួន ដែលមានអត្រាពិតចូលរៀនថ្មីនៅថ្នាក់ទី១ ដល់ទៅ១០០% មុនដំណាច់ឆ្នាំ២០០៥ (រូប ២.២.១)។

**រូប ២.២.១: និន្នាការ និងចំណុចដៅនៃអត្រាពិតចូលរៀនថ្មី**




ប្រភព: ក្រសួងអប់រំ យុវជន និងកីឡា ១៩៩៨, ១៩៩៩, ២០០០, ២០០១ និង ២០០២ក។

អត្រាពិតនៃការសិក្សានៅបឋមសិក្សាមាន ៨៧% នៅឆ្នាំ២០០១។ អត្រានេះបាននិងកំពុងកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក លើកលែងតែនៅឆ្នាំ២០០០ ដែលគេបានសង្កេតឃើញថាមានការចុះថយបន្តិច។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជាទំនងជានឹងសំរេចបាននូវចំណុចដៅរបស់ខ្លួន ក្នុងអត្រាពិតនៃការសិក្សាអោយបាន ១០០% មុនឆ្នាំ២០១០ (រូប ២.២.២)។

**រូប ២.២.២: និន្នាការ និងចំណុចដៅនៃអត្រាពិតនៃការសិក្សានៅបឋមសិក្សា**




ប្រភព: ក្រសួងអប់រំ យុវជន និងកីឡា ១៩៩៨, ១៩៩៩, ២០០០, ២០០១ និង២០០២ក។

ប្រសិនបើទិន្នន័យត្រូវបានបែងចែកទៅតាមភេទ នោះនិន្នាការរបស់ក្រុមមនុស្សទាំងពីរភេទ គឺស្ថិតនៅពីលើចំណុចដៅរបស់ខ្លួន ដែលនឹងប្រសព្វគ្នានៅក្នុងឆ្នាំ២០០៥។ នេះមានន័យថា ប្រទេសកម្ពុជា នឹងសំរេចបាននូវចំណុចដៅរបស់ខ្លួន ទាំងក្រុមកុមារា និងក្រុមកុមារី។ លើសពីនេះទៅទៀត កម្ពុជានឹងអាចសំរេចបាននូវសមភាពយេនឌ័រក្នុងអត្រាពិតនៃការសិក្សានៅបឋមសិក្សាផងដែរ នៅឆ្នាំ២០០៥ (រូប ២.២.២.១)។

### រូប ២.២.២.១: និន្នាការ និងចំណុចដៅនៃអត្រាពិតនៃការសិក្សានៅបឋមសិក្សា តាមភេទ




ប្រភព: ក្រសួងអប់រំ យុវជន និង កីឡា ១៩៩៨, ១៩៩៩, ២000, ២00១ និង ២00២ក ហើយនិងទិន្នន័យមូលដ្ឋាននៃស្ថិតិ និងអាំងឌីការទ័រអប់រំ ឆ្នាំ១៩៩៧/១៩៩៨, ១៩៩៨/១៩៩៩, ១៩៩៩/២000, ២000/២00១ និង២00១/២00២។

អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិនៅថ្នាក់ជាតិមាន ១៩% នៅឆ្នាំ២00១។ អត្រានេះបានធ្លាក់ចុះនៅឆ្នាំ១៩៩៨ បន្ទាប់មកក៏បានកើនឡើងបន្តិចរហូតដល់ឆ្នាំថ្មីៗនេះ។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជាដូចជាមិនអាចនឹងមានលទ្ធភាពសំរេចនូវចំណុចដៅ១00% របស់ខ្លួនមុនដំណាច់ឆ្នាំ២0១៥ឡើយ (រូប ២.២.៣)។

### រូប ២.២.៣: និន្នាការ និងចំណុចដៅនៃអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ




ប្រភព: ក្រសួងអប់រំ យុវជន និង កីឡា ១៩៩៨, ១៩៩៩, ២000, ២00១ និង ២00២ក។

ប្រសិនបើទិន្នន័យត្រូវបានបែងចែកទៅតាមភេទ នោះនិន្នាការរបស់ក្រុមសិស្សទាំងពីរភេទ ស្ថិតនៅពីក្រោមចំណុចដៅរបស់ខ្លួន ដែលនឹងប្រសព្វគ្នានៅក្នុងកំលុងឆ្នាំ២0១0។ ប្រទេសកម្ពុជា មិនទំនងជាអាចសំរេចនូវចំណុចដៅរបស់ខ្លួន ទាំងក្រុមសិស្សប្រុស និងក្រុមសិស្សស្រី។ ក៏ប៉ុន្តែ ប្រទេសកម្ពុជាអាចនឹងសំរេចនូវសមភាពយេនឌ័រក្នុងអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ នៅឆ្នាំ២0១0 (រូប ២.២.៣.១)។

## រូប ២.២.៣.១: និន្នាការ និងចំណុចដៅនៃអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ តាមភេទ




ប្រភព: ក្រសួងអប់រំ យុវជន និង កីឡា ១៩៩៨, ១៩៩៩, ២000, ២00១ និង ២00២ក ហើយនិងទិន្នន័យមូលដ្ឋាននៃស្ថិតិ និងអាំងឌីការទ័រអប់រំ ឆ្នាំ១៩៩៧/១៩៩៨, ១៩៩៨/១៩៩៩, ១៩៩៩/២000, ២000/២00១ និង២00១/២00២។

សមាមាត្រកុមារអាយុពី ៦ ទៅ ១៤ឆ្នាំ ដែលមិនបានចូលរៀនមាន ៣៥% នៅឆ្នាំ១៩៩៩។ អត្រានេះបានធ្លាក់ចុះតែបន្តិចចាប់តាំងពីឆ្នាំ១៩៩៧មក។ ប្រសិនបើនិន្នាការកន្លងមកនៅតែបន្តទៀតនោះ កម្ពុជាមិនទំនងជាអាចសំរេចបានចំណុចដៅរបស់ខ្លួន ក្នុងការលុបបំបាត់នូវករណីកុមារមានអាយុពី ៦ ទៅ ១៤ឆ្នាំ ដែលមិនបានចូលរៀននៅសាលានោះឡើយ (រូប ២.២.៤)។

## រូប ២.២.៤: និន្នាការ និងចំណុចដៅនៃសមាមាត្រកុមារអាយុពី៦-១៤ឆ្នាំដែលមិនបានចូលរៀន




ប្រភព: ទិន្នន័យមូលដ្ឋាន នៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា នៅឆ្នាំ១៩៩៧ និងឆ្នាំ១៩៩៩។

អត្រាគង់វង្សនៃសិស្សវាស់វែងនូវប្រសិទ្ធភាពនៃប្រពន្ធ័អប់រំ។ អត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ទី៥ នៅថ្នាក់ជាតិមាន ៥៨% នៅឆ្នាំ២00១ ហើយបានកើនឡើងខ្លាំងនៅក្នុងរយៈពេលពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២00១។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជាទំនងជាអាចសំរេចបាន ចំណុចដៅរបស់ខ្លួនឱ្យបានដល់ ១00% នូវអត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៥ នៅមុនឆ្នាំ២0១៥ (រូប ២.២.៥)។

**រូប ២.២.៥: និន្នាការ និងចំណុចដៅនៃអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ទី៥**




ប្រភព: ទិន្នន័យមូលដ្ឋាននៃស្ថិតិ និងអាំងឌីការទ័រអប់រំ ឆ្នាំ១៩៩៧/១៩៩៨, ១៩៩៨/១៩៩៩, ១៩៩៩/២០០០, ២០០០/២០០១ និង ២០០១/២០០២។

អត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ទី៦ នៅថ្នាក់ជាតិមាន ៥១% នៅឆ្នាំ២០០១ ហើយបានកើនឡើងខ្លាំង នៅក្នុងរយៈពេលពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០១។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជាទំនងជាអាចសំរេចបានចំណុចដៅរបស់ខ្លួនឱ្យបានដល់ ១០០% នៃអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ទី៦ មុនឆ្នាំ២០១៥ (រូប ២.២.៦)។

**រូប ២.២.៦: និន្នាការ និងចំណុចដៅនៃអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ទី៦**




ប្រភព: ទិន្នន័យមូលដ្ឋាននៃស្ថិតិ និងអាំងឌីការទ័រអប់រំ ឆ្នាំ១៩៩៧/១៩៩៨, ១៩៩៨/១៩៩៩, ១៩៩៩/២០០០, ២០០០/២០០១ និង ២០០១/២០០២។

អត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ទី៩ នៅថ្នាក់ជាតិមាន ៣៣% នៅឆ្នាំ២០០១ ហើយបានកើនឡើងយ៉ាងថេរចាប់ពីឆ្នាំ១៩៩៧មក។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជាមិនទំនងជាអាចសំរេចបានចំណុចដៅរបស់ខ្លួនឱ្យបានដល់ ១០០% នៃអត្រាគង់វង្សនៃសិស្សដែលបានរៀនពីថ្នាក់ទី១ ដល់ទី៩ នៅមុនដំណាច់ឆ្នាំ២០១៥ នោះឡើយ (រូប ២.២.៧)។

### រូប ២.២.៧: និន្នាការ និងចំណុចដៅនៃអត្រាគង់វង្សនៃសិស្ស ដែលបានរៀនពីថ្នាក់ទី១ ដល់ទី៩




ប្រភព: ទិន្នន័យមូលដ្ឋាននៃស្ថិតិ និងអាំងឌីការទ័រអប់រំ ឆ្នាំ១៩៩៧/១៩៩៨, ១៩៩៨/១៩៩៩, ១៩៩៩/២០០០, ២០០០/២០០១ និង ២០០១/២០០២។

អត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី១៥ ទៅ ២៤ឆ្នាំ នៅថ្នាក់ជាតិមាន ៨២% នៅឆ្នាំ១៩៩៩ ដោយកើនឡើងពី ៧៩% នៅក្នុងឆ្នាំ១៩៩៦។ ប្រសិនបើអត្រានេះនៅតែបន្តដដែល ប្រទេសកម្ពុជាមិនទំនងជាអាចសំរេចបាននូវចំណុចដៅនៃ គអស របស់ខ្លួនឱ្យបានដល់ ១០០% នៃអត្រាអក្ខរកម្មនេះ នៅមុនដំណាច់ឆ្នាំ២០១៥ នោះទេ (រូប ២.២.៨)។

### រូប ២.២.៨: និន្នាការ និងចំណុចដៅនៃអត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី១៥ ទៅ២៤ឆ្នាំ




ប្រភព: ទិន្នន័យមូលដ្ឋាននៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា នៅឆ្នាំ១៩៩៦, ១៩៩៧ និង១៩៩៩។

សមភាពយេនឌ័រក្នុងការអប់រំមូលដ្ឋានត្រូវបានវាស់វែង ដោយផលធៀបចំនួនកុមារី ជាមួយកុមារា ដែលរៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ផលធៀបចំនួនកុមារីជាមួយកុមារា ដែលរៀននៅបឋមសិក្សាមាន ៨៧% នៅឆ្នាំ២០០១ ហើយបានកើនឡើងបន្តិច ចាប់តាំងពីឆ្នាំ១៩៩៧មក។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជាមិនទំនងជាអាចផ្សារភ្ជាប់នូវគំលាតយេនឌ័រនៅបឋមសិក្សា ឱ្យបានមុនដំណាច់ឆ្នាំ២០១០ បានឡើយ (រូប ២.២.៩)។

**រូប ២.២.៩: និន្នាការ និងចំណុចដៅនៃផលធៀបចំនួនកុមារីជាមួយកុមារាដែលរៀននៅបឋមសិក្សា**




ប្រភព: ទិន្នន័យមូលដ្ឋាននៃស្ថិតិ និងអាំងឌីការទ័រអប់រំឆ្នាំ១៩៩៧/១៩៩៨, ១៩៩៨/១៩៩៩, ១៩៩៩/២០០០, ២០០០/២០០១ និង២០០១/២០០២។

ផលធៀបចំនួនកុមារីជាមួយកុមារា ដែលរៀននៅមធ្យមសិក្សាបឋមភូមិនៅថ្នាក់ជាតិមាន ៦៣% នៅឆ្នាំ ២០០១ ធៀបទៅនឹង ៥៤% នៅឆ្នាំ១៩៩៧។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជានឹងមិនទំនងអាចសំរេចនូវសមភាពយេនឌ័រនៅមធ្យមសិក្សាបឋមភូមិ ដូចដែលបានដៅទុកនោះឡើយ (រូប ២.២.១០)។

**រូប ២.២.១០: និន្នាការ និងចំណុចដៅនៃផលធៀបចំនួនកុមារីជាមួយកុមារា ដែលរៀននៅធ្យមសិក្សាបឋមភូមិ**




ប្រភព: ទិន្នន័យមូលដ្ឋាននៃស្ថិតិ និងអាំងឌីការទ័រអប់រំ ឆ្នាំ១៩៩៧/១៩៩៨, ១៩៩៨/១៩៩៩, ១៩៩៩/២០០០, ២០០០/២០០១ និង២០០១/២០០២។

### ២.២.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក២

នាពេលបច្ចុប្បន្ន គោលនយោបាយចំនួន ៥ ត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ជាមួយដៃគូរបស់ខ្លួន តាំងពីពាក់កណ្តាលឆ្នាំ២០០២មកម្ល៉េះ។ ក្នុងគោលនយោបាយនីមួយៗ មានផែនការសកម្មភាពជាយុទ្ធសាស្ត្រសំរាប់ឆ្នាំ២០០៣ ដល់ឆ្នាំ២០០៦ ដើម្បីធានាការសំរេចឱ្យបាននូវគោលដៅ និងចំនុចដៅទាំងឡាយនៃវិស័យអាទិភាព។ គោលនយោបាយទាំង ៥ មានដូចតទៅ:

១. ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្ពោះទៅរកការអប់រំសំរាប់ទាំងអស់គ្នា។

២. បង្កើនលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌។

៣. កំណែលំអគុណភាព និងប្រសិទ្ធភាពផ្ទៃក្នុងនៃការអប់រំ។

៤. បង្កើនការគ្រប់គ្រង និងវិសហមជ្ឈការនៃសេវាអប់រំ។

៥. បង្កើនការបែងចែកធនធានឱ្យបានច្រើនដល់វិស័យអប់រំ។

កម្មវិធីគាំទ្រវិស័យអប់រំ ២០០២-២០០៦ បានរាយឈ្មោះកម្មវិធីសកម្មភាពអាទិភាពចំនួន ១២ ដែលក្នុងចំណោមនោះមាន ៨ កម្មវិធី ដែលផ្ដោតទៅលើការអប់រំមូលដ្ឋាន តាមរយៈផ្នែកផ្សេងៗដូចតទៅនេះ: កម្មវិធីបង្កើនប្រសិទ្ធភាពនៃសេវាអប់រំ កម្មវិធីបង្កើនប្រសិទ្ធភាព និងគុណភាពនៃការអប់រំកំរិតបឋមសិក្សា កម្មវិធីបង្កើនប្រសិទ្ធភាព និងគុណភាពនៃការអប់រំកំរិតមធ្យមសិក្សា កម្មវិធីបន្តពង្រឹងសមត្ថភាពគ្រូបង្រៀន កម្មវិធីផ្គត់ផ្គង់សំភារៈឧបទ្ទេសគោលប្រកបដោយចិរភាព កម្មវិធីពង្រីកការអប់រំក្រៅប្រព័ន្ធ កម្មវិធីពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងកម្មវិធីផ្ដល់អាហារូបករណ៍ និងរង្វាន់លើកទឹកចិត្តសំរាប់ការចូលរៀនប្រកបដោយសមធម៌។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលមានកម្មវិធីវិនិយោគ ដែលផ្ដោតជាសំខាន់លើការសាងសង់អាគារសិក្សា និងបំពាក់បរិក្ខារសិក្សាដល់សាលារៀន ហើយនិងការអភិវឌ្ឍន៍ស្ថាប័ន និងការកសាងសមត្ថភាព។

**២.២.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក២**

បញ្ហាប្រឈមសំខាន់ៗនៅក្នុងវិស័យអប់រំចំនួន ៦ ត្រូវបានកំណត់ដូចតទៅ:

- ទី១ គឺតំរូវការដោះស្រាយវិសមភាពក្នុងវិស័យអប់រំ តាមស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច យេនឌ័រ ជនជាតិ និងតំបន់។ គំលាតទាំងនេះមានការពាក់ព័ន្ធទៅនឹងលទ្ធភាពទទួលបានការអប់រំ និងគុណភាពអប់រំ ហើយមានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើង នៅពេលដែលកំរិតនៃការអប់រំកើនឡើង។
- ទី២ គឺការកែលំអបរិមាណ និងគុណភាពនៃសេវាអប់រំក្នុងបណ្ដាបញ្ហាប្រឈមដ៏ធំៗរបស់រាជរដ្ឋាភិបាលនៅក្នុងវិស័យអប់រំ។ បញ្ហាទាំងនោះមាន ការផ្គត់ផ្គង់សាលារៀនមិនបានគ្រប់គ្រាន់ធៀបនឹងដង់ស៊ីតេប្រជាជន ការផ្គត់ផ្គង់សាលារៀនមិនមានគ្រប់កំរិតថ្នាក់សំរាប់ការអប់រំមូលដ្ឋាន កង្វះបុគ្គលិកដែលបានឆ្លងវគ្គបណ្ដុះបណ្ដាល កង្វះការលើកទឹកចិត្តក្នុងចំណោមបុគ្គលិកបង្រៀនឱ្យសមស្របទៅនឹងការបំពេញកិច្ចការនៅកំរិតខ្ពស់ និងលើកទឹកចិត្តគ្រូទៅបង្រៀននៅតំបន់ដាច់ស្រយាល ការត្រួតពិនិត្យការបំពេញការងារ និងវត្តមានរបស់បុគ្គលិក កង្វះសំភារៈឧបទ្ទេស និងកង្វះបង្គន់អនាម័យ និងទឹកស្អាតនៅតាមសាលារៀន។
- ទី៣ ពាក់ព័ន្ធអ្នកប្រើប្រាស់សេវាកម្ម ត្រូវបង្កើនតំរូវការខាងការអប់រំតាមរយៈ (i) បន្ថយតំលៃចំណាយនៅត្រង់កន្លែងណាដែលមានឧបសគ្គ (ii) ផ្លាស់ប្ដូរផ្នត់គំនិតឱ្យវិលត្រឡប់ទៅរកការអប់រំ (iii) កាត់បន្ថយតំលៃកាលានុវត្តភាពនៃការចូលរៀនសំរាប់គ្រួសារក្រីក្រ និង (iv) កាត់បន្ថយកង្វះខាតអាហារូបត្ថម្ភដែលជះឥទ្ធិពលដល់ការយកចិត្តទុកដាក់រៀនសូត្ររបស់សិស្សក្នុងថ្នាក់ និងដល់ការបំពេញកិច្ចការសាលា។
- ទី៤ ការបង្កើននូវដំណើរការវិមជ្ឈការ និងបង្កើនការចូលរួមពីសហគមន៍ឱ្យបានធំធេងជាងមុននៅក្នុងការគ្រប់គ្រងសាលា គឺជាបញ្ហាប្រឈមទៅមុខដ៏វែងឆ្ងាយមួយទៀត ចំពោះវិស័យអប់រំ។ វាជាការចាំបាច់ក្នុងការជួយឱ្យសាលារៀន គ្រឹះស្ថានសិក្សា និងសហគមន៍ ឱ្យមានសំលេង និងការទទួលខុសត្រូវច្រើនជាងមុននៅក្នុងដំណើរការ និងការគ្រប់គ្រងសេវាអប់រំ។ ក្នុងបរិបទប្រទេសកម្ពុជា ការចូលរួមពីសហគមន៍ដ៏

ទូលំទូលាយជាងមុន នឹងមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការកែលំអគុណភាពសេវាអប់រំ ក៏ដូចជាបង្កើនគំរូវិការសេវាទាំងនោះដោយគ្រួសារនានា។

- បញ្ហាដែលបានលើកឡើងខាងលើ ស្តីអំពីការផ្គត់ផ្គង់ និងតំរូវការសេវាអប់រំ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអត្រាដ៏ទាបនៃការគង់វង្សរបស់សិស្សរៀននៅសាលាបឋមសិក្សា និងនៅអនុវិទ្យាល័យ ក៏ដូចជានៅក្នុងអត្រាដ៏ទាបនៃការចូលរៀននៅអនុវិទ្យាល័យ។ ដូច្នេះ បញ្ហាប្រឈមទី៥ គឺធ្វើយ៉ាងណាឱ្យកុមារដែលបានចូលរៀនហើយមិនបោះបង់សាលាវិញ តាមរយៈជំរើសផ្សេងៗ។
- បញ្ហាប្រឈមចុងក្រោយ គឺទាក់ទងទៅនឹងការកែលំអគុណភាព និងលទ្ធភាពទទួលបានការអប់រំមត្តេយ្យសិក្សា។ កុមារតូចៗជាច្រើន មិនមានភាពពេញលក្ខណៈគ្រប់គ្រាន់ ដើម្បីទទួលបានការសិក្សានៅពេលដែលពួកគេចូលរៀនជាលើកដំបូង។ បញ្ហានេះវាទាក់ទងទៅនឹងកង្វះអាគារមត្តេយ្យសិក្សា អាហារូបត្ថម្ភ និងការគាំពារសុខភាព។

## ២.២.៥ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅ គអសក២

គំនិតផ្តួចផ្តើមគោលនយោបាយសំខាន់ៗ មានផែនការយុទ្ធសាស្ត្រអប់រំ (ESP) កម្មវិធីគាំទ្រវិស័យអប់រំ (ESSP) និងផែនការអប់រំសំរាប់ទាំងអស់គ្នា (EFA)។ សមាសធាតុស្នូល នៃគំនិតផ្តួចផ្តើមទាំងអស់នេះមានសេចក្តីសង្ខេបដូចខាងក្រោម:

- ការធានាឱ្យបាននូវលទ្ធភាពទទួលបានការអប់រំមូលដ្ឋានប្រកបដោយសមធម៌ តាមរយៈការបង្កើនថវិកាអោយបានច្រើនដល់ការអប់រំមូលដ្ឋាន (ការអប់រំកំរិតបឋមសិក្សា និងកំរិតមធ្យមសិក្សាបឋមភូមិ) និងការផ្តល់នូវប្រាក់ឧបត្ថម្ភចំពោះអ្នក ដែលគ្មានលទ្ធភាពចំណាយលើការរៀនសូត្រ។ ក្រៅពីនេះ រាជរដ្ឋាភិបាលនឹងត្រូវលើកកំពស់ការចូលរួមពីសហគមន៍ និងពីមាតាបិតាសិស្សឱ្យបានច្រើនជាងមុន នៅក្នុងការគ្រប់គ្រងសេវាអប់រំ តាមរយៈសមាគមមាតាបិតាសិស្ស និងគ្រូបង្រៀន ហើយនិងសមាគមផ្សេងៗ ដែលមានលក្ខណៈដូចគ្នានេះ។
- ផ្តោតការយកចិត្តទុកដាក់ដល់សិស្សានុសិស្សដែលចេញពីគ្រួសារក្រីក្រ ដើម្បីធានានូវឱកាសស្មើគ្នា តាមរយៈការផ្តល់ជាមធ្យោបាយធ្វើដំណើរ និងអាហារូបករណ៍ ជាពិសេសសំរាប់កុមារី។ យុទ្ធសាស្ត្រជាអាទិភាពសំរាប់កាត់បន្ថយនូវកំរិតអនក្ខរកម្មរបស់យុវជនយុវនារីនៅប្រទេសកម្ពុជា ក្នុងរយៈពេលវែង គឺត្រូវយកចិត្តទុកដាក់ទៅលើការសិក្សានៅតាមសាលា ដែលធានានូវសិទ្ធរបស់កុមារកម្ពុជាទាំងអស់ ក្នុងការបញ្ចប់ការសិក្សាកំរិតមូលដ្ឋានប្រកបដោយគុណភាពល្អ។ អាទិភាពនឹងត្រូវផ្តល់ទៅលើការកាត់បន្ថយឱ្យបានបន្តិចម្តងៗ នូវចំនួនសាលាដែលមិនមានលក្ខណៈពេញលេញ ក្នុងរយៈពេលមធ្យម ដោយកាត់បន្ថយនូវការបង្រៀនថ្នាក់គួប តាមមធ្យោបាយដូចខាងក្រោម:
    - បែងចែកនូវខ្ទង់ថវិកាប្រតិបត្តិរបស់សាលា ដោយផ្អែកទៅលើរូបមន្ត ដែលផ្តល់ផលប្រយោជន៍ទៅឱ្យសាលាតូចៗ។

- ផ្តល់អាទិភាពទៅឱ្យសាលាណា ដែលមិនមានគ្រប់កំរិតសិក្សា ក្នុងកម្មវិធីស្ថាបនាអាគារសិក្សា ។
- បញ្ចូលការលើកទឹកចិត្តបែបថ្មី ចំពោះការបង្រៀនថ្នាក់គួប និងចំពោះអ្នកធ្វើការនៅតំបន់ដាច់ស្រយាល ។
- ធ្វើការងារជាបឋម លើកម្មវិធីសិក្សាសំរាប់បណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់គួប ។

- ការលើកកំពស់កំនែលំអគុណភាព និងប្រសិទ្ធភាព តាមរយៈការបង្កើនប្រាក់បៀវត្សរ៍គ្រប់គ្រាន់ និងចំណាយប្រតិបត្តិដែលមិនមែនជាប្រាក់បៀវត្សរ៍ ដោយតំរង់ទិសទៅរកការផ្គត់ផ្គង់សំភារៈឧបទ្ទេស និងបំពាក់បរិក្ខារដល់ផ្នែកអប់រំមូលដ្ឋាន ការអភិវឌ្ឍន៍គ្រូបង្រៀន និងកំនែទំរង់តាមដានគុណភាព និងអភិបាលកិច្ច ។ វិធានការដ៏មានប្រសិទ្ធភាព នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការដាក់ពង្រាយបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀនឱ្យមានប្រសិទ្ធភាពជាងមុន ។ អាទិភាពដទៃទៀត មានដូចជា (i) ពង្រីក និងកែលំអការថែទាំ និងការអប់រំកុមារតូចៗដើម្បីបង្កើននូវភាពត្រៀមខ្លួនជាស្រេចក្នុងការចូលរៀននៅសាលា ផលិតភាព និងប្រសិទ្ធភាពក្នុងការបង្រៀន និង (ii) បង្កើតវិធីសាស្ត្រ និងសំភារៈបង្រៀនដែលសមស្របទៅតាមអាយុ ដើម្បីធានាថាសិស្សានុសិស្សរីករាយនឹងបទពិសោធន៍ក្នុងការរៀនសូត្ររបស់ពួកគេ នៅឯសាលារៀន និងការចំរើនឡើងពីមួយថ្នាក់ទៅមួយថ្នាក់ទៀត ដោយមិនមានការត្រួតថ្នាក់រហូតដល់ពួកគេបញ្ចប់ការសិក្សាកំរិតមូលដ្ឋាន ។
- ពន្លឿនដំណើរការវិមជ្ឈការ ដោយបង្កើនស្វ័យភាពក្នុងការគ្រប់គ្រងគ្រឹះស្ថានអប់រំទាំងអស់ ពង្រីកការផ្ទេរសិទ្ធិអំណាចឱ្យដល់ខេត្តនិងស្រុក ក្នុងការធ្វើផែនការនិងការគ្រប់គ្រង ដោយផ្សារភ្ជាប់ជាមួយនឹងគំនិតផ្តួចផ្តើមរបស់ឃុំ/សង្កាត់ លើការអប់រំសំរាប់ទាំងអស់គ្នា និងដោយពង្រឹងនូវប្រព័ន្ធតាមដាន និងសាវនកម្មដែលមានលក្ខណៈវិមជ្ឈការនោះ ។

### ២.២.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក២

រូប ២.២.១១ បង្ហាញពីការបែងចែកតាមតំបន់នៃសូចនាករ គអសក២ តាមខេត្ត/ក្រុង ។ តំលៃនីមួយៗតំណាងអោយសន្ទស្សន៍មានទំងន់មធ្យមស្មើគ្នា (equally weighted index) នៃសូចនាករ ដែលមានទិន្នន័យទាំងអស់របស់ គអសក២ ។ សន្ទស្សន៍រួមរបស់ គអសក២ បង្ហាញតាមរយៈផែនទី ដែលបែងចែកតាមស្ថានភាពរបស់ប្រទេស ដែលទាក់ទងទៅនឹងការអប់រំមូលដ្ឋានជាទូទៅ ។ លទ្ធផលនៃលំហាត់នេះ អនុញ្ញាតិឱ្យយើងធ្វើចំណាត់ថ្នាក់ខេត្តជាបីលំដាប់ថ្នាក់ ទៅតាមលំដាប់សន្ទស្សន៍របស់ខេត្តទាំងនោះ ។ ខេត្ត/ក្រុងណា ដែលមានពណ៌បៃតង គឺជាខេត្តដែលមានលទ្ធភាពប្រសើរជាងគេក្នុងការសំរេចចំណុចដៅ ។ ចំណែកពណ៌លឿង និងពណ៌ក្រហម គឺជាខេត្ត/ក្រុងទាំងឡាយណា ដែលមានលទ្ធភាពមធ្យម និងអន់ជាងគេតាមលំដាប់ ក្នុងការសំរេចចំណុចដៅ ។ បណ្តាខេត្ត/ក្រុង ដែលមានពណ៌ក្រហម គឺច្រើនតែស្ថិតនៅតំបន់ភាគខាងជើង និងភាគនិរតីនៃប្រទេស ។

## រូប ២.២.១១: សន្ទស្សន៍រួមនៃ គអសក២ តាមខេត្ត/ក្រុង




សំគាល់: សន្ទស្សន៍របស់ គអសក២ គឺជាមធ្យមភាគដែលមានទំងន់ស្មើគ្នា ទៅតាមលំដាប់ខេត្តនីមួយៗលើអថេរនៃសូចនាករទាំង១០ របស់ គអសក២ (សូចនាករ: ២.១, ២.២, ២.៣, ២.៤, ២.៥, ២.៦, ២.៧, ២.៨, ២.៩ និង ២.១០) ។

# តារាង ២.២.៣: សន្ទស្សន៍រួមនៃ គអសក២ តាមខេត្ត/ក្រុង

| លេខ កូដ | ខេត្ត-ក្រុង | សន្ទស្សន៍នៃសូចនាករ | | | | | | | | | | | | | | សន្ទស្សន៍ គអសក២ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២.១[ក] | ២.២[ក] | ២.២.១[គ] | ២.២.២[ក] | ២.៣[ក] | ២.៣.១[គ] | ២.៣.២[ក] | ២.៤[ខ] | ២.៥[គ] | ២.៦[គ] | ២.៧[គ] | ២.៨[ខ] | ២.៩[គ] | ២.១០[គ] | |
| ១២ | ភ្នំពេញ | ០,៨៧២ | ០,៩៥៦ | ០,៩៤៥ | ០,៩៦០ | ១,០០០ | ១,០០០ | ១,០០០ | ១,០០០ | ១,០០០ | ១,០០០ | ១,០០០ | ១,០០០ | ០,៨៥៥ | ០,៩៤០ | **០,៩៦២** |
| ០៨ | កណ្ដាល | ០,៩២៨ | ០,៨៨៤ | ០,៨០៧ | ០,៩៣៦ | ០,៥៦១ | ០,៥៨១ | ០,៥៣២ | ០,៧៧១ | ០,៨៦៣ | ០,៨៤២ | ០,៥៩៣ | ០,៩២៦ | ០,៨១៣ | ០,៦១០ | **០,៧៧៩** |
| ២១ | តាកែវ | ០,៩៥៧ | ០,៩២៨ | ០,៨៤៨ | ០,៩៨៤ | ០,៦៨៥ | ០,៧៨៨ | ០,៥៥៨ | ០,៥៧១ | ០,៩៣៤ | ០,៩២៥ | ០,៧៨៩ | ០,៨៧៨ | ០,៨០៨ | ០,២៣៩ | **០,៧៧១** |
| ០៧ | កំពត | ០,៩១៤ | ០,៩១៧ | ០,៨៩៤ | ០,៩៣០ | ០,៧២៤ | ០,៨០១ | ០,៦២៦ | ០,៦៩១ | ០,៨២៩ | ០,៨២២ | ០,៦៣៣ | ០,៨៦៩ | ០,៧៣៧ | ០,៥៣៧ | **០,៧៦៧** |
| ០៣ | កំពង់ចាម | ០,៩៣៦ | ០,៩៧៤ | ០,៩២៩ | ១,០០០ | ០,៤៥៤ | ០,៤៨១ | ០,៤១៧ | ០,៦៩០ | ០,៦៦៩ | ០,៦៣២ | ០,៣៨៩ | ០,៨៨២ | ០,៨៧៥ | ០,៧១៤ | **០,៧២២** |
| ១៨ | ក្រុងព្រះសីហនុ | ០,៩០៣ | ១,០០០ | ០,៩៨៧ | ០,៩៩៩ | ០,៤២០ | ០,៤៣៨ | ០,៣៩៩ | ០,៧៨៤ | ០,៦១២ | ០,៥៧២ | ០,៤២៦ | ០,៩០៦ | ០,៨០២ | ០,៥៩៨ | **០,៧០២** |
| ០២ | បាត់ដំបង | ០,៧៥៥ | ០,៩២៨ | ០,៨៦៣ | ០,៩៧១ | ០,២៩៦ | ០,២៨១ | ០,៣០៩ | ០,៧២៦ | ០,៥៥៦ | ០,៥៤២ | ០,៤០១ | ០,៨៦១ | ០,៨៦១ | ១,០០០ | **០,៦៩៣** |
| ០៤ | កំពង់ឆ្នាំង | ០,៩០៣ | ០,៩៦៤ | ០,៩២៦ | ០,៩៨៥ | ០,៣២១ | ០,៣៧៤ | ០,២៦០ | ០,៦១៦ | ០,៧៣៨ | ០,៦៨៧ | ០,៥២៤ | ០,៧៨៩ | ០,៨៧២ | ០,៤១៤ | **០,៦៨៣** |
| ២០ | ស្វាយរៀង | ១,០០០ | ០,៩៦៦ | ០,៩២៩ | ០,៩៨៨ | ០,៥២៤ | ០,៦៥២ | ០,៣៦៨ | ០,៦៩៣ | ០,៧៣១ | ០,៧១៦ | ០,៤៥៥ | ០,៨៩២ | ០,៧៣១ | ០,១២៣ | **០,៦៨៣** |
| ២៣ | ក្រុងកែប | ០,៨៥៦ | ០,៩៥១ | ០,៩៧០ | ០,៩២៣ | ០,៤១៧ | ០,៣៩៧ | ០,៤៣៤ | ០,៥៥៧ | ០,៦០០ | ០,៥៥៤ | ០,៤៣៨ | ០,៧០៧ | ០,៦៩០ | ០,៧៨៤ | **០,៦៥៥** |
| ១៥ | ពោធិ៍សាត់ | ០,៩៧៧ | ០,៩៦៦ | ១,០០០ | ០,៩៣៥ | ០,២១៧ | ០,២៤៣ | ០,១៨៣ | ០,៦២៤ | ០,៦០០ | ០,៥៣៧ | ០,៤០៨ | ០,៩៣១ | ០,៨២៦ | ០,៤៥០ | **០,៦៥៤** |
| ០៦ | កំពង់ធំ | ០,៧៤៣ | ០,៧៩៨ | ០,៧១០ | ០,៨៦២ | ០,៣៨៦ | ០,៤១២ | ០,៣៥៣ | ០,៥៣៦ | ០,៥៩០ | ០,៥៧៧ | ០,៤២៤ | ០,៧២២ | ១,០០០ | ០,៧៣៦ | **០,៦៥១** |
| ០១ | បន្ទាយមានជ័យ | ០,៧០៤ | ០,៨៨៤ | ០,៨២២ | ០,៩២៤ | ០,២៣៤ | ០,២៤២ | ០,២២០ | ០,៧៨៦ | ០,៦៦៣ | ០,៥៩៩ | ០,៣៦៨ | ០,៨២៨ | ០,៧៩៥ | ០,៦៤៣ | **០,៦៥០** |
| ១០ | ក្រចេះ | ០,៧០០ | ០,៨០៦ | ០,៦៦៤ | ០,៩១៥ | ០,៣៦១ | ០,៣៥៣ | ០,៣៦៩ | ០,៥៣៣ | ០,៥៤៦ | ០,៥០០ | ០,៣៩៧ | ០,៦២៩ | ០,៩៤៦ | ០,៩២៧ | **០,៦៣៥** |
| ១៤ | ព្រៃវែង | ០,៩៧៧ | ០,៩២៥ | ០,៨៩៨ | ០,៩៣៦ | ០,៤២៨ | ០,៥១៨ | ០,៣២១ | ០,៦៧៩ | ០,៥៩៣ | ០,៥៥២ | ០,៣៨២ | ០,៧២១ | ០,៦៨៨ | ០,១៦៩ | **០,៦១១** |
| ០៥ | កំពង់ស្ពឺ | ១,០០០ | ០,៩៣៣ | ០,៩០៨ | ០,៩៤៧ | ០,៣៣៨ | ០,៤០៩ | ០,២៥៤ | ០,៥២៤ | ០,៦០៨ | ០,៥៨៧ | ០,៣៧៤ | ០,៦៩៤ | ០,៨០៤ | ០,១៥៦ | **០,៦០២** |
| ១៧ | សៀមរាប | ០,៤៩៨ | ០,៩៦៤ | ០,៩៤៩ | ០,៩៦៤ | ០,២៨២ | ០,៣០៥ | ០,២៥០ | ០,៥៣៣ | ០,៥៩៥ | ០,៥៥០ | ០,៤៥៥ | ០,៦៦១ | ០,៧៩៩ | ០,៦៥២ | **០,៥៩៥** |
| ២៤ | ក្រុងប៉ៃលិន | ០,២៥៩ | ០,៥០៦ | ០,៤៧៨ | ០,៥២៩ | ០,០៩០ | ០,០៨៦ | ០,០៩០ | ០,៣៨១ | ០,៨៨៦ | ០,៩៥៥ | ០,៨២៣ | ០,៦៦៧ | ០,៨៥៩ | ០,០១៥ | **០,៥៤៤** |
| ០៩ | កោះកុង | ០,៦៥២ | ០,៤៥៧ | ០,៣២០ | ០,៥៦៦ | ០,១៣០ | ០,១៦៤ | ០,០៨៧ | ០,៣១៣ | ០,៣៩៤ | ០,៣៥៤ | ០,២៥២ | ០,៤៤២ | ០,៧៦១ | ០,៣២៦ | **០,៤០៨** |
| ១៩ | ស្ទឹងត្រែង | ០,៧២០ | ០,៧៤៧ | ០,៦៩៩ | ០,៧៧៧ | ០,០៩៦ | ០,០៦៣ | ០,១៣១ | ០,០០០ | ០,៣៦០ | ០,៣១៩ | ០,២៧២ | ០,០០០ | ០,៧៣៦ | ០,៧១៩ | **០,៣៩៧** |
| ១៣ | ព្រះវិហារ | ០,៥២១ | ០,៧១១ | ០,៧១៦ | ០,៦៩៩ | ០,០៤៥ | ០,០៤៣ | ០,០៤៥ | ០,០៩០ | ០,២៣៤ | ០,២១៨ | ០,១០៧ | ០,៣៧២ | ០,៨២៦ | ០,៤៩៣ | **០,៣៦២** |
| ២២ | ឧត្ដរមានជ័យ | ០,៧៣៣ | ០,៨៦០ | ០,៧៥៨ | ០,៩៣៣ | ០,០៣៤ | ០,០៥០ | ០,០១២ | ០,១២៦ | ០,២៩៥ | ០,២៤៤ | ០,១៧២ | ០,១២១ | ០,៦៨៥ | ០,០០០ | **០,៣២៧** |
| ១៦ | រតនគិរី | ០,០២៩ | ០,០០០ | ០,០០០ | ០,០០០ | ០,០០០ | ០,០០០ | ០,០០០ | ០,៤៩៩ | ០,១១១ | ០,១១៦ | ០,០៦៨ | ០,៤៥៨ | ០,០០០ | ០,២៩១ | **០,១៥៣** |
| ១១ | មណ្ឌលគិរី | ០,០០០ | ០,១៧៣ | ០,០៨១ | ០,២៤៩ | ០,០៣៧ | ០,០២៧ | ០,០៤៧ | ០,៣៨៣ | ០,០០០ | ០,០០០ | ០,០០០ | ០,០៩៦ | ០,៣៤៧ | ០,៤៥៥ | **០,១៤៩** |

ប្រភព: [ក] - ក្រសួងអប់រំ យុវជន និង កីឡា ២០០២ក។ [ខ] - ទិន្នន័យមូលដ្ឋាននៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៩។ [គ] - ទិន្នន័យមូលដ្ឋាននៃស្ថិតិនិងអាំងឌីការទ័រអប់រំ ឆ្នាំ២០០១/២០០២។

## ២.៣ គោលដៅទី៣: លើកកំពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

គោលដៅទី ៣ នេះ មានគោលបំណងលុបបំបាត់នូវភាពខុសគ្នានៃយេនឌ័រ ទាំងនៅក្នុងជីវភាពសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ។

### ២.៣.១ សូចនាករ និងចំណុចដៅនៃ គអសក៣

តារាង ២.៣.១ បានបង្ហាញឱ្យឃើញនៅក្នុងជួរឈរខាងឆ្វេង គឺជាចំណុចដៅ និងសូចនាករដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ រីឯជួរឈរខាងស្តាំ បង្ហាញពីចំណុចដៅ និងសូចនាករដែលបានជ្រើសរើសដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗរួចមក ។

**តារាង ២.៣.១: មូលដ្ឋានីយកម្មនៃ គអស៣ ទៅជា គអសក៣**

| គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលទី៣ | គអសក៣ |
|---|---|
| **ចំណុចដៅទី៤:** លុបបំបាត់គំលាតយេនឌ័រនៅកំរិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ឱ្យបាននៅឆ្នាំ២០០៥ និងគ្រប់កំរិតទាំងអស់នៃវិស័យអប់រំមិនឱ្យហួសពីឆ្នាំ២០១៥ | **ចំណុចដៅរួមទី៥:** កាត់បន្ថយឱ្យបាននូវគំលាតយេនឌ័រ នៅកំរិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា |
| **សូចនាករ៩:** ផលធៀបរវាងសិស្សស្រី និងសិស្សប្រុសនៅកំរិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា (១) | **សូចនាករ៣.១:** ផលធៀបរវាងសិស្សស្រី និងសិស្សប្រុសនៅកំរិតមធ្យមសិក្សាទុតិយភូមិ |
| | **សូចនាករ៣.២:** ផលធៀបរវាងនិស្សិតស្រី និងប្រុសនៅឧត្តមសិក្សា |
| **សូចនាករ១០:** ផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរស អាយុ ១៥-២៤ឆ្នាំ | **សូចនាករ៣.៣:** ផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរស អាយុ ១៥-២៤ឆ្នាំ |
| | **សូចនាករ៣.៤:** ផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរស អាយុ ២៥-៤៤ឆ្នាំ |
| | **ចំណុចដៅរួមទី៦:** លុបបំបាត់គំលាតយេនឌ័រ សំរាប់ការងារមានប្រៀវត្សរ៍ នៅគ្រប់វិស័យសេដ្ឋកិច្ច |
| **សូចនាករ១១:** បមាណភាគនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យមិនមែនកសិកម្ម | **សូចនាករ៣.៥:** សមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យកសិកម្ម (ប្រភេទវិស័យទី១) |
| | **សូចនាករ៣.៦:** សមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យឧស្សាហកម្ម (ប្រភេទវិស័យទី២) |
| | **សូចនាករ៣.៧:** សមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យសេវាកម្ម (ប្រភេទវិស័យទី៣) |
| | **ចំណុចដៅរួមទី៧:** លុបបំបាត់គំលាតយេនឌ័រនៅក្នុងកិច្ចការរដ្ឋាភិបាល |
| **សូចនាករ១២:** សមាមាត្រអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ | **សូចនាករ៣.៨:** សមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ |
| | **សូចនាករ៣.៩:** សមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងព្រឹទ្ធសភា |
| | **សូចនាករ៣.១០:** សមាមាត្រនៃស្ត្រីជារដ្ឋមន្ត្រី |
| | **សូចនាករ៣.១១:** សមាមាត្រនៃស្ត្រីជារដ្ឋលេខាធិការ |
| | **សូចនាករ៣.១២:** សមាមាត្រនៃស្ត្រីជាអនុរដ្ឋលេខាធិការ |
| | **សូចនាករ៣.១៣:** សមាមាត្រនៃស្ត្រីជាអភិបាលខេត្ត |

| | |
|---|---|
| | **សូចនាករ៣.១៤:** សមាមាត្រនៃស្ត្រីជាអភិបាលខេត្តរង |
| | **សូចនាករ៣.១៥:** សមាមាត្រនៃស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ |
| | **ចំណុចដៅរួមទី៨:** កាត់បន្ថយគ្រប់ទំរង់អំពើហិង្សាចំពោះស្ត្រី និងកុមារ |
| | **សូចនាករ៣.១៦:** ភាគរយនៃប្រជាជនដែលដឹងថាអំពើហិង្សាចំពោះស្ត្រី គឺជាអាកប្បកិរិយាខុសឆ្គង និងជាបទឧក្រិដ្ឋ |
| | **សូចនាករ៣.១៧:** ភាគរយករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបាន ពិគ្រោះយោបល់ដោយបុគ្គលិកដែលមានជំនាញ |
| | **សូចនាករ៣.១៨:** ច្បាប់ប្រឆាំងគ្រប់ទំរង់អំពើហិង្សាចំពោះស្ត្រី និង កុមារ ដែលត្រូវបានតាក់តែងឡើង និងអនុវត្តដោយអនុលោមទៅ តាមបទដ្ឋាន និងតំរូវការអន្តរជាតិ |
| | **សូចនាករ៣.១៩:** ប្រមូលទិន្នន័យស្ថិតិប្រចាំឆ្នាំដើម្បីតាមដានអំពើហិង្សា ចំពោះស្ត្រី |
| | **សូចនាករ៣.២០:** បង្កើតផែនការទប់ស្កាត់ និងអនុវត្ត |

(១) សូចនាករ៩ ដែលមាននៅក្នុងបញ្ជី គអស ត្រូវបានភ្ជាប់ទៅនឹងគោលដៅទី៣ ។ ប៉ុន្តែអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច បានសំរេចដាក់ផ្នែកខ្លះនៃចំណុចដៅទី៤ និងសូចនាករ៩ ដែលពាក់ព័ន្ធទៅនឹងការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិឱ្យមកនៅជាមួយ គអសក២ វិញ ដោយសារគោលដៅនេះមានការពាក់ព័ន្ធនិងមានលក្ខណៈរួមទៅនឹងគោលដៅដែលទាក់ទងនឹងយេនឌ័រ ។

តារាង ២.៣.២ បង្ហាញនូវតំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករនៃ គអសក៣ សំរាប់ឆ្នាំ២០០៥ ២០១០ និង២០១៥ ។ តំលៃនៃឆ្នាំមូលដ្ឋានរបស់សូចនាករនីមួយៗ មានលក្ខណៈខុសៗគ្នា ដោយប្រែប្រួលទៅតាមទិន្នន័យដែលមាន ។

**តារាង ២.៣.២: តំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករនៃ គអសក៣ តាមលំដាប់ឆ្នាំ**

| សូចនាករ | ទិន្នន័យមូលដ្ឋាន | | ចំណុចដៅ | | |
|---|---|---|---|---|---|
| | តំលៃ | ឆ្នាំ | ២០០៥ | ២០១០ | ២០១៥ |
| ៣.១ ផលធៀបរវាងសិស្សស្រី និងប្រុសនៅកំរិតមធ្យមសិក្សាទុតិយភូមិ | ៤៨ | ២០០១ | ៥៥ | ៨០ | ១០០ |
| ៣.២ ផលធៀបរវាងនិស្សិតស្រី និងប្រុសនៅឧត្តមសិក្សា | ៣៨ | ២០០១ | ៥០ | ៧០ | ៨៥ |
| ៣.៣ ផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរស អាយុ ១៥-២៤ឆ្នាំ | ៨៧ | ១៩៩៨ | ៩៥ | ១០០ | ១០០ |
| ៣.៤ ផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរស អាយុ ២៥-៤៤ឆ្នាំ | ៧៨ | ១៩៩៨ | ៨៥ | ១០០ | ១០០ |
| ៣.៥ សមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យកសិកម្ម (ប្រភេទវិស័យទី១) | ៣៥ | ១៩៩៨ | ៥០ | ៥០ | ៥០ |
| ៣.៦ សមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យឧស្សាហកម្ម (ប្រភេទវិស័យទី២) | ៤៤ | ១៩៩៨ | ៥០ | ៥០ | ៥០ |
| ៣.៧ សមាមាត្រនៃស្ត្រីធ្វើការងារមានប្រៀវត្សរ៍ក្នុងវិស័យសេវាកម្ម (ប្រភេទវិស័យទី៣) | ២១ | ១៩៩៨ | ៣០ | ៣៧ | ៥០ |
| ៣.៨ សមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ | ១២ | ២០០៣ | ១៧ | ២៤ | ៣០ |
| ៣.៩ សមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងព្រឹទ្ធសភា | ១៣ | ២០០៣ | ១៧ | ២៤ | ៣០ |
| ៣.១០ សមាមាត្រនៃស្ត្រីជារដ្ឋមន្ត្រី | ៨ | ២០០៣ | ៩ | ១២ | ១៥ |

| | | | | | |
|---|---|---|---|---|---|
| ៣.១១ សមាមាត្រនៃស្ត្រីជារដ្ឋលេខាធិការ | ៦ | ២០០៣ | ៨ | ១៥ | ១៨ |
| ៣.១២ សមាមាត្រនៃស្ត្រីជាអនុរដ្ឋលេខាធិការ | ៥ | ២០០៣ | ៨ | ១៧ | ២០ |
| ៣.១៣ សមាមាត្រនៃស្ត្រីជាអភិបាលខេត្ត | 0 | ២០០៣ | ៣ | ៦ | ១០ |
| ៣.១៤ សមាមាត្រនៃស្ត្រីជាអភិបាលខេត្តរង | ១ | ២០០៣ | ៤ | ៨ | ១៥ |
| ៣.១៥ សមាមាត្រនៃស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ | ៨ | ២០០៣ | ៨ | ១៥ | ២៥ |
| ៣.១៦ ភាគរយនៃប្រជាជនដែលដឹងថាអំពើហិង្សាចំពោះស្ត្រីគឺជាអាកប្បកិរិយាខុសឆ្គង និងជាបទឧក្រិដ្ឋ | គ្មាន | | ២៥ | ៥០ | ១០០ |
| ៣.១៧ ភាគរយនៃករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានពិគ្រោះយោបល់ដោយបុគ្គលិកដែលមានជំនាញ | គ្មាន | | ២០ | ៥០ | ១០០ |
| ៣.១៨ ច្បាប់ប្រឆាំងគ្រប់ទំរង់អំពើហិង្សាចំពោះស្ត្រី និងកុមារ ដែលនឹងត្រូវតាក់តែងឡើង និងអនុវត្តដោយអនុលោមទៅតាមនិយាមអន្តរជាតិ | | | ✓ | | |
| ៣.១៩ ប្រមូលទិន្នន័យស្ថិតិប្រចាំឆ្នាំដើម្បីតាមដានអំពើហិង្សាចំពោះស្ត្រី | | | ✓ | | |
| ៣.២០ បង្កើតផែនការទប់ស្កាត់ និងអនុវត្ត | | | ✓ | | |

### ២.៣.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៣

ផលធៀបរវាងសិស្សស្រី និងប្រុសនៅកំរិតមធ្យមសិក្សាទុតិយភូមិ បានថយចុះពី ៥៦% នៅឆ្នាំ១៩៩៧ មក ៤៨% នៅឆ្នាំ២០០១។ នៅទីក្រុងភ្នំពេញ សូចនាករនេះបានធ្លាក់ចុះពី ៧២.២% នៅឆ្នាំ១៩៩៧ មក ៦៥.៤% នៅឆ្នាំ២០០១ ខណៈពេលដែលនៅតំបន់ជនបទ សូចនាករនេះបានធ្លាក់ចុះពី ៤៣.៩% មកនៅត្រឹម ៣៧% ក្នុងរយៈពេលដូចគ្នា។ ផ្ទុយមកវិញនៅតំបន់ទីក្រុង/ទីប្រជុំជន អត្រានេះបានកើនឡើងពី ៥៥.៦% នៅឆ្នាំ១៩៩៧ រហូតដល់ ៥៧.៨% នៅឆ្នាំ២០០១ ក្នុងរយៈពេលដូចគ្នានេះ។ តាមនិន្នាការកន្លងមក ប្រទេសកម្ពុជា មិនទំនងជាអាចសំរេចបាននូវចំណុចដៅ ស្តីអំពីសមភាពយេនឌ័រនៅក្នុងកំរិតមធ្យមសិក្សាទុតិយភូមិ មុនដំណាច់ឆ្នាំ២០១៥ បានទេ។

**រូប ២.៣.១: និន្នាការ និងចំណុចដៅនៃផលធៀបរវាងសិស្សស្រី និងប្រុសនៅកំរិតមធ្យមសិក្សាទុតិយភូមិ**




ប្រភព: ក្រសួងអប់រំ យុវជន និងកីឡា, ស្ថិតិអប់រំ និងអាំងឌីកាទ័រ ១៩៩៦/៩៧, ១៩៩៧/៩៨, ១៩៩៨/៩៩, ១៩៩៩/០០, ២០០០/០១, ២០០១/០២។

ផលធៀបរវាងនិស្សិតស្រី និងប្រុសនៅឧត្តមសិក្សា បានកើនឡើងយ៉ាងលឿននៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះគឺពី ១៩% នៅឆ្នាំ១៩៩៧ រហូតដល់ ៣៧,៨% នៅឆ្នាំ២០០១។ ការផ្លាស់ប្តូរគួរឱ្យកត់សំគាល់ បានកើនឡើងចាប់តាំងពីឆ្នាំ១៩៩៩ គឺចាប់ពីមានការកែទំរង់នៃវិស័យអប់រំដោយមាន ការបង្កើតឡើងនូវគ្រឹះស្ថានឯកជន។ និន្នាការកន្លងមកបានបង្ហាញថាសូចនាករនៃ គអស ដែលស្តីអំពីសមភាពយេនឌ័រ នៅកំរិតឧត្តមសិក្សាអាចនឹងឈានទៅដល់ចំណុចដៅនៅឆ្នាំ២០១៥។ តែទោះជាយ៉ាងណាក៏ដោយ ផ្នែកទៅលើគំលាតដ៏ធំនៃយេនឌ័រនៅកំរិតមធ្យមសិក្សាទុតិយភូមិ ជាហេតុផលដែលត្រូវតែប្រយ័ត្នប្រយែងក្នុងការសន្និដ្ឋាននេះ។

**រូប ២.៣.២: និន្នាការ និងចំណុចដៅនៃផលធៀបរវាងនិស្សិតស្រី និងប្រុសនៅឧត្តមសិក្សា**




ប្រភព: ក្រសួងអប់រំ យុវជន និងកីឡា, ស្ថិតិអប់រំឧត្តមសិក្សា ១៩៩៦/៩៧, ១៩៩៧/៩៨, ១៩៩៨/៩៩, ១៩៩៩/០០, ២០០០/០១។

ទោះបីជាអត្រាអក្ខរកម្ម ក្នុងចំណោមមនុស្សពេញវ័យមានកំរិតទាបក៏ដោយ ក៏កម្ពុជាបានបន្តកត់ត្រានូវភាពប្រសើរឡើងនៃគំលាតយេនឌ័រនៅក្នុងអត្រាអក្ខរកម្មយុវវ័យ។ ផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរសអាយុ ១៥-២៤ឆ្នាំ បានកើនឡើងបន្តិចពី ៨៧% ទៅ ៨៨% រវាងឆ្នាំ១៩៩៣ និងឆ្នាំ១៩៩៩ នៅខណៈដែលផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរសអាយុពី ២៥-៤៤ឆ្នាំ បានកើនឡើងពី ៧៨% ដល់ ៨០% ក្នុងចន្លោះឆ្នាំ១៩៩៨ និង ១៩៩៩។ ដូច្នេះប្រទេសកម្ពុជា រំពឹងថានឹងអាចសំរេចបាននូវសមភាពយេនឌ័រ នៅដំណាច់ឆ្នាំ២០១០។

ការងារមានប្រាក់បៀវត្សរ៍នៅក្នុងវិស័យកសិកម្ម បានកើនឡើងទាំងក្នុងចំណោមស្ត្រី និងបុរស។ សមាមាត្រស្ត្រីធ្វើការងារមានប្រាក់បៀវត្សរ៍ក្នុងវិស័យកសិកម្ម បានកើនឡើងពី ៣៤,៩% ដល់ ៥០,៧% រវាងឆ្នាំ ១៩៩៨ និងឆ្នាំ២០០១។ ការកើនឡើងនេះអាចពាក់ព័ន្ធទៅនឹងការរីកដុះដាលទីផ្សារផ្នែកផលិតកម្មកសិកម្ម ដែលមានទ្រង់ទ្រាយធំជាងមុន ការកើនឡើងនូវភាពគ្មានដីធ្លី កំណើនប្រជាជនខ្ពស់ និងការកើនឡើងនូវចំណាកស្រុកទៅរកតំបន់ដែលអំណោយផលផ្នែកកសិកម្ម។

ការអង្កេតពីកំលាំងពលកម្ម ឆ្នាំ២០០១ បានបង្ហាញថាបុរសមានការចូលរួមនៅក្នុងពលកម្ម ដែលមានប្រាក់បៀវត្សរ៍មានចំនួនច្រើនជាងស្ត្រី។ សមាមាត្រស្ត្រីនៅក្នុងការងារដែលមានប្រាក់បៀវត្សរ៍ បានកើនឡើងគួរឱ្យកត់សំគាល់ ដែលភាគច្រើនកើនឡើងនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ។ បមាណភាគស្ត្រីធ្វើការងារមានប្រាក់បៀវត្សរ៍ក្នុងវិស័យឧស្សាហកម្ម នៅឆ្នាំ២០០១ បានកើនឡើងដល់ ៦០,៨% ដែលនៅឆ្នាំ១៩៩៨ មានតែ ៤៣,៧% ប៉ុណ្ណោះ។ បមាណភាគស្ត្រីធ្វើការងារមានប្រាក់បៀវត្សរ៍ក្នុងវិស័យសេវាកម្ម បានកើនឡើងបន្តិចពី ២១% នៅឆ្នាំ

១៩៩៨ ដល់ ២៥% ឆ្នាំ២០០១។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ថា វាមានការលំបាកក្នុងការប្រើប្រាស់ សូចនាករទាំងនេះ ដើម្បីប៉ាន់ស្មានទៅលើសមភាពយេនឌ័រ ដោយសារតែពុំមានពត៌មានស្តីអំពីភាពខុសគ្នាខាងយេនឌ័រទៅតាមប្រភេទនៃការងារ រឺក៏ក្នុងល័ក្ខខ័ណ្ឌផ្សេងៗនៃការងារ។

សមាមាត្រស្ត្រីដែលមានអសនៈនៅក្នុងរដ្ឋសភា បានកើនពី ៦% នៅឆ្នាំ១៩៩៣ រហូតដល់ ១២% នៅឆ្នាំ ២០០៣។ ប្រមាណជា ១៣% នៃអសនៈនៅក្នុងព្រឹទ្ធសភាបច្ចុប្បន្ន គឺកាន់កាប់ដោយស្ត្រី។ ប្រសិនបើនិន្នាការកន្លងមកនៅតែបន្ត សមាមាត្រស្ត្រីនៅក្នុងរដ្ឋសភានឹងអាចឡើងដល់ ១៩% នៅឆ្នាំ២០១៥ ដែលមានគំលាតក្រោមចំណុចដៅ ១១%។

**រូប ២.៣.៣: និន្នាការ និងចំណុចដៅនៃសមាមាត្រអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ**




ប្រភព: អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា បញ្ជីសមាជិកសភា ឆ្នាំ១៩៩៣ ១៩៩៨ និង ២០០១

នៅក្នុងវិស័យសាធារណៈ ប្រហែលជា ៣១% នៃនិយោជិកជាស្ត្រី។ នៅក្នុងតួនាទីជាន់ខ្ពស់នៃផ្នែកសាធារណៈមានប្រមាណជា៨% ប៉ុណ្ណោះដែលស្ត្រីជារដ្ឋមន្ត្រី ៦%ជារដ្ឋលេខាធិការ និង៥%ជាអនុរដ្ឋលេខាធិការ។ នៅថ្នាក់មូលដ្ឋាន មិនមានស្ត្រីណាម្នាក់កាន់មុខតំណែងជាអភិបាលខេត្ត និងអភិបាលស្រុកឡើយ គឺមានតែ ១% ប៉ុណ្ណោះដែលស្ត្រីកាន់មុខតំណែងជាអភិបាលខេត្តរង ហើយមានតែ ០,៥%ប៉ុណ្ណោះ ជាអភិបាលស្រុករង។ យ៉ាងណាក៏ដោយ អត្រាទាំងនេះអាចនឹងមានការប្រែប្រួល នៅពេលដែលរាជរដ្ឋាភិបាលថ្មីត្រូវបានបង្កើតឡើងក្នុងពេលដ៏ឆាប់ខាងមុខនេះ។

## ២.៣.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក៣

ផែនការយុទ្ធសាស្ត្រ *នារីរតនៈ ២០០១-២០០៥* គឺជាផែនការរយៈពេលប្រាំឆ្នាំ ដែលបានផ្តោតជាអាទិភាពទៅលើវិស័យបួនដែលរួមមាន សុខភាព អប់រំ កិច្ចការពារផ្លូវច្បាប់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ក្រៅពីវិស័យទាំងបួននេះ ការបញ្ជ្រាបយេនឌ័រក៏ត្រូវបានទទួលស្គាល់ថាជាវិស័យដ៏មានសារៈសំខាន់ នៅក្នុងការធានាថាបញ្ហាយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគោលនយោបាយ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។

រាជរដ្ឋាភិបាលកម្ពុជា កំពុងតែអនុវត្តយុទ្ធសាស្ត្រពាណិជ្ជកម្មគាំទ្រដល់អ្នកក្រីក្រ ហើយកំពុងតែត្រៀមខ្លួនចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ឱ្យបានមុនឆ្នាំ២០០៥។ រាជរដ្ឋាភិបាលក៏បានចុះហត្ថលេខាទៅ

លើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់អាស៊ាន (ASEAN) ដែលទាមទារនូវការបញ្ចុះអត្រាពន្ធគយបន្តិចម្តងៗ ឱ្យដល់កំរិតសូន្យរវាងប្រទេសអាស៊ានទាំង ១០។ យុទ្ធសាស្ត្រនេះមានឥទ្ធិពលយ៉ាងច្រើនចំពោះស្ត្រី ដោយសារតែ ឧស្សាហកម្មវាយនភ័ណ្ឌនាំចេញបានក្លាយទៅជាប្រភពដ៏សំខាន់ នៃការរកចំនូលជារូបិយប័ណ្ណបរទេស និងជាប្រភព ដ៏សំខាន់នៃការងាររបស់ស្ត្រីនៅក្នុងតំបន់ទីក្រុង/ទីប្រជុំជនផងដែរ។

ផែនការសកម្មភាពអភិបាលកិច្ច (GAP) ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលនៅឆ្នាំ២០០១ បានគ្រប ដណ្តប់ទៅលើវិស័យរួមចំនួនប្រាំ គឺកំនែទំរង់ខាងប្រព័ន្ធច្បាប់និងតុលាការ ហិរញ្ញវត្ថុសាធារណៈ កំនែទំរង់សេវាកម្ម ស៊ីវិល ការប្រឆាំងនឹងអំពើពុករលួយ និងសមធមិយេនឌ័រ។ ទាក់ទងទៅនឹងវិស័យទាំងនេះ ផែនការសកម្មភាព អភិបាលកិច្ចបានកំនត់នូវគោលដៅចំនួន៤គឺ (i)ការអនុវត្តន៍ និងសម្របសម្រួលកម្មវិធីផ្សេងៗ ដើម្បីលើកកំពស់ សិទ្ធិស្ត្រី (ii)ជំរុញអោយមានឥទ្ធិពលទៅលើកម្មវិធីផ្សេងៗ ក្នុងកំណែទំរង់រដ្ឋ ដើម្បីអោយកម្មវិធីទាំងនេះអាច ពិចារណាបានយ៉ាងទូលំទូលាយលើតំរូវការពិសេសរបស់ស្ត្រី (iii)ទទួលស្គាល់នូវការចូលរួមរបស់ស្ត្រីជាសមាជិក ពេញលេញរបស់សង្គម (iv)វិនិយោគនៅក្នុងតួនាទីមគ្គុទេសក៍របស់ស្ត្រី។ មានភាពជឿនលឿនមួយចំនួន ដែល សំរេចបានតាមមូលដ្ឋាន កំណត់ជាឯកត្ថ័ននានាដូចជា (១)ក្រុមប្រឹក្សាជាតិសំរាប់ស្ត្រីត្រូវបានបង្កើតឡើង ហើយ បាននឹងកំពុងតែដំណើរការ (២)ក្របខ័ណ្ឌច្បាប់ប្រឆាំងនឹងការជួញដូរស្ត្រីត្រូវបានរៀបចំចប់សព្វគ្រប់ (៣)ច្បាប់ ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារចំពោះស្ត្រីត្រូវបានបញ្ចប់សព្វគ្រប់ ហើយបានដាក់ជូនរដ្ឋសភា និង(៤)ចំនួនស្ត្រីជា អ្នកសំរេចចិត្តនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនបានកើនឡើង។ យ៉ាងណាក៏ដោយគួរបញ្ជាក់ថា យើងត្រូវ ការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដោយសារតែរដ្ឋសភាមិនបានជោគជ័យ នៅក្នុងការអនុម័តច្បាប់ស្តីអំពីអំពើ ហិង្សាក្នុងគ្រួសារ ហើយការចូលរួមរបស់ស្ត្រីក្នុងការសំរេចចិត្ត ក្នុងជីវភាពសាធារណៈ នៅមានកំរិតតិចតួចនៅ ឡើយ។

រីឯរដ្ឋបាលមូលដ្ឋានវិញ កម្ពុជាបានដំណើរការអនុវត្តន៍នូវប្រព័ន្ធវិមជ្ឈការចាប់តាំងពីឆ្នាំ១៩៩៥ មកម្ល៉េះ។ ប្រព័ន្ធនេះបានវិវត្តន៍ក្នុងរយៈកាលកន្លងមក ដោយមានការផ្លាស់ប្តូរមួយដ៏សំខាន់នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សា ឃុំ/សង្កាត់ នាខែកុម្ភៈ ឆ្នាំ២០០២។ បទពិសោធន៍វិមជ្ឈការកន្លងមកត្រូវបានចាត់ទុកថាទទួលបានជោគជ័យ ជា ពិសេស នៅក្នុងការបង្កើនការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសំរេចចិត្ត។ សមត្ថភាពរបស់ស្ត្រីដែលត្រូវបាន បោះឆ្នោតជ្រើសរើសថ្មីៗទាំងនេះ កំពុងត្រូវបានពង្រឹងដោយកម្មវិធីបណ្តុះបណ្តាល របស់ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន និងកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលនឹងត្រូវបានបន្តគាំទ្រដោយអ្នកផ្តល់ជំនួយ។ គណៈកម្មាធិការរៀបចំផែនការ និងថវិកាថ្មី មានសមាសភាពស្ត្រីម្នាក់ និងបុរសម្នាក់មកពីភូមិនិមួយៗ ដែលស្ថិត នៅក្នុងឃុំ/សង្កាត់នោះជាសមាជិក។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា កំលាំងមហាជនគឺជាកត្តាដ៏សំខាន់មួយ ដើម្បីផ្តល់ឱ្យស្ត្រីនូវទំនុកចិត្ត ក្នុងការចូលរួមឱ្យបានសស្រាក់សស្រាំ។ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់កម្មវិធី សិលា ឆ្នាំ២០០១-២០០៥ ក៏បានផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រនៅក្នុង រដ្ឋបាលមូលដ្ឋាន ហើយនិងអាជ្ញាធរនៅក្នុងសហគមន៍តាមរយៈ (i)ការកសាងសមត្ថភាព និងការប្តេជ្ញាចិត្ត (ii)ការ

បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើផែនការ និងអភិបាលកិច្ចក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋាន (iii)លើកតំកើងសមត្ថភាពសំរាប់តាមដាន វាយតំលៃ និងការគ្រប់គ្រងទិន្នន័យអំពីបញ្ហាយេនឌ័រ ។

**២.៣.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៣**

បញ្ហាប្រឈមសំខាន់ៗក្នុងផ្នែកសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចទៅឱ្យស្ត្រី គឺស្ថិតនៅក្នុងផ្នែកសង្គម សេដ្ឋកិច្ច នយោបាយ និងខាងផ្លូវច្បាប់:

- ក្នុងវិស័យសង្គម យកចិត្តទុកដាក់ជាចាំបាច់ក្នុងការកាត់បន្ថយឱ្យបាន នូវគំលាតយេនឌ័រនៅក្នុងការចូលរៀននៅមធ្យមសិក្សា និងកិច្ចប្រឹងប្រែងនៅក្នុងកំរិតបឋមសិក្សាផងដែរ ។ លើសពីនេះទៅទៀត ក៏ត្រូវឱ្យមានវិធានការ ដើម្បីដោះស្រាយដោយផ្ទាល់នូវបញ្ហាអំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងបទដ្ឋានវប្បធម៌ដែលបង្កឱ្យមានវិសមភាពយេនឌ័រ នៅក្នុងផ្នែកជាច្រើននៃជីវភាពសង្គម ។
- នៅក្នុងវិស័យសេដ្ឋកិច្ច បញ្ហាប្រឈមចំបងៗពាក់ព័ន្ធទៅនឹងការកើនឡើងនូវលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបាននូវទ្រព្យធនប្រកបដោយផលិតភាពដូចជា ដើមទុនហិរញ្ញវត្ថុដោយកាត់បន្ថយនូវ ការរើសអើងខាងយេនឌ័រនៅក្នុងទីផ្សារពលកម្ម និងផ្តល់នូវបរិយាកាសអំណោយផល ដើម្បីឱ្យមានការចូលរួមរបស់ស្ត្រីឱ្យបានច្រើនជាងមុនទៅក្នុងការងារដែលមានគុណភាពខ្ពស់ជាង ។
- ទាក់ទងទៅនឹងបញ្ហាប្រឈមខាងនយោបាយ និងផ្លូវច្បាប់ បញ្ហាជាគន្លឹះរួមមាន លើកកំពស់ ការចូលរួមរបស់ស្ត្រីនៅក្នុងរចនាសម្ព័ន្ធការធ្វើសេចក្តីសំរេចចិត្តជាផ្លូវការ និងក្រៅផ្លូវការ កែលំអលទ្ធភាពរបស់ស្ត្រីក្នុងការកាន់មុខតំណែងខ្ពស់ៗ ក្នុងផ្នែករដ្ឋបាលសាធារណៈ ធានាឱ្យមាននីតិកម្មប្រកបដោយប្រសិទ្ធភាព ក្នុងការដោះស្រាយអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរស្ត្រី ក៏ដូចជាការធានានូវការពង្រឹងការអនុវត្តន៍វិស័យទាំងនេះផងដែរ ។

**២.៣.៥ ក្របខ័ណ្ឌការងារ ដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅ គអសក៣**

ការបញ្ជ្រាបយេនឌ័រ ត្រូវបានទទួលយកដោយរាជរដ្ឋាភិបាលកម្ពុជា សំរាប់ដាក់ចូលទៅក្នុងគោលនយោបាយ និងកម្មវិធីទាំងអស់របស់ខ្លួន នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទី២ (២០០១-២០០៥) ដែលបានដាក់បញ្ចូលនូវយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន នោះគឺផែនការយុទ្ធសាស្ត្រ *នារីរតនៈ*។ ផែនការនេះក៏ជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រផងដែរ ។

សកម្មភាពមួយចំនួន ដែលនឹងត្រូវអនុវត្ត ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយ ដែលបានកំនត់ខាងលើមានដូចតទៅ:

- បង្កើននូវលទ្ធភាពទទួលបានការអប់រំរបស់សិស្ស/និស្សិតស្រី នៅកំរិតមធ្យមសិក្សា និងឧត្តមសិក្សាតាមរយៈ:
  - ការផ្តល់អាហារូបករណ៍ដល់កុមារី ដើម្បីបង្កើននូវការសិក្សាបន្តនៅក្នុងប្រព័ន្ធអប់រំតទៅទៀត ។
  - បង្កើតឱ្យមានអន្តេវាសិកដ្ឋានប្រកបដោយសុវត្ថិភាព និងមានអនាម័យសំរាប់ឱ្យកុមារី ដែលមកសិក្សាឆ្ងាយពីផ្ទះដើម្បីស្នាក់នៅ ។

- សង់បង្គន់អនាម័យ សំរាប់សិស្ស/និស្សិតស្រី ដោយឡែកពីសិស្ស/និស្សិតប្រុស នៅកំរិតមធ្យមសិក្សា និងឧត្តមសិក្សា។
- ពង្រីកគ្រឹះស្ថានឧត្តមសិក្សាឱ្យមានរហូតដល់ថ្នាក់តំបន់។
- ពង្រីកវិធីសាស្ត្រថ្មីៗនៅក្នុងការអប់រំក្រៅប្រព័ន្ធ ដែលស្ថិតក្នុងសហគមន៍ ដើម្បីបង្កើននូវអក្ខរកម្មក្នុងចំណោមស្ត្រី។
- អនុវត្តកម្មវិធីសិក្សាពេលយប់ នៅក្នុងតំបន់ទីក្រុង/ទីប្រជុំជន ដើម្បីលើកទឹកចិត្តឱ្យសិស្សស្រីចូលរៀននៅសាលាបន្ទាប់ពីធ្វើការងារពេញម៉ោងនៅពេលថ្ងៃ។

- ផ្តល់លទ្ធភាពដល់ស្ត្រីចាប់យកឱកាសសេដ្ឋកិច្ចតាមរយៈ:
  - លើកតំកើងការអភិវឌ្ឍន៍នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដោយផ្តល់នូវប្រាក់សន្សំ ឥណទាន និងសេវាធានារ៉ាប់រងដល់ស្ត្រីជាពិសេសស្ត្រីក្រីក្រ។
  - គាំទ្រនូវកម្មវិធីផ្តល់សិទ្ធិអំណាចដល់ស្ត្រី ដើម្បីលើកកំពស់សមត្ថភាពរបស់ខ្លួន ក្នុងការរកការងារធ្វើនៅក្នុងទីផ្សារពលកម្ម ឬបង្កើននូវសកម្មភាពរកប្រាក់ចំណូលនៅក្នុងវិស័យកសិកម្ម ផលិតកម្ម និងសេវាកម្ម។
- ផ្លាស់ប្តូរនូវផ្នត់គំនិតខាងប្រពៃណីទំនៀមទំលាប់ចំពោះស្ត្រីៈ
  - ធ្វើយុទ្ធនាការផ្សព្វផ្សាយពត៌មាន ការអប់រំ និងទំនាក់ទំនង ដើម្បីលើកកំពស់ការយល់ដឹងទាំងក្នុងចំណោមបុរស និងស្ត្រី ស្តីអំពីបញ្ហាយេនឌ័រ និងដើម្បីផ្លាស់ប្តូរនូវផ្នត់គំនិតជាទំលាប់របស់ខ្លួន ចំពោះតួនាទី និងការទទួលខុសត្រូវខាងយេនឌ័រ។
- បង្កើននូវចំណែកចូលរួមរបស់ស្ត្រីក្នុងតួនាទីនយោបាយតាមរយៈ:
  - ជំរុញដល់គណបក្សនយោបាយ ដើម្បីដាក់បេក្ខនារីឱ្យស្ថិតនៅក្នុងលំដាប់ជួរមុខ នៃបញ្ជីបោះឆ្នោតសំរាប់ការបោះឆ្នោតឃុំ/សង្កាត់ និងការបោះឆ្នោតជាតិ។
  - ផ្តល់ការអប់រំស្តីពីនយោបាយ និងយេនឌ័រ ចំពោះបុរស និងស្ត្រីរួមទាំងការអភិវឌ្ឍន៍សមត្ថភាព ដើម្បីរៀបចំគាំទ្រកម្មវិធីនានា។
- បង្កើននូវចំណែកចូលរួមរបស់ស្ត្រីក្នុងផ្នែករដ្ឋបាលសាធារណៈតាមរយៈ:
  - ការបង្កើតនូវលក្ខណៈវិនិច្ឆ័យ និងទំរង់ការសំរាប់ការជ្រើសរើស ឬតំឡើងឋានៈ ដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រសំរាប់សេវាកម្មស៊ីវិល និងតុលាការ។
  - បង្កើនការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងពាក់ព័ន្ធ តាមរយៈសកម្មភាពបណ្តុះបណ្តាល ដែលផ្តល់ចំពោះបុរស និងស្ត្រី។
  - បង្កើនធនធាន ដើម្បីអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃកម្មវិធីសិលា និងដើម្បីកសាងសមត្ថភាព និងលើកកំពស់ការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសំរេចចិត្តនៅថ្នាក់ខេត្ត។
  - គាំទ្រកម្មវិធីបណ្តុះបណ្តាលនៅថ្នាក់មូលដ្ឋាន (ថ្នាក់ស្រុក ឃុំ/សង្កាត់ និងថ្នាក់ភូមិ) ស្តីអំពីបញ្ហាយេនឌ័រ ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងទំនុកចិត្តលើខ្លួនឯង។

- ប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាមកលើស្ត្រីតាមរយៈ

- ការធ្វើយុទ្ធនាការផ្សព្វផ្សាយការអប់រំ និងពតិមានប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ។
- ធ្វើវិសោធនកម្មច្បាប់ប្រឆាំងនឹងការជួញដូរស្ត្រី និងអនុម័តច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ។
- អនុវត្តផែនការស្តីអំពីការទប់ស្កាត់ការជួញដូរស្ត្រីតាមរយៈការអប់រំ និងការតស៊ូមតិ ។

## ២.៣.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៣

រូប ២.៣.៤ បង្ហាញពីការបែងចែកតាមតំបន់នៃសូចនាករ គអសក៣ តាមខេត្ត/ក្រុង ។ តំលៃនីមួយៗ តំណាងអោយសន្ទស្សន៍មានទំងន់មធ្យមស្មើគ្នា (equally weighted index) នៃសូចនាករដែលមានទិន្នន័យទាំងអស់របស់ គអសក៣ ។ សន្ទស្សន៍រួមរបស់សូចនាករទាំងនោះបង្ហាញនូវរូបភាពបែងចែកនៃស្ថានភាពរបស់ប្រទេសទាក់ទងទៅនឹងសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ។ លទ្ធផលទាំងនេះ អនុញ្ញាតិឱ្យយើងធ្វើការបែងចែកខេត្ត/ក្រុងជាបីលំដាប់ថ្នាក់ ។ ខេត្ត/ក្រុងដែលមានពណ៌បៃតង ជាខេត្តដែលមានលទ្ធភាពប្រសើរជាងគេក្នុងការឈានទៅសំរេចចំណុចដៅ ។ ខេត្ត/ក្រុងដែលមានពណ៌លឿង ជាខេត្តដែលមានលទ្ធភាពមធ្យម ហើយខេត្ត/ក្រុងដែលមានពណ៌ក្រហម មានលទ្ធភាពខ្សោយជាងគេ ក្នុងការឈានទៅសំរេចចំណុចដៅនៅឆ្នាំ ២០១៥ ។ ខេត្ត/ក្រុងដែលស្ថិតនៅលំដាប់ថ្នាក់អន់ជាងគេ ភាគច្រើនស្ថិតនៅតំបន់ភាគខាងជើង តំបន់ព្រៃសាន តំបន់និរតី និងតំបន់ភាគខាងលិច ( ក្រុងប៉ៃលិន) នៃប្រទេស ។

**រូប ២.៣.៤: សន្ទស្សន៍រួមនៃ គអសក៣ តាមខេត្ត/ក្រុង**




សំគាល់: សន្ទស្សន៍របស់ គអសក៣ គឺជាមធ្យមភាគដែលមានទំងន់ស្មើគ្នា ទៅតាមលំដាប់ខេត្តនីមួយៗ លើអថេរ នៃសូចនាករ៦ របស់ គអសក៣ ។

## តារាង ២.៣.៣: សន្ទស្សន៍រួមនៃ គអសកព តាមខេត្ត/ក្រុង

| លេខកូដ | ខេត្ត/ក្រុង | សូចនាករ ៣.១ | សូចនាករ ៣.៣ | សូចនាករ ៣.៤ | សូចនាករ ៣.៥ | សូចនាករ ៣.៦ | សូចនាករ ៣.៧ | សន្ទស្សន៍ គអសកព |
|---|---|---|---|---|---|---|---|---|
| ១២ | ភ្នំពេញ | ១,០០០ | ១,០០០ | ០,៨៧៥ | គ្មាន | ០,៦៦៧ | ០,៥៨៣ | ០,៨២៥ |
| ១០ | ក្រចេះ | ០,៧៧៨ | ០,៩៥៧ | ០,៧៧១ | ០,៩១៩ | ០,៤៩៧ | ០,៤៩១ | ០,៧៣៥ |
| ០៧ | កំពត | ០,៤៣០ | ០,៩៥៧ | ០,៨៣១ | គ្មាន | ១,០០០ | ០,៣៦០ | ០,៧១៦ |
| ២៣ | ក្រុងកែប | ០,៥២៩ | ១,០០០ | ០,៤៨៩ | ០,៧៥៧ | ០,៤៨៧ | ១,០០០ | ០,៧១០ |
| ០៦ | កំពង់ធំ | ០,៦២៣ | ០,៨៣២ | ០,៨៣៨ | ០,៣៣២ | ០,៥៣២ | ០,៩៦១ | ០,៦៨៦ |
| ១៥ | ពោធិ៍សាត់ | ០,៥៣១ | ០,៩៨៨ | ០,៧៣៩ | ០,០០០ | ១,០០០ | ០,៥៦២ | ០,៦៣៧ |
| ២០ | ស្វាយរៀង | ០,២០៨ | ១,០០០ | ០,៥៥៧ | ០,៨១៨ | ០,៧៤២ | ០,៤៦០ | ០,៦៣១ |
| ០៨ | កណ្ដាល | ០,៤៦១ | ០,៨៨០ | ០,៧៦៨ | ០,៣៧៦ | ០,៧៤៨ | ០,៥២៧ | ០,៦២៧ |
| ០២ | បាត់ដំបង | ០,៨៩៥ | ០,៩២៧ | ០,៧២៥ | ០,៥៦១ | ០,០០០ | ០,៥១៦ | ០,៦០៤ |
| ១៨ | ក្រុងព្រះសីហនុ | ០,៧២២ | ១,០០០ | ០,៦០៦ | ០,២៨០ | ០,៧០០ | ០,៥២៧ | ០,៦០៣ |
| ០៣ | កំពង់ចាម | ០,៦១១ | ០,៩០៨ | ០,៦៩៦ | គ្មាន | ០,១៩៥ | ០,៤៩៨ | ០,៥៥៥ |
| ១៤ | ព្រៃវែង | ០,២១៦ | ០,៩៨៩ | ០,៦២៧ | ០,៥៣៣ | ០,៦៤៨ | ០,១៨៨ | ០,៥៣៤ |
| ០១ | បន្ទាយមានជ័យ | ០,៤៨៨ | ០,៨៦១ | ០,៧៧២ | ០,៧១២ | ០,២៦៨ | ០,០០០ | ០,៥១៧ |
| ២១ | តាកែវ | ០,២០៤ | ០,៩៣៩ | ០,៤៥៤ | ០,៥៦៤ | ០,៥៦៣ | ០,២៣៦ | ០,៤៩៣ |
| ១៧ | សៀមរាប | ០,៦៦៧ | ១,០០០ | ០,៤៨២ | ០,៣១៦ | ០,២០០ | ០,២៥១ | ០,៤៨៦ |
| ០៤ | កំពង់ឆ្នាំង | ០,៤៦៧ | ០,៨០៩ | ០,៨០៦ | ០,០០០ | ០,៣២៣ | ០,៤៩៨ | ០,៤៨៤ |
| ១៣ | ព្រះវិហារ | ០,៣៥០ | ០,៣៧៥ | ០,៩៣៥ | គ្មាន | គ្មាន | ០,១៧១ | ០,៤៥៨ |
| ០៥ | កំពង់ស្ពឺ | ០,២០២ | ០,៧១៤ | ០,៤៩៨ | ០,៥៦៨ | ០,៦២០ | ០,០៤៣ | ០,៤៤១ |
| ២៤ | ក្រុងប៉ៃលិន | ០,៣០៩ | ០,៦៩៦ | ០,២២០ | ០,៧១៤ | ០,៤៨៩ | ០,០៨០ | ០,៤១៨ |
| ១៩ | ស្ទឹងត្រែង | ០,៤៩៤ | ០,០៩០ | ១,០០០ | ០,៥២៧ | ០,១៣៤ | ០,២៥៤ | ០,៤១៧ |
| ១៦ | រតនគិរី | ០,២៤៣ | ០,៤៩៧ | ០,៥២៤ | ០,២៤៦ | គ្មាន | ០,០៣៤ | ០,៣០៩ |
| ០៩ | កោះកុង | ០,៣០០ | ០,៣៤១ | ០,៤៧៤ | គ្មាន | ០,០៤០ | ០,៣៧៤ | ០,៣០៦ |
| ១១ | មណ្ឌលគិរី | ០,១៧៧ | ០,០០០ | ០,១៧២ | ១,០០០ | គ្មាន | ០,១៤៨ | ០,២៩៩ |
| ២២ | ឧត្ដរមានជ័យ | ០,០០០ | ០,១៧៩ | ០,០០០ | ០,៥៣៤ | គ្មាន | ០,២៤៤ | ០,១៩១ |

ប្រភព: អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ១៩៩៩ និង អង្កេតកំលាំងពលកម្មកម្ពុជា ២០០១ វិជ្ជាស្ថានជាតិស្ថិតិ ។ ស្ថិតិអប់រំ និងអាំងឌីកាទ័រ ២០០០/០១ ក្រសួងអប់រំ យុវជន និងកីឡា ។

## ២.៤ គោលដៅទី៤: កាត់បន្ថយអត្រាមរណភាពកុមារ

គោលដៅទី ៤ សំដៅកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ និងអត្រាមរណភាពទារក និងបង្កើនសមាមាត្រនៃទារកអាយុក្រោម ១ឆ្នាំ បានចាក់ថ្នាំការពារជម្ងឺកញ្រ្ជិល និងការអនុវត្តន៍ការបំបៅដោះទារក។

### ២.៤.១ សូចនាករ និងចំណុចដៅនៃ គអសក៤

តារាង ២.៤.១ បានបង្ហាញឱ្យឃើញនៅក្នុងជួរឈរខាងឆ្វេង គឺជាចំណុចដៅ និងសូចនាករដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ រីឯជួរឈរខាងស្តាំ បង្ហាញពីចំណុចដៅ និងសូចនាករដែលបានជ្រើសរើសដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ សំខាន់ៗរួចមក។

**តារាង ២.៤.១: មូលដ្ឋានីយកម្មនៃ គអស៤ ទៅជា គអសក៤**

| គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលទី៤ | គអសក៤ |
|---|---|
| **ចំណុចដៅទី៥:** បន្ថយអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ ឱ្យបាន ២/៣ ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៥ | **ចំណុចដៅរួមទី៥:** បន្ថយអត្រារណភាពកុមារក្រោមអាយុ ៥ឆ្នាំ |
| **សូចនាករ១៣:** អត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ | **សូចនាករ៤.១:** អត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ |
| **សូចនាករ១៤:** អត្រាមរណភាពទារក | **សូចនាករ ៤.២:** អត្រាមរណភាពទារក |
| **សូចនាករ១៥:** សមាមាត្រនៃកុមារអាយុ ១ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺកញ្រ្ជិល | **សូចនាករ៤.៣:** សមាមាត្រនៃកុមារអាយុ ១ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺកញ្រ្ជិល |
| | **សូចនាករ៤.៤:** សមាមាត្រនៃកុមារអាយុ ៦ ដល់ ៥៩ ខែ បានទទួលថ្នាំវីតាមីនអា |
| | **សូចនាករ៤.៥:** សមាមាត្រនៃកុមារអាយុក្រោម ១ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស |
| | **សូចនាករ៤.៦:** សមាមាត្រនៃទារកត្រូវបានបំបៅដោះដល់អាយុ ៦ខែ |
| | **សូចនាករ៤.៧:** សមាមាត្រនៃម្តាយ ដែលចាប់ផ្តើមបំបៅដោះទារកទើបនឹងកើតក្នុងចន្លោះពេល ១ម៉ោង នៃកំណើត |

តារាង ២.៤.២ បង្ហាញនូវតំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៤ សំរាប់ឆ្នាំ២០០៥ ២០១០ និង២០១៥។ តម្លៃទិន្នន័យឆ្នាំមូលដ្ឋានរបស់សូចនាករនីមួយៗ មានលក្ខណៈខុសគ្នាអាស្រ័យលើទិន្នន័យដែលមាន ។

**តារាង ២.៤.២: តំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៤ តាមលំដាប់ឆ្នាំ[៥]**

| សូចនាករ | ទិន្នន័យមូលដ្ឋាន | | ចំណុចដៅ | | |
|---|---|---|---|---|---|
| | តំលៃ | ឆ្នាំ | ២០០៥ | ២០១០ | ២០១៥ |
| ៤.១ អត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ (ក្នុង ១០០០ កំណើតរស់) | ១២៤ | ១៩៩៨ | ១០៥ | ៨៥ | ៦៥ |
| ៤.២ អត្រាមរណភាពទារក (ក្នុង ១០០០ កំណើតរស់) | ៩៥ | ១៩៩៨ | ៧៥ | ៦០ | ៥០ |
| ៤.៣ សមាមាត្រនៃកុមារអាយុក្រោម ១ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺកញ្រ្ជិល | ៤១% | ២០០០ | ៨០% | ៨៥% | ៩០% |
| ៤.៤ សមាមាត្រនៃកុមារអាយុ ៦-៥៩ខែ បានទទួលថ្នាំវីតាមីនអា | ២៨% | ២០០០ | ៧០% | ៨០% | ៩០% |
| ៤.៥ សមាមាត្រនៃកុមារអាយុក្រោម ១ឆ្នាំ បានទទួលការចាក់ថ្នាំការពារជម្ងឺខាន់ស្លាក់ ក្អកមាន់ តតោនុស | ៤៣% | ២០០០ | ៨០% | ៨៥% | ៩០% |
| ៤.៦ សមាមាត្រនៃទារកត្រូវបានបំបៅដោះដល់អាយុ ៦ខែ | ១១.៤% | ២០០០ | ២០% | ៣៤% | ៤៩% |
| ៤.៧ សមាមាត្រនៃម្តាយ ដែលចាប់ផ្តើមបំបៅដោះទារកទើបនឹងកើតក្នុងចន្លោះពេល ១ម៉ោង នៃកំណើត | ១១% | ២០០០ | ២៨% | ៤៥% | ៦២% |

[៥] គ្រប់តំលៃឆ្នាំមូលដ្ឋានទាំងអស់ដកស្រង់ចេញពីអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០០ យោងទៅលើឆ្នាំ២០០០ ឬក៏រយៈពេល ៥ឆ្នាំចុងក្រោយមុនពេលធ្វើអង្កេត។ ក្នុងករណីអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ និងអត្រាមរណភាពទារក ឆ្នាំ១៩៩៨ ត្រូវបានជ្រើសរើសជាឆ្នាំមូលដ្ឋានដែរ។

## ២.៤.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៤

ប្រភពទិន្នន័យផ្សេងៗគ្នា បង្ហាញនូវភស្តុតាងផ្ទុយគ្នា អំពីកំរិត និងនិន្នាការ នៃអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ ក្នុងទសវត្សរ៍កន្លងមក។ ទិន្នន័យពីការធ្វើអង្កេតជាតិចំនួនពីរ ពោលគឺការធ្វើអង្កេតសុខភាពជាតិ (NHS) ឆ្នាំ១៩៩៨ និងការធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០០០ បង្ហាញថាអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ បានកើនឡើងបន្តិចក្នុងរយៈពេលមួយទសវត្សរ៍នេះ។ និន្នាការស្រដៀងគ្នានេះក៏ទទួលបានពីការប៉ាន់ស្មានដោយផ្ទាល់ និងដោយប្រយោលរបស់ធនាគារពិភពលោក និងអង្គការយូនីសេស ដែលបង្ហាញពីការកើនឡើងនៃអត្រាមរណភាពនេះ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ការវាយតម្លៃផ្សេងទៀតដែលពុំផ្អែកលើទិន្នន័យអង្កេត បង្ហាញនូវការថយចុះបង្គួរពីកំរិតមួយដែលខ្ពស់ (រូប ២.៤.១)។ ទោះបីជាការជ្រើសរើសយកទិន្នន័យណាក្តី ក៏ប្រទេសកម្ពុជា ទំនងជាពុំអាចសំរេចបាននូវចំណុចដៅរបស់ខ្លួន ក្នុងការកាត់បន្ថយអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ មកត្រឹម ៦៥នាក់ ក្នុងកំណើតរស់ ១០០០នាក់ ឱ្យបានមុនដំណាច់ឆ្នាំ២០១៥។ លើសពីនេះទៀត តួលេខជាតិបានបង្ហាញនូវភាពខុសគ្នាដ៏ធំរវាងតំបន់ទីក្រុង/ប្រជុំជន និងជនបទ រវាងបណ្តាខេត្ត/ក្រុងទាំងឡាយ និងក្នុងចំណោមក្រុមសេដ្ឋកិច្ច-សង្គមកិច្ចផ្សេងៗ។

**រូប ២.៤.១: និន្នាការនៃអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ**




ប្រភព: ក្រសួងសុខាភិបាល ១៩៩៤ ១៩៩៥ ១៩៩៦ ១៩៩៨ ១៩៩៨ក និងក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១។

ជាថ្មីម្តងទៀតប្រភពទិន្នន័យផ្សេងៗគ្នា បង្ហាញនូវនិន្នាការខុសគ្នានៃអត្រាមរណភាពទារក ក្នុងទសវត្សរ៍កន្លងមកនេះ។ យោងតាមទិន្នន័យនៃអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០០០ និងអង្កេតសុខភាពជាតិ (NHS) ឆ្នាំ១៩៩៨ អត្រាមរណភាពទារក បានកើនឡើងបន្តិចក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ការវាយតម្លៃដែលមិនផ្អែកលើការធ្វើអង្កេត បង្ហាញនូវការថយចុះជាបង្គួរពីកំរិតមួយដែលខ្ពស់។ ដូចជាការស្លាប់របស់កុមារក្រោមអាយុ ៥ឆ្នាំដែរ ទោះបីជាការជ្រើសរើសយកទិន្នន័យណាក្តី ក៏ប្រទេសកម្ពុជាទំនងជាពុំអាចសំរេចបាននូវចំណុចដៅរបស់ខ្លួនក្នុងការកាត់បន្ថយអត្រាមរណភាពទារកមកត្រឹម ៥០ ក្នុងកំណើតរស់ ១០០០នាក់ ឱ្យបានមុនដំណាច់ឆ្នាំ២០១៥ (រូប ២.៤.២)។

**រូប ២.៤.២: និន្នាការនៃអត្រាមរណភាពទារក**




ប្រភព: ក្រសួងសុខាភិបាល ១៩៩៤ ១៩៩៥ ១៩៩៦  ១៩៩៨ ១៩៩៨ក  និងក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១។

អត្រាចាក់ថ្នាំការពារជម្ងឺកញ្ជ្រឹល  សំរាប់កុមារក្រោមអាយុ  ១ឆ្នាំ  បានកើនឡើងពី  ៣៧% (ក្រសួងសុខាភិបាល ១៩៩៤) ដល់ ៤១% (ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១) រវាងឆ្នាំ១៩៩០ និង ២០០០។ ដោយផ្អែកលើនិន្នាការកន្លងមក សមាមាត្រនៃកុមារអាយុក្រោម ១ឆ្នាំ ដែលបានទទួលការចាក់ថ្នាំការពារជម្ងឺកញ្ជ្រឹលអាចឡើងដល់ ៤៨% ដល់ឆ្នាំ២០១៥ ដែលស្ថិតនៅក្រោមចំណុចដៅ ៩០% នៃ គអសក៤។

អត្រាកុមារដែលបានទទួលការចាក់ថ្នាំការពារជម្ងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស បានកើនឡើង ៦% ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ (ក្រសួងសុខាភិបាល ១៩៩៤ និងក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១)។ ក្នុងល្បឿននេះ សមាមាត្រនៃកុមារអាយុក្រោម ១ឆ្នាំ ដែលបានទទួលការចាក់ថ្នាំការពារ ជម្ងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស នឹងកើនឡើងត្រឹម ៥២% ប៉ុណ្ណោះ ដល់ឆ្នាំ២០១៥  ដែលស្ថិតនៅឆ្ងាយពីចំណុចដៅដែលបានកំណត់ ៩០%។

ភាគរយនៃកុមារអាយុ ៦-៥៩ខែ ដែលបានទទួលថ្នាំវីតាមីនអា គឺមាន២៨% នៅក្នុងឆ្នាំ២០០០ (ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១) ដែលស្ថិតនៅឆ្ងាយក្រោមចំណុចដៅ គអសក៤ ដែលបានកំណត់ ៩០% នៅឆ្នាំ២០១៥។ ដូចជាសូចនាករជាច្រើនទៀតដែរ មានភាពខុសគ្នាយ៉ាងខ្លាំងតាមតំបន់ភូមិសាស្ត្រ និងគ្រួសារដែលមានកំរិតសេដ្ឋកិច្ច-សង្គមកិច្ចខុសគ្នា។

សមាមាត្រនៃមាតាដែលចាប់ផ្តើមបំបៅដោះទារកក្នុងចន្លោះពេល ១ម៉ោងនៃកំណើតកូន បានកើនឡើង ៥% ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ (ក្រសួងសុខាភិបាល ១៩៩៦ និងក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១)។ ប្រសិនបើនិន្នាការកន្លងមកបន្តទៅទៀត សូចនាករនេះនឹងកើនឡើងដល់ ៣០% នៅឆ្នាំ២០១៥ ដែលស្ថិតនៅក្រោមចំណុចដៅ ៦២% នៅក្នុងឆ្នាំ២០១៥។

## ២.៤.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក៤

អាទិភាពនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទីពីរ ត្រូវបានផ្តល់ដល់ការបង្កើនលទ្ធភាពទទួលសេវាគាំពារសុខភាពរបស់ជនក្រីក្រ ដោយមានវត្ថុបំណងដូចខាងក្រោមនេះ:

១. កែលំអសេវាគាំពារសុខភាពជាមូលដ្ឋាន ។
២. អភិវឌ្ឍធនធានមនុស្ស ។
៣. លើកកំពស់ការយល់ដឹងរបស់ប្រជាជន អំពីរបៀបរស់នៅប្រកបដោយសុខភាពល្អ ។
៤. ផ្តល់ការយកចិត្តទុកដាក់ ជាពិសេសដល់សុខភាព និងអាហារូបត្ថម្ភរបស់កុមារ ។
៥. ជំរុញនីតិកម្មខាងសុខាភិបាល ។

ផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០០៣-២០០៧ របស់ក្រសួងសុខាភិបាលមានទិសដៅ:

១. កាត់បន្ថយការស្លាប់របស់ទារក និងកុមារដែលរួមមាន កាត់បន្ថយការស្លាប់ក្រោយពេលសំរាលភ្លាម ការស្លាប់ដោយសារជំងឺដែលទាក់ទងនឹងការរាគរូស ជម្ងឺឆ្លងតាមផ្លូវដង្ហើម ជម្ងឺដែលអាចបង្ការបានដោយចាក់វ៉ាក់សាំង ជម្ងឺគ្រុនឈាម និងជម្ងឺគ្រុនចាញ់ ។
២. កាត់បន្ថយអត្រាកង្វះអាហារូបត្ថម្ភ និងចំណីអាហារខ្វះជីវជាតិ ក្នុងចំណោមកុមារ ។

គោលដៅសំខាន់ៗនឹងត្រូវសំរេចជោគជ័យតាមរយៈ:

១. ធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាសុខភាព នៅមណ្ឌលសុខភាព និងពង្រឹងការផ្តល់ការគាំពារសុខភាព ជាពិសេសអ្នកក្រីក្រ និងក្រុមដែលងាយរងគ្រោះដទៃទៀត ។
២. កែប្រែឱ្យល្អប្រសើរនូវអាកប្បកិរិយា របស់អ្នកផ្តល់សេវាសុខភាពចំពោះអតិថិជន ជាពិសេសចំពោះជនក្រីក្រ ។
៣. បញ្ចូល និងអភិវឌ្ឍវប្បធម៌គុណភាពទៅក្នុងវិស័យសុខាភិបាលសាធារណៈ ។
៤. ធានាឱ្យបាននូវលំហូរមូលនិធិទៀងទាត់ និងគ្រប់គ្រាន់ដល់វិស័យសុខាភិបាល និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ ។
៥. ផ្តល់សមត្ថភាពខាងវិជ្ជាជីវៈបន្ថែមទៀត ដល់បុគ្គលិកសុខាភិបាលរដ្ឋ ។
៦. ផ្តល់ថ្នាំ និងបរិក្ខារពេទ្យបន្ថែមទៀតដល់មន្ទីរពេទ្យសាធារណៈ និងមណ្ឌលសុខភាព ។
៧. ពង្រីកការផ្តល់សេវាពតិមានសុខាភិបាល ដល់សាធារណៈជន ។

**២.៤.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៤**

បញ្ហាប្រឈមសំខាន់ៗ ដែលប្រទេសកម្ពុជាត្រូវដោះស្រាយ ដើម្បីសំរេចបាននូវ គអសក៤ ក្នុងឆ្នាំ២០១៥ មានដូចខាងក្រោមនេះ:

- ការកាត់បន្ថយអត្រាដ៏ខ្ពស់នៃកង្វះអាហារូបត្ថម្ភ ដែលជាកត្តាដ៏ចំបងមួយនៃការស្លាប់ទារក និងកុមារ ។
- ការធ្វើអោយប្រសើរផ្នែកអនាម័យ ការទទួលបានទឹកស្អាត និងការរស់នៅស្អាត ។ កង្វះខាតផ្នែកនេះអាចបណ្តាលអោយកុមារស្លាប់តាមរយៈជម្ងឺ ដែលឆ្លងតាមទឹក និងការទម្លាប់រស់នៅខ្វះអនាម័យ ។
- ការកែលំអ និងពង្រីកសេវាចាក់ថ្នាំបង្ការ ក៏ដូចជាសេវាការពារ និងព្យាបាលជម្ងឺទាំងឡាយដែលទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការស្លាប់របស់កុមារ និងទារកដូចជា ជម្ងឺរាគ និងជម្ងឺឆ្លងតាមផ្លូវដង្ហើម ។

- ការពង្រឹងសេវាកម្មផែនការគ្រួសារ ដើម្បីបង្កើនការពន្យារកំណើត និងពន្យារអាយុនៅពេលមានផ្ទៃពោះដំបូង ។
- ការលើកកំពស់ការយល់ដឹង អំពីការថែទាំសុខភាពកុមារដ៏សមស្របនៅក្នុងកិរិតគ្រួសាររួមមាន ការផ្តល់ចំណីអាហារដ៏ត្រឹមត្រូវដល់កុមារ ភាពស្អាត និងអនាម័យសមស្របក្នុងការរស់នៅ ។
- ការកែលំអគុណភាពនៃការផ្តល់ការគាំពារសុខភាព តាមរយៈការផ្លាស់ប្តូរអាកប្បកិរិយា និងទម្លាប់ក្នុងចំណោមអ្នកផ្តល់សេវាសុខភាពសាធារណៈ ។
- ដោះស្រាយវិសមភាពក្នុងការទទួលការគាំពារសុខភាព ដោយយកចិត្តទុកដាក់ជាពិសេសដល់អ្នកក្រីក្រ និងសហគមន៍នៅតំបន់ដាច់ស្រយាល ។

**២.៤.៥ ក្របខ័ណ្ឌការងារ ដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅ គអសក៤**

ទិសដៅជាគន្លឹះនៃក្របខ័ណ្ឌការងារ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក៏ដូចជាដើម្បីសំរេចឱ្យបាននូវ គអសក៤ រួមមានៈ

- ផ្តោតលើកម្មវិធីទាំងឡាយរបស់រាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ លើការកែលំអសុខភាពកុមារជាពិសេស តាមរយៈការពង្រីកកម្មវិធីចាក់ថ្នាំបង្ការជម្ងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស និងជម្ងឺកញ្រ្ជិល ។ ធ្វើឱ្យប្រសើរឡើងនូវបរិក្ខារអនាម័យ និងលទ្ធភាពទទួលទឹកស្អាត ដោយផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់អ្នកក្រីក្រ និងតំបន់ដាច់ស្រយាល ។ ពង្រឹងសេវាកម្មនៅមន្ទីរពេទ្យបង្អែកដោយផ្តល់ការថែទាំពេញលេញដល់កុមារដែលខ្វះអាហារូបត្ថម្ភ ។ល ។
- បង្កើនចំណាយសាធារណៈដល់សេវាសុខាភិបាល នៅតាមមណ្ឌលសុខភាពស្រុក និងឃុំ ។
- ធ្វើយុទ្ធនាការអប់រំ និងផ្តល់ពត៌មានដែលលើកឡើងពីការផ្តល់អាហារត្រឹមត្រូវ និងអាហារូបត្ថម្ភរបស់កុមារ ភាពស្អាត និងអនាម័យសមស្របក្នុងការរស់នៅ ។
- កែលំអប្រសិទ្ធភាពនៃប្រព័ន្ធសុខាភិបាលសាធារណៈ ដោយឈានឆ្ពោះទៅកាន់វិធីគ្រប់គ្រង ដែលផ្អែកលើលទ្ធផល និងការពង្រីកវិមជ្ឈការ ។
- បង្កើនលទ្ធភាពខាងហិរញ្ញវត្ថុដល់កុមារក្រីក្រ ក្នុងការទទួលបានការគាំពារសុខភាព តាមរយៈការសាកល្បងនូវជំរើសផ្សេងៗ ដូចជា ការលើកលែងថ្លៃឈ្នួល និងផែនការធានារ៉ាប់រងខ្នាតតូច ។
- ធ្វើយុទ្ធនាការផ្តល់ពត៌មានអំពីប្រភេទសេវាកម្ម ដែលមានសំរាប់កុមារ នៅតាមបណ្តាញសុខភាពសាធារណៈ ។

**២.៤.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៤**

រូប ២.៤.៣ បង្ហាញពីការបែងចែកតាមតំបន់នៃសូចនាករ គអសក៤ តាមខេត្ត/ក្រុង ។ តំលៃនីមួយៗ តំណាងអោយសន្ទស្សន៍មានទំងន់មធ្យមស្មើគ្នា (equally weighted index) នៃសូចនាករដែលមានទិន្នន័យទាំងអស់របស់ គអសក៤ ។ សន្ទស្សន៍រួមដែលជាលទ្ធផលបង្ហាញនូវរូបភាពបំបែកមួយនៃស្ថានភាពប្រទេសទាក់ទង

ទៅនឹងការស្លាប់របស់ទារក និងកុមារ។ លទ្ធផលទាំងនេះ អនុញ្ញាតិឱ្យយើងធ្វើការបែងចែកខេត្ត/ក្រុងជាបីលំដាប់ថ្នាក់។ ខេត្ត/ក្រុងដែលមានពណ៌បៃតង ជាខេត្ត/ក្រុងដែលមានលទ្ធភាពប្រសើរជាងគេ ក្នុងការឈានទៅសំរេចចំណុចដៅ។ ខេត្ត/ក្រុងដែលមានពណ៌លឿង ជាខេត្ត/ក្រុងដែលមានលទ្ធភាពមធ្យម ហើយខេត្ត/ក្រុងដែលមានពណ៌ក្រហម មានលទ្ធភាពខ្សោយជាងគេ ក្នុងការឈានទៅសំរេចចំណុចដៅ នៅឆ្នាំ២០១៥។ ខេត្ត/ក្រុងដែលស្ថិតនៅលំដាប់ថ្នាក់អន់ជាងគេ ភាគច្រើនស្ថិតនៅតំបន់ភាគខាងកើត តំបន់និរតី និងតំបន់ភាគខាងលិចនៃប្រទេស។

**រូប ២.៤.៣: សន្ទស្សន៍រួមនៃ គអសក៤ តាមខេត្ត/ក្រុង**




សំគាល់: សន្ទស្សន៍របស់ គអសក៤ គឺជាមធ្យមភាគដែលមានទំងន់ស្មើគ្នាទៅតាមលំដាប់ខេត្តនីមួយៗ លើអថេរ នៃសូចនាករ៤ របស់ គអសក៤។

**តារាង ២.៤.៣: សន្ទស្សន៍រួមនៃ គអសក៤ តាមខេត្ត/ក្រុង**

| លេខកូដ | ខេត្ត/ក្រុង | សូចនាករ ៤.១ | សូចនាករ ៤.២ | សូចនាករ ៤.៤ | សូចនាករ ៤.៧ | សន្ទស្សន៍ គអសក៤ |
|---|---|---|---|---|---|---|
| ១២ | ភ្នំពេញ | ១,០០០ | ១,០០០ | ១,០០០ | ០,៣០៨ | **០,៨២៧** |
| ០៥ | កំពង់ស្ពឺ | ០,៧៨២ | ០,៧៧៣ | ០,៧៧៧ | ០,៨៩៤ | **០,៨០៦** |
| ០១ | បន្ទាយមានជ័យ | ០,៦៧៦ | ០,៦៩៧ | ០,៦៨៦ | ០,៨៩៧ | **០,៧៣៩** |
| ០៦ | កំពង់ធំ | ០,៧២១ | ០,៨០៣ | ០,៥៩២ | ០,២០២ | **០,៥៦៩** |
| ២១ | តាកែវ | ០,៦២០ | ០,៥៦១ | ០,៥៨៧ | ០,៤៣០ | **០,៥៤៩** |
| ០៩ | កោះកុង | ០,៧៧១ | ០,៧៥០ | ០,៤៣៥ | ០,២៤០ | **០,៥៤៩** |
| ២០ | ស្វាយរៀង | ០,៥៩៣ | ០,៥១៥ | ០,០៦៣ | ១,០០០ | **០,៥៣៣** |
| ០៨ | កណ្តាល | ០,៦៧៦ | ០,៦១៤ | ០,២១៤ | ០,៣៧៦ | **០,៤៧០** |
| ១៩ | ស្ទឹងត្រែង | ០,៦១៥ | ០,៧៥០ | ០,០០០ | ០,៤០៣ | **០,៤៤២** |
| ១៣ | ព្រះវិហារ | ០,៦១៥ | ០,៧៥០ | ០,០០០ | ០,៤០៣ | **០,៤៤២** |
| ១០ | ក្រចេះ | ០,៦១៥ | ០,៧៥០ | ០,០០០ | ០,៤០៣ | **០,៤៤២** |
| ០៤ | កំពង់ឆ្នាំង | ០,៣៨៥ | ០,៣១១ | ០,៨៨៤ | ០,១១០ | **០,៤២២** |
| ០៣ | កំពង់ចាម | ០,៥៣១ | ០,៤៧០ | ០,៤១០ | ០,១៣៧ | **០,៣៨៧** |
| ១៧ | សៀមរាប | ០,៥៨១ | ០,៦៩៧ | ០,០៨១ | ០,១៨៦ | **០,៣៨៦** |
| ២២ | ឧត្តរមានជ័យ | ០,៥៨១ | ០,៦៩៧ | ០,០៨១ | ០,១៨៦ | **០,៣៨៦** |
| ២៤ | ប៉ៃលិន | ០,៥៧០ | ០,៥៤៥ | ០,២៨៤ | ០,១២២ | **០,៣៨០** |
| ០២ | បាត់ដំបង | ០,៥៧០ | ០,៥៤៥ | ០,២៨៤ | ០,១២២ | **០,៣៨០** |
| ១៤ | ព្រៃវែង | ០,៤៣៦ | ០,៤៤៧ | ០,៣៣០ | ០,១១៤ | **០,៣៣២** |
| ១៨ | ក្រុងព្រះសីហនុ | ០,៥៨៧ | ០,៥៣០ | ០,១៩២ | ០,០០០ | **០,៣២៧** |
| ២៣ | ក្រុងកែប | ០,៥៨៧ | ០,៥៣០ | ០,១៩២ | ០,០០០ | **០,៣២៧** |
| ០៧ | កំពត | ០,៥៨៧ | ០,៥៣០ | ០,១៩២ | ០,០០០ | **០,៣២៧** |
| ១៦ | រតនគិរី | ០,០០០ | ០,០០០ | ០,០៧៩ | ០,៩៣៥ | **០,២៥៤** |
| ១១ | មណ្ឌលគិរី | ០,០០០ | ០,០០០ | ០,០៧៩ | ០,៩៣៥ | **០,២៥៤** |
| ១៥ | ពោធិ៍សាត់ | ០,៣១៣ | ០,២៣៥ | ០,២៨០ | ០,១២៥ | **០,២៣៨** |

ប្រភព: ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១។

## ២.៥ គោលដៅទី៥: លើកកំពស់សុខភាពមាតា

គោលដៅទី ៥ សំដៅកាត់បន្ថយផលធៀបមរណភាពមាតា និងបង្កើនសមាមាត្រនៃការសំរាលកូន ដែលបានទទួលការថែទាំដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ។

### ២.៥.១ សូចនាករ និងចំណុចដៅនៃ គអសក៥

តារាង ២.៥.១ បានបង្ហាញឱ្យឃើញនៅក្នុងជួរឈរខាងឆ្វេង គឺជាចំណុចដៅ និងសូចនាករដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ រីឯជួរឈរខាងស្តាំបង្ហាញពីចំណុចដៅ និងសូចនាករដែលបានជ្រើសរើស ដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ សំខាន់ៗរួចមក។

**តារាង ២.៥.១: មូលដ្ឋានីយកម្មនៃ គអសស៥ ទៅជា គអសក៥**

| គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលទី៥ | គអសក៥ |
|---|---|
| **ចំណុចដៅទី៦:** កាត់បន្ថយមរណភាពមាតាឱ្យបាន ៣/៤ រវាងឆ្នាំ១៩៩០ និងឆ្នាំ២០១៥ | **ចំណុចដៅរួមទី១០:** កាត់បន្ថយផលធៀបមរណភាពមាតា |
| **សូចនាករ១៦:** ផលធៀបមរណភាពមាតា | **សូចនាករ៥.១:** ផលធៀបមរណភាពមាតា |
| **សូចនាករ១៧:** សមាមាត្រនៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ | **សូចនាករ៥.២:** អត្រាលទ្ធភាពផ្តល់កំណើតសរុប |
| | **សូចនាករ៥.៣:** សមាមាត្រនៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ |
| | **សូចនាករ៥.៤:** សមាមាត្រនៃស្ត្រីរៀបការដែលប្រើវិធីពន្យារកំណើតទំនើប |
| | **សូចនាករ៥.៥:** ភាគរយនៃស្ត្រីមានផ្ទៃពោះដែលបានទទួលការពិគ្រោះមុនពេលសំរាលបានពីរដង ឬច្រើនជាងជាមួយបុគ្គលិកសុខាភិបាលដែលមានជំនាញ |
| | **សូចនាករ៥.៦:** សមាមាត្រនៃស្ត្រីមានផ្ទៃពោះដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក |
| | **សូចនាករ៥.៧:** សមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលមានផលធៀបទំងន់ទៅនឹងកំពស់ក្រោម ១៨,៥ គីឡូក្រាម/ម៉ែត្រការ៉េ |
| | **សូចនាករ៥.៨:** សមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក |
| | **សូចនាករ៥.៩:** សមាមាត្រនៃស្ត្រីមានផ្ទៃពោះដែលសំរាលកូនដោយការវះកាត់ |

តារាង ២.៥.២ បង្ហាញនូវតំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៥ សំរាប់ឆ្នាំ២០០៥ ២០១០ និង២០១៥។ តម្លៃទិន្នន័យឆ្នាំមូលដ្ឋានរបស់សូចនាករនីមួយៗ មានលក្ខណៈខុសគ្នាអាស្រ័យលើទិន្នន័យដែលមាន។

**តារាង ២.៥.២: តំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៥ តាមលំដាប់ឆ្នាំ**[១០]

| សូចនាករ | ទិន្នន័យមូលដ្ឋាន | | ចំណុចដៅ | | |
|---|---|---|---|---|---|
| | តំលៃ | ឆ្នាំ | ២០០៥ | ២០១០ | ២០១៥ |
| ៥.១ ផលធៀបមរណភាពមាតា (ក្នុង ១០០០០០ កំណើតកូន) | ៤៣៧ | ១៩៩៧ | ៣៤៣ | ២៤៣ | ១៤០ |
| ៥.២ អត្រាលទ្ធភាពផ្តល់កំណើតសរុប | ៤,០ | ១៩៩៨ | ៣,៨ | ៣,៤ | ៣,០ |
| ៥.៣ សមាមាត្រនៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ | ៣២% | ២០០០ | ៦០% | ៧០% | ៨០% |
| ៥.៤ សមាមាត្រនៃស្ត្រីរៀបការដែលប្រើវិធីពន្យារកំណើតទំនើប | ១៨,៥% | ២០០០ | ៣០% | ៤៤% | ៦០% |
| ៥.៥ ភាគរយនៃស្ត្រីមានផ្ទៃពោះ ដែលបានទទួលការពិគ្រោះមុនពេលសំរាលបានពីរដង ឬច្រើនជាង ជាមួយបុគ្គលិកសុខាភិបាល ដែលមានជំនាញ | ៣០% | ២០០០ | ៦០% | ៧៥% | ៩០% |
| ៥.៦ សមាមាត្រនៃស្ត្រីមានផ្ទៃពោះដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក | ៦៦% | ២០០០ | ៥០% | ៣៩% | ៣៣% |
| ៥.៧ សមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ ឆ្នាំ ដែលមានផលធៀបទំងន់ទៅនឹងកំពស់ក្រោម ១៨,៥ គីឡូក្រាម/ម៉ែត្រការ៉េ | ២១% | ២០០០ | ១៧% | ១២% | ៨% |
| ៥.៨ សមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ ឆ្នាំ ដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក | ៥៨% | ២០០០ | ៤៥% | ៣២% | ១៩% |
| ៥.៩ សមាមាត្រនៃស្ត្រីមានផ្ទៃពោះដែលសំរាលកូនដោយការវះកាត់ | ០,៨% | ២០០០ | ២% | ៣% | ៤% |

### ២.៥.២ និន្នាការកន្លងមក និងការវិភាគពីតំលាតនៃសូចនាករ គអសក៥

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ផលធៀបមរណភាពមាតា នៅចន្លោះ៤០០ និង៥០០ នៅប្រទេសកម្ពុជា។ ការវាយតម្លៃមួយនៅឆ្នាំ១៩៩៥ ដោយផ្អែកលើគំរូមួយរបស់អង្គការសុខភាពពិភពលោក បានកំណត់ផលធៀបក្នុងកំរិត៤៧៣ ហើយការធ្វើអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០ បានសន្មតថាផលធៀបជាមធ្យមគឺ៤៣៧ ក្នុងអំឡុងឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០០។ ពុំមានទិន្នន័យ ដែលស៊ីសង្វាក់គ្នាជាលក្ខណៈស៊េរី សំរាប់សូចនាករនេះដែលអាចអនុញ្ញាតិឱ្យមានការប៉ាន់ស្មាននិន្នាការឡើយ ប៉ុន្តែកំរិតនៃសូចនាករនេះពុំសំរេចបាននូវចំណុចដៅដែលសំដៅកាត់បន្ថយផលធៀបមរណភាពមាតា មកត្រឹម១៤០ ក្នុង១០០០០០ កំណើតកូននៅឆ្នាំ២០១៥។

យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០ អត្រាលទ្ធភាពផ្តល់កំណើតមានចំនួន ៤នាក់ នៅក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០។ កង្វះទិន្នន័យដែលស៊ីសង្វាក់គ្នាជាលក្ខណៈស៊េរី មិនអាចធ្វើចំណោលនិន្នាការបាន ប៉ុន្តែចំណុចដៅដែលកំណត់ត្រឹម ៣នាក់ ដល់ឆ្នាំ២០១៥ ទំនងជាអាចសំរេចបាន។

សមាមាត្រនៃការសំរាលកូន ដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ នៅតែមានកំរិតទាប ប្រមាណ ៣២% ក្នុងអំឡុងទសវត្សរ៍កន្លងមកនេះ។ កត្តានេះបណ្តាលមកពីកង្វះបុគ្គលិកសុខាភិបាល មានជំនាញដែលរួម

[១០] គ្រប់តំលៃឆ្នាំមូលដ្ឋានទាំងអស់ដកស្រង់ចេញពីអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០០ យោងទៅលើឆ្នាំ២០០០ ឬក៏រយៈពេល ៥-៧ឆ្នាំចុងក្រោយមុនពេលធ្វើអង្កេត។ ជាលទ្ធផល ឆ្នាំ១៩៩៧-៩៨ ត្រូវបានជ្រើសរើសជាឆ្នាំមូលដ្ឋានសំរាប់ផលធៀបមរណភាពមាតា និងអត្រាលទ្ធភាពផ្តល់កំណើតសរុប។

មាន ឆ្នប ការចំណាយខ្ពស់លើការថែទាំ ភាពខុសគ្នាខាងភូមិសាស្ត្រ ក្នុងការផ្តល់សេវាគាំពារសុខភាពបន្តពូជ ក៏រិតអប់រំទាបនៅក្នុងចំណោមស្ត្រីមានផ្ទៃពោះ និងភាពក្រីក្រ។ ប្រសិនបើនិន្នាការកន្លងមកនៅបន្ត ប្រទេសកម្ពុជាទំនងជាមិនអាចសំរេចបានចំណុចដៅរបស់ខ្លួនក្នុងដំណាច់ឆ្នាំ២០១៥ ឡើយ។

**រូប ២.៥.១: និន្នាការ និងចំណុចដៅនៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ**




ប្រភព: ក្រសួងសុខាភិបាល ១៩៩៤ ១៩៩៥ ២០០៣ ។

សមាមាត្រនៃស្ត្រីរៀបការ ដែលប្រើវិធីពន្យារកំណើតទំនើបបានកើនឡើងពី ៨% (ក្រសួងសុខាភិបាល ១៩៩៤) ក្នុងឆ្នាំ១៩៩២ ដល់ ១៨.៥% ក្នុងឆ្នាំ២០០០ (ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១)។ ក្នុងអត្រាកំណើននេះ ប្រទេសកម្ពុជានឹងពុំអាចសំរេចបាននូវចំណុចដៅ ៦០% របស់ខ្លួនដល់ឆ្នាំ២០១៥ ឡើយ។ ដូចសូចនាករខាងលើដែរ មានភាពខុសគ្នាតាមតំបន់ភូមិសាស្ត្រ និងក្រុមសេដ្ឋកិច្ចសង្គមកិច្ចទាក់ទងនឹងសូចនាករនេះ។

មានស្ត្រីកម្ពុជាចំនួនតែ ៣០% ប៉ុណ្ណោះ បានទទួលការពិគ្រោះពិនិត្យផ្ទៃពោះមុនពេលសំរាលកូនបានពីរដង ឬច្រើនជាង ដែលជាតួលេខមួយមិនបានកើនឡើង ក្នុងទសវត្សរ៍កន្លងមក (ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១)។ អត្រានេះពុំគ្រប់គ្រាន់ឡើយ ដើម្បីធ្វើឱ្យប្រទេសកម្ពុជាអាចសំរេចបាននូវ ចំណុចដៅនៃគអសក៥ របស់ខ្លួនឱ្យបានចំនួន ៩០% ដល់ឆ្នាំ២០១៥។ ជាថ្មីម្តងទៀត តួលេខទាំងនេះបានបង្ហាញ នូវភាពខុសគ្នាតាមភូមិសាស្ត្រ ការអប់រំ និងកំរិតសេដ្ឋកិច្ច សង្គមកិច្ចរបស់ស្ត្រី។

សមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលមានផលធៀបទំងន់ទៅនឹងកំពស់ក្រោម ១៨.៥ គីឡូក្រាម/ម៉ែត្រការ៉េ មានកំរិតខ្ពស់នៅប្រទេសកម្ពុជាគឺ ២១% (ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១)។ សមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលមានផលធៀបទំងន់ទៅនឹងកំពស់ក្រោម ១៨.៥ គីឡូក្រាម/ម៉ែត្រការ៉េ មានលក្ខណៈខុសៗគ្នាទៅតាមខេត្ត/ក្រុង និងកត្តាសេដ្ឋកិច្ច សង្គមកិច្ច មួយចំនួនទៀត។ ទិន្នន័យដែលសំរាប់ធ្វើការប៉ាន់ស្មាននិន្នាការពុំមានទេសំរាប់សូចនាករនេះ។

នៅប្រទេសកម្ពុជា សមាមាត្រនៃស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលមានជម្ងឺស្លេកស្លាំងខ្វះជាតិដែក មានកំរិតខ្ពស់ណាស់ ៥៨% ក្នុងឆ្នាំ២០០០ (ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១)។ ដូចសូចនាករដទៃទៀតដែរ

ជម្ងឺស្លេកស្លាំងខ្វះជាតិដែក គឺខុសៗគ្នាទៅតាមទីកន្លែង កំរិតអប់រំ និងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់ស្ត្រី។ តំបន់នៅដាច់ពីគេ និងតំបន់ដាច់ស្រយាលមានលក្ខណៈអាក្រក់ជាងគេ។

សមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលសំរាលកូនដោយការវះកាត់មាន ០,៨% នៅក្នុងទូទាំងប្រទេសក្នុងឆ្នាំ២០០០ (ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១)។ សូចនាករនេះ គឺខុសៗគ្នាទៅតាមតំបន់ភូមិសាស្ត្រ និងកំរិតអប់រំ។ ដោយផ្អែកលើនិន្នាការកន្លងមក (ក្រសួងសុខាភិបាល ១៩៩៧) សមាមាត្រនេះនឹងកើនឡើងដល់ ១,៥៥% នៅឆ្នាំ២០១៥។ គំលាតគួរឱ្យកត់សំគាល់នៅតែត្រូវបំពេញរវាងចំណោល និងចំណុចដៅដែលបានកំណត់ ៤% នៅដំណាច់ឆ្នាំ២០១៥។ កិច្ចខិតខំប្រឹងប្រែង និងធនធានបន្ថែមទៀតនឹងត្រូវការ ដើម្បីសំរេចឱ្យបាននូវចំណុចដៅឆ្នាំ២០១៥។

### ២.៥.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗ នាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក៥

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទីពីរ មានទិសដៅលើកកំពស់សុខភាពមាតា តាមរយៈការផ្តល់ការថែទាំ មុននិងក្រោយពេលសំរាលកូន ដោយជំរុញការពន្យារកំណើតសំរាប់ក្រុម ដែលមានលទ្ធភាពផ្តល់កំណើតខ្ពស់។ លើសពីនេះទៀត ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទីពីរសំដៅ (១)ផ្តល់សេវាសុខភាពជាមូលដ្ឋាន (២)អភិវឌ្ឍធនធានមនុស្ស (៣)ជំរុញការយល់ដឹងរបស់ប្រជាជន អំពីវិធីរស់នៅប្រកបដោយសុខភាពល្អ ផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់សុខភាព និងអាហារូបត្ថម្ភរបស់ស្ត្រី និង (៤)ជំរុញនីតិកម្មសុខាភិបាល។

លើសពីនេះទៀត ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ឆ្នាំ២០០៣-២០០៧ របស់ក្រសួងសុខាភិបាល បានកំណត់គោលនយោបាយអាទិភាពនៅក្នុងវិស័យពីរ គឺ (១)ពង្រីកបរិក្ខារសុខាភិបាលឱ្យបានទៅដល់អ្នកក្រីក្រ និងអ្នកដែលខ្វះសេវាសុខាភិបាលនៅតំបន់ជនបទ (២)ផ្តល់សេវាសុខភាពរបស់មាតា ដោយរួមមានការពន្យារកំណើត ការថែទាំមុន និងក្រោយពេលសំរាលកូន ការសំរាលកូនប្រកបដោយសុវត្ថិភាព និងការគាំពារសុខភាពក្នុងពេលសំរាលកូនបន្ទាន់ ការរំលូតកូនប្រកបដោយសុវត្ថិភាព និងការផ្តល់ប្រឹក្សាក្រោយពេលរំលូតកូន។

យុទ្ធសាស្ត្រទាំងនេះសំដៅ (១)ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពអាចទទួលសេវាសុខភាព នៅមណ្ឌលសុខភាព និងពង្រឹងការផ្តល់ការគាំពារសុខភាព ជាពិសេសចំពោះអ្នកក្រីក្រ និងក្រុមដែលងាយរងគ្រោះ (២)ផ្លាស់ប្តូរឱ្យបានប្រសើរនូវអាកប្បកិរិយារបស់អ្នកផ្តល់សេវាសុខាភិបាល ចំពោះអតិថិជនជាពិសេស ចំពោះអ្នកក្រីក្រ (៣)ដាក់បញ្ចូល និងអភិវឌ្ឍវប្បធម៌គុណភាពនៅក្នុងវិស័យសុខាភិបាលសាធារណៈ (៤)បង្កើនចំនួនឆ្មបតាមរយៈការបណ្តុះបណ្តាលជាមូលដ្ឋាន (៥)ធានាឱ្យបាននូវលំហូរមូលនិធិទៀងទាត់ និងគ្រប់គ្រាន់ដល់វិស័យសុខាភិបាល និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ (៦)កែទំរង់រចនាសម្ព័ន្ធ និងនីតិវិធីគ្រប់គ្រងនៅក្រសួងសុខាភិបាល ដើម្បីលើកទឹកចិត្តបុគ្គលិក (៧)ផ្តល់សមត្ថភាពវិជ្ជាជីវៈបន្ថែមទៀតដល់បុគ្គលិកសុខាភិបាល (៨)ផ្តល់ថ្នាំសង្កូវ និងសំភារៈបរិក្ខារពេទ្យបន្ថែមទៀតដល់មន្ទីរពេទ្យសាធារណៈ និងមណ្ឌលសុខភាព និងពង្រីកយុទ្ធនាការផ្តល់ពត៌មានសុខាភិបាលដល់សាធារណៈជន។

### ២.៩.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៥

ការសំរេចបាននូវចំណុចដៅនៃ គអសក៥ ចាំបាច់ត្រូវដោះស្រាយបញ្ហាប្រឈមដូចខាងក្រោមៈ

- កែលំអលទ្ធភាពទទួលសេវាសុខាភិបាលសាធារណៈ ក្នុងចំណោមស្ត្រីក្រីក្រ។ កង្វះលទ្ធភាពជារូបវ័ន្ត ក៏ដូចជាអសមត្ថភាពក្នុងការចំណាយលើការគាំពារសុខភាព បានរាំងខ្ទប់លទ្ធភាពទទួលបានការគាំពារសុខភាពសំរាប់ស្ត្រីក្រីក្រជាច្រើន។
- បង្កើនថវិកាក្នុងវិស័យសុខាភិបាល និងធានាឱ្យបាននូវលំហូរមូលនិធិទៀងទាត់ ទៅថ្នាក់មូលដ្ឋានសំរាប់ការគាំពារសុខភាពក្នុងពេលសំរាលកូន រួមទាំងការរំលូតកូនប្រកបដោយសុវត្ថិភាព។
- បង្កើនចំនួនបុគ្គលិកជំនាញ និងធានាឱ្យបាននូវការបញ្ជូនពួកគេឱ្យទៅបំរើការ នៅតំបន់ខ្វះសេវាសុខាភិបាល។ កង្វះបុគ្គលិកជំនាញនៅតំបន់ដាច់ស្រយាល បានរាំងខ្ទប់លទ្ធភាពទទួលសេវាការសំរាលកូនដោយសុវត្ថិភាពសំរាប់ស្ត្រីជាច្រើន។
- ពង្រីកចំណេះដឹងអំពីសារៈសំខាន់ នៃការគាំពារសុខភាពបន្តពូជក្នុងចំណោមស្ត្រីក្រីក្រ ក៏ដូចជាអំពីប្រសិទ្ធភាពនៃការប្រើប្រាស់វិធីពន្យារកំនើត និងវិធីដទៃទៀតនៃការធ្វើផែនការគ្រួសារ ជាពិសេសក្នុងចំណោមអ្នករស់នៅតំបន់ដាច់ស្រយាល ដែលជំនឿទំនៀមទំលាប់នៅមានឥទ្ធិពលនៅឡើយ។
- ផ្តល់អំណាចដល់ស្ត្រី លើជំរើសលទ្ធភាពបន្តពូជ ដោយរួមទាំងការប្រើប្រាស់វិធីពន្យារកំនើត។

### ២.៩.៥ ក្របខ័ណ្ឌការងារ ដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅ គអសក៥

ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងបញ្ហាប្រឈម ដែលបានលើកឡើងខាងលើរួមមាន ចំណុចសំខាន់ៗ ដូចខាងក្រោមនេះៈ

- ធនធានហិរញ្ញវត្ថុសាធារណៈត្រូវកំណត់ សំរាប់បែងចែកដល់សេវាកម្មសុខាភិបាលសំខាន់ៗ ដើម្បីធានាឱ្យបាននូវការផ្គត់ផ្គង់នាពេលអនាគត និងលំហូរថវិកាទៀងទាត់ទៅដល់កំរិតមូលដ្ឋាន។
- ចំណាយលើវិស័យសុខាភិបាលឱ្យកាន់តែប្រសើរឡើង ដល់តំបន់ដាច់ពីគេ និងតំបន់ដាច់ស្រយាល ដើម្បីបង្កើនសុវត្ថិភាពមាតា និងសេវាកម្មដទៃទៀតទៅដល់មូលដ្ឋាន ដូចជាការចាក់ថ្នាំការពារ ការថែទាំមុនពេលសំរាលកូន ការពន្យារកំនើត ការផ្តល់ប្រឹក្សា និងការតាមដានលើអាហារូបត្ថម្ភ។
- បង្កើនបន្ថែមទៀតនូវចំនួនឆ្មបជំនាញ ទៅធ្វើការនៅតំបន់ជនបទដាច់ស្រយាល តាមរយៈការលើកទឹកចិត្តខាងហិរញ្ញវត្ថុ។
- កែលំអការគ្រប់គ្រងប្រព័ន្ធសុខាភិបាលសាធារណៈ ដើម្បីផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាពល្អប្រសើរដល់ស្ត្រីទាំងអស់ដោយរួមទាំងអ្នកក្រីក្រផងដែរ។ ប្រការនេះរួមមានការឈានឆ្ពោះទៅរកវិធីគ្រប់គ្រង ដែលផ្អែកលើលទ្ធផល និងការពង្រីកវិមជ្ឈការ។
- បង្កើនលទ្ធភាពទទួលបានថវិកាដល់ស្ត្រីក្រីក្រ ក្នុងការគាំពារសុខភាពតាមរយៈជំរើសគោលនយោបាយមួយចំនួន ជាពិសេសការលើកលែងថ្លៃឈ្នួល និងផែនការធានារ៉ាប់រងខ្នាតតូច។

- ពង្រីកយុទ្ធនាការពត៌មានអប់រំ និងទំនាក់ទំនងស្តីពីភាពជាមាតាប្រកបដោយសុវត្ថិភាព ការធ្វើផែនការគ្រួសារ ។ល។ ដែលសំដៅលើស្ត្រី និងបុរសក្រីក្រ។
- យុទ្ធនាការផ្សព្វផ្សាយពត៌មាន អំពីប្រភេទនៃសេវាកម្មទាំងឡាយ ដែលមាននៅតាមមន្ទីរពេទ្យសាធារណៈសំរាប់ស្ត្រី។

### ២.៥.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៥

រូប ២.៥.២ បង្ហាញពីការបែងចែកតាមតំបន់នៃសូចនាករ គអសក៥ តាមខេត្ត/ក្រុង។ តំលៃនីមួយៗតំណាងអោយសន្ទស្សន៍មានទំងន់មធ្យមស្មើគ្នា (equally weighted index) នៃសូចនាករដែលមានទិន្នន័យទាំងអស់របស់ គអសក៥។ សន្ទស្សន៍រួមដែលជាលទ្ធផលបង្ហាញនូវរូបភាពបំបែកមួយ នៃស្ថានភាពប្រទេសទាក់ទងទៅនឹងការលើកកំពស់សុខភាពមាតា។ លទ្ធផលទាំងនេះអនុញ្ញាតិឱ្យយើង ធ្វើការបែងចែកខេត្ត/ក្រុងជាបីលំដាប់ថ្នាក់។ ខេត្ត/ក្រុងដែលមានពណ៌បៃតង ជាខេត្ត/ក្រុងដែលមានលទ្ធភាពប្រសើរជាងគេក្នុងការឈានទៅសំរេចចំណុចដៅ។ ខេត្ត/ក្រុងដែលមានពណ៌លឿង ជាខេត្ត/ក្រុងដែលមានលទ្ធភាពមធ្យម ហើយខេត្ត/ក្រុងដែលមានពណ៌ក្រហម មានលទ្ធភាពខ្សោយជាងគេក្នុងការឈានទៅសំរេចចំណុចដៅនៅឆ្នាំ២០១៥។ បណ្តាខេត្ត/ក្រុងដែលមានលក្ខណៈអន់ជាងគេទាំងនោះ ភាគច្រើនគឺស្ថិតនៅភាគខាងជើង ភាគឦសាន និងភាគកណ្តាលនៃប្រទេស។

**រូប ២.៥.២: សន្ទស្សន៍រួមនៃ គអសក៥ តាមខេត្ត/ក្រុង**




សំគាល់: សន្ទស្សន៍របស់ គអសក៥ គឺជាមធ្យមភាគដែលមានទំងន់ស្មើគ្នា ទៅតាមលំដាប់ខេត្តនីមួយៗ លើអថេរ នៃសូចនាករ៥ របស់ គអសក៥។

### តារាង ២.៥.៣: សន្ទស្សន៍រួមនៃ គអសក៥ តាមខេត្ត/ក្រុង

| លេខកូដ | ខេត្ត/ក្រុង | សូចនាករ ៥.២ | សូចនាករ ៥.៣ | សូចនាករ ៥.៤ | សូចនាករ ៥.៧ | សូចនាករ ៥.៨ | សន្ទស្សន៍ គអសក៥ |
|---|---|---|---|---|---|---|---|
| ១២ | ភ្នំពេញ | ១,០០០ | ១,០០០ | ០,៩០០ | ០,៣៥៩ | ០,៦៦៩ | **០,៧៨៦** |
| ២៤ | ប៉ៃលិន | ០,៤២៩ | ០,៤២៥ | ១,០០០ | ១,០០០ | ០,៨៧៥ | **០,៧៤៦** |
| ០២ | បាត់ដំបង | ០,៤២៩ | ០,៤២៥ | ១,០០០ | ១,០០០ | ០,៨៧៥ | **០,៧៤៦** |
| ០៩ | កោះកុង | ០,៤៧៦ | ០,២៤២ | ០,៣០០ | ០,៧០៥ | ១,០០០ | **០,៥៤៥** |
| ១៨ | ក្រុងព្រះសីហនុ | ០,៥២៤ | ០,២៤៤ | ០,៦០០ | ០,៦០៩ | ០,៧១៨ | **០,៥៣៩** |
| ២៣ | ក្រុងកែប | ០,៥២៤ | ០,២៤៤ | ០,៦០០ | ០,៦០៩ | ០,៧១៨ | **០,៥៣៩** |
| ០៧ | កំពត | ០,៥២៤ | ០,២៤៤ | ០,៦០០ | ០,៦០៩ | ០,៧១៨ | **០,៥៣៩** |
| ០១ | បន្ទាយមានជ័យ | ០,៤៧៦ | ០,៣២០ | ០,៩៩៥ | ០,៣៦៥ | ០,១៥៣ | **០,៤៦២** |
| ០៨ | កណ្ដាល | ០,៥៩៥ | ០,៥៣៣ | ០,៤០០ | ០,០៥១ | ០,៦០៥ | **០,៤៣៧** |
| ២០ | ស្វាយរៀង | ០,៦៦៧ | ០,១៣៥ | ០,៦៥០ | ០,៣៥៩ | ០,៣៦៣ | **០,៤៣៥** |
| ១៤ | ព្រៃវែង | ០,៦៦៧ | ០,១៧៣ | ០,៣៥០ | ០,២១៨ | ០,៥៨៩ | **០,៣៩៩** |
| ១៥ | ពោធិ៍សាត់ | ០,៤០៥ | ០,០៩១ | ០,៣០០ | ០,៦៣៥ | ០,២៣៨ | **០,៣៣៤** |
| ០៣ | កំពង់ចាម | ០,៥០០ | ០,១៣៧ | ០,២៥០ | ០,៣០១ | ០,៤៤៤ | **០,៣២៦** |
| ២១ | តាកែវ | ០,៥២៤ | ០,៣៥៨ | ០,៥៥០ | ០,០០០ | ០,១៨៥ | **០,៣២៣** |
| ១៩ | ស្ទឹងត្រែង | ០,៤០៥ | ០,៣៧១ | ០,១៥០ | ០,២៦៣ | ០,៣៦៧ | **០,៣១១** |
| ១៣ | ព្រះវិហារ | ០,៤០៥ | ០,៣៧១ | ០,១៥០ | ០,២៦៣ | ០,៣៦៧ | **០,៣១១** |
| ១០ | ក្រចេះ | ០,៤០៥ | ០,៣៧១ | ០,១៥០ | ០,២៦៣ | ០,៣៦៧ | **០,៣១១** |
| ០៦ | កំពង់ធំ | ០,៤៧៦ | ០,០៤៤ | ០,៤៥០ | ០,៣៩១ | ០,០៩៧ | **០,២៩២** |
| ០៤ | កំពង់ឆ្នាំង | ០,២៦២ | ០,០៦០ | ០,៣០០ | ០,០៥៨ | ០,៧១៨ | **០,២៧៩** |
| ០៥ | កំពង់ស្ពឺ | ០,៤០៥ | ០,០៤០ | ០,០៥០ | ០,១៦០ | ០,៣៨៧ | **០,២០៨** |
| ១៧ | សៀមរាប | ០,៤០៥ | ០,០០០ | ០,២៥០ | ០,២៨៨ | ០,០០០ | **០,១៨៩** |
| ២២ | ឧត្តរមានជ័យ | ០,៤០៥ | ០,០០០ | ០,២៥០ | ០,២៨៨ | ០,០០០ | **០,១៨៩** |
| ១៦ | រតនគិរី | ០,០០០ | ០,០២៩ | ០,០០០ | ០,២០៥ | ០,២៥០ | **០,០៩៧** |
| ១១ | មណ្ឌលគិរី | ០,០០០ | ០,០២៩ | ០,០០០ | ០,២០៥ | ០,២៥០ | **០,០៩៧** |

ប្រភព: ក្រសួងផែនការ និងក្រសួងសុខាភិបាល ២០០១។

## ២.៦ គោលដៅទី៦: ការប្រយុទ្ធនឹងមេរោគអេដស៍/ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺដទៃទៀត

គោលដៅទី ៦ សំដៅទប់ស្កាត់ព្រមទាំងកាត់បន្ថយ នូវការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ អត្រាឆ្លងថ្មីនៃជម្ងឺគ្រុនចាញ់ និងជម្ងឺធ្ងន់ធ្ងរដទៃទៀតដូចជាជម្ងឺរបេងជាដើម។

### ២.៦.១ សូចនាករ និងចំណុចដៅនៃ គអសក៦

តារាង ២.៦.១ បានបង្ហាញឱ្យឃើញនៅក្នុងជួរឈរខាងឆ្វេង គឺជាចំណុចដៅ និងសូចនាករដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ រីឯជួរឈរខាងស្ដាំ បង្ហាញពីចំណុចដៅ និងសូចនាករដែលបានជ្រើសរើសដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ សំខាន់ៗរួចមក។

**តារាង ២.៦.១: មូលដ្ឋានីយកម្មនៃ គអស៦ ទៅជា គអសក៦**

| គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលទី៦ | គអសក៦ |
|---|---|
| **ចំណុចដៅទី៧:** ទប់ស្កាត់ និងកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ អោយបាននៅឆ្នាំ២០១៥ | **ចំណុចដៅរួមទី១១:** បន្ថយការរីករាលដាល នៃមេរោគអេដស៍/ជម្ងឺអេដស៍ |
| **សូចនាករ១៨:** អត្រាប្រេវ៉ាឡង់ នៃមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះដែលមានអាយុពី ១៥-២៤ឆ្នាំ | **សូចនាករ៦.១:** អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥-៤៩ឆ្នាំ |
| | **សូចនាករ៦.២:** អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ ដែលមានអាយុពី ១៥-២៤ឆ្នាំ បានពិនិត្យផ្ទៃពោះមុនពេលសំរាលកូន |
| **សូចនាករ១៩:** អត្រាប្រើស្រោមអនាម័យក្នុងអត្រាប្រេវ៉ាឡង់នៃការពន្យារកំនើត | **សូចនាករ៦.៣:** អត្រាប្រើស្រោមអនាម័យ ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ ក្នុងពេលរួមភេទចុងក្រោយ |
| | **សូចនាករ៦.៤:** ភាគរយនៃយុវជនអាយុពី ១៥-២៤ឆ្នាំ ដែលបានរាយការណ៍ ពីការប្រើស្រោមអនាម័យ ក្នុងពេលរួមភេទជាមួយដៃគូមិនទៀងទាត់ |
| | **សូចនាករ៦.៥:** សមាមាត្រនៃការប្រើស្រោមអនាម័យ ដែលបានរាយការណ៍ដោយស្ត្រីរៀបការដែលដឹងថាខ្លួនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ |
| **សូចនាករ២០:** ចំនួនកុមារកំព្រាដោយសារជម្ងឺអេដស៍ | **សូចនាករ៦.៦:** ភាគរយនៃស្ត្រីពិនិត្យផ្ទៃពោះមុនពេលសំរាល ដែលមានផ្ទុកមេរោគអេដស៍ ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្ដាយទៅកូន |
| | **សូចនាករ៦.៧:** ភាគរយនៃអ្នកជំងឺអេដស៍ ដែលបានទទួលថ្នាំប្រឆាំងនឹងមេរោគអេដស៍ |
| **ចំណុចដៅទី៨:** ទប់ស្កាត់ និងការកាត់បន្ថយអត្រាឆ្លងថ្មីនៃជម្ងឺគ្រុនចាញ់ និងជម្ងឺធ្ងន់ធ្ងរដទៃទៀតអោយបាននៅឆ្នាំ២០១៥ | **ចំណុចដៅរួមទី១២:** បន្ថយការរីករាលដាល នៃជម្ងឺគ្រុនចាញ់ គ្រុនឈាម និងរបេង |
| **សូចនាករ២១:** អត្រាប្រេវ៉ាឡង់ និងអត្រាស្លាប់ដោយសារជម្ងឺគ្រុនចាញ់ | **សូចនាករ៦.៨:** អត្រាស្លាប់ដោយសារជម្ងឺគ្រុនចាញ់ ដែលបានរាយការណ៍ ដោយផ្នែកសុខាភិបាលសាធារណ: |
| **សូចនាករ២២:** សមាមាត្រនៃប្រជាជននៅតំបន់ប្រឈមមុខនឹងជម្ងឺគ្រុនចាញ់ ដែលប្រើប្រាស់វិធីបង្ការ និងវិធានការ | **សូចនាករ៦.៩:** សមាមាត្រនៃប្រជាជន នៅតំបន់មានជម្ងឺគ្រុនចាញ់ខ្ពស់ ដែលប្រើមុងជ្រលក់ថ្នាំកាលពីយប់កន្លងមក |

| | |
|---|---|
| ព្យាបាលប្រកបដោយប្រសិទ្ធភាព | **សូចនាករ៦.១០:** ចំនួនអ្នកជំងឺគ្រុនចាញ់បានទទួលការព្យាបាលក្នុងផ្នែកសុខាភិបាលសាធារណៈក្នុងប្រជាជន ១០០០ នាក់ |
| | **សូចនាករ៦.១១:** សមាមាត្រនៃសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់ពីរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់៩៥%តាមរូបមន្តជាតិ |
| | **សូចនាករ៦.១២:** ចំនួនអ្នកជម្ងឺគ្រុនឈាមទទួលការព្យាបាល ក្នុងផ្នែកសុខាភិបាលសាធារណៈក្នុងប្រជាជន ១០០០ នាក់ |
| | **សូចនាករ៦.១៣:** អត្រាស្លាប់ដោយសារជម្ងឺគ្រុនឈាមដែលបានរាយការណ៍ពីផ្នែកសុខាភិបាលសាធារណៈ |
| **សូចនាករ២៣:** អត្រាប្រេវ៉ាឡង់ និងអត្រាស្លាប់ដោយសារជម្ងឺរបេង | **សូចនាករ៦.១៤:** អត្រាប្រេវ៉ាឡង់នៃជម្ងឺរបេងសួតវិជ្ជមាន BK ក្នុងប្រជាជន ១០០០០០ នាក់ |
| | **សូចនាករ៦.១៥:** អត្រាស្លាប់ ដោយសារជម្ងឺរបេង ក្នុងប្រជាជន ១០០០០០ នាក់ |
| **សូចនាករ២៤:** សមាមាត្រនៃករណីជម្ងឺរបេងដែលបានរកឃើញ និងព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) | **សូចនាករ៦.១៦:** សមាមាត្រនៃអ្នកដែលបានប៉ាន់ស្មានថាមានករណីជម្ងឺរបេងសួតវិជ្ជមាន BK ថ្មី បានរកឃើញក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) |
| | **សូចនាករ៦.១៧:** សមាមាត្រនៃអ្នកជម្ងឺរបេងសួតវិជ្ជមាន BK ដែលបានកត់ត្រា ហើយបានព្យាបាលប្រកបដោយជោគជ័យក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) |

តារាង ២.៦.២ បង្ហាញនូវតំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៦ តាមលំដាប់ឆ្នាំ។ តម្លៃទិន្នន័យមូលដ្ឋានទាំងនេះ គឺជាតួលេខដែលមានថ្មីៗបំផុត។

**តារាង ២.៦.២: តំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៦ តាមលំដាប់ឆ្នាំ**

| **សូចនាករ** | **ទិន្នន័យមូលដ្ឋាន** | | **ចំណុចដៅ** | | |
|---|---|---|---|---|---|
| | **តំលៃ** | **ឆ្នាំ** | **២០០៥** | **២០១០** | **២០១៥** |
| ៦.១ អត្រាប្រេវ៉ាឡង់ នៃមេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ័យ អាយុពី ១៥-៤៩ឆ្នាំ | ៣.៣% | ១៩៩៧ | ២.៣ | ២.០ | ១.៨ |
| ៦.២ អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ ដែលមានអាយុពី ១៥-២៤ឆ្នាំ បានពិនិត្យផ្ទៃពោះមុនពេលសំរាល | ២.៨% | ១៩៩៨ | ២.៤ | ២.០ | ១.៥ |
| ៦.៣ អត្រាប្រើស្រោមអនាម័យ ក្នុងចំណោមអ្នករកស៊ីផ្លូវភេទក្នុងពេលរួមភេទចុងក្រោយ | ៩១% | ២០០២ | ៩៨ | ៩៨ | ៩៨ |
| ៦.៤ ភាគរយនៃយុវជនអាយុពី ១៥-២៤ឆ្នាំ ដែលបានរាយការណ៍ពីការប្រើស្រោមអនាម័យក្នុងពេលរួមភេទជាមួយដៃគូមិនទៀងទាត់ | ៨២% | ២០០២ | ៨៥ | ៩០ | ៩៥ |
| ៦.៥ សមាមាត្រនៃការប្រើស្រោមអនាម័យ ដែលបានរាយការណ៍ដោយស្ត្រីរៀបការដែលដឹងថាខ្លួនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ | ១% | ២០០០ | ២ | ៥ | ១០ |
| ៦.៦ ភាគរយនៃស្ត្រីពិនិត្យផ្ទៃពោះមុនពេលសំរាល ដែលមានផ្ទុកមេរោគអេដស៍ ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្តាយទៅកូន | ២.៧% | ២០០២ | ១០ | ៣៥ | ៥០ |
| ៦.៧ ភាគរយនៃអ្នកជំងឺអេដស៍ ដែលបានទទួលថ្នាំប្រឆាំងនឹងមេរោគអេដស៍ | ៣% | ២០០២ | ២៥ | ៦០ | ៧៥ |
| ៦.៨ អត្រាស្លាប់ដោយសារជម្ងឺគ្រុនចាញ់ ដែលបានរាយការណ៍ ដោយផ្នែកសុខាភិបាលសាធារណៈ | ០,៤% | ២០០០ | ០,៣ | ០,២ | ០,១ |
| ៦.៩ សមាមាត្រនៃប្រជាជន នៅតំបន់មានជម្ងឺគ្រុនចាញ់ខ្ពស់ ដែលប្រើមុងជ្រលក់ថ្នាំកាលពីយប់កន្លងមក | ២៤% | ១៩៩៨ | ៨០ | ៩៥ | ៩៨ |

| | | | | | |
|---|---|---|---|---|---|
| ៦.១០ ចំនួនអ្នកជំងឺគ្រុនចាញ់ ដែលបានទទួលការព្យាបាល នៅក្នុងផ្នែកសុខាភិបាលសាធារណៈ ក្នុងប្រជាជន ១០០០ នាក់ | ១១.៤ | ២០០០ | ៩ | ៧ | ៤ |
| ៦.១១ សមាមាត្រនៃសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់ពីរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់ ៩៥% តាមរូបមន្តជាតិ | ៦០% | ២០០២ | ៧០ | ៨០ | ៩៥ |
| ៦.១២ ចំនួនអ្នកជម្ងឺគ្រុនឈាម ដែលបានទទួលការព្យាបាល នៅក្នុងផ្នែកសុខាភិបាលសាធារណៈ ក្នុងប្រជាជន ១០០០ នាក់ | ១ | ២០០១ | ០,៨ | ០,៦ | ០,៤ |
| ៦.១៣ អត្រាស្លាប់ដោយសារជម្ងឺគ្រុនឈាម ដែលបានរាយការណ៍ ពីផ្នែកសុខាភិបាលសាធារណៈ | ១,៥% | ២០០៣ | ១ | ០,៥ | ០,៣ |
| ៦.១៤ អត្រាប្រេវ៉ាឡង់ នៃជម្ងឺរបេងសួតវិជ្ជមាន BK ក្នុង ១០០០០០ នាក់ | ៤២៨ | ១៩៩៧ | ៣២១ | ២១៤ | ១៣៥ |
| ៦.១៥ អត្រាស្លាប់ ដោយសារជម្ងឺរបេង ក្នុងប្រជាជន ១០០០០០ នាក់ | ៩០ | ១៩៩៧ | ៦៨ | ៤៥ | ៣២ |
| ៦.១៦ សមាមាត្រនៃអ្នកដែលបានប៉ាន់ស្មានថាមានករណីជម្ងឺរបេងសួតវិជ្ជមាន BK ថ្មី បានរកឃើញក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) | ៥៧% | ២០០២ | ៧០ | >៧០ | >៧០ |
| ៦.១៧ សមាមាត្រនៃអ្នកជម្ងឺរបេងសួតវិជ្ជមាន BK ដែលបានកត់ត្រា ហើយបានព្យាបាលប្រកបដោយជោគជ័យ ក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) | ៨៩% | ២០០២ | >៨៥ | >៨៥ | >៨៥ |

សំគាល់: សំរាប់សូចនាករ ៦.១ និង ៦.២ ឆ្នាំ១៩៩៧ និង១៩៩៨ ត្រូវបានជ្រើសរើសជាទិន្នន័យឆ្នាំមូលដ្ឋាន ដោយសារក្នុងរយៈពេលនោះ វាជាការឆ្លើយតបយ៉ាងយកចិត្តទុកដាក់ចំពោះការរាតត្បាតដែលបានចាប់ផ្តើម ។ ករណីផ្សេងទៀត ទិន្នន័យមូលដ្ឋានតំណាងអោយទិន្នន័យដែលមាន ។

## ២.៦.២ មេរោគអេដស៍/ជម្ងឺអេដស៍

### ២.៦.២.១ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៦ ស្តីពីមេរោគអេដស៍/ជំងឺអេដស៍

អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ ក្នុងប្រជាជនពេញវ័យ (អាយុពី ១៥-៤៩ឆ្នាំ) បានធ្លាក់ចុះពី ៣,៣% មក ២,៦% ក្នុងរវាងឆ្នាំ១៩៩៧ និងឆ្នាំ២០០២ ។ ការបន្ទាយនិន្នាការជាខ្សែបន្ទាត់បង្ហាញថា ប្រទេសកម្ពុជានឹងសំរេចបាននូវចំណុចដៅ គអសក ដែលមាន ១,៨% ក្នុងឆ្នាំ២០១៥ ។ ក៏ដូចជាក្នុងផ្នែកដទៃទៀតនៃឯកសារនេះដែរ ចំណោលជាបន្ទាត់នៃនិន្នាការកន្លងមក គួរតែត្រូវបកស្រាយដោយប្រុងប្រយ័ត្ន ព្រោះមានកត្តាជាច្រើនអាច ប្រែប្រួលដូចជា អាយុកាលអាចរស់បានរបស់អ្នកផ្ទុកមេរោគអេដស៍ និងការផ្លាស់ប្តូរទំលាប់នៃការប្រព្រឹត្ត ។

**រូប ២.៦.១: និន្នាការ និងចំណុចដៅនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ័យ អាយុពី ១៥-៤៩ឆ្នាំ**




ប្រភព: មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងមេរោគអេដស៍/ជម្ងឺអេដស៍ សើរស្បែក និងកាមរោគ ២០០២

អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ (អាយុពី ១៥-២៤ឆ្នាំ) បានពិនិត្យផ្ទៃពោះមុនពេលសំរាលកើនឡើងពី ០,៧៥% ទៅ ២,៧% ក្នុងរវាងឆ្នាំ១៩៩៣ និងឆ្នាំ២០០២។ សូចនាករតំណាងនៃការឆ្លងពីម្តាយទៅកូននេះ នៅមានកំរិតខ្ពស់ណាស់ហើយមិនទំនងជាថយចុះវិញទេ ក្នុងពេលខ្លីខាងមុខនេះ។ ដោយហេតុនេះត្រូវការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីអាចសំរេចបាននូវចំណុចដៅដែលបានកំណត់ ១,៥% ក្នុងឆ្នាំ២០១៥។

## រូប ២.៦.២: និន្នាការ និងចំណុចដៅនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមស្ត្រីអាយុពី ១៥-២៤ឆ្នាំ បានពិនិត្យផ្ទៃពោះមុនពេលសំរាល




ប្រភព: មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ សើរស្បែក និងកាមរោគ ២០០២

ប្រទេសកម្ពុជាបានសំរេចនូវសមិទ្ធិផលយ៉ាងធំ លើការប្រើស្រោមអនាម័យក្នុងចំណោមអ្នករកស៊ីផ្លូវភេទដោយផ្ទាល់។ សូចនាករនេះបានកើនឡើងយ៉ាងលឿនពី ១៦% ទៅដល់ជាង ៩១% ក្នុងរវាងឆ្នាំ១៩៩៦ និងឆ្នាំ២០០២ ដែលធ្វើឱ្យប្រទេសកម្ពុជាស្ថិតនៅក្នុងមាគ៌ាមួយដ៏ល្អឆ្ពោះទៅសំរេចចំណុចដៅរបស់ គអសក នៃការប្រើស្រោមអនាម័យ ១០០%។ ប៉ុន្តែគួរកត់សំគាល់ដែរថា ការប្រើស្រោមអនាម័យដោយអ្នករកស៊ីផ្លូវភេទដោយប្រយោល នៅមានកំរិតទាបជាងច្រើន គឺប្រហាក់ប្រហែល ៥៦%ប៉ុណ្ណោះ (NCHADS ២០០២ក)។

សូចនាករមួយចំនួន ពុំមានទិន្នន័យគ្រប់ឆ្នាំ សំរាប់ធ្វើចំណោលនិន្នាការបានទេ សូចនាករទាំងនោះ រួមមានភាគរយនៃយុវជនអាយុពី ១៥-២៤ឆ្នាំ ដែលបានរាយការណ៍ពីការប្រើស្រោមអនាម័យ ក្នុងពេលរួមភេទជាមួយដៃគូមិនទៀងទាត់ ៨២% ឆ្នាំ២០០២ (NCHADS ២០០២ក) សមាមាត្រនៃការប្រើស្រោមអនាម័យ ដែលបានរាយការណ៍ដោយស្ត្រីរៀបការ ដែលដឹងថាខ្លួនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ១% ឆ្នាំ២០០០ (MOP & MOH 2001) ភាគរយនៃស្ត្រីពិនិត្យផ្ទៃពោះមុនពេលសំរាល ដែលមានផ្ទុកមេរោគអេដស៍ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្តាយទៅកូន ២,៧% ឆ្នាំ២០០២ (NAA ២០០៣) ភាគរយនៃអ្នកជំងឺអេដស៍ដែលបានទទួលថ្នាំប្រឆាំងនឹងមេរោគអេដស៍ ៣% (NAA ២០០៣)។ ចំណុចដៅដែលបានស្នើឡើងសំរាប់សូចនាករទាំងនេះ ត្រូវបានកំណត់តាមលំដាប់លំដោយក្នុងកំរិត ៩៥% ១០% ៥០% និង ៧៥% ក្នុងឆ្នាំ២០១៥។

### ២.៦.២.២ គោលនយោបាយ និងកម្មវិធីសំខាន់ៗនាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់មេរោគអេដស៍/ជម្ងឺអេដស៍

អាជ្ញាធរជាតិប្រយុទ្ធជម្ងឺអេដស៍ដែលរួមទាំងក្រសួងចំនួន ២៦ទៀត ជាអង្គការកំពូលដែលត្រូវបានបង្កើតឡើងដើម្បីដឹកនាំការឆ្លើយតបជាពហុវិស័យ ចំពោះមេរោគអេដស៍/ជម្ងឺអេដស៍។ ក្រសួងសុខាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ បានរៀបចំផែនការយុទ្ធសាស្ត្រជាតិមួយ ដើម្បីកាត់បន្ថយមេរោគអេដស៍/ជម្ងឺអេដស៍ក្នុងប្រទេសកម្ពុជា ព្រមទាំងផ្តល់ការថែទាំ និងការគាំទ្រដល់អ្នករស់នៅដែល ផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍។ ផែនការយុទ្ធសាស្ត្រជាតិសំរាប់ការបង្ការ និងការថែទាំអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងជម្ងឺកាមរោគ (២០០១-២០០៥) ផ្តោតទៅលើចំនុចសំខាន់ៗបីៈ ១) ចាំបាច់ត្រូវកាត់បន្ថយការឆ្លងនៅក្នុងក្រុមដែលប្រឈមមុខនឹងស្ថានភាពគ្រោះថ្នាក់ខ្ពស់ ២) ត្រូវការជាចាំបាច់នូវការអប់រំសុខភាព និងកិច្ចប្រឹងប្រែងបង្ការថែមទៀតក្នុងចំណោមប្រជាជនទូទៅ និង ៣) ចាំបាច់ត្រូវបំពាក់បរិក្ខារដល់ប្រព័ន្ធសុខាភិបាល ដើម្បីដោះស្រាយតំរូវការដែលចេះតែកើនឡើង។ លើសពីនេះទៀត ចក្ខុវិស័យរបស់អាជ្ញាធរជាតិប្រយុទ្ធមេរោគអេដស៍/ជំងឺអេដស៍ត្រូវបានដាក់បញ្ចូលទៅក្នុង "ផែនការយុទ្ធសាស្ត្រជាតិចំពោះការឆ្លើយតបជាពហុវិស័យ និងទូលំទូលាយស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ឆ្នាំ២០០១-២០០៥" ដែលផ្អែកទៅលើវិធីសាស្ត្ររួមផ្សំពីរ នៃការតស៊ូមតិអោយមានការផ្លាស់ប្តូរផ្នត់គំនិត។ វិធីសាស្ត្រទីមួយសំដៅលើការមានឥទ្ធិពលរបស់បុគ្គលចំពោះការយល់ដឹងលើសុវត្ថិភាពការប្រព្រឹត្ត គឺជាជំរើសដ៏ល្អ រីឯវិធីសាស្ត្រទីពីរ សំដៅលើការផ្លាស់ប្តូរបរិបទ សេដ្ឋកិច្ច-សង្គមកិច្ច ដែលមានកន្លងមក ដើម្បីគាំទ្រដល់បុគ្គល ក៏ដូចជាការការពារពួកគេពីការឆ្លងមេរោគអេដស៍ ព្រមទាំងដោះស្រាយនូវផលវិបាកដោយសារមេរោគអេដស៍/ជំងឺអេដស៍។ យោងតាមក្របខ័ណ្ឌការងារនេះ មានយុទ្ធសាស្ត្រ ៧ ត្រូវបានចងក្រងឡើងដូចខាងក្រោម (អាជ្ញាធរជាតិប្រយុទ្ធមេរោគអេដស៍/ជំងឺអេដស៍ ឆ្នាំ២០០១)ៈ

- ផ្តល់សិទ្ធិអំណាចដល់បុគ្គល គ្រួសារ និងសហគមន៍ ក្នុងការការពារមេរោគអេដស៍ និងដោះស្រាយផលវិបាកនៃមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈការលើកកំពស់បរិស្ថានសង្គម វប្បធម៌ និងសេដ្ឋកិច្ច ដែលនាំមកនូវការបង្ការ ការថែទាំ និងទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍។
- កែលំអរិធានការនីតិបញ្ញត្តិ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍។
- ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង ដំណើរការ និងយន្តការ ដើម្បីបង្កើនសមត្ថភាពផ្នែកសំរបសំរួល តាមដាន និងអនុវត្តសកម្មភាពមេរោគអេដស៍/ជំងឺអេដស៍ និងបង្កើនសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងអន្តរជាតិ។
- ពង្រឹង និងពង្រីកវិធានការបង្ការដែលមានប្រសិទ្ធភាព និងអន្តរាគមន៍ផ្សេងៗ។
- ពង្រឹង និងពង្រីកសកម្មភាពថែទាំ និងគាំទ្រ ប្រកបដោយប្រសិទ្ធភាព និងអន្តរាគមន៍ថ្មីៗ។
- ពង្រឹងសមត្ថភាពជាតិ សំរាប់ការតាមដាន ការវាយតំលៃ និងការស្រាវជ្រាវ។
- កៀរគរធនធាន ដើម្បីធានានូវសមត្ថភាពមនុស្ស និងការផ្តល់មូលនិធិគ្រប់គ្រាន់ នៅគ្រប់លំដាប់ថ្នាក់។

អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ជាអ្នកទទួលខុសត្រូវ លើការអភិវឌ្ឍន៍គោលនយោបាយ ពង្រឹងទំនាក់ទំនងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសំរបសំរួលការឆ្លើយតបជាពហុវិស័យចំពោះមេរោគអេដស៍

/ជម្ងឺអេដស៍ កៀរគរធនធានពីស្ថាប័ន និងភ្នាក់ងារជាតិ និងអន្តរជាតិ បញ្ចុះបញ្ចូលឱ្យមានការគាំទ្រផ្នែកនីតិបញ្ញត្តិ និងស្រាវជ្រាវលើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមកិច្ចនៃមេរោគអេដស៍/ជម្ងឺអេដស៍ សំរបសំរួលកម្មវិធីស្រាវជ្រាវ និងពិនិត្យឡើងវិញព្រមទាំងអនុម័តកម្មវិធីពតិមាន អប់រំ និងទំនាក់ទំនង នៅក្នុងគ្រប់វិស័យទាំងអស់។ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មានគោលបំណងកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ស្ត្រី និងក្មេងស្រី ចំពោះមេរោគអេដស៍/ជម្ងឺអេដស៍ និងបង្កើនស្ថានភាពរបស់ពួកគាត់ ដោយរិះរកវិធីដើម្បីលុបបំបាត់នូវអាកប្បកិរិយារើសអើងក្នុងសង្គម ជាពិសេសនៅក្នុងចំណោមបុរស។ មជ្ឈមណ្ឌលជាតិប្រយុទ្ធមេរោគអេដស៍/ជម្ងឺអេដស៍ សើរស្បែក និងកាមរោគ មានភារកិច្ចទទួលខុសត្រូវលើប្រព័ន្ធតាមដានថ្នាក់ជាតិ និងអនុវត្តកម្មវិធីទាំងឡាយសំរាប់ប្រជាជនដែលទទួលរងមេរោគអេដស៍/ជម្ងឺអេដស៍។ លើសពីនេះទៀត ច្បាប់ស្តីពីការបង្ការ និងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវបានអនុម័តដោយសភាជាតិ នៅថ្ងៃទី ១៤ ខែមិថុនា កាលពីឆ្នាំទៅ។

នៅក្នុងឯកសារយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ យុទ្ធសាស្ត្របង្ការ និងលុបបំបាត់មេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវបានដឹកនាំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍។ គោលនយោបាយនេះសំដៅ (១)ពង្រឹងទំនាក់ទំនងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធទាំងអស់ និងសំរបសំរួលការឆ្លើយតបជាពហុវិស័យ ចំពោះមេរោគអេដស៍/ជម្ងឺអេដស៍ (២)កៀរគរធនធានពីស្ថាប័ន និងភ្នាក់ងារជាតិ និងអន្តរជាតិ (៣)លើកកំពស់ការផ្តល់ពតិមាន និងការអប់រំជាសាធារណៈលើការយល់ដឹងអំពីមេរោគអេដស៍/ជម្ងឺអេដស៍ (៤)បង្កើតកម្មវិធីជាក់លាក់សំរាប់ក្រុមប្រជាជនខុសៗគ្នា (៥)ពង្រឹង និងពង្រីកកម្មវិធីបង្ការ សំដៅចំពោះការឆ្លងពីម្តាយទៅកូន និងកម្មវិធីដទៃទៀតដូចជា កម្មវិធីមិត្តអប់រំមិត្ត កម្មវិធីសុវត្ថិភាពឈាម និងកម្មវិធីការប្រុងប្រយ័ត្នជាសកល។

នៅក្នុងឯកសារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើកទីពីរ ផែនការយុទ្ធសាស្ត្រសំរាប់ការបង្ការ និងការថែទាំអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងកាមរោគសំរាប់រយៈពេលឆ្នាំ២០០១-២០០៥ ត្រូវបានរៀបចំដោយក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិប្រយុទ្ធមេរោគអេដស៍/ជម្ងឺអេដស៍ សើរស្បែក និងកាមរោគ។ គោលដៅនៃផែនការយុទ្ធសាស្ត្រនេះគឺ ១)កាត់បន្ថយអត្រាឆ្លងថ្មីនៃមេរោគអេដស៍ ២)ផ្តល់ការថែទាំ និងការឧបត្ថម្ភគាំទ្រដល់អ្នកដែលរស់នៅ និងអ្នកដែលរងគ្រោះដោយផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និង ៣)កាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចសង្គមកិច្ច និងធនធានមនុស្សនៃជម្ងឺអេដស៍លើបុគ្គល គ្រួសារ សហគមន៍ និងសង្គម។

**២.៦.២.៣ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃមេរោគអេដស៍/ជម្ងឺអេដស៍**

បញ្ហាប្រឈមសំខាន់ៗ ដែលចាំបាច់ត្រូវជំនះឱ្យបាន ដើម្បីសំរេចបាននូវចំណុចដៅនៃមេរោគអេដស៍/ជម្ងឺអេដស៍មានដូចខាងក្រោម:

- ផ្លាស់ប្តូរការយល់ដឹង និងទំលាប់នៃការប្រព្រឹត្តរបស់ប្រជាជន ចំពោះការប្រើស្រោមអនាម័យ ការប្រើគ្រឿងញៀន ការប្រព្រឹត្តផ្លូវភេទ យន្តការចំលងមេរោគអេដស៍/ជម្ងឺអេដស៍ និងកាត់បន្ថយការស្អប់ខ្ពើមចំពោះអ្នករស់នៅដោយផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍។
- ធ្វើឱ្យប្រសើរឡើងនូវការប្រមូល និងវិភាគទិន្នន័យលើស្ថានភាព និន្នាការ និងផលប៉ះពាល់សេដ្ឋកិច្ច-សង្គមកិច្ចនៃរោគរាតត្បាតនេះ។

- បង្កើន និងពង្រីកកម្មវិធីឧបត្ថម្ភគាំទ្រដល់អ្នករស់នៅដោយផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ដោយសង្កត់ធ្ងន់ទៅលើការថែទាំតាមសហគមន៍មូលដ្ឋាន។
- បង្កើនលទ្ធភាពទទួលថ្នាំប្រឆាំងនឹងមេរោគអេដស៍។
- ដោះស្រាយការរើសអើងផ្នែកយេនឌ័រ តាមរយៈយុទ្ធនាការអប់រំ និងការផ្តល់អំណាចដល់ស្ត្រី។
- កសាងសមត្ថភាពស្ថាប័ន និងបុគ្គលព្រមទាំងបង្កើនការគ្រប់គ្រង និងការទទួលខុសត្រូវខាងហិរញ្ញវត្ថុ។
- បង្កើនការសំរបសំរួល និងភាពជាដៃគូរវាងវិស័យផ្សេងៗ រួមមាន ស្ថាប័នឯកជន ស្ថាប័នសាធារណៈ និងស្ថាប័នសាសនា អ្នករស់នៅដោយផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងការរៀបចំដំណើរការនៃភាពជាដៃគូទាំងនេះ។

### ២.៦.២.៤ ក្របខណ្ឌការងារ ដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃមេរោគអេដស៍/ជម្ងឺអេដស៍

ដើម្បីដោះស្រាយបញ្ហាប្រឈមជាគន្លឹះ ដែលបានលើកឡើងខាងលើ និងដើម្បីសំរេចឱ្យបាននូវចំណុចដៅនៃមេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវអនុវត្តតាមទិសដៅជាយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោមៈ

- ធ្វើយុទ្ធនាការផ្តល់ពត៌មាន ការអប់រំ និងទំនាក់ទំនងដែលតម្រង់ចំពោះប្រជាជនទូទៅ ស្តីអំពីសុវត្ថិភាពនៃការប្រព្រឹត្តផ្លូវភេទ យន្តការចំលងមេរោគអេដស៍/ជម្ងឺអេដស៍ ការមិនស្អប់ខ្ពើម ចំពោះអ្នកងាយរងគ្រោះដោយរស់នៅផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងគ្រួសាររបស់ពួកគេ ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងទំនៀមទំលាប់វប្បធម៌ ដែលយល់ដឹងមិនសមហេតុផលអំពីការប្រព្រឹត្តផ្លូវភេទលើស្ត្រី ដែលមានពីមុនមក។
- ពង្រឹងប្រព័ន្ធពត៌មាន ក៏ដូចជាពង្រឹងយន្តការតាមដាន និងវាយតម្លៃផលប៉ះពាល់ ដើម្បីតាមដានការរីករាលដាល និងឥទ្ធិពលនៃមេរោគ។
- ពង្រឹងបរិក្ខារផ្នែកថែទាំសំរាប់អ្នករស់នៅដោយផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ តាមរយៈភាពជាដៃគូនៅក្នុងគ្រប់កំរិត ដោយប្រតិបត្តិជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ និងការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការផ្តល់ការថែទាំជាបណ្តោះអាសន្ន។
- អនុវត្តការថែទាំជាបន្ត តាមរយៈលទ្ធភាពទទួលសេវាកម្មសង្គមកិច្ច និងសុខាភិបាលដោយបង្កើនថវិកាសំរាប់ការព្យាបាលដោយថ្នាំប្រឆាំងនឹងមេរោគអេដស៍ ដល់អ្នករស់នៅដោយផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍។
- ពង្រីកកម្មវិធីបង្ការសំរាប់ការឆ្លងពីម្តាយទៅកូនរួមមាន ការលើកកំពស់សេវាប្រឹក្សា និងការពិនិត្យឈាមដោយស្ម័គ្រចិត្តសំរាប់ស្ត្រីមានផ្ទៃពោះ។

## ២.៦.៣ ជម្ងឺគ្រុនចាញ់ និងគ្រុនឈាម

### ២.៦.៣.១ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៦ ស្តីពីជំងឺគ្រុនចាញ់ និងគ្រុនឈាម

សូចនាករដែលបានអនុម័តដោយក្រសួងសុខាភិបាល ដើម្បីតាមដានការវិវឌ្ឍន៍នៃជម្ងឺគ្រុនចាញ់ រួមមានៈ អត្រាស្លាប់ដោយសារជំងឺគ្រុនចាញ់បានថយចុះពី ០,៦៩% ក្នុងឆ្នាំ១៩៩៦ មកនៅត្រឹម ០.៣៨% ក្នុងឆ្នាំ២០០២ (មជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០០២)។ តាមល្បឿននេះ ប្រទេសកម្ពុជាស្ថិតនៅលើមាគ៌ាដ៏ល្អឆ្ពោះទៅសំរេចបាននូវចំណុចដៅនៃ គអសក ដែលមាន ០,១% ក្នុងឆ្នាំ២០១៥។

សូចនាករទីពីរ សមាមាត្រនៃប្រជាជននៅតំបន់មានជម្ងឺគ្រុនចាញ់ខ្ពស់ ដែលប្រើមុងជ្រលក់ថ្នាំកាលពីយប់កន្លងមកបានកើនពី ២៤% ទៅ ៩៧% ក្នុងរវាងឆ្នាំ១៩៩៨ និងឆ្នាំ២០០២ (មជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០០២)។ ជាថ្មីម្តងទៀត តាមអត្រានេះ ប្រទេសកម្ពុជានឹងសំរេចបាននូវចំណុចដៅ គអសក ដែលមាន ៩៨% ក្នុងឆ្នាំ២០១៥។

មានសូចនាករបន្ថែមចំនួនពីរទៀត ដែលពុំមានទិន្នន័យជានិន្នាការ។ ចំនួនអ្នកជំងឺគ្រុនចាញ់ដែលបានទទួលការព្យាបាលនៅក្នុងវិស័យសុខាភិបាលសាធារណៈ ក្នុងប្រជាជន ១០០០នាក់ មានចំនួន១១,៤ ក្នុងឆ្នាំ២០០០ (មជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០០០) ធៀបទៅនឹងចំណុចដៅដែលមានចំនួន ៤ ក្នុងឆ្នាំ២០១៥។ សមាមាត្រនៃសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់ពីរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់ ៩៥% តាមរូបមន្តជាតិមាន ៦០% ក្នុងឆ្នាំ២០០២ (មជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០០២) រីឯចំណុចដៅ គអសក គឺ ៩៥% ក្នុងឆ្នាំ២០១៥។

ប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេស ដែលរងគ្រោះយ៉ាងខ្លាំងដោយសារជម្ងឺគ្រុនឈាម នៅក្នុងឧបទ្វីបអាស៊ីអគ្នេយ៍ ហើយមានការរាតត្បាតធ្ងន់ធ្ងរមួយចំនួនក្នុងទសវត្សរ៍កន្លងមកនេះ។ សូចនាករចំនួនពីរពាក់ព័ន្ធនឹងជម្ងឺគ្រុនឈាម ដែលបានអនុម័តដោយក្រសួងសុខាភិបាលរួមមាន ចំនួនអ្នកជម្ងឺគ្រុនឈាមដែលបានទទួលការព្យាបាលនៅក្នុងផ្នែកសុខាភិបាលសាធារណៈ ក្នុងប្រជាជន ១០០០នាក់ ដែលមានត្រឹមតែ ១ ក្នុងប្រជាជន ១០០០នាក់ ក្នុងឆ្នាំ២០០១ និងអត្រាស្លាប់ដោយសារជម្ងឺគ្រុនឈាម ដែលបានរាយការណ៍ដោយផ្នែកសុខាភិបាលសាធារណៈមានចំនួន ១,៥% ក្នុងខែមិថុនា ឆ្នាំ២០០៣ (មជ្ឈមណ្ឌជាតិកំចាត់ជំងឺគ្រុនឈាម ឆ្នាំ ២០០៣)។ ពុំមានទិន្នន័យជានិន្នាការទេសំរាប់សូចនាករទាំងពីរនេះ ដែលតម្លៃចំណុចដៅសំរាប់ ឆ្នាំ២០១៥ គឺ ០,៤% និង ០,៣% តាមលំដាប់។

### ២.៦.៣.២ គោលនយោបាយ និងកម្មវិធីសំខាន់ៗនាពេលបច្ចុប្បន្នដែលរួមចំណែកដល់ជម្ងឺគ្រុនចាញ់/គ្រុនឈាម

#### កម្មវិធីជាតិគ្រប់គ្រងជម្ងឺគ្រុនចាញ់

កម្មវិធីជាតិគ្រប់គ្រងជម្ងឺគ្រុនចាញ់មាននាយកដ្ឋានបួន ដែលទទួលខុសត្រូវការអនុវត្តន៍កម្មវិធីនៅក្នុងមជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់: (១)ការបង្ការ និងការអប់រំសុខភាព (២)រោគវិនិច្ឆ័យ (៣)ការព្យាបាល (៤)ការស្រាវជ្រាវរោគសាស្ត្ររាតត្បាត និងប្រតិបត្តិការ។ យុទ្ធសាស្ត្រសំខាន់ៗបួន និងអន្តរាគមន៍ជាគន្លឹះបីនៅក្នុងមជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់:

**- ទិសដៅជាយុទ្ធសាស្ត្រទាំងបួន ដែលមជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់អនុវត្តៈ**

១. ពង្រឹងសមត្ថភាពស្ថាប័ននៃកម្មវិធីជាតិគ្រប់គ្រងជម្ងឺគ្រុនចាញ់ ថ្នាក់ជាតិ ក៏ដូចជាថ្នាក់មូលដ្ឋាន ។

២. បង្កើនការគ្រប់គ្រងករណីជម្ងឺគ្រុនចាញ់ សំរាប់គ្រប់ស្រទាប់ប្រជាជន ។

៣. បង្កើនវិធានការបង្ការ ដើម្បីការពារក្រុមប្រជាជន ដែលប្រឈមមុខនឹងគ្រោះថ្នាក់ ។

៤. បង្កើនទំហំ និងប្រសិទ្ធភាពនៃពតិមាន ការអប់រំ និងទំនាក់ទំនង សំរាប់ប្រជាជន ដែលរស់នៅក្នុងតំបន់ដែលប្រឈមនឹងគ្រោះថ្នាក់ ។

ការផ្តោតទៅលើទិសដៅយុទ្ធសាស្ត្រទី៣ និងទី៤ គឺការចែកមុងជ្រលក់ថ្នាំដោយមជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដល់គ្រប់សហគមន៍ក្នុងតំបន់រាតត្បាតទាំងឡាយ និងលើកទឹកចិត្តប្រជាជនអោយប្រើមុងទាំងនោះ ដើម្បីការពារខ្លួនកុំអោយមូសខាំ។ ការចែកមុងជ្រលក់ថ្នាំទាំងនេះជាកិច្ចប្រឹងប្រែងរួមរបស់មជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់ មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ បុគ្គលិកមណ្ឌលសុខភាព និងអាជ្ញាធរមូលដ្ឋាន។ ប្រការសំខាន់បំផុតគឺការចូលរួមរបស់អ្នកដឹកនាំសហគមន៍ និងប្រជាជនខ្លួនឯងតែម្តង ។

**- អន្តរាគមន៍ជាគន្លឹះទាំងបីរបស់មជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់រួមមានៈ**

១. ការអនុវត្តន៍វិធីព្យាបាលរួមផ្សំជាមុន បន្ទាប់ពីដឹងអំពីរោគវិនិច្ឆ័យដោយឌិបស្ទិក/មីក្រូស្កុប (Dipstick/ Microscopy) ។

២. ការចែកមុងជ្រលក់ថ្នាំតាមក្រុមនៃគ្រប់តំបន់គ្រុនចាញ់ក្នុងប្រទេស ។

៣. ការរកទីផ្សារសំរាប់ឌិបស្ទិក ថ្នាំកំចាត់ជម្ងឺគ្រុនចាញ់ និងមុងជ្រលក់ថ្នាំ ។

**កម្មវិធីជាតិគ្រប់គ្រងជម្ងឺគ្រុនឈាម**

កម្មវិធីជាតិគ្រប់គ្រងជម្ងឺគ្រុនឈាម មានមូលដ្ឋាននៅក្នុងមជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់ នៃក្រសួងសុខាភិបាល គឺជាស្ថាប័នទទួលបន្ទុកផ្ទាល់លើការគ្រប់គ្រងជម្ងឺគ្រុនឈាម។ ស្របតាមយុទ្ធសាស្ត្រជាសកលរបស់អង្គការសុខភាពពិភពលោកក្នុងការបង្ការ និងការគ្រប់គ្រងជម្ងឺគ្រុនឈាម/ជម្ងឺគ្រុនឈាមធ្ងន់ធ្ងរ នៅក្នុងឆ្នាំ១៩៩៩ ក្រសួងសុខាភិបាលកម្ពុជា បានកំណត់គោលដៅចំបងពីរលើផ្នែកគ្រប់គ្រងជម្ងឺគ្រុនឈាមដូចខាងក្រោមៈ

១. ទប់ស្កាត់អត្រាស្លាប់របស់កុមារ ដោយសារជម្ងឺគ្រុនឈាមធ្ងន់ធ្ងរ ដោយពង្រឹងការគ្រប់គ្រងមន្ទីរព្យាបាល និងការចូលព្យាលបាលនៅមន្ទីរពេទ្យទាន់ពេល ។

២. កាត់បន្ថយអត្រាជម្ងឺគ្រុនឈាម/ជម្ងឺគ្រុនឈាមធ្ងន់ធ្ងរ តាមរយៈការអនុវត្តន៍អន្តរាគមន៍គ្រប់គ្រងសមស្របលើភ្នាក់ងារចម្លងមេរោគ ។

កម្មវិធីគ្រប់គ្រងនេះ ត្រូវបានឧបត្ថម្ភគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) ក្រោមកម្មវិធីជំនួយពិភពលោក ដើម្បីអនុវត្តចំណុចសំខាន់៧ចំនួន ៥ ដូចខាងក្រោមនេះ

១. បង្កើនការរៀបចំ និងត្រួតពិនិត្យលើរោគរាតត្បាត ។

២. អង្កេតតាមដានការរាតត្បាតនៃជម្ងឺគ្រុនឈាម/ជម្ងឺគ្រុនឈាមធ្ងន់ធ្ងរ ព្យាករណ៍ពីគ្រោះថ្នាក់នៃការរាតត្បាត និងដាស់តឿនជាបន្ទាន់អំពីការរាតត្បាតដែលមាន។

៣. បង្ការការឆ្លងជម្ងឺគ្រុនឈាម/ជម្ងឺគ្រុនឈាមធ្ងន់ធ្ងរ។

៤. បណ្តុះបណ្តាលបុគ្គលិកសុខាភិបាល លើការគ្រប់គ្រងជម្ងឺគ្រុនឈាម/ជម្ងឺគ្រុនឈាមធ្ងន់ធ្ងរ។

៥. លើកកំពស់ការគ្រប់គ្រងជម្ងឺគ្រុនឈាម ដោយសហការជាមួយវិស័យដទៃទៀត។

កម្មវិធីជាតិគ្រប់គ្រងជម្ងឺគ្រុនឈាម ដោយមានជំនួយបច្ចេកទេសពីអង្គការសុខភាពពិភពលោក បានប្តេជ្ញាអនុវត្តគ្រប់គ្រងបញ្ហាគន្លឹះទាំងនេះ តាំងពីឆ្នាំ២០០១ ហើយបានសំរេចគួរអោយកត់សំគាល់នូវការកាត់បន្ថយអត្រាស្លាប់ពី ៣% នៅឆ្នាំ១៩៩៨ មក ១,៥% ក្នុងខែមិថុនា ឆ្នាំ២០០៣។ ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់ក្រសួងសុខាភិបាលបានកំណត់ចំណុចដៅត្រឹម ១% មុនដំណាច់ឆ្នាំ២០០៥។ ភាពកាន់តែប្រសើរនៃការធ្វើអង្កេតតាមដានជម្ងឺផ្អែកលើប្រព័ន្ធពត៌មានសុខាភិបាល ត្រូវបានធានានូវសេចក្តីរាយការណ៍ទាន់ពេល អំពីករណីអ្នកជំងឺដែលសំរាកក្នុងមន្ទីរពេទ្យនៅទូទាំងប្រទេស។ តាមរយៈការឧបត្ថម្ភគាំទ្រខាងហិរញ្ញវត្ថុ របស់ធនាគារពិភពលោក សំរាប់ឆ្នាំ២០០៣ ដល់ឆ្នាំ២០០៧ កម្មវិធីបង្ការ និងគ្រប់គ្រងប្រកបដោយចីរភាពមួយទៀត អាចត្រូវបានបង្កើតឡើង ដើម្បីសំរេចគោលដៅនៃកម្មវិធី។

**២.៦.៣.៣ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺគ្រុនចាញ់ និងគ្រុនឈាម**

បញ្ហាប្រឈមជាគន្លឹះដើម្បីសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺគ្រុនចាញ់ និងគ្រុនឈាមមានដូចខាងក្រោមៈ

- កាត់បន្ថយឧបសគ្គហិរញ្ញវត្ថុក្នុងចំណោមអ្នកក្រីក្រ ចំពោះគ្រប់ការបង្ការជម្ងឺគ្រុនចាញ់ ប្រកបដោយប្រសិទ្ធភាព ដោយឧបត្ថម្ភចំណាយលើវិធានការបង្ការរោគ និង/ឬ ដោយបង្កើនប្រាក់ចំណូលរបស់អ្នកជនបទ។
- បង្កើនការយល់ដឹងអំពីប្រសិទ្ធភាពនៃវិធានការបង្ការ និងព្យាបាលរោគដ៏ត្រឹមត្រូវរួមមាន ការកាត់បន្ថយការរាតត្បាតនៃភ្នាក់ងារចម្លងមេរោគគ្រុនចាញ់ ការប្រើមុងជ្រលក់ថ្នាំ ។ល។
- ជំរុញការចែកចាយមុងជ្រលក់ថ្នាំ និងការព្យាបាលជម្ងឺគ្រុនចាញ់ដល់ប្រជាជនក្រីក្រ នៅគ្រប់តំបន់ជនបទដែលមានជម្ងឺនេះរាតត្បាត។
- បង្កើនសមត្ថភាពខាងគ្រប់គ្រង និងបច្ចេកទេសដល់បុគ្គលិកនៃកម្មវិធីជាតិគ្រប់គ្រង និងមន្ទីរសុខាភិបាលខេត្ត/ក្រុង។
- លើកកំពស់ការចូលរួម និងការកៀរគរសហគមន៍ ដើម្បីលុបបំបាត់ដង់ស៊ីតេកំណើតខ្ពស់ នៃភ្នាក់ងារចម្លងមេរោគគ្រុនឈាមនេះ ទាំងនៅក្នុងតំបន់ទីក្រុង/ទីប្រជុំជន ក៏ដូចជាតំបន់ជនបទ។
- ពង្រីកការផ្គត់ផ្គង់ទឹករ៉ូប៊ីនេ និងកម្មវិធីអនាម័យតាមគ្រួសារ ដើម្បីកាត់បន្ថយចំនួនសក្តានុពល នៃការប្រើប្រាស់ធុងសំរាប់ផ្ទុកទឹកបម្រុង។

- ពង្រឹងគ្រប់សកម្មភាពគ្រប់គ្រង លើភ្នាក់ងារចម្លងមេរោគ ដោយយកចិត្តទុកដាក់លើពាងទឹក ប្រើប្រាស់ឧបករណ៍មានស្រាប់ ឬឧបករណ៍ថ្មី សំរាប់គ្រប់គ្រងភ្នាក់ងារចម្លងមេរោគ (ដូចជា ឧបករណ៍គ្រឿងយន្ត សារធាតុជីវសាស្ត្រ និងសារធាតុគីមី)។

**២.៦.៣.៤ ក្របខ័ណ្ឌការងារដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺគ្រុនចាញ់ និងគ្រុនឈាម**

ដើម្បីជំនះលើបញ្ហាប្រឈមជាគន្លឹះ និងសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺគ្រុនចាញ់ និងគ្រុនឈាម ទិសដៅជាគន្លឹះមួយចំនួនមានដូចខាងក្រោមៈ

- ធ្វើយុទ្ធនាការផ្តល់ពត៌មាន ការអប់រំ និងទំនាក់ទំនង ដល់ប្រជាជនទូទៅនៅតំបន់រងគ្រោះ អំពីវិធានការដ៏ត្រឹមត្រូវនៃការបង្ការ និងការព្យាបាលជម្ងឺគ្រុនចាញ់ ព្រមទាំងដោះស្រាយបញ្ហាជំនឿប្រពៃណី ដែលអនុវត្តខុសកន្លងមក។
- បង្កើនចំណាយថវិកា ដើម្បីប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ ទន្ទឹមគ្នានឹងការបង្កើនប្រសិទ្ធភាព នៅក្នុងការអនុវត្តន៍កម្មវិធីនាបច្ចុប្បន្ន តាមរយៈការពង្រីកការគ្រប់គ្រង ដោយផ្អែកលើលទ្ធផលរបស់ប្រព័ន្ធសុខាភិបាលសាធារណៈ ព្រមទាំងផ្លាស់ប្តូរបែបបទនៃការលើកទឹកចិត្ត ដើម្បីជារង្វាន់ដល់ភ្នាក់ងារសុខាភិបាលក្នុងប៉ុស្តិ៍សុខភាព និងក្នុងគ្រប់កម្មវិធីដែលបានបង្កើតឡើង ដើម្បីប្រយុទ្ធនឹងជំងឺគ្រុនចាញ់ក្នុងគ្រប់តំបន់ដែលរងគ្រោះ។
- បង្កើនចំនួនមុងជ្រលក់ថ្នាំ និងថ្នាំប្រឆាំងជម្ងឺគ្រុនចាញ់ សំរាប់ប្រើក្នុងតំបន់រងគ្រោះតាមរយៈហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដ៏ប្រសើរ ការចែកចាយដោយសមភាពនូវគ្រប់សំភារៈបរិក្ខារដែលត្រូវផ្តល់ ធ្វើអោយកាន់តែប្រសើរឡើងនូវការផ្តល់សេវាសុខាភិបាល ព្រមទាំងផ្តល់សេវាកម្មអោយបានច្រើនដល់តំបន់ដែលមានរោគគ្រុនចាញ់រាតត្បាត ដោយបុគ្គលិកសុខាភិបាល។
- មានការសំរបសំរួលល្អក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ ក្នុងការប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់។
- បង្កើនបំណែងចែកថវិកាសំរាប់ការអនុវត្តន៍ការបង្ការ និងការគ្រប់គ្រងជម្ងឺគ្រុនឈាម/ជម្ងឺគ្រុនឈាមធ្ងន់ធ្ងរ នៅគ្រប់ថ្នាក់ខេត្ត/ក្រុង។
- បង្កើនករណីរោគវិនិច្ឆ័យ និងការគ្រប់គ្រងបច្ចេកទេស ទាំងនៅក្នុងវិស័យសាធារណៈ និងឯកជន។
- ពង្រឹងការគ្រប់គ្រងកម្មវិធី និងសមត្ថភាពបុគ្គលិក នៅគ្រប់លំដាប់ថ្នាក់រួមទាំងក្នុងមន្ទីរសុខាភិបាលខេត្ត/ក្រុង។
- ធ្វើឱ្យមានចីរភាព ចំពោះកិច្ចប្រឹងប្រែងចូលរួមរបស់សហគមន៍ ដោយប្រើយុទ្ធសាស្ត្រកៀរគរសង្គមដែលមានលក្ខណៈសមស្រប។
- អនុម័តវិធីសាស្ត្រ "គ្រប់គ្រងភ្នាក់ងារចម្លងមេរោគរួម" ជាយុទ្ធសាស្ត្រគ្រប់គ្រងភ្នាក់ងារចម្លងមេរោគនៅក្នុងគ្រប់តំបន់ ដែលប្រឈមនឹងគ្រោះថ្នាក់ខ្ពស់។

## ២.៦.៤ ជម្ងឺរបេង

ប្រទេសកម្ពុជាស្ថិតក្នុងចំណោម ២៣ ប្រទេសក្នុងពិភពលោក ដែលមានបន្ទុកជម្ងឺរបេងដ៏ធ្ងន់ធ្ងរ។ យោងតាមការប្រជុំរបស់ជំនាញការអង្គការសុខភាពពិភពលោក នៅក្រុងម៉ានីល នាឆ្នាំ១៩៩៧ កន្លងមក បានប៉ាន់ស្មានថាមាន ៦៤% នៃចំនួនប្រជាជនសរុប ជាពិសេសអ្នកដែលរស់នៅក្នុងស្ថានភាពកកកុញ និងខ្វះអនាម័យ ត្រូវបានឆ្លងជម្ងឺរបេង។

### ២.៦.៤.១ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៦ ស្តីពីជំងឺរបេង

មានសូចនាករពីរ ត្រូវបានប្រើដោយក្រសួងសុខាភិបាល ដើម្បីតាមដានជម្ងឺរបេង តែពុំមានទិន្នន័យជានិន្នាការឡើយ។ អត្រាប្រេវ៉ាឡង់នៃជម្ងឺរបេងស្ទួតវិជ្ជមាន BK ក្នុងប្រជាជន ១០០០០០នាក់ មាន ៤២៨ ក្នុងឆ្នាំ១៩៩៧ (Dye et al., 1999) ធៀបទៅនឹងចំណុចដៅ គអសក មានចំនួន ១៣៥ ក្នុងឆ្នាំ២០១៥។ លើសពីនេះទៀត អត្រាស្លាប់ដោយសារជម្ងឺរបេង ក្នុងប្រជាជន ១០០០០០នាក់ មាន ៩០ ក្នុងឆ្នាំ១៩៩៧ (Dye et al., 1999) រីឯចំណុចដៅ គអសក វិញបានកំណត់ត្រឹមតែ ៣២ សំរាប់ឆ្នាំ២០១៥។

សមាមាត្រនៃអ្នកដែលបានប៉ាន់ស្មានថា មានករណីជម្ងឺរបេងស្ទួតវិជ្ជមាន BK ថ្មីបានរកឃើញក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) បានកើនឡើងពី ៥១% ដល់ ៥៧% ក្នុងរវាងឆ្នាំ២០០១ និងឆ្នាំ២០០២ (ក្រសួងសុខាភិបាល ឆ្នាំ២០០២) បញ្ជាក់ថាចំណុចដៅ គអសក ដែលបានកំណត់ធំជាង ៧០% ក្នុងឆ្នាំ២០១៥ នឹងអាចសំរេចបាន។ ដូចជាផ្នែកដទៃទៀតដែរ គួរតែមានការប្រុងប្រយ័ត្ន នៅពេលធ្វើចំណោលបន្ទាយជាខ្សែបន្ទាត់ចេញពីនិន្នាការកន្លងមក ព្រោះកត្តាកំណត់និន្នាការនេះអាចប្រែប្រួល។

សមាមាត្រនៃអ្នកជម្ងឺរបេងស្ទួតវិជ្ជមាន BK ដែលបានកត់ត្រា ហើយបានព្យាបាលប្រកបដោយជោគជ័យក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) បានកើនឡើងពី ៨៨% ក្នុងឆ្នាំ២០០១ ទៅ ៨៩% ក្នុងឆ្នាំ២០០២ (ក្រសួងសុខាភិបាល ឆ្នាំ២០០២) ដែលលើសពីចំណុចដៅ គអសក ដែលបានកំណត់អោយនៅលើ ៨៥% សំរាប់ឆ្នាំ២០០៥។

### ២.៦.៤.២ គោលនយោបាយ និងកម្មវិធីសំខាន់ៗនាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ជម្ងឺរបេង

កម្មវិធីជាតិគ្រប់គ្រងជម្ងឺរបេងបានដំណើរការ ក្រោមការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន ហើយស្ថិតនៅក្នុងប្រព័ន្ធសុខាភិបាលជាតិទាំងមូល។ ផែនការ៥ឆ្នាំថ្មីមួយ (២០០១-២០០៥) សំរាប់គ្រប់គ្រងរោគរបេងត្រូវបានចេញផ្សាយ ក្នុងឆ្នាំ២០០១ ស្របពេលជាមួយនឹងក្របខ័ណ្ឌការងារសុខាភិបាលជាតិថ្មីមួយ ត្រូវបានអនុម័តដោយក្រសួងសុខាភិបាល។ ក្នុងដំណាច់ឆ្នាំ២០០៥ វិធីសាស្ត្រព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) គួរតែមានក្នុងគ្រប់ ៩៤៦ មណ្ឌលសុខភាព (មណ្ឌលសុខភាពមួយ សំរាប់ប្រជាជន ១០០០០នាក់) ដែលកំពុងត្រូវបានរៀបចំ ឬសាងសង់ នៅទូទាំងប្រទេសបន្ថែមទៅលើមន្ទីរពេទ្យជាតិចំនួន ៨ និងមន្ទីរពេទ្យបង្អែកចំនួន ៦៨ ទៀត។

មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន បានផ្សព្វផ្សាយការផ្តួចផ្តើមគំនិតជាច្រើន លើផ្នែកអប់រំសុខភាព តាមរយៈប្រព័ន្ធផ្សព្វផ្សាយពតិមាន ដើម្បីលើកទឹកចិត្តអ្នកដែលមានរោគសញ្ញាជម្ងឺរបេង ឱ្យទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត ដើម្បីពិនិត្យ និងព្យាបាល។ ការព្យាបាល គឺពុំមានការបង់ប្រាក់ឡើយ ហើយអ្នកជម្ងឺរបេងក៏បានទទួលអាហារឧបត្ថម្ភពីអង្គការកម្មវិធីស្បៀងអាហារពិភពលោក ក្នុងរយៈពេលនៃការព្យាបាលរបស់ពួកគេ។ គោលដៅសំខាន់របស់កម្មវិធីជាតិគ្រប់គ្រងជម្ងឺរបេង គឺបង្កើនសមិទ្ធិផលសុខាភិបាល ក៏ដូចជាលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ គោលនយោបាយសុខាភិបាលជាតិសំរាប់ការគ្រប់គ្រងជម្ងឺរបេង ឆ្នាំ២០០១-២០០៥ រួមមាន សេចក្តីថ្លែងការណ៏គោលនយោបាយសំខាន់ៗចំនួន ៥ ដូចខាងក្រោមៈ

- មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន សន្មតការទទួលខុសត្រូវរួម សំរាប់កម្មវិធីជាតិគ្រប់គ្រងជម្ងឺរបេងដែលត្រូវបានអនុវត្តនៅទូទាំងប្រទេស តាមរយៈប្រព័ន្ធផ្តល់ការថែទាំសុខភាព នៅក្នុងប្រទេសកម្ពុជា។
- យោងតាមពិធីការ និងគោលការណែនាំថ្នាក់ជាតិ កម្មវិធីជាតិគ្រប់គ្រងជម្ងឺរបេងត្រូវធានាអោយបានគុណភាពល្អនូវសេវាព្យាបាល បង្ការ និងលើកកំពស់សេវាជំងឺរបេង ដល់អ្នកជម្ងឺរបេងដែលអាចប្រើប្រាស់បានរហូតដល់សហគមន៍ ដោយមិនបង់ប្រាក់។
- ក្រសួងសុខាភិបាលនឹងខិតខំធានាឱ្យបានថា ហិរញ្ញវត្ថុពីគ្រប់ប្រភពទាំងអស់ សំរាប់គ្រប់សកម្មភាពគ្រប់គ្រងជម្ងឺរបេង ត្រូវបានកៀរគរយ៉ាងពេញទំហឹង និងត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព នៅក្នុងការគ្រប់គ្រងជម្ងឺរបេង ដែលពុំមានការអាក់ខាននូវការផ្គត់ផ្គង់ថ្នាំរបេង ដែលមានគុណភាពល្អ ហើយដែលផ្តល់អាទិភាព ដល់ការធ្វើវិនិយោគលើធនធានមនុស្ស និងសំភារៈ សំរាប់សកម្មភាពគ្រប់គ្រងជម្ងឺរបេង។
- កម្មវិធីជាតិគ្រប់គ្រងជម្ងឺរបេង នឹងពង្រឹងប្រព័ន្ធពតិមានព្រមទាំងលើកកំពស់សកម្មភាពស្រាវជ្រាវដើម្បីគ្រប់គ្រងកម្មវិធីអោយបានល្អ។ ប្រធានបទស្រាវជ្រាវរួមមាន គំរូនៃរោគសាស្ត្រវាតត្បាត ឥរិយាបថក្នុងការស្វែងរកសេវាសុខាភិបាល និងបញ្ហាដទៃទៀត ដែលទាក់ទិននឹងជម្ងឺរបេងនៅក្នុងប្រទេសកម្ពុជា។
- ភាពជាដៃគូទាំងក្នុង និងក្រៅប្រទេស គួរតែជាកត្តាស្នូលក្នុងការសំរេចបាននូវវត្ថុបំណង របស់កម្មវិធីជាតិគ្រប់គ្រងជម្ងឺរបេង។ ធនធានទាំងអស់គួរតែត្រូវបានកៀរគរ និងត្រូវបានសំរបសំរួល ដើម្បីបង្កើនសកម្មភាពគ្រប់គ្រងជម្ងឺរបេងនៅគ្រប់កំរិតទាំងអស់ ទាំងក្នុង និងក្រៅប្រព័ន្ធគាំពារសុខភាព។

**២.៦.៤.៣ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺរបេង**

ដើម្បីសំរេចឱ្យបាននូវចំណុចដៅ គអសក ទាក់ទងទៅនឹងជម្ងឺរបេងដែលនៅសេសសល់ បញ្ហាប្រឈមដូចខាងក្រោមត្រូវតែដោះស្រាយតាមលំដាប់លំដោយៈ

- បង្កើនសមត្ថភាពបុគ្គលិកនៅគ្រប់កំរិត ជាពិសេសនៅក្នុងការធ្វើផែនការ ការគ្រប់គ្រង និងការអនុវត្តន៏វិធីសាស្ត្រព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) ក៏ដូចជាការដោះស្រាយលើគ្រឿងលើកទឹកចិត្តសំរាប់និយោជិកបំរើការងារក្នុងវិស័យសាធារណៈ។

- ស្របពេលជាមួយគ្នានេះ ត្រូវដោះស្រាយបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ ភាពក្រីក្រ ផ្ទះសំបែង/អនាម័យ និងជម្ងឺរបេងផងដែរ។
- បន្ថយការបាត់បង់ឱកាសរកចំណូល ដោយសារការព្យាបាលជម្ងឺរបេង ដែលទាមទារពេលវែង។
- បង្កើនការយល់ដឹងលើសញ្ញា និងរោគសញ្ញានៃជម្ងឺរបេង ក៏ដូចជាការអនុវត្តន៍ត្រឹមត្រូវនូវការព្យាបាលតាមវេជ្ជបញ្ជា។
- ពង្រឹងការចូលរួមរបស់ដៃគូដទៃទៀត ក្នុងការគ្រប់គ្រងជម្ងឺរបេងដូចជា វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន និងគ្រប់ស្ថាប័នរាជរដ្ឋាភិបាលក្នុងការស្រាវជ្រាវ និងព្យាបាលជម្ងឺរបេង។

### ២.៦.៤.៤ ក្របខ័ណ្ឌការងារ ដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅនៃជម្ងឺរបេង

ដើម្បីជំនះលើបញ្ហាប្រឈមជាគន្លឹះ និងសំរេចឱ្យបាននូវចំណុចដៅ គអសក ទិសដៅជាគន្លឹះមួយចំនួនមានដូចខាងក្រោមៈ

- បង្កើនថវិកាដើម្បីប្រយុទ្ធនឹងជម្ងឺរបេង ក៏ដូចជាបង្កើនការប្រើប្រាស់ដោយប្រសិទ្ធភាពនូវធនធានទាំងនោះដោយពង្រីកការគ្រប់គ្រងផ្អែកលើលទ្ធផលជាមូលដ្ឋាននៃប្រព័ន្ធសុខាភិបាលសាធារណៈ។
- បង្កើនសមត្ថភាពបុគ្គលិកគ្រប់លំដាប់ថ្នាក់ ជាពិសេសសមត្ថភាពក្នុងការធ្វើផែនការ ការគ្រប់គ្រង និងការអនុវត្តន៍វិធីសាស្ត្រព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS)។
- ពង្រីកកម្មវិធីព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) និងមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព សំរាប់ការព្យាបាលរោគរបេងនៅតាមសហគមន៍។
- ធ្វើយុទ្ធនាការផ្តល់ពតិមាន ការអប់រំ និងទំនាក់ទំនង ដល់ប្រជាជនទូទៅអំពីការបង្ការ ការស្រាវជ្រាវ និងព្យាបាលជម្ងឺរបេងអោយបានត្រឹមត្រូវ។

### ២.៦.៥ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៦

រូប ២.៦.៤ បង្ហាញពីការបែងចែកតាមតំបន់នៃសូចនាករ គអសក៦ តាមខេត្ត/ក្រុង។ តំលៃនីមួយៗតំណាងអោយសន្ទស្សន៍មានទំងន់មធ្យមស្មើគ្នា (equally weighted index) នៃសូចនាករ ដែលមានទិន្នន័យទាំងអស់របស់ គអសក៦។ លទ្ធផលនៃសន្ទស្សន៍រួមនេះ បង្ហាញនូវរូបភាពខុសគ្នា នៃស្ថានភាពប្រទេសទាក់ទងទៅនឹងការប្រយុទ្ធនឹងមេរោគអេដស៍/ជម្ងឺអេដស៍ ជម្ងឺគ្រុនចាញ់ និងជម្ងឺដទៃទៀត។ លទ្ធផលទាំងនេះអនុញ្ញាតិឱ្យយើងធ្វើការបែងចែកខេត្ត/ក្រុងជាបីលំដាប់ថ្នាក់។ ខេត្ត/ក្រុងដែលមានពណ៌បៃតង ជាខេត្ត/ក្រុងដែលមានលទ្ធភាពប្រសើរជាងគេក្នុងការឈានទៅសំរេចចំណុចដៅ។ ខេត្ត/ក្រុងដែលមានពណ៌លឿង ជាខេត្ត/ក្រុងដែលមានលទ្ធភាពមធ្យម ហើយខេត្ត/ក្រុងដែលមានពណ៌ក្រហម មានលទ្ធភាពខ្សោយជាងគេ ក្នុងការឈានទៅសំរេចចំណុចដៅនៅឆ្នាំ២០១៥។ បណ្តាខេត្តដែលមានពណ៌ក្រហម ច្រើនស្ថិតនៅភូមិភាគពាយ័ព្យ និងភាគខាងត្បូងនៃប្រទេស។

## រូប ២.៦.៣: សន្ទស្សន៍រួមនៃ គអសក៦ តាមខេត្ត/ក្រុង




សំគាល់: សន្ទស្សន៍របស់ គអសក៦ គឺជាមធ្យមភាគដែលមានទំងន់ស្មើគ្នា ទៅតាមលំដាប់ខេត្តនីមួយៗ លើអថេរនៃសូចនាករ៤ របស់ គអសក៦ ។

## តារាង ២.៦.៣: សន្ទស្សន៍រួមនៃ គអសក៦ តាមខេត្ត/ក្រុង

| លេខកូដ | ខេត្ត/ក្រុង | សូចនាករ ៦.២ | សូចនាករ ៦.១០ | សូចនាករ ៦.១២ | សូចនាករ ៦.១៤ | គអសក៦ |
|---|---|---|---|---|---|---|
| ២២ | ឧត្តរមានជ័យ | គ្មាន | 0,១២៣ | 0,000 | គ្មាន | **0,៩៣៨** |
| ១៣ | ព្រះវិហារ | 0,000 | 0,៣១0 | 0,0២៧ | 0,១៩0 | **0,៨៦៨** |
| ១១ | មណ្ឌលគិរី | គ្មាន | 0,៣៨៧ | 0,0១១ | 0,១៤៦ | **0,៨១៩** |
| 0៨ | កណ្ដាល | 0,000 | 0,0៣៧ | 0,២៩៧ | 0,៤៣៨ | **0,៨0៧** |
| ១៤ | ព្រៃវែង | 0,១៣៧ | 0,0៤៤ | 0,១៨៧ | 0,៤៥២ | **0,៧៩៥** |
| ១២ | ភ្នំពេញ | 0,៤៧១ | 0,000 | 0,១0៤ | 0,២៦៦ | **0,៧៩0** |
| 0៦ | កំពង់ធំ | 0,៣៧៣ | 0,0៥៧ | 0,១២៦ | 0,៤៩១ | **0,៧៣៨** |
| 0៣ | កំពង់ចាម | 0,១៥៧ | 0,៣៥២ | 0,៣៦៣ | 0,១៨៧ | **0,៧៣៥** |
| ១៥ | ពោធិ៍សាត់ | 0,១៧៦ | 0,២៨៣ | 0,៤២៩ | 0,១៧១ | **0,៧៣៥** |
| ២0 | ស្វាយរៀង | 0,២៣៥ | 0,១២៩ | 0,១១៥ | 0,៦១២ | **0,៧២៧** |
| ១៩ | ស្ទឹងត្រែង | 0,៥៤៩ | 0,៥៤៩ | 0,0៩៩ | 0,000 | **0,៧0១** |
| 0៤ | កំពង់ឆ្នាំង | 0,៣៩២ | 0,១៩0 | 0,២៥៨ | 0,៤៨៣ | **0,៦៨២** |
| 0៩ | កោះកុង | 0,៧២៥ | 0,៤១៣ | 0,0៩៣ | 0,0៦៩ | **0,៦៧៥** |
| 0២ | បាត់ដំបង | 0,៧៦៥ | 0,៣២៤ | 0,0២៧ | 0,២១៥ | **0,៦៦៧** |
| ១៨ | ក្រុងព្រះសីហនុ | 0,២៥៥ | 0,១៧៤ | 0,៥១១ | 0,៤៣១ | **0,៦៥៧** |
| ១0 | ក្រចេះ | 0,៤៩0 | 0,២៩២ | 0,៥៦៦ | 0,២0២ | **0,៦១២** |
| 0៧ | កំពត | 0,0៩៨ | 0,៣៧១ | ១,000 | 0,១៤៨ | **0,៥៩៦** |
| ២៣ | ក្រុងកែប | គ្មាន | 0,២៦២ | គ្មាន | 0,៥៥៦ | **0,៥៩១** |
| ១៦ | រតនគិរី | 0,៨៤៣ | 0,២៨២ | គ្មាន | 0,១៥៤ | **0,៥៧៤** |
| ២១ | តាកែវ | គ្មាន | 0,១៥0 | 0,៨0២ | 0,៣៦៧ | **0,៥៦0** |
| 0៥ | កំពង់ស្ពឺ | 0,៥៤៩ | 0,២២៤ | 0,៤0៧ | 0,៦0១ | **0,៥៥៥** |
| 0១ | បន្ទាយមានជ័យ | ១,000 | 0,១៧៦ | 0,៣៧៩ | 0,២៣៥ | **0,៥៥២** |
| ១៧ | សៀមរាប | 0,៨៨២ | 0,៣៥២ | 0,0១៦ | 0,៧៣២ | **0,៥0៤** |
| ២៤ | ក្រុងប៉ៃលិន | 0,៩២២ | ១,000 | 0,១៨៧ | ១,000 | **0,២២៣** |

សំគាល់: ការថ្លឹងថ្លែង ត្រូវបានកែសំរួលទៅតាមទិន្នន័យដែលខ្វះចន្លោះ ។

ប្រភព: - អង្កេតតាមដានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធមេរោគអេដស៍/ជម្ងឺអេដស៍ សើរស្បែក និងកាមរោគ ២00២ ។

- របាយការណ៍ស្ថិតិសុខាភិបាលជាតិ ក្រសួងសុខាភិបាល ២000 ។

- ស្ថិតិជម្ងឺរបេងប្រចាំឆ្នាំ ក្នុងប្រទេសកម្ពុជា ២000 ( ក្រសួងសុខាភិបាល កម្មវិធីជាតិកំចាត់រោគរបេង) ។

## ២.៧ គោលដៅទី៧: ធានាចីរភាពបរិស្ថាន

គោលដៅទី ៧ មានគោលបំណងបញ្ចូលគោលការណ៍អភិវឌ្ឍន៍ចីរភាពទៅក្នុងគ្រប់គោលនយោបាយ និងកម្មវិធីជាតិ សំដៅបង្កើនធនធានបរិស្ថាន និងរក្សាអោយបានគង់វង្សនូវគំរបព្រៃឈើ ព្រមទាំងជំរុញអោយមានទឹកស្អាតប្រើប្រាស់ និងធានាអោយប្រជាជនមានសុវត្ថិភាពកាន់កាប់ដីធ្លី។

### ២.៧.១ សូចនាករ និងចំនុចដៅនៃ គអសក៧

តារាង ២.៧.១ បានបង្ហាញឱ្យឃើញនៅក្នុងជួរឈរខាងឆ្វេង គឺជាចំណុចដៅ និងសូចនាករដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ រីឯជួរឈរខាងស្តាំ បង្ហាញពីចំណុចដៅ និងសូចនាករដែលបានជ្រើសរើសដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗរួចមក។

**តារាង ២.៧.១: មូលដ្ឋានីយកម្មនៃ គអសព៧ ទៅជា គអសក៧**

| គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលទី៧ | គអសក៧ |
|---|---|
| **ចំណុចដៅទី៩:** បញ្ចូលគោលការណ៍អភិវឌ្ឍន៍ចីរភាពទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន | **ចំណុចដៅរួមទី១៣:** បញ្ចូលគោលការណ៍អភិវឌ្ឍន៍ចីរភាពទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន |
| **សូចនាករ២៥:** សមាមាត្រផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | **សូចនាករ៧.១:** គំរបព្រៃឈើជាភាគរយនៃផ្ទៃដីសរុប |
| **សូចនាករ២៦:** ផ្ទៃដីតំបន់ការពារ ដើម្បីថែរក្សាជីវចំរុះ | **សូចនាករ៧.២:** ផ្ទៃដីតំបន់ការពារធម្មជាតិ |
| | **សូចនាករ៧.៣:** ផ្ទៃដីតំបន់អភិរក្សព្រៃឈើ |
| | **សូចនាករ៧.៤:** ចំនួនអ្នកអភិរក្សក្នុងតំបន់ការពារធម្មជាតិ |
| | **សូចនាករ៧.៥:** ចំនួនអ្នកអភិរក្សក្នុងតំបន់អភិរក្សព្រៃឈើ |
| | **សូចនាករ៧.៦:** សមាមាត្រផ្ទៃទឹកឡូត៍នេសាទដែលប្រគល់ទៅអោយសហគមន៍មូលដ្ឋាន |
| | **សូចនាករ៧.៧:** ចំនួនសហគមន៍នេសាទ |
| | **សូចនាករ៧.៨:** ផ្ទៃទឹកនៃតំបន់ការពារដែលជាជំរកមច្ឆជាតិ |
| **សូចនាករ២៧:** ផលិតផលក្នុងស្រុកសរុបក្នុងមួយឯកតានៃការប្រើប្រាស់ថាមពល (ជាតំណាងអោយប្រសិទ្ធភាពថាមពល) | **សូចនាករ៧.៩:** អត្រាគ្រួសារប្រើអុសជាថាមពល |
| **សូចនាករ២៨:** ការបំភាយឧស្ម័នកាបូនិច (ក្នុងមនុស្សម្នាក់) (បូកបន្ថែមការបំពុលបរិយាកាសពិភពលោកតាមរបៀបពីរយ៉ាង: ការធ្លាយស្រទាប់អូសូន និងការកើនឡើងនៃកំដៅបរិយាកាសពិភពលោក) | |
| **ចំណុចដៅទី១០:** កាត់បន្ថយសមាមាត្រប្រជាជនដែលគ្មានទឹកស្អាតប្រើប្រាស់ជាប្រចាំអោយបានពាក់កណ្តាល នៅឆ្នាំ២០១៥ | **ចំណុចដៅរួមទី១៤:** កាត់បន្ថយសមាមាត្រប្រជាជន ដែលគ្មានទឹកស្អាតប្រើប្រាស់ជាប្រចាំ អោយបានពាក់កណ្តាល នៅឆ្នាំ២០១៥ |
| **សូចនាករ២៩:** សមាមាត្រប្រជាជន ដែលមានប្រភពទឹកស្អាតប្រើប្រាស់ជាប្រចាំ | **សូចនាករ៧.១០:** សមាមាត្រប្រជាជនជនបទ ដែលមានប្រភពទឹកស្អាតប្រើប្រាស់ |
| | **សូចនាករ៧.១១:** សមាមាត្រប្រជាជនទីក្រុង/ប្រជុំជន ដែលមានប្រភពទឹកស្អាតប្រើប្រាស់ |
| **ចំណុចដៅទី១១:** ធ្វើអោយមានជីវភាពរស់នៅល្អប្រសើរដល់អ្នកក្រីក្រទីក្រុងយ៉ាងតិច ១០០លាននាក់ នៅឆ្នាំ២០២០ | **ចំណុចដៅរួមទី១៥:** កាត់បន្ថយសមាមាត្រប្រជាជនដែលខ្វះប្រព័ន្ធអនាម័យឱ្យកាន់តែប្រសើរឡើងបានពាក់កណ្តាល នៅឆ្នាំ២០១៥ |

| | |
|---|---|
| **សូចនាករ៣០:** សមាមាត្រប្រជាជនដែលមានប្រព័ន្ធអនាម័យប្រសើរឡើង | **សូចនាករ ៧.១២:** សមាមាត្រប្រជាជនជនបទដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង |
| | **សូចនាករ ៧.១៣:** សមាមាត្រប្រជាជនទីក្រុង/ប្រជុំជន ដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង |
| **សូចនាករ៣១:** អត្រានៃប្រជាជន ដែលមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី | **ចំណុចដៅរួមទី ១៦:** បង្កើនអត្រានៃប្រជាជនដែលមានសុវត្ថិភាពកាន់កាប់ដីធ្លីទូទាំងប្រទេស ទាំងជនបទ និងទីក្រុង ឱ្យបានច្រើននៅឆ្នាំ២០១៥ |
| | **សូចនាករ៧.១៤:** អត្រានៃប្រជាជនដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងជនបទ និងទីក្រុង |

តារាង ២.៧.២ បង្ហាញនូវតំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៧ សំរាប់ឆ្នាំ ២០០៥ ឆ្នាំ២០១០ និងឆ្នាំ២០១៥។ ទិន្នន័យមូលដ្ឋាននេះ ប្រែប្រួលទៅតាមទិន្នន័យដែលមាន។

**តារាង ២.៧.២: តំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៧ តាមលំដាប់ឆ្នាំ**

| **សូចនាករ** | **ទិន្នន័យមូលដ្ឋាន** | | **ចំណុចដៅ** | | |
|---|---|---|---|---|---|
| | **តំលៃ** | **ឆ្នាំ** | **២០០៥** | **២០១០** | **២០១៥** |
| ៧.១ គំរបព្រៃឈើជាភាគរយនៃផ្ទៃដីសរុប | ៦០ | (១) | ៦០ | ៦០ | ៦០ |
| ៧.២ ផ្ទៃដីតំបន់ការពារធម្មជាតិទាំង ២៣ (លានហិកតា) | ៣,៣ | ១៩៩៣ | ៣,៣ | ៣,៣ | ៣,៣ |
| ៧.៣ ផ្ទៃដីតំបន់អភិរក្សព្រៃឈើថ្មីទាំង ៦ (លានហិកតា) | ១,៣៥ | ១៩៩៦ | ១,៣៥ | ១,៣៥ | ១,៣៥ |
| ៧.៤ ចំនួនអ្នកអភិរក្សក្នុងតំបន់ការពារធម្មជាតិ | ៦០០ | ២០០១ | ៧៧២ | ៩៨៧ | ១.២០០ |
| ៧.៥ ចំនួនអ្នកអភិរក្សក្នុងតំបន់អភិរក្សព្រៃឈើ | ៥០០ | ២០០១ | ៥០០ | ៥០០ | ៥០០ |
| ៧.៦ សមាមាត្រផ្ទៃទឹកឡូត៍នេសាទ ដែលប្រគល់ទៅអោយសហគមន៍មូលដ្ឋាន | ៥៦ | ១៩៩៨ | ៥៨ | ៦០ | ៦០ |
| ៧.៧ ចំនួនសហគមន៍នេសាទ | ២៦៤ | ២០០០ | ៣៦៤ | ៤៦៤ | ៥៨៩ |
| ៧.៨ ផ្ទៃទឹកតំបន់ការពារដែលជាជំរកមច្ឆាជាតិ (ពាន់ហិចតា) | ២៦៤ | ២០០០ | ៥៨១ | ៥៨១ | ៥៨១ |
| ៧.៩ អត្រាគ្រួសារដែលប្រើអុសជាចំណីបាតុពល | ៩២ | ១៩៩៣ | ៧០ | ៦១ | ៥២ |
| ៧.១០ សមាមាត្រប្រជាជនជនបទដែលមានប្រភពទឹកស្អាតប្រើប្រាស់ | ២៤ | ១៩៩៨ | ៣០ | ៤០ | ៥០ |
| ៧.១១ សមាមាត្រប្រជាជនទីក្រុង/ប្រជុំជនដែលមានប្រភពទឹកស្អាតប្រើប្រាស់ | ៦០ | ១៩៩៨ | ៦៨ | ៧៤ | ៨០ |
| ៧.១២ សមាមាត្រប្រជាជនជនបទ ដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង | ៨,៦ | ១៩៩៨ | ១២ | ២០ | ៣០ |
| ៧.១៣ សមាមាត្រប្រជាជនទីក្រុង/ប្រជុំជនដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង | ៤៩ | ១៩៩៨ | ៥៩ | ៦៧ | ៧៤ |
| ៧.១៤ អត្រានៃប្រជាជនដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងជនបទ និងទីក្រុង[១១] | ១៥ | ២០០០ | ១៦ | ៣២ | ៦៥ |

(១) ឆ្នាំមូលដ្ឋានគឺជាមធ្យមភាគនៃគំរបព្រៃឈើក្នុងទសវត្សរ៍កន្លងមក (១៩៩២-២០០២)។

[១១] នៅពេលទិន្នន័យអាចរកបាន របាយការណ៍ក្នុងពេលអនាគតនឹងផ្តល់សូចនាករផ្សេងៗសំរាប់តំបន់ទីក្រុង/ប្រជុំជន និងជនបទ។

### ២.៧.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៧

នៅឆ្នាំ១៩៦៩ ព្រៃឈើបានគ្របសណ្តប់លើផ្ទៃដី ១៣.២ លានហិកតា ដែលស្មើនឹង ៧៣% នៃផ្ទៃដីប្រទេស។ រហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៧០ ការគ្រប់គ្រងព្រៃឈើនៅមានលក្ខណៈល្អប្រសើរ ដោយមិនសូវមានផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីទេ។ តំបន់ព្រៃឈើត្រូវបានបែងចែកទៅជាប្រភេទព្រៃបំរុង ដែលត្រូវគ្រប់គ្រងទៅតាមតួនាទី ដោយផ្តោតជាពិសេសទៅលើផលិតកម្មចីរភាព ការការពារ ការបង្កើតតំបន់ជំរកសត្វព្រៃ និងតំបន់ស្រាវជ្រាវ និងការអភិរក្សធនធានធម្មជាតិនៅជុំវិញតំបន់អង្គរវត្ត។

គំរបព្រៃឈើបានធ្លាក់ចុះមកនៅ ៥៨.៧% នៃផ្ទៃដីប្រទេសនៅឆ្នាំ១៩៩៧ ទោះបីជាមានការដាំឈើឡើងវិញចំនួន ១១១២៥ ហិកតា នៅចន្លោះឆ្នាំ១៩៨៥ និងឆ្នាំ២០០២ ក៏ដោយ។ គំរបព្រៃឈើដែលធ្លាក់ចុះនៅចន្លោះពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ឆ្នាំ២០០២ មានចំនួនជិត ២លានហិកតា បើគិតជាអត្រាបាត់បង់ គឺតិចជាងកន្លះភាគរយក្នុងមួយឆ្នាំៗ។ អត្រានេះធ្វើអោយកម្ពុជាស្ថិតនៅក្រោមចំនុចដៅ ៦០% របស់ខ្លួនដែលបានកំណត់សំរាប់ឆ្នាំ២០០៥ ដល់ឆ្នាំ២០១៥។

**រូប ២.៧.១: និន្នាការ និងចំនុចដៅស្តីពីគំរបព្រៃឈើកម្ពុជា គិតជាភាគរយធៀបនឹងផ្ទៃដីប្រទេស**




ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៣។

### ផ្ទៃដីតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សព្រៃឈើ

ព្រះរាជក្រិត្យមួយចេញឆ្នាំ១៩៩៣ បានបង្កើតអោយមានប្រព័ន្ធតំបន់ការពារធម្មជាតិបច្ចុប្បន្ន។ ផ្ទៃតំបន់ការពារធម្មជាតិមាន ៣២៧៣២០០ ហិកតា ចំណែកឯផ្ទៃតំបន់អភិរក្សព្រៃឈើវិញមាន ១៣៤៦២៦៨ ហិចតា។

### ចំនួនអ្នកអភិរក្សនៅក្នុងតំបន់ការពារធម្មជាតិ និងតំបន់អភិរក្សព្រៃឈើ

នៅឆ្នាំ១៩៩៨ មានអ្នកអភិរក្សចំនួន ៧៥នាក់ ហើយនៅឆ្នាំ២០០១ ចំនួនអ្នកអភិរក្សបានកើនឡើងរហូតដល់ ៦០០នាក់។ តួលេខនេះមិនបានរាប់បញ្ចូលអ្នកអភិរក្សប្រមាណជា ៥០នាក់ទៀត ដែលអង្គការអន្តរជាតិបានជួលអោយមកជួយអភិរក្សតំបន់ការពារធម្មជាតិ។ ចំពោះអ្នកអភិរក្សតំបន់អភិរក្សព្រៃឈើវិញមានចំនួន ៥០០ នាក់ ហើយចំនួននេះនឹងត្រូវរក្សាទុករហូតដល់ឆ្នាំ២០១៥។

**សមាមាត្រឡូត៍នេសាទ ដែលត្រូវបានប្រគល់ទៅអោយសហគមន៍មូលដ្ឋាន**

ចាប់តាំងពីឆ្នាំ១៩៩៨មក រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់ឡូត៍នេសាទអាជីវកម្មចំនួន ៥៦% ទៅអោយសហគមន៍មូលដ្ឋានវិញ។ កំណែទំរង់នេះនឹងធ្វើអោយកម្ពុជាឈានទៅសំរេចចំនុចដៅរបស់ខ្លួន ៦០% កំណត់នៅត្រឹមឆ្នាំ២០១០។

**ចំនួនសហគមន៍នេសាទមូលដ្ឋាន**

ចាប់តាំងពីឆ្នាំ២០០១មក រាជរដ្ឋាភិបាលបង្កើតបានសហគមន៍នេសាទចំនួន ២៦៤ ហើយមានទិសដៅបង្កើនចំនួនសហគមន៍នេសាទនេះអោយបាន ៥៨៩ នៅឆ្នាំ២០១៥។

**ផ្ទៃទឹកតំបន់ការពារដែលជាជំរកមច្ឆជាតិ**

តាមការប៉ាន់ស្មាននៅឆ្នាំ២០០០ ផ្ទៃទឹកតំបន់ការពារដែលជាជំរកមច្ឆជាតិទឹកសាប សំរាប់អភិរក្ស និងបង្កាត់ពូជមានចំនួន ២៦៤៥០០ហិកតា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានទិសដៅពង្រីកបន្ថែមនូវផ្ទៃទឹកតំបន់អភិរក្ស និងបង្កាត់ពូជត្រីនេះអោយបាន ៥៨០៨០០ហិកតា នៅឆ្នាំ២០១៥។

**អត្រាគ្រួសារដែលប្រើអុសជាថាមពល**

នៅកម្ពុជា ប្រជាជនជាង ៩២% ពឹងផ្អែកទៅលើអុសជាប្រភពថាមពលចំបង។ រាជរដ្ឋាភិបាលមានទិសដៅកាត់បន្ថយអត្រាប្រជាជន ដែលពឹងផ្អែកលើថាមពលអុសនេះអោយមកនៅត្រឹមតែ ៥២% នៅឆ្នាំ២០១៥។

**សមាមាត្រប្រជាជនជនបទ និងទីក្រុង/ប្រជុំជន ដែលមានទឹកស្អាតប្រើប្រាស់**

សមាមាត្រប្រជាជន ដែលមានទឹកស្អាតប្រើប្រាស់នៅតំបន់ទីក្រុង/ប្រជុំជន មានទំហំធំជាងនៅតំបន់ជនបទចំនួនពីរដង។ និន្នាការនេះឡើងខ្ពស់ ទាំងនៅក្នុងតំបន់ជនបទ និងទីក្រុង/ប្រជុំជន ទោះបីជាកម្ពុជាត្រូវសំរេចចំនុចដៅរបស់ខ្លួន ៥០% សំរាប់តំបន់ជនបទ នៅឆ្នាំ២០១៥ ក៏ដោយ។ សំរាប់តំបន់ទីក្រុង/ប្រជុំជន កម្ពុជានឹងស្ថិតនៅក្រោមចំនុចដៅកំណត់ ៨០% របស់ខ្លួនប្រហែលជា ១០%។

**រូប ២.៧.២: ទិន្នន័យ និងចំនុចដៅនៃសមាមាត្រប្រជាជនមានទឹកស្អាតប្រើប្រាស់នៅជនបទ និងទីក្រុង/ប្រជុំជន**




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០០, ក្រសួងផែនការ ឆ្នាំ២០០០ និងអង្គការសុខភាពពិភពលោក/អង្គការយូនីសេហ្វ ឆ្នាំ២០០១។

**សមាមាត្រប្រជាជនជនបទ និងទីក្រុង/ប្រជុំជន ដែលមានប្រព័ន្ធអនាម័យប្រសើរឡើង**

នៅឆ្នាំ១៩៩៨ ប្រជាជនជនបទចំនួន ៨.៦% និងប្រជាជនទីក្រុង/ប្រជុំជនចំនួន ៤៩% មានប្រព័ន្ធអនាម័យប្រសើរឡើង។ តាំងពីឆ្នាំនោះមក ចំនួនប្រជាជនដែលមានសេវាអនាម័យប្រើប្រាស់ ទាំងនៅក្នុងតំបន់ជនបទ និងទីក្រុង/ប្រជុំជន បានកើនឡើងក្នុងល្បឿនមួយដែលអាចឈានទៅសំរេចចំនុចដៅ គអសក នៅឆ្នាំ ២០១៥។ តាមការប៉ាន់ស្មានផ្អែកលើអត្រានេះ បានអោយដឹងថាប្រជាជនទីក្រុង/ប្រជុំជនចំនួន ១០០% និងប្រជាជនជនបទចំនួន ៥៥% នឹងមានប្រព័ន្ធអនាម័យប្រសើរឡើង លើសពីចំនុចដៅ ៧៤% និង ៣០% កំណត់ត្រឹមឆ្នាំ២០១៥។

**រូប ២.៧.៣: ទិន្នន័យ និងចំនុចដៅនៃភាគរយប្រជាជនជនបទ និងទីក្រុង/ប្រជុំជន ដែលមានប្រព័ន្ធអនាម័យប្រសើរឡើង**




ប្រភព: វិជ្ជាស្ថានជាតិស្ថិតិ ឆ្នាំ២០០០, ក្រសួងផែនការ ឆ្នាំ២០០០ និងអង្គការសុខភាពពិភពលោក/អង្គការយូនីសេហ្វ ឆ្នាំ២០០១។

**អត្រានៃប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ**

នៅឆ្នាំ២០០០ ប្រជាជនទូទាំងប្រទេស ទាំងទីក្រុង និងជនបទ មានប័ណ្ណកម្មសិទ្ធិដីធ្លីតែ ១៥% ប៉ុណ្ណោះ។ តាមផែនការប៉ាន់ស្មានរបស់គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) បានកំណត់ចំនុចដៅថានៅឆ្នាំ២០១៥ ប្រជាជនទូទាំងប្រទេស ទាំងទីក្រុង និងជនបទចំនួន ៦៥% នឹងមានប័ណ្ណកម្មសិទ្ធិដីធ្លី។

**២.៧.៣ គោលនយោបាយ និងកម្មវិធីសំខាន់ៗនាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក៧**

ដើម្បីទប់ស្កាត់កុំអោយមានការបាត់បង់ព្រៃឈើ ដូចក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ រដ្ឋសភាបានអនុម័តច្បាប់ព្រៃឈើ កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២។ ដើម្បីអោយមានចីរភាពបរិស្ថាន និងព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ ៥៤០ កសក នៅខែធ្នូ ឆ្នាំ២០០២ ស្តីអំពីការបញ្ឈប់រាល់សកម្មភាពព្រៃសម្បទាន។

ក្របខ័ណ្ឌស្ថាប័នច្បាស់លាស់មួយ សំរាប់តំបន់ការពារធម្មជាតិត្រូវបានបង្កើតឡើង ដោយបានបញ្ចូលតួនាទីរបស់ក្រសួងបរិស្ថាន (នាយកដ្ឋានអភិរក្ស និងការពារធម្មជាតិ និងមន្ទីរបរិស្ថានខេត្ត/ក្រុង) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានជលផល នាយកដ្ឋានរុក្ខាប្រមាញ់ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត/ក្រុង) និងរដ្ឋអំណាចខេត្ត/ក្រុង និងស្រុក។

គោលនយោបាយថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជាគឺសំដៅ: (១) ផ្គត់ផ្គង់ថាមពលអោយបានគ្រប់គ្រាន់នៅទូទាំងប្រទេស (២) ធានាអោយបាននូវការផ្គត់ផ្គង់ចរន្តអគ្គិសនីគ្រប់គ្រាន់តាមតំរូវការ (៣) ជំរុញអោយមានការរុករក និងស្រាវជ្រាវនូវប្រភពធនធានថាមពល តាមមធ្យោបាយមួយដែលធ្វើអោយមានចីរភាពបរិស្ថាន និងបំពេញបាននូវតំរូវការសង្គម និង (៤) ជំរុញការប្រើប្រាស់ថាមពលអោយមានប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីការប្រើប្រាស់ធនធានថាមពលទាំងនោះ ។

គោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលសំដៅ: (ក) ពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដើម្បីបង្កើនប្រសិទ្ធភាព និងទំនុកចិត្តលើទីផ្សារដី និងរក្សាភាពសុខដុមក្នុងសង្គមដោយការទប់ស្កាត់ជាមុន ឬការដោះស្រាយទំនាស់ដីធ្លី (ខ) ធានាការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដោយនិរន្តរភាព និងសមធម៌ និង (គ) ជុំរុញឱ្យមានការបែងចែកដីដោយសមធម៌ ។

ចំនុចដៅ គអស មានភាពស៊ីសង្វាក់គ្នាជាមួយនឹងយុទ្ធសាស្ត្រផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ដែលថ្មីៗនេះត្រូវបានអនុម័តនៅក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីកាលពី ខែកុម្ភៈ ឆ្នាំ២០០៣ កន្លងទៅនេះ ។ យុទ្ធសាស្ត្រផ្គត់ផ្គង់ទឹក និងអនាម័យជនបទ សំរាប់ទស្សនៈវិស័យរយៈពេល ២៥ឆ្នាំ (ពីឆ្នាំ២០០០ ដល់ឆ្នាំ២០២៥) បានចែងថា "មនុស្សគ្រប់រូបនៅក្នុងសហគមន៍ជនបទ ត្រូវទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជាប្រចាំ ហើយរស់នៅក្នុងបរិស្ថានដែលមានអនាម័យល្អនៅត្រឹមឆ្នាំ២០២៥" ។ មធ្យោបាយដើម្បីសំរេចបានទស្សនៈវិស័យនេះត្រូវបានកំណត់ដោយក្រុមការងារទឹកស្អាត និងអនាម័យ របស់ក្រសួងសំខាន់ៗ ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាអ្នកដឹកនាំ ។

### ២.៧.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៧

ក្នុងរយៈពេលមួយទសវត្សរ៍ខាងមុខនេះ កម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដើម្បីធានាអោយមានចីរភាពធនធានធម្មជាតិបរិស្ថាន ។ បញ្ហាប្រឈមសំខាន់ៗទាំងនោះគឺ:

- ជំរុញអោយសហគមន៍ចូលរួមកាន់តែច្រើន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដោយផ្តល់នូវរង្វាន់លើកទឹកចិត្តដល់ការប្រើប្រាស់ធនធានធម្មជាតិ តាមមធ្យោបាយមួយដែលមានចីរភាព។ យុទ្ធវិធីថ្មៃប្រឌិតគឺជាតំរូវការចាំបាច់ដើម្បីជំរុញអោយមានតុល្យភាព រវាងការធ្វើអាជីវកម្មលើធនធានធម្មជាតិ និងការអភិរក្ស ។ លើសពីនេះទៀត ត្រូវជំរុញអោយមានតម្លាភាព និងការទទួលខុសត្រូវខ្ពស់លើការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសនៅមូលដ្ឋាន ។
- ពង្រឹងការគ្រប់គ្រងដីរដ្ឋ ដោយធ្វើសមាហរណកម្មការធ្វើអត្តសញ្ញាណកម្ម ការកសាងផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ដើម្បីចុះបញ្ជីសារពើភ័ណ្ឌដីរដ្ឋ។ ទាំងការការពារ ការធ្វើអាជីវកម្ម និងការផ្តល់សម្បទាន ជួល ឬផ្ទេរដីរដ្ឋ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នឹងជួបការលំបាក ហើយនាំឱ្យខូចខាតបរិស្ថានធ្ងន់ធ្ងរ ប្រសិនបើដីរដ្ឋគ្រប់គ្រងមិនបានល្អ។ ដោយមានការគាំទ្រពីបណ្តាប្រទេសផ្តល់ជំនួយ រាជរដ្ឋាភិបាលនឹងជំរុញឱ្យមានបទដ្ឋានគតិយុត្តិ ដើម្បីធានាដល់ការគ្រប់គ្រងទ្រព្យរដ្ឋ ដោយតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ ។

- បង្កើនការវិនិយោគទាំងផ្នែកសាធារណៈ និងឯកជន លើការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងការផលិត និងបែងចែកប្រភពថាមពល។ តាមការប៉ាន់ស្មានរបស់ធនាគារពិភពលោក បានអោយដឹងថាដើម្បីសំរេចគអស ទុនវិនិយោគលើការផ្គត់ផ្គង់ទឹក និងអនាម័យត្រូវមានទឹកប្រាក់រហូតដល់ ៦០០លានដុល្លា សំរាប់រយៈពេលពីឥឡូវនេះរហូតដល់ឆ្នាំ២០១៥។
- ដោះស្រាយបញ្ហាថាមពលជំនួស ឆ្ពោះទៅប្រើប្រាស់ប្រភពថាមពលដែលមិនប៉ះពាល់ដល់បរិស្ថានអោយបានកាន់តែច្រើន។ កង្វះការវិនិយោគលើថាមពលដែលអាចកកើតមានជាថ្មី បានជំរុញអោយប្រជាជនជនបទ ពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើអុស ដើម្បីបំពេញតំរូវការថាមពលរបស់ពួកគេ។ បញ្ហាប្រឈមដែលត្រូវដោះស្រាយ គឺបង្កើតអោយមានបរិយាកាសអនុគ្រោះដល់ការវិនិយោគលើការផលិត និងការបែងចែកជំរើសនៃប្រភពថាមពល ដែលអាចមានលទ្ធភាពទទួលយកនៅតំបន់ជនបទ។ នៅពេលដោះស្រាយបញ្ហាទាំងនេះបាន រាជរដ្ឋាភិបាលក៏អាចកាត់បន្ថយការពឹងផ្អែកទៅលើឥន្ធនៈនាំចូលបានដែរ។
- ធានាអោយមានការសហការរវាងស្ថាប័នរាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ។ មានការបែងចែកភារកិច្ចទទួលខុសត្រូវជាន់គ្នា នៅក្នុងប្រព័ន្ធគ្រប់គ្រងនៃក្រសួងមួយចំនួន ដែលនាំអោយមានវិវាទនៅក្នុងចំណោមអាជ្ញាធរទទួលខុសត្រូវផ្សេងៗ។ បញ្ហាប្រឈមដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវដោះស្រាយ គឺត្រូវពិនិត្យមើលតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរាជរដ្ឋាភិបាលទាំងនោះឡើងវិញ ដើម្បីលើកកំពស់ប្រសិទ្ធភាពក្នុងកម្មវិធី និងគោលនយោបាយបរិស្ថាន។ រាជរដ្ឋាភិបាលត្រូវបញ្ជាក់អោយបានច្បាស់លាស់អំពីការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធ លើការអភិវឌ្ឍន៍ជនបទ និងទីក្រុង/ប្រជុំជន និងបង្កើនកិច្ចសហការគ្នាៈ (១)ក្នុងចំណោមស្ថាប័នរាជរដ្ឋាភិបាល (២)រវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ និង (៣)ក្នុងចំណោមម្ចាស់ជំនួយ។
- កាត់បន្ថយអត្រាកំណើនប្រជាជន ដើម្បីកាត់បន្ថយសម្ពាធលើធនធានធម្មជាតិបណ្តាលមកពីមានតំរូវការកាន់តែច្រើនចំពោះអុស ផ្ទះសំបែង ទឹក និងអនាម័យ និងដីធ្លី។ បញ្ហាប្រឈម ដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយ គឺរៀបចំអោយមានគោលនយោបាយស្តីពីផែនការគ្រួសារ ដែលមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយអត្រាកំណើនប្រជាជន។
- បង្កើនសមត្ថភាពបច្ចេកទេសដល់រាជរដ្ឋាភិបាល និងបង្កើតស្ថាប័នទទួលខុសត្រូវផ្នែកគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ដីធ្លី។ កង្វះសមត្ថភាពបច្ចេកទេស ធ្វើអោយបញ្ហាបរិស្ថាន មានសភាពកាន់តែធ្ងន់ធ្ងរថែមទៀតគិតចាប់ពីការរៀបចំដីធ្លី រហូតដល់ការគ្រប់គ្រងជីវៈចំរុះ និងព្រៃឈើ និងបង្កអោយមានភាពស្មុគ្រស្មាញដល់ការបង្កើតស្ថាប័ន សំរាប់ដោះស្រាយបញ្ហាពហុវិស័យទាំងនេះ។
- ពង្រឹងការប្រតិបត្តិច្បាប់ឱ្យបានសមស្រប ដោយបំបាត់ឥទ្ធិពលផ្សេងៗ បំបាត់កិច្ចអភិវឌ្ឍន៍ដោយខ្វះការត្រួតពិនិត្យ និងក្រុមអ្នកមានអំណាចហិរញ្ញវត្ថុ។ បញ្ហាប្រឈមដែលត្រូវដោះស្រាយ គឺការធានាឱ្យមាន

ការអនុវត្តន៍ច្បាប់តាមរយៈការកែទម្រង់វិស័យតុលាការ យោធា និងប៉ូលីស ដើម្បីធានាឱ្យបាននូវតម្លាភាពគោលនយោបាយសាធារណៈ ការប្រឆាំងអំពើពុករលួយ និងទទួលខុសត្រូវខ្ពស់របស់មន្ត្រីដឹកនាំ។

- ធ្វើយ៉ាងណាអោយមានការអនុវត្តន៍យុទ្ធសាស្ត្រ និងអោយអ្នកនយោបាយធ្វើតាមការសន្យារបស់ខ្លួន។ ផែនការយុទ្ធសាស្ត្រជាច្រើន មិនត្រូវបានយកទៅអនុវត្តដោយសាររាជរដ្ឋាភិបាលខ្វះធនធានហិរញ្ញវត្ថុ។

**២.៧.៥ ក្របខ័ណ្ឌការងារ ដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅ គអសក៧**

មានការយល់ស្របគ្នាថាធនធានធម្មជាតិអាចរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ប្រទេស និងជួយដល់ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍ជនបទ និងការបង្កើនការងារ ប្រសិនបើធនធានទាំងនោះត្រូវបានគ្រប់គ្រងអោយបានត្រឹមត្រូវ។ ទិសដៅយុទ្ធសាស្ត្រមានបង្ហាញដូចខាងក្រោមៈ

- កែលំអប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ អោយមានតម្លាភាព និងអាចព្យាករណ៍អំពីធនធានធម្មជាតិ (ជាពិសេសព្រៃឈើ ទឹក និងសត្វព្រៃ) ដោយឆ្លុះបញ្ចាំងនូវភាពកម្រ និងតំលៃពិត នៃធនធានទាំងនោះ។
- ពង្រឹងសមត្ថភាពដល់ស្ថាប័ន ក្នុងការអនុវត្តន៍អនុសញ្ញាស្តីពីជីវៈចំរុះ រួមទាំងការខិតខំប្រឹងប្រែង ដើម្បីពង្រឹងការរៀបចំ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិផង។
- អនុវត្តតាមបទដ្ឋាន ផ្នែកទឹក និងអនាម័យ (WATSAN)។
- ពង្រឹងការតាមដានការអនុវត្តន៍ច្បាប់ និងយុទ្ធសាស្ត្រទាក់ទងនឹងធនធានធម្មជាតិ។
- ពង្រឹងការសហការគ្រប់គ្រង លើការប្រើប្រាស់ធនធានឥន្ធនៈអោយមានចីរភាព។
- រៀបចំអោយមានការសិក្សាវាយតំលៃ ផ្នែកបរិស្ថានតាមបែបចូលរួមអោយបានហ្មត់ចត់ ទៅលើគំរោងវារីអគ្គិសនី នៅក្នុងតំបន់ការពារធម្មជាតិ។
- រៀបចំអោយមានក្របខ័ណ្ឌច្បាប់ រដ្ឋបាល និងបច្ចេកទេស ដើម្បីបង្កើនសុវត្ថិភាពកម្មសិទ្ធិដីធ្លី ជាពិសេសសំរាប់បងប្អូនជនជាតិភាគតិចនៅតំបន់ខ្ពង់រាប។
- រៀបចំអោយមានយុទ្ធនាការផ្សព្វផ្សាយពតិមាន ការអប់រំ និងការប្រាស្រ័យទាក់ទងជាមួយប្រជាជន ជាពិសេសស្ត្រី ដើម្បីអោយពួកគេមានការយល់ដឹងអំពីសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ។
- ជំរុញអោយមានមុខរបរចិញ្ចឹមជីវិតចំរុះសំរាប់សហគមន៍ ដែលរស់នៅជិតតំបន់ការពារធម្មជាតិ ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើធនធានព្រៃឈើ។
- លើកទឹកចិត្តផ្នែកឯកជន អោយធ្វើការវិនិយោគលើវិស័យថាមពល ទឹក និងគ្រប់គ្រងអាជីវកម្មព្រៃឈើ ដោយបង្កើតអោយមានបរិយាកាសល្អ រួមមានតម្លាភាព សមធម៌ និងការអនុវត្តន៍ច្បាប់ លទ្ធភាពទទួលបានឥណទាន ការកសាងសមត្ថភាព និងការចូលរួមរបស់សហគមន៍ បន្ថយនូវឧបសគ្គរាំងនានា និងបែងចែកអោយបានច្បាស់ពីតួនាទីរបស់បណ្តាក្រសួងពាក់ព័ន្ធ ដើម្បីកាត់បន្ថយភាពមិនច្បាស់លាស់ រវាងបញ្ហាជនបទ និងបញ្ហាទីក្រុង/ប្រជុំជន។
- ជំរុញផ្នែកឧស្សាហកម្ម ដោយបង្កើនការកែច្នៃលើសំភារៈដែលប្រើប្រាស់រួច។
- លើកកំពស់កិច្ចសហការល្អរវាង ស្ថាប័នរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ។

## ២.៧.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៧

រូប ២.៧.៤ បង្ហាញពីការបែងចែកតាមតំបន់នៃសូចនាករ គអសក៧ តាមខេត្ត/ក្រុង។ តំលៃនីមួយៗ តំណាងអោយសន្ទស្សន៍មានទំងន់មធ្យមស្មើគ្នា (equally weighted index) នៃសូចនាករដែលមានទិន្នន័យទាំងអស់របស់ គអសក៧។ សន្ទស្សន៍រួមទាំងនោះបង្ហាញនូវរូបភាពបែងចែកនូវស្ថានភាពរបស់ប្រទេស ទាក់ទងទៅនឹងចីរភាពបរិស្ថាន។ លទ្ធផលទាំងនេះអនុញ្ញាតិឱ្យយើង ធ្វើការបែងចែកខេត្ត/ក្រុងជាបីលំដាប់ថ្នាក់។ ខេត្ត/ក្រុងដែលមានពណ៌បៃតង ជាខេត្ត/ក្រុងដែលមានលទ្ធភាពប្រសើរជាងគេ ក្នុងការឈានទៅសំរេចចំណុចដៅ។ ខេត្ត/ក្រុងដែលមានពណ៌លឿង ជាខេត្ត/ក្រុងដែលមានលទ្ធភាពមធ្យម ហើយខេត្ត/ក្រុងដែលមានពណ៌ក្រហមមានលទ្ធភាពខ្សោយជាងគេ ក្នុងការឈានទៅសំរេចចំណុចដៅនៅឆ្នាំ២០១៥។ បណ្តាខេត្ត/ក្រុងដែលអន់ជាងគេមានពណ៌ក្រហម គឺច្រើនតែស្ថិតនៅភាគខាងជើង និងផ្ទៃកកណ្តាលនៃភាគខាងត្បូងនៃប្រទេស។

**រូប ២.៧.៤: សន្ទស្សន៍រួមនៃ គអសក៧ តាមខេត្ត/ក្រុង**




សំគាល់: សន្ទស្សន៍របស់ គអសក៧ គឺជាមធ្យមភាគដែលមានទំងន់ស្មើគ្នា ទៅតាមលំដាប់ខេត្តនីមួយៗ លើអថេរនៃសូចនាករ៤ របស់ គអសក៧។

## តារាង ២.៧.៣: សន្ទស្សន៍រួមនៃ គអសក៧ តាមខេត្ត/ក្រុង

| លេខកូដ | ខេត្ត/ក្រុង | សូចនាករ ៧.១២/៧.១៣ | សូចនាករ ៧.១០/៧.១១ | ការកើនឡើងឬថយចុះនៃគំរបព្រៃឈើពីឆ្នាំ១៩៩៣-៩៧ | សូចនាករ ៧.៩ | គអសក៧ |
|---|---|---|---|---|---|---|
| ១២ | ភ្នំពេញ | ១,០០០ | ១,០០០ | ១,០០០ | ០,៩៥៥ | ០,៩៨៩ |
| ២០ | ស្វាយរៀង | ០,១០១ | ០,៦៨៩ | ០,៩២៣ | ០,១៥៥ | ០,៤៦៧ |
| ១៤ | ព្រៃវែង | ០,០៥៣ | ០,៧៧៣ | ០,៨៩៧ | ០,១១១ | ០,៤៥៩ |
| ២៤ | ប៉ៃលិន | ០,០៥៩ | ០,១៩០ | គ្មាន | ១,០០០ | ០,៤១៦ |
| ០៨ | កណ្តាល | ០,១៧៤ | ០,៤៨០ | ០,៩៤៩ | ០,០៣៣ | ០,៤០៩ |
| ១៨ | ក្រុងព្រះសីហនុ | ០,២៨៤ | ០,១៦៨ | ០,៥៣៨ | ០,៥១៣ | ០,៣៧៦ |
| ១០ | ក្រចេះ | ០,១៧៩ | ០,៣៧៧ | ០,៨៧២ | ០,០៥៤ | ០,៣៧០ |
| ០៩ | កោះកុង | ០,១៧៦ | ០,៤៣៤ | ០,៣៣៣ | ០,៤៥៩ | ០,៣៥១ |
| ២៣ | ក្រុងកែប | ០,១៣២ | ០,២៥៩ | ០,៩៧៤ | ០,០៣៦ | ០,៣៥០ |
| ០៣ | កំពង់ចាម | ០,១៣៩ | ០,២៤៤ | ០,៩៤៩ | ០,០២៩ | ០,៣៤០ |
| ០២ | បាត់ដំបង | ០,២០៩ | ០,១៨៩ | ០,៨២១ | ០,១៣៥ | ០,៣៣៨ |
| ០៤ | កំពង់ឆ្នាំង | ០,០៥៣ | ០,២១៨ | ០,៩២៣ | ០,០៤៥ | ០,៣១០ |
| ១៥ | ពោធិ៍សាត់ | ០,០៥៩ | ០,១០២ | ០,៨៩៧ | ០,០៦០ | ០,២៩០ |
| ១១ | មណ្ឌលគិរី | ០,០៦៦ | ០,០៧២ | ០,៨៤៦ | ០,០១៤ | ០,២៥០ |
| ១៩ | ស្ទឹងត្រែង | ០,០៣១ | ០,១៥៦ | ០,៧១៨ | ០,០៦៦ | ០,២៤៣ |
| ០៧ | កំពត | ០,០៨៨ | ០,១១២ | ០,៦៤១ | ០,០៨៥ | ០,២៣១ |
| ០៦ | កំពង់ធំ | ០,១៧៤ | ០,០១០ | ០,៦៩២ | ០,០៤៨ | ០,២៣១ |
| ១៣ | ព្រះវិហារ | ០,០៣១ | ០,១១៣ | ០,៧៦៩ | ០,០០០ | ០,២២៨ |
| ០៥ | កំពង់ស្ពឺ | ០,០៣៧ | ០,២៨១ | ០,៣៣៣ | ០,០២៩ | ០,១៧០ |
| ១៧ | សៀមរាប | ០,០២៩ | ០,០៨០ | ០,៥១៣ | ០,០៤០ | ០,១៦៥ |
| ២១ | តាកែវ | ០,០៥១ | ០,១៥៥ | ០,២៣១ | ០,០៣៨ | ០,១១៩ |
| ១៦ | រតនគិរី | ០,០២៤ | ០,០២៤ | ០,៣៨៥ | ០,០៣៨ | ០,១១៧ |
| ០១ | បន្ទាយមានជ័យ | ០,១១៥ | ០,១៨៩ | ០,០២៦ | ០,១០៤ | ០,១០៨ |
| ២២ | ឧត្តរមានជ័យ | ០,០០០ | ០,០០០ | ០,០០០ | ០,០១៧ | ០,០០៤ |

ប្រភព: នាយកដ្ឋានរុក្ខាប្រមាញ់ ឆ្នាំ២០០៣ ក្រសួងផែនការ ឆ្នាំ១៩៩៨ ក្រសួងផែនការ/ក្រសួងសុខាភិបាល ឆ្នាំ២០០១ ក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ២០០៣។

## ២.៨ គោលដៅទី៨: បង្កើតភាពជាដៃគូជាសកលសំរាប់កិច្ចអភិវឌ្ឍន៍

គអសថ៨[១២] តំណាងឱ្យការទទួលខុសត្រូវរួមសំរាប់បង្កើនភាពជាដៃគូ រវាងបណ្តាប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍។ គោលដៅនេះទាក់ទងនឹងបណ្តាសកម្មភាពនានា ដែលរួមមានផ្នែកជំនួយអភិវឌ្ឍន៍ទៅដល់ផ្នែកបំណុល ពីផ្នែកពាណិជ្ជកម្មអន្តរជាតិ និងហិរញ្ញវត្ថុទៅដល់ភាពមានការងារធ្វើ ពីការទទួលបានបច្ចេកវិទ្យាថ្មីៗទៅផ្នែកកម្មសិទ្ធិបញ្ញា។

**តារាង ២.៨.១: ចំនុចដៅ និងសូចនាករ ជាសកល**

| ចំណុចដៅរួម | សូចនាករ |
|---|---|
| ១៧. បង្កើតថែមទៀតការបើកចំហប្រព័ន្ធពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ប្រកបដោយមូលដ្ឋានច្បាប់អាចប៉ាន់ស្មានបាន និងមិនមានការរើសអើងដោយរួមមាន ការប្តេជ្ញាឱ្យមានអភិបាលកិច្ចល្អ កិច្ចអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រទាំងថ្នាក់ជាតិ និងអន្តរជាតិ | **ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)**<br>៨.១ ODA សុទ្ធ ជាភាគរយនៃកិច្ចអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (DAC) ចំនូលជាតិសរុប (GNI) របស់ម្ចាស់ជំនួយ [ចំណុចដៅសរុប ០.៧% និង ០.៥% សំរាប់ប្រទេសក្រីក្របំផុត (LDC)]<br>៨.២ សមាមាត្រនៃ ODA ធៀបជាមួយសេវាសង្គមជាមូលដ្ឋាន (ការអប់រំមូលដ្ឋាន ការថែទាំសុខភាពបឋម អាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ) |
| ១៨. កំណត់ពីតំរូវការពិសេសរបស់ LDCs រួមមានការរួចពន្ធលើទំនិញនាំចេញឬនាំចូល និងកូតាដល់ការនាំចេញរបស់ LDC ជំរុញកម្មវិធីសំរាលបំណុលដល់បណ្តាប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ (HIPC) និងការទុកជាមោឃៈនូវបំណុលទ្វេភាគីផ្លូវការដល់បណ្តាប្រទេសដែលប្តេជ្ញាក្នុងការកាត់បន្ថយភាពក្រីក្រ | ៨.៣ សមាមាត្រនៃ ODA ឥតសំណង<br>៨.៤ សមាមាត្រនៃ ODA សំរាប់ផ្នែកបរិស្ថាននៅក្នុងបណ្តារដ្ឋដែនដីកោះតូចៗ<br>៨.៥ សមាមាត្រនៃ ODA សំរាប់ផ្នែកដឹកជញ្ជូននៅក្នុងបណ្តាប្រទេសមិនជាប់សមុទ្រ<br>**ការទទួលបានទីផ្សារ**<br>៨.៦ សមាមាត្រនៃការនាំចេញ (គិតជាតំលៃមិនបញ្ចូលអាវុធ) ដោយការរួចពន្ធ និងកូតា<br>៨.៧ កំរិតជាមធ្យមពន្ធលើទំនិញនាំចេញឬនាំចូល និងកូតាលើផលិតផលកសិកម្ម និងវាយនភ័ណ្ឌ និងសំលៀកបំពាក់ |
| ១៩. កំណត់តំរូវការពិសេសរបស់បណ្តាប្រទេសមិនជាប់សមុទ្រ និងបណ្តារដ្ឋដែនកោះតូចៗ (តាមរយៈកម្មវិធី Barbados និងបទបញ្ញត្តិរបស់មហាសន្និបាតសហប្រជាជាតិលើកទី ២២) | ៨.៨ ឧបត្ថម្ភធននៅក្នុងស្រុក និងការនាំចេញផលិតផលកសិកម្មនៅក្នុងបណ្តាប្រទេសនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD)<br>៨.៩ សមាមាត្រនៃ ODA ដែលផ្តល់ឱ្យដើម្បីជួយបង្កើនសមត្ថភាពពាណិជ្ជកម្ម |
| ២០. ដោះស្រាយបញ្ហាបំណុលនៃប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈវិធានការជាតិ និងអន្តរជាតិនានា ដើម្បីធ្វើឱ្យបំណុលមានចីរភាពក្នុងរយៈពេលវែង | **ចីរភាពបំណុល**<br>៨.១០ សមាមាត្រនៃបំណុលទ្វេភាគីផ្លូវការរបស់ HIPC ដែលបានលុបចោល<br>៨.១១ សេវាបំណុលជាភាគរយនៃការនាំចេញទំនិញ និង |

[១២] ការធ្វើមូលដ្ឋានីយកម្ម គអសថ៨ ទៅជា គអសកថ៨ នឹងត្រូវបញ្ចប់នៅពេលខាងមុខដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

| | |
|---|---|
| | សេវាកម្ម<br>៨.១២ សមាមាត្រនៃ ODA ដែលបានផ្តល់ឱ្យជាការសំរាលបំណុល<br>៨.១៣ ចំនួនប្រទេសដែលទទួលបានការសំរេចចិត្តជា HIPC និងការបំពេញល័ក្ខខ័ណ្ឌនានា |
| ២១. សហការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រសំរាប់ការងារសមរម្យ និងប្រកបដោយផលិតភាពសំរាប់យុវជន | ៨.១៤ អត្រាអត់ការងារធ្វើនៃអ្នកដែលមានអាយុ ១៥-២៤ឆ្នាំ |
| ២២. សហការជាមួយក្រុមហ៊ុនឱសថដើម្បីផ្តល់លទ្ធភាពអាចទទួលបានឱសថសារវ័ន្តនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ | ៨.១៥ សមាមាត្រប្រជាជនអាចទទួលបានឱសថសារវ័ន្តឈរលើមូលដ្ឋានប្រកបដោយចីរភាព |
| ២៣. សហការជាមួយផ្នែកឯកជនដើម្បីធ្វើឱ្យមានអត្ថប្រយោជន៍នៃបច្ចេកវិទ្យាថ្មីៗ ជាពិសេសផ្នែកពត៌មាន និងទូរគមនាគមន៍ | ៨.១៦ ចំនួនខ្សែទូរស័ព្ទក្នុងមនុស្ស ១០០០ នាក់<br>៨.១៧ ចំនួនកុំព្យូទ័រផ្ទាល់ខ្លួនក្នុងមនុស្ស ១០០០នាក់<br>សូចនាករ ដទៃទៀតនឹងត្រូវបង្កើតឡើង |

របាយការណ៍មិនបានផ្តល់ចំនុចដៅសូចនាករ និងក្របខ័ណ្ឌវិភាគស៊ីជំរៅ ដែលត្រូវធ្វើមូលដ្ឋានីយកម្មនៃគោលដៅនេះទេ។ ការនេះមិនត្រូវបកស្រាយច្រឡំ ហើយមិនត្រូវយល់ថាជាការព្យាយាមធ្វើឱ្យខ្សោយដល់ពតិមាននៅក្នុងគោលដៅនេះទេ ដោយសារវាមានន័យផ្ទុយពីនេះ។ ផ្នែកសំខាន់នៃ គអស៨ ស្តីពី គអស រួមត្រូវបានទទួលស្គាល់ទូលំទូលាយ។ ដូច្នេះទាមទារឱ្យមានការរួមបញ្ចូលយ៉ាងទូលំទូលាយ និងការពិគ្រោះយោបល់ក្នុងចំណោមការអភិវឌ្ឍន៍ទាំងអស់នៅកម្ពុជា។ ប៉ុន្តែទំហំនៃការពិគ្រោះយោបល់ និងរយៈពេលនៃដំណើរការនេះត្រូវការពេលវេលាបន្ថែមទៀតក្នុងការធ្វើឯកសារបច្ចុប្បន្ននេះ។ ក្នុងន័យនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាកំពុងដំណើរការធ្វើការវាយតំលៃទូលំទូលាយនៃ គអស៨ ដែលនឹងត្រូវបញ្ចប់ក្នុងប៉ុន្មានខែខាងមុខ។ គោលបំណង គឺបង្កើតឱ្យមានការយល់គ្នាទៅវិញទៅមកលើការទទួលខុសត្រូវ រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួន។ មានបញ្ហាបីដែលទាក់ទងជាពិសេសនឹងបរិបទកម្ពុជាដូចជា ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) លទ្ធភាពរកទីផ្សារ/ពាណិជ្ជកម្ម និងបំណុល។

**ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)**

ជំនួយអភិវឌ្ឍន៍ផ្លូវការមានសារៈសំខាន់នៅប្រទេសកម្ពុជា ដោយសារជំនួយអភិវឌ្ឍន៍ផ្លូវការតំណាងឱ្យសមាមាត្រដ៏ធំមួយនៃធនធានហិរញ្ញវត្ថុសាធារណៈ (ក្នុងឆ្នាំ២០០១ ចំណូលរដ្ឋាភិបាលទាំងមូលតិចជាង ៤០០ លានដុល្លាអាមេរិក ក្នុងខណៈដែលការបញ្ចេញប្រាក់ របស់ជំនួយអភិវឌ្ឍន៍ផ្លូវការមានច្រើនជាង ៤៧០លានដុល្លាអាមេរិក)។ ការធានាឱ្យបានប្រាកដថា ធនធានជំនួយអភិវឌ្ឍន៍ផ្លូវការត្រូវបានប្រើប្រាស់ក្នុងលក្ខណៈមានប្រសិទ្ធភាព និងមានការទទួលខុសត្រូវចំពោះ គអស មានសារៈសំខាន់បំផុត។ ដើម្បីសំរេចគោលដៅនេះឱ្យបានអាជ្ញាធរនានាបានបង្កើតប្រព័ន្ធគ្រប់គ្រង និងយន្តការស្ថាប័ន ដើម្បីជួយសំរបសំរួល និងគ្រប់គ្រងជំនួយតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា មានគំលាតខ្លាំងខាងសមត្ថភាពនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់ខ្លួនសំរាប់ទាក់ទងជាមួយម្ចាស់ជំនួយ ពីព្រោះរចនាសម្ព័ន្ធនិមួយៗមានច្បាប់ទំលាប់ និងបែបបទរៀងខ្លួន ដែលជាបន្ទុក

ដ៏ធំមួយ។ ដំណោះស្រាយមួយត្រូវបានស្នើឡើងដោយ OECD/DAC សំរាប់ដៃគូអភិវឌ្ឍន៍ បរទេសរបស់កម្ពុជា ដើម្បីយល់ព្រមឱ្យម្ចាស់ជំនួយជាអ្នកដឹកនាំលើផ្នែកនិមួយៗ។ ប្រទេសកម្ពុជាក៏សំណូមពរផងដែរថា ដើម្បីជំរុញឱ្យមានភាពស៊ីចង្វាក់គ្នាលើបញ្ហានានា OECD/DAC គួរតែពិនិត្យមើលលទ្ធភាពទាំងឡាយ ក្នុងការបង្កើតអនុក្រុមដែលមានសមាជិកនានាចូលរួម ដោយផ្តោតលើតំបន់ជាក់លាក់ណាមួយក្នុងពិភពលោក។ វិធីសាស្រ្តបែបនេះអាចឱ្យម្ចាស់ជំនួយ និងប្រទេសទទួលជំនួយនៅក្នុងតំបន់និមួយៗ រួមគ្នាបង្កើតនូវដំណោះស្រាយរួម ដែលទទួលស្គាល់ការលំបាក និងកាលានុវត្តភាពនានា នៅក្នុងបណ្តាប្រទេសទាំងឡាយនៅក្នុងតំបន់និមួយៗ។

ទោះបីជាមានការធ្វើអោយប្រសើរឡើង ក៏ស្ថានភាពបច្ចុប្បន្ន គឺស្ថិតក្នុងលក្ខណៈមួយដែលសមាមាត្រមួយភាគធំនៃ ODA ត្រូវបានធ្វើផែនការ និងផ្តល់ជូនដោយគ្មានការពិគ្រោះ និង/ឬការចូលរួមពីស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ស្ថានភាពនេះបានបណ្តាលឱ្យមានភាពជាម្ចាស់មិនពេញលេញរបស់រាជរដ្ឋាភិបាល លើគំរោងជាច្រើន កិច្ចប្រឹងប្រែង "ដាច់ពីគ្នា" និងការសំរបសំរួលមិនគ្រប់គ្រាន់ដោយភ្នាក់ងារផ្តល់ជំនួយ លើបញ្ហាតាមវិស័យ និងការកសាងស្ថាប័ន ការរីកដាលនៃវិធីលទ្ធកម្មដាច់ៗគ្នា ការបញ្ចេញប្រាក់ ការធ្វើសវនកម្ម និងបែបបទតាមដានខុសៗគ្នាក្នុងចំណោមភ្នាក់ងារទាំងឡាយ។

ក្នុងខណៈដែលប្រសិទ្ធភាពនៃជំនួយ និងការរួមវិភាគទានរបស់ជំនួយដល់កិច្ចអភិវឌ្ឍន៍ជាតិ ត្រូវបានរងគ្រោះដោយសារកត្តាដូចបានលើកឡើងខាងលើ មានភាពជឿនលឿនថ្មីៗមួយចំនួន ដែលនាំឱ្យមានសុទិដ្ឋិនិយម។ ភ្នាក់ងារប្រព័ន្ធអង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា បានបង្កើតឡើងនូវក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ក្នុងគោលបំណងធ្វើឱ្យមានភាពស៊ីសង្វាក់គ្នាថែមទៀត ចំពោះកម្មវិធីនានារបស់អង្គការសហប្រជាជាតិ។ ជាទូទៅសហគមន៍អន្តរជាតិបានបង្កើតក្រុមការងារ នៅតាមវិស័យនិមួយៗ ដើម្បី សំរបសំរួល វាយតំលៃ និងតាមដានការអនុវត្តន៍កម្មវិធីជំនួយនៅប្រទេសកម្ពុជា។ នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់លើកទី៦ បានប្រព្រឹត្តិទៅនៅក្នុងប្រទេសកម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០០២ សំណើមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតក្រុមការងារភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយត្រូវបានយល់ព្រមដោយមតិភាគច្រើនលើសលុប ហើយក្រុមការងារនេះបានត្រូវ បង្កើតឡើងជាផ្លូវការ នៅក្នុងខែសីហា ឆ្នាំ២០០២។ នៅក្នុងវិស័យអប់រំ និងសុខាភិបាល រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យ ក្នុងការកសាងភាពជាដៃគូ ដើម្បីអនុវត្តការធ្វើផែនការ និងកម្មវិធីរួមគ្នា ដែលនាំទៅដល់ការសំរេចបាននូវផែនការយុទ្ធសាស្រ្តអប់រំកម្មវិធីគាំទ្រវិស័យអប់រំ និងផែនការយុទ្ធសាស្រ្តសំរាប់វិស័យសុខាភិបាល។ មានតំរូវការអោយមានកិច្ចប្រឹងប្រែង និងត្រូវបង្កើតយន្តការសមស្របថែមទៀតដើម្បី: (១)វាយតម្លៃក្នុងលក្ខណៈជាប្រព័ន្ធនូវ កម្លាំងប្រៀបធៀបរបស់ដៃគូអភិវឌ្ឍន៍ និង (២)ធានាឱ្យបាននូវភាពស៊ីសង្វាក់គ្នារវាងម្ចាស់ជំនួយ ដែលចូលរួមក្នុងកិច្ចសំរុះសំរួលភាពជាដៃគូ ក្រោមវិធីសាស្រ្តតាមផ្នែកដ៏ទំលំទូលាយ (SWAP) និងអ្នកដែលមានបំណងបន្តអនុវត្តជំនួយ ដោយផ្អែកលើគំរោងជំនួយមូលដ្ឋាន (៣)សំរួល និងធ្វើឱ្យស្របគ្នានូវវិធានការ និងនីតិវិធីផ្ទៃក្នុង និងបែបបទរបស់ភ្នាក់ងារជាច្រើន និងធ្វើឱ្យស៊ីសង្វាក់គ្នានូវភាពផ្សេងៗគ្នាដទៃទៀតនៃការកសាងសមត្ថភាពរបស់ម្ចាស់ជំនួយ។

**បច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា** Information Communication Technology (ICT)

វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា មានឥទ្ធិពលលើគ្រប់វិស័យ និងដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ដោយទទួលស្គាល់នូវសារៈសំខាន់នេះ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា (NiDA) ដោយមាននាយករដ្ឋមន្ត្រីជាប្រធាន។ ការបង្កើតឡើងនូវអាជ្ញាធរនេះ និងមាននាយករដ្ឋមន្ត្រីធ្វើជាប្រធាន បង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលបានអនុម័តយកវិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា ជាអាទិភាពនៃកិច្ចអភិវឌ្ឍន៍របស់ខ្លួន។

ដោយយល់ឃើញថាវិស័យ ICT មានឥទ្ធិពលដល់ការអភិវឌ្ឍន៍គ្រប់វិស័យទាំងអស់ និងមានសារៈសំខាន់សំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់វិស័យ ICT ជាកំលាំងចលករដ៏ធំមហិមាជួយរុញច្រានការអភិវឌ្ឍន៍ដោយគ្មានការរារែក។ ដូច្នេះ ICT ក៏ជាបញ្ហាដ៏សំខាន់មួយទៀតដែលនឹងត្រូវបានប្រើប្រាស់ជាឧបករណ៍ជួយជំរុញឱ្យមានភាពស៊ីសង្វាក់គ្នា និងអន្តរប្រតិបត្តិការ។

រាជរដ្ឋាភិបាលបាន និងកំពុងប្រកាន់យកនូវជំហររឹងមាំឥតស្ទាក់ស្ទើរ អនុវត្តនូវគំរោងប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យា ក្រោយពីបានសិក្សាទៅលើគំរោងខាងលើនេះ ដែលអនុវត្តនៅប្រទេសមួយចំនួននៅក្នុងតំបន់។ គំរោងប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យានេះរួមមាន Application បីទៀតដូចជា ការចុះបញ្ជីអ្នកស្នាក់នៅ ការចុះបញ្ជីយានយន្ត និងការចុះបញ្ជីដីធ្លី។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាបានឆ្លងកាត់ដំណាក់កាលសាកល្បង និងកាត់បន្ថយពេលវេលាប្រមាណជា ១៥ឆ្នាំ ក្នុងដំណើរការនេះ។ ការបន្តផ្តល់ជំនួយ គឺដើម្បីពង្រីកប្រព័ន្ធដែលមានសព្វថ្ងៃ និងដើម្បីពង្រឹងសមត្ថភាពរបស់យើងឱ្យកាន់តែមានការិតខ្ពស់។

គំរោងប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យាគឺជាគំរោងសង្គមកិច្ចចំបង ហើយគួរតែមាននិរន្តរភាព។ ប្រព័ន្ធនេះគឺជាគំរោងមេ ឬជាកម្មវិធីរួមសំរាប់ Application ផ្សេងៗទៀតដែលនឹងត្រូវដាក់បញ្ចូលគ្នានាពេលអនាគត។ ដូច្នេះវាគួរតែត្រូវបានបង្កើតឡើងជាប្រព័ន្ធមានលក្ខណៈបើកចំហ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់ និងអន្តរប្រតិបត្តិការសំរាប់អ្នកបង្កើតប្រព័ន្ធ ឬអាស្រ័យទៅលើតំរូវការ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តគំរោងដទៃទៀតដូចជា ការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធពត៌មានវិទ្យា ការធ្វើជំរឿនស្ថិតិ ប្រព័ន្ធបង់ប្រាក់អេឡិចត្រូនិច ការកាត់វិសាយកងទ័ព ប្រព័ន្ធចុះបញ្ជី និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការជំរុញឱ្យមានការអនុវត្តន៍ និងការអភិវឌ្ឍន៍គំរោងប្រព័ន្ធរដ្ឋបាលពត៌មានវិទ្យា ឱ្យបានចំហទូលំទូលាយលើគ្រប់វិស័យជាបណ្តើរៗដូចជា ការគ្រប់គ្រងនូវវិស័យមួយចំនួនតាមអេឡិចត្រូនិចជាអាទិ៍ វិស័យទេសចរណ៍ ពាណិជ្ជកម្ម គយនិងរដ្ឋាករ ការងារប្រេងកាត និងការងារអាស៊ានជាដើម ដើម្បីរៀបចំមូលដ្ឋានគ្រឹះនៃសមត្ថភាពរបស់ខ្លួន សំរាប់ស្វែងរកដៃគូក្បៀរគរជំនួយពីសហគមន៍អន្តរជាតិ និងបណ្តាប្រទេសជាមិត្តលើសកលលោក។ គំរោងទាំងនេះបានរួមចំណែកយ៉ាងធំដល់កិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការធ្វើឱ្យការងាររដ្ឋាភិបាលកាន់តែប្រសើរឡើង និងនៅក្នុងការប្រើប្រាស់ធនធានដែលមានការិតរបស់យើងសំរាប់ការអភិវឌ្ឍន៍។

### ភាពជាដៃគូ ដើម្បីនិរន្តភាពនៃការអភិវឌ្ឍន៍នៅកម្ពុជា

ប្រទេសជាច្រើនក្នុងពិភពលោក ជាពិសេសប្រទេសដែលមានការអភិវឌ្ឍន៍ទាប បានទទួលនូវការរងគ្រោះដ៏ធ្ងន់ធ្ងរដោយសារសង្គ្រាមត្រជាក់ ។ ប្រទេសកម្ពុជា ដែលជាប្រទេសមួយក្នុងបណ្តាប្រទេសរងគ្រោះ បានឆ្លងកាត់ភ្នក់ភ្លើងសង្គ្រាមរ៉ាំរ៉ៃ ជាហេតុធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យត្រូវបានបំផ្លាញ ធនធានមនុស្សរាប់លាននាក់ត្រូវបានបាត់បង់ និងធ្វើឱ្យបាត់បង់ឱកាសសំរាប់កម្ពុជាក្នុងការអភិវឌ្ឍន៍ប្រទេស។ គំលាតរវាងប្រទេសដែលមានការអភិវឌ្ឍន៍ខ្ពស់ និងប្រទេសដែលមានការអភិវឌ្ឍន៍ទាប កាន់តែមានទំហំធំឡើង ជាហេតុធ្វើឱ្យមានកុងសង់ស៊ូសទូទាំងពិភពលោកថា ប្រទេសដែលមានការអភិវឌ្ឍន៍ខ្ពស់ មានករណីយកិច្ចចាំបាច់ត្រូវផ្តល់ធនធានប្រមាណ 0.៧% នៃផលិតផលជាតិរបស់គេ ដើម្បីជួយស្តារ និងអភិវឌ្ឍន៍ប្រទេសដែលមានការអភិវឌ្ឍន៍ទាប។

ម៉្យាងវិញទៀត កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស បានតំរូវឱ្យសហគមន៍អន្តរជាតិ មានកាតព្វកិច្ចជួយស្តារ កសាង និងអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ ដោយបង្កើតឱ្យមាននូវ "គណៈកម្មាធិការអន្តរជាតិស្តីពីការកសាងកម្ពុជាឡើងវិញ" (ICORC) ដើម្បីធ្វើការតាមដាន និងសំរបសំរួលការផ្តល់វិភាគទានពីសហគមន៍អន្តរជាតិ។

តាមរយៈការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ដែលមានការសន្យាជួយស្តារ និងអភិវឌ្ឍន៍កម្ពុជាក្នុងរយៈពេលជាង ១០ឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាបានសំរេចនូវសមិទ្ធិផលសំខាន់ៗជាច្រើន (ជាពិសេសក្នុងវិស័យអប់រំ និងសុខាភិបាល) តាមរយៈធនធានផ្ទាល់ និងការខិតខំប្រឹងប្រែងផ្ទាល់របស់ខ្លួន រួមផ្សំនឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយសហគមន៍អន្តរជាតិ។ យន្តការតាមដាន និងសំរបសំរួលនៃកិច្ចសហប្រតិបត្តិការទាំងនេះ ត្រូវបានដាក់ឱ្យអនុវត្តដែលមានលក្ខណៈចំហរ (Open) តម្លាភាព និងទទួលខុសត្រូវខ្ពស់ (Accountability)។ ការដកបទពិសោធន៍ក្នុងរយៈពេលជាង ១០ឆ្នាំ កន្លងមក បានបង្ហាញឱ្យឃើញថាកិច្ចសហប្រតិបត្តិការក្នុងការស្តារ កសាង និងអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យមានចីរភាព ចាំបាច់ត្រូវឈរលើទស្សនៈនៃ "ភាពជាដៃគូ ដើម្បីពង្រឹងភាពជាម្ចាស់ និងមគ្គុទេសក៍ភាពរបស់កម្ពុជា" (Partnership to strengthen ownership and leadership of Cambodia)។ នៅក្នុងស្មារតីនេះ ចាំបាច់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ ៤ ធំៗគឺ: ១-ការគោរពគ្នាទៅវិញទៅមក (Mutual Respect), ២-ការទុកចិត្តគ្នាទៅវិញទៅមក (Mutual Trust), ៣-ការទទួលខុសត្រូវទៅវិញទៅមក (Mutual Accountability), ៤-តម្លាភាពទៅវិញទៅមក (Mutual Transparency)។

កន្លងមក គោលការណ៍ទាំង៤ខាងលើ មិនបានអនុវត្តគ្រប់ជ្រុងជ្រោយ និងក្នុងពេលព្រមៗគ្នាបានទេ ថ្វីត្បិតតែយន្តការតាមដាន សំរបសំរួល និងវាយតំលៃត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយលក្ខណៈចំហរ តម្លាភាព និងទទួលខុសត្រូវក៏ដោយ (កិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍ផ្តល់ជំនួយប្រចាំឆ្នាំ ឆមាស និងត្រីមាស)។

ដូចនេះក្នុងការអនុវត្តន៍ទៅអនាគត ស្តីអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជា រាជរដ្ឋាភិបាលយល់ឃើញថា យើងត្រូវមាននីតិវិធានការកែលំអមួយចំនួន ដើម្បីអនុវត្តឱ្យបានល្អនូវគោលការណ៍ទាំង ៤ ខាងលើ ដូចជា:

១-ផែនការសកម្មភាពទាំងឡាយ ត្រូវឆ្លើយតបទៅនឹងអាទិភាព និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងការយកចិត្តទុកដាក់ជាចំបងទៅលើការអនុវត្តន៍ ជាជាងការធ្វើផែនការមិនឈប់ឈរ។

២-ការអនុវត្តន៍ផែនការសកម្មភាពទាំងឡាយ ត្រូវយកចិត្តទុកដាក់ និងគិតគូរទៅដល់សមត្ថភាពធនធាន និងពេលវេលាដ៏សមស្របរបស់ប្រទេសកម្ពុជា។

៣-បង្កើនការពិគ្រោះយោបល់គ្នា (Dialogue Approach) ជាជាងការធ្វើសុពលភាព (Validation Approach) ដែលការងារនេះតំរូវឱ្យសហគមន៍ផ្តល់ជំនួយធ្វើប្រតិភូកម្ម (Empower) ឱ្យតំណាងរបស់ខ្លួនប្រចាំនៅកម្ពុជាមានលទ្ធភាពពង្រឹងការងារបន្តទៀត។

៤-ការកំណត់នូវលទ្ធផលគ្រោងទុក (Expectation) ត្រូវឱ្យមានភាពប្រាកដនិយមដោយមានការពិគ្រោះយោបល់ជាមួយភាគីកម្ពុជា ដើម្បីជៀសវាងការវាយតំលៃខុសៗគ្នាលើលទ្ធផលដែលសំរេចបាន និងឈរលើលក្ខណៈវិនិច្ឆ័យនៃការវាយតំលៃ ដែលត្រូវកំណត់ជាមួយគ្នាឱ្យបានជាក់លាក់។

៥-ការផ្សព្វផ្សាយជាសាធារណៈ នូវរាល់ឯកសារឬរបាយការណ៍ទាំងឡាយ ត្រូវមានការពិគ្រោះយោបល់ និងឯកភាពជាមុនពីរាជរដ្ឋាភិបាលកម្ពុជា។

៦-ការអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេសត្រូវបានគិតគូរជាអាទិភាពខ្ពស់ ដើម្បីពង្រឹងភាពជាម្ចាស់។

៧-ការសំរបសំរួលឱ្យមានភាពរលូន ក្នុងសហគមន៍ផ្តល់ជំនួយតាមអាទិភាព របស់រាជរដ្ឋាភិបាលត្រូវបានពង្រឹង។

៨-ប្រទេសអភិវឌ្ឍន៍ខ្ពស់ ត្រូវបំពេញករណីយកិច្ច និងការសន្យារបស់ខ្លួនក្នុងការជួយជ្រោមជ្រែងប្រទេសដែលការអភិវឌ្ឍន៍នៅមានកំរិតទាប ឱ្យមានការរីកចំរើនទៅតាមអាទិភាពរបស់គេរៀងៗខ្លួន។

ដូច្នេះក្នុងការបន្តការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ដើម្បីស្តារកសាង និងអភិវឌ្ឍន៍ប្រទេសកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ឡើង ចាំបាច់ត្រូវពង្រឹងភាពជាដៃគូ និងភាពជាម្ចាស់របស់ប្រទេសកម្ពុជា តាមរយៈគោលការណ៍ដូចបានលើកឡើងខាងលើ។

**លទ្ធភាពរកទីផ្សារ/ពាណិជ្ជកម្ម**

រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ ក្នុងការធ្វើសមាហរណកម្មប្រទេសកម្ពុជាបន្ថែមទៀតទៅក្នុងសេដ្ឋកិច្ចពិភពលោក តាមរយៈការបង្កើនកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគីនៅពេលចូលសាកល្បងក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដ៏ខ្លីខាងមុខ។ លើសពីជំនួយអភិវឌ្ឍន៍ផ្លូវការ ដែលនឹងត្រូវកាត់បន្ថយតាមពេលវេលា ពាណិជ្ជកម្មគឺជាម៉ាស៊ីននៃការលូតលាស់ ដែលមានសក្តានុពលក្នុងការចូលរួមវិភាគទានដល់ការកាត់បន្ថយភាពក្រីក្រ និង គអសក ប្រកបដោយចីរភាព។ មានបញ្ហាទាក់ទងនឹងពាណិជ្ជកម្មមួយចំនួន ដែលជារឿងក្តីបារម្ភ។ ទី១ ភាពចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាពនៃវិស័យនាំចេញសំខាន់ៗ ដែលប្រឈមនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើង។ ទី២ ភាពចាំបាច់ដើម្បីធ្វើឱ្យលក្ខណៈចំរុះដល់មូលដ្ឋាននាំចេញ ដោយពឹងផ្អែកសំខាន់លើឧស្សាហកម្មកាត់ដេរ តាមរយៈការជំរុញវិស័យណា ដែលកម្ពុជាទំនងជាអាចមានប្រៀបដូចជា កសិឧស្សាហកម្ម។ ទី៣ ទាក់ទងនឹងការសម្រាល នូវផលប៉ះពាល់ជាអវិជ្ជមាននៃកំណែទំរង់ពាណិជ្ជកម្ម ដោយគិតទុកជាមុនថាអ្នក

ដែលទំនងជាឈ្នះ និងអ្នកដែលទំនងជាចាញ់ និងការអនុវត្តន៍កម្មវិធីទាំងឡាយ ដើម្បីទ្រទ្រង់អ្នកដែលទទួលផល ប៉ះពាល់ជាអវិជ្ជមាននេះ។ ទី៤ ទាក់ទងនឹងភាពចាំបាច់នៃការទទួលបាននូវចំណេះដឹងខាងបច្ចេកទេស និងវិនិយោគ ដើម្បីធ្វើឱ្យប្រទេសកម្ពុជាស្ថិតក្នុងស្ថានភាពមួយ ដែលនឹងអាចចាប់យកបាននូវកាលានុវត្តភាពទីផ្សារនាំចេញ។

រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកផ្នែកឯកជន ទាំងក្នុងស្រុកនិងបរទេស ជាគ្រឿងម៉ាស៊ីនសំរាប់ការរីកចំរើន។ ដើម្បីបំបាត់នូវការលំបាកសំខាន់ៗ ដែលរារាំងដល់ការអភិវឌ្ឍន៍ផ្នែកឯកជន ក៏ដូចជាការផ្តល់ធនធានក្នុងដំណើរការកំណែទំរង់ផ្នែកច្បាប់ និងរដ្ឋបាល វេទិការវាងរដ្ឋាភិបាល និងផ្នែកឯកជន ត្រូវបានបង្កើតឡើងក្នុងខែធ្នូ ឆ្នាំ១៩៩៩។ វេទិកានេះប្រព្រឹត្តទៅរៀងរាល់៦ខែម្តង ហើយត្រូវបានគាំទ្រដោយក្រុមការងារតាមផ្នែករបស់រដ្ឋាភិបាល និងក្រុមហ៊ុនជំនួញចំនួន៧ ដែលជួបគ្នារាល់ខែ ដើម្បីកំណត់សកម្មភាព និងធ្វើអនុសាសន៍ដើម្បីដោះស្រាយបញ្ហាជាក់លាក់តាមផ្នែក។

**បំណុល**

ថ្វីបើបន្ទុកបំណុលមានលក្ខណៈអាចគ្រប់គ្រងបាន រហូតមកដល់ពេលនេះ វាកំពុងមានការកើនឡើងយ៉ាងលឿនហើយប្រកបដោយគ្រោះថ្នាក់ ដែលសេវាបំណុលនឹងស្រូបយកកាន់តែច្រើនឡើងៗ នូវថវិកាសាធារណៈដ៏មានកំរិតដែលបណ្តាលឱ្យខ្វះធនធាន សំរាប់វិនិយោគក្នុងកិច្ចអភិវឌ្ឍន៍នានា។ លើសពីនេះទៀត មានភាពចាំបាច់ដើម្បីបង្កើនផលិតភាពនៃវិនិយោគសាធារណៈ ដើម្បីធានាឱ្យបានប្រាកដថាប្រាក់កំចី អាចបង្កើតបានចំណូលគ្រប់គ្រាន់សំរាប់សងបំណុលវិញ។ បញ្ហាពាក់ព័ន្ធមួយទៀត គឺការចែករំលែក និងការប្រើប្រាស់ជំនួយគ្មានសំណង និងប្រាក់កំចីនៅក្នុងជំនួយអភិវឌ្ឍន៍ផ្លូវការ។ មានភាពចាំបាច់ ដើម្បីមានកិច្ចព្រមព្រៀងគ្នាក្នុងការបង្កើនចំណែកនៃជំនួយគ្មានសំណងនៅក្នុងជំនួយអភិវឌ្ឍន៍ផ្លូវការ និងការប្រើប្រាស់ប្រាក់កំចីសំរាប់វិនិយោគ ដែលត្រូវបានរំពឹងទុកថាមានចំណូលខាងសេដ្ឋកិច្ចខ្ពស់។

## ២.៩ គោលដៅទី៩: ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ

គោលដៅទី ៩ មិនមានទំនាក់ទំនងជាមួយ គអស ទេ តែត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាអាទិភាពចំបងមួយក្នុងចំណោមអាទិភាពនានាសំរាប់ការស្តារ និងអភិវឌ្ឍន៏ប្រទេស ។ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្តន៏សន្ធិសញ្ញាទីក្រុងអូតាវ៉ា ដែលហាមប្រាមការប្រើប្រាស់ ការស្តុកទុក ការផលិត និងការជួញដូរគ្រាប់មីនប្រឆាំងនឹងមនុស្សជាតិ និងសំដៅអោយធ្វើការបំផ្លាញចោល ។ រាជរដ្ឋាភិបាលកម្ពុជាបានក្លាយជាហត្ថលេខីនៃសន្ធិសញ្ញានេះ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៩៧ ។ ហេតុដូច្នេះ គោលដៅនេះត្រូវបានបង្កើតឡើងជាពិសេសសំរាប់ឆ្លើយតបនឹងបញ្ហាប្រឈមនានា ទាំងបច្ចុប្បន្នក៏ដូចជាអនាគតរបស់កម្ពុជា ។

### ២.៩.១ ចំណុចដៅ និងសូចនាករនៃ គអសក៩

តារាង ២.៩.១ បង្ហាញនូវតំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករនៃ គអសក៩ តាមលំដាប់ឆ្នាំ ។ ទិន្នន័យមានតាំងពីឆ្នាំ១៩៩០ ហើយមានបង្ហាញនៅក្នុងតារាងខាងក្រោម ។

**តារាង ២.៩.១: តំលៃទិន្នន័យមូលដ្ឋាន និងតំលៃចំណុចដៅសំរាប់សូចនាករ គអសក៩**

| សូចនាករ | ទិន្នន័យមូលដ្ឋាន | | ចំណុចដៅ | | |
|---|---|---|---|---|---|
| | តំលៃ | ឆ្នាំ | ២០០៥ | ២០១០ | ២០១២ |
| **ចំនុចដៅរួមទី២៤:** ឆ្ពោះទៅរកអត្រាសូន្យនៃផលប៉ះពាល់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះត្រឹមឆ្នាំ២០១២ | | | | | |
| **សូចនាករ ៩.១:** ចំនួនជនស៊ីវិលរងគ្រោះថ្នាក់ប្រចាំឆ្នាំ | ១៦៩១ | ១៩៩៣ | ៥០០ | ២០០ | 0 |
| **សូចនាករ ៩.២:** ភាគរយនៃផ្ទៃដីដែលបានដោះមីនពីផ្ទៃដី ដែលបានសង្ស័យថាជាចំការមីនកំរិតធ្ងន់/ខ្ពស់/មធ្យម/ទាប | ១០ | ១៩៩៥ | ៥១ | ៧៧ | ១០០ |
| **ចំនុចដៅរួមទី២៥:** លុបបំបាត់ផលប៉ះពាល់ជាអវិជ្ជមានដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះលើមនុស្សជាតិ និងសេដ្ឋកិច្ចសង្គមកិច្ច ត្រឹមឆ្នាំ២០២៥ | | | | | |
| **សូចនាករ ៩.៣:** ក្របខ័ណ្ឌការងារដ៏ទូលំទូលាយមួយសំរាប់ជួយជនរងគ្រោះត្រូវបានបង្កើត និងអនុវត្ត | | | បាន បង្កើត | កំពុង អនុវត្ត | កំពុង អនុវត្ត |
| **សូចនាករ ៩.៤:** ចំនួនជនរងគ្រោះដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះត្រូវបានទទួលកញ្ចប់ឧបត្ថម្ភ និងធ្វើសមាហរណកម្មទៅក្នុងសង្គម | គ្មាន | | មិនទាន់ កំណត់ | មិនទាន់ កំណត់ | មិនទាន់ កំណត់ |

### ២.៩.២ និន្នាការកន្លងមក និងការវិភាគពីគំលាតនៃសូចនាករ គអសក៩

ក្រោយពីជំលោះជាងបីទសវត្សរ៍កន្លងមក កម្ពុជាបានក្លាយជាប្រទេសមួយដែលមានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះច្រើនបំផុតលើពិភពលោក ។ យោងតាមការអង្កេតថ្នាក់ជាតិកំរិត ១ ដែលបានបញ្ចប់នៅខែមេសា ឆ្នាំ២០០២ បង្ហាញថាប្រហែលជា ១២% នៃភូមិនៅកម្ពុជារងការប៉ះពាល់កំរិតខ្ពស់ ដោយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ។ នៅឆ្នាំ១៩៩៦ ចំនួនជនរងគ្រោះកើនឡើងរហូតដល់ ៤៣១៣នាក់ ដែលក្នុងនោះមានជនស៊ីវិលរងគ្រោះចំនួន ១៧៤៣នាក់ ។ រូប ២.៩.១ បង្ហាញពីចំនួនជនស៊ីវិលរងគ្រោះប្រចាំឆ្នាំ (ទាំងស្លាប់ និងរបួស) ដែលបានកត់

ត្រា។ តួលេខនេះអាចបញ្ជាក់ថា ប្រជាជនបានទៅធ្វើការតាំងទីលំនៅកាន់តែជិតចំការមីន ក្រោយពីប្រទេសកម្ពុជាទទួលបានសន្តិភាព។

ឆ្លើយតបនឹងស្ថានភាពដ៏បន្ទាន់នេះ នៅឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ដែលនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ រួមជាមួយកងយោធពលខេមរភូមិន្ទ និងអង្គការពីរទៀតគឺ HALO Trust និង MAG បានឈានទៅសំរេចយ៉ាងសំបើម ទាំងការកាត់បន្ថយចំនួនជនស៊ីវិលរងគ្រោះ និងការពង្រីកផ្ទៃដីដោះមីន (រូប ២.៩.១)។ ចេញពីលទ្ធផលនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចំណុចដៅឆ្ពោះទៅរកអត្រាសូន្យនៃផលប៉ះពាល់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះត្រឹមឆ្នាំ២០១២។ និន្នាការកន្លងមកបង្ហាញថាកម្ពុជាបានកាត់បន្ថយយ៉ាងសំបើមនូវ ចំនួនជនស៊ីវិលរងគ្រោះប្រចាំឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ តាមការធ្វើចំណោល ចំនុចដៅដែលបានកំណត់ប្រហែលជាមិនអាចសំរេចបានឡើយ។

**រូប ២.៩.១: និន្នាការ និងចំណុចដៅនៃចំនួនជនស៊ីវិលរងគ្រោះដែលបានកត់ត្រា (មិនរាប់បញ្ចូលយោធា)**




ប្រភព: ប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីននៅកម្ពុជា កាកបាទក្រហមកម្ពុជា និងអង្គការជនពិការអន្តរជាតិ ឆ្នាំ២០០៣។

ចំការមីនត្រូវបានទទួលស្គាល់ថា ជាបន្ទុកដ៏ធ្ងន់ធ្ងរចំពោះជីវភាពរស់នៅរបស់ប្រជាជននៅជនបទ។ ហេតុដូច្នេះ រាជរដ្ឋាភិបាលបានធ្វើការប្តេជ្ញាយ៉ាងមុតមាំ ដោយកំណត់ចំណុចដៅប្រកបដោយមហិច្ឆតាសំដៅលុបបំបាត់ការរងគ្រោះថ្នាក់ និងការបោសសំអាតចំការមីនអោយអស់ត្រឹមឆ្នាំ២០១២[១៣]។

តាមនិន្នាការកន្លងមក (រូប ២.៩.២) បង្ហាញថាភាគរយនៃផ្ទៃដី ដែលបានបោសសំអាតមីនប្រចាំឆ្នាំនៅកម្ពុជាបានកើនឡើងក្នុងល្បឿនយឺត។ ដូច្នេះ ចំណោលទៅមុខបង្ហាញថា ទោះជារាជរដ្ឋាភិបាលខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏ប្រហែលជាមិនអាចសំរេចបានតាមចំនុចដៅ ដែលបានកំណត់ត្រឹមឆ្នាំ២០១២ បានឡើយ។ តាមចំណោលត្រឹមឆ្នាំ២០១៥ កម្ពុជាប្រហែលជាអាចសំរេចបានត្រឹមតែ ៨១% ការបោសសំអាតមីនចេញពីតំបន់ដែលបានសង្ស័យថាមានមីន និងគ្រាប់មិនទាន់ផ្ទុះ។ ការបោសសំអាតមីន និងគ្រាប់មិនទាន់ផ្ទុះ ១០០% ទំនងជាអាចសំរេចបាននៅត្រឹមឆ្នាំ២០២០។

---

[១៣] សន្និសញ្ញាទីក្រុងអូតាវ៉ា បានទាមទារអោយកម្ពុជាបំបាត់គ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ និងបោសសំអាតចំការមីនអោយអស់ត្រឹមឆ្នាំ២០០៩។ បើសិនជាកម្ពុជាមិនអាចសំរេចបានទេ នោះត្រូវសុំពន្យាររយៈពេល ១០ឆ្នាំ បន្តទៀតជាមួយការប្តេជ្ញាចិត្តដ៏មោះមុតជាងមុន។

### រូប ២.៩.២: និន្នាការ និងចំណុចដៅនៃភាគរយផ្ទៃដីដែលបានដោះមីនលើផ្ទៃដីដែលបានសង្ស័យក្នុងកំរិតធ្ងន់ ខ្ពស់ មធ្យម និងទាប




ប្រភព: អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការ ឆ្នាំ២០០៣។

### ២.៩.៣ គោលនយោបាយ និងកម្មវិធីបច្ចុប្បន្នសំខាន់ៗនាពេលបច្ចុប្បន្ន ដែលរួមចំណែកដល់ គអសក៩

ដើម្បីធានាការបង្កើត និងអនុវត្តគោលនយោបាយជាតិអោយមានប្រសិទ្ធភាព និងមានការសំរបសំរួលល្អ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (CMAA) នៅខែកញ្ញា ឆ្នាំ២០០០។ CMAA ដូចអាជ្ញាធរផ្សេងទៀតដែរ នឹងជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតគោលនយោបាយ និងក្របខ័ណ្ឌបញ្ញត្តិសំរាប់ការគ្រប់គ្រងសកម្មភាពកំចាត់មីន និងធានាថាកម្មវិធីសកម្មភាពកំចាត់មីននានា នឹងរួមចំណែកដល់អាទិភាព និងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

ដើម្បីសំរេចបានតាមបេសកកម្មរបស់ខ្លួន CMAA បានរៀបចំយុទ្ធសាស្ត្រជាតិ សំរាប់សកម្មភាពកំចាត់មីន នៅឆ្នាំ២០០៣ សំដៅធ្វើសមាហរណកម្មសកម្មភាពកំចាត់មីន ទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ថ្នាក់ជាតិ និងបានកំណត់ចក្ខុវិស័យរយៈពេលមធ្យម និងវែង។ ចក្ខុវិស័យរយៈពេលមធ្យម គឺការលុបបំបាត់ផលប៉ះពាល់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះអោយដល់កំរិតសូន្យនៅត្រឹមឆ្នាំ២០១២ ដើម្បីជាការរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទាំងនេះអាចធានាបានតាមរយៈការដោះមីនចេញពីតំបន់ដែលមានការសង្ស័យកំរិតធ្ងន់ធ្ងរ និងខ្ពស់ និងបង្កើតកម្មវិធីអប់រំរយៈពេលខ្លីៗ ស្តីពីគ្រោះថ្នាក់ដោយសារគ្រាប់មីននៅតំបន់ដែលមានការសង្ស័យទាំងនោះ។ រីឯចក្ខុវិស័យរយៈពេលវែង គឺធានាថាកម្ពុជានឹងចាកផុតពីផលប៉ះពាល់ជាអវិជ្ជមានដល់មនុស្សជាតិ និងសេដ្ឋកិច្ចសង្គមកិច្ចដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះត្រឹមឆ្នាំ២០២៥ ដោយធានាអោយបានសមត្ថភាពថ្នាក់ជាតិ ដើម្បីដោះស្រាយបញ្ហានានានៅតំបន់ ដែលមិនបានបោសសំអាត និងតំបន់ដាច់ស្រយាលចាប់ពីឆ្នាំ២០១២ តទៅ។

នៅក្រោមយុទ្ធសាស្ត្រជាតិសំរាប់សកម្មភាពកំចាត់មីន ផែនការអភិវឌ្ឍន៍សកម្មភាពមីនរយៈពេល ៥ឆ្នាំ (២០០៣-២០០៧) ត្រូវបានបង្កើតឡើងដែលជាផែនការរំកិល។ ផែនការនេះមានគោលដៅបួនដែលក្រោមគោលដៅនីមួយៗមានវត្ថុបំណង និងសកម្មភាពជាច្រើនត្រូវបានកំណត់។ គោលដៅទាំងបួនរួមមាន:

- ការអនុវត្តន៏ការសំរបសំរួលថ្នាក់ជាតិ ដោយរួមមានការបង្កើតភាពជាអ្នកដឹកនាំថ្នាក់ជាតិ មូលដ្ឋានទិន្នន័យសកម្មភាពមីនថ្នាក់ជាតិ និងការអនុលោមតាមសន្ធិសញ្ញាទីក្រុងអូតាវ៉ា ។
- ការធ្វើអោយប្រសើរឡើងសកម្មភាពសេដ្ឋកិច្ចសង្គមកិច្ច ដោយរួមមានការកាត់បន្ថយភាពក្រីក្រ ការចូលរួមក្នុងកិច្ចអភិវឌ្ឍន៏ថ្នាក់ជាតិ និងការអនុវត្តន៏យន្តការភាពសេដ្ឋកិច្ច សង្គមកិច្ច ។
- ពង្រីកសមិទ្ធិផលសកម្មភាពមីន ដោយរួមមានការកំណត់និយមន័យតំបន់មានមីន ការធ្វើអាទិភាពសកម្មភាពបោសសំអាតមីន ដោយផ្អែកលើផលប៉ះពាល់ការអនុវត្តន៏បទដ្ឋានសកម្មភាពមីន ប្រព័ន្ធតាមដានប្រកបដោយប្រសិទ្ធភាព និងចីរភាព និងការបង្កើតសមត្ថភាពគ្រប់គ្រងដែលមានគុណភាព ។
- ការអភិវឌ្ឍន៏វិធានការឆ្លើយតបទៅនឹងការការពារ និងការព្យាបាលដោយរួមមាន ការកាត់បន្ថយហានិយភ័យ និងការតាមដានរាល់ជំនួយឧបត្ថម្ភដល់ជនរងគ្រោះដោយសារមីន ។

បច្ចុប្បន្ននេះ CMAA កំពុងអនុវត្តផែនការអភិវឌ្ឍន៏សកម្មភាពមីនរយៈពេល ៥ឆ្នាំ លើសកម្មភាពរួមមានផែនការការងារថ្នាក់ជាតិ បទដ្ឋានសកម្មភាពមីន យន្តការសេដ្ឋកិច្ចសង្គមកិច្ច បទបញ្ញត្តិ និងការកសាងសមត្ថភាព ។ ស្របពេលជាមួយកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា មានកម្មវិធី និងគំរោងជាច្រើនបាន និងកំពុងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងការបណ្តុះបណ្តាល និងស្តារនិតិសម្បទាដល់ជនពិការ ។ ទោះជាយ៉ាងនេះក្តី សកម្មភាពទាំងនេះពុំមានការសំរបសំរួលបានល្អទេ ហើយអង្គការមួយចំនួនកំពុងស្ថិតនៅក្នុងដំណាក់កាលបិទគំរោងរបស់ខ្លួន ។

**២.៩.៤ បញ្ហាប្រឈមសំខាន់ៗ ចំពោះការសំរេចឱ្យបាននូវចំណុចដៅនៃ គអសក៩**

នៅពេលបច្ចុប្បន្ន កម្ពុជាកំពុងខិតខំយ៉ាងខ្លាំងក្លាក្នុងការបោសសំអាតមីន និងគ្រាប់មិនទាន់ផ្ទុះដែលមានចំនួនរាប់លានគ្រាប់ ហើយរហូតដល់ពេលនេះមីន និងគ្រាប់មិនទាន់ផ្ទុះទាំងនោះបានធ្វើអោយគ្រោះថ្នាក់ដល់មនុស្សជាង ៥ម៉ឺននាក់ មកហើយ និងកំពុងបន្តគ្រោះថ្នាក់ដល់មនុស្សរាប់រយនាក់ជារៀងរាល់ឆ្នាំ ។ ក្នុងចំណោមជនរងគ្រោះដែលនៅរស់រានមានជីវិតមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលទទួលបានការស្តារនិតិសម្បទាពីសំណាក់អង្គការជាតិ និងអន្តរជាតិ ។ រហូតដល់ពេលនេះ នៅពុំទាន់មានផែនការជំនួយឧបត្ថម្ភដល់ជនរងគ្រោះនៅឡើយ ទោះបីជារាជរដ្ឋាភិបាលកម្ពុជា មានគោលនយោបាយសំរាប់ជំនួយឧបត្ថម្ភ និងការធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងសង្គមក៏ដោយ ។ បញ្ហាប្រឈមនានាមានដូចតទៅ:

- ផែនការជំរុញអត្រាដោះមីនអោយបាន ៥០% ប្រចាំឆ្នាំ នឹងមានន័យថាត្រូវបង្កើនការចំណាយ និងមធ្យោបាយថែមទៀតក្នុងសកម្មភាពបោសសំអាតមីន ។ ការបោសសំអាតមីននៅតំបន់កាន់តែឆ្ងាយមានការលំបាកកាន់តែច្រើន ។ ប្រតិបត្តិការមួយចំនួនកំពុងសាកល្បងគ្រឿងយន្តប្រភេទផ្សេងៗ ក្នុងការបោសសំអាតមីន ។
- ការថយចុះជំនួយបរទេស: សព្វថ្ងៃនេះចំណាយលើសកម្មភាពបោសសំអាតមីនក្នុងមួយឆ្នាំ គឺប្រហែលជា ៣០លានដុល្លា ។ ថវិកាទាំងនេះបានមកពីប្រភពផ្សេងៗគ្នា ។ ម្ចាស់ជំនួយមួយចំនួនបានបង្ហាញពីការផ្លាស់

ប្តូរអទិភាពរបស់ខ្លួននៅពេលខាងមុខនេះ ដែលសបញ្ជាក់ពីការថយចុះជំនួយនៅពេលអនាគត។ ដូច្នេះ នៅពេលនេះជាការចាំបាច់ ដែលត្រូវធ្វើការធានាចំពោះមុខម្ចាស់ជំនួយដោយធ្វើអោយគេមើលឃើញថា មូលនិធិរបស់គេត្រូវបានប្រើប្រាស់ដ៏មានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ។

- ក្របខ័ណ្ឌការងារដ៏ទូលំទូលាយ និងសមស្របថ្នាក់ជាតិមួយសំរាប់ជំនួយឧបត្ថម្ភដល់ជនរងគ្រោះ ត្រូវតែ បង្កើតឡើងតាមលក្ខណៈសិទ្ធិត្រូវទទួលបាន ជាជាងតាមលក្ខណៈម៉ូឌុលសំរាប់ជនពិការ។ មូលនិធិសំរាប់ ជំនួយឧបត្ថម្ភដល់ជនរងគ្រោះនៅពុំទាន់បានធានានៅឡើយ។ ឱកាសសំរាប់ទទួលបានមូលនិធិកាន់តែ មានតិចនៅពេលដែលម្ចាស់ជំនួយផ្លាស់ប្តូរអាទិភាពរបស់គេ។ ដូច្នេះ ជំនួយឧបត្ថម្ភដល់ជនរងគ្រោះត្រូវ តែបញ្ជ្រាបទៅក្នុងកម្មវិធីអភិវឌ្ឍន៍នានា និងចលនាជួយខ្លួនឯង។ អង្គការអន្តរជាតិធំៗមួយចំនួនកំពុងតែ សាកល្បងកម្មវិធីបែបនេះ នៅកម្ពុជាដោយមានការគាំទ្រពីម្ចាស់ជំនួយ។
- ការធ្វើអោយប្រសើរឡើង នូវស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់ជនរងគ្រោះ ត្រូវតែកំណត់អោយបាន។ ម៉ូឌុលសេដ្ឋកិច្ចមួយត្រូវតែបង្កើតឡើង ដែលអាចវាស់វែងបានរវាងការចំណាយ និងផលចំណេញពី សកម្មភាពបោសសំអាតមីនទាំងក៏រិតម៉ាក្រូ និងមីក្រូ។
- ត្រូវពង្រីកយុទ្ធសាស្រ្តកាត់បន្ថយហានិភ័យ។ ទីមួយ ត្រូវពង្រីកកម្មវិធីអប់រំ ដោយធ្វើការសំរបសំរួល អោយបានល្អតាមតំបន់ភូមិសាស្រ្ត។ ទីពីរ ត្រូវផ្តោតការយកចិត្តទុកដាក់លើបំលាស់ប្តូរលក្ខណៈប្រជា សាស្រ្តរបស់ជនរងគ្រោះដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ។
- កងកំលាំងប្រដាប់អាវុធនឹងត្រូវដើរតួរនាទីកាន់តែសំខាន់ ក្នុងការដោះមីននៅថ្ងៃអនាគត។ នេះបានន័យ ថាសមត្ថភាពរបស់ពួកគេ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ ត្រូវតែធ្វើអោយប្រសើរឡើងថែម ទៀត។
- មានការពិភាក្សាយ៉ាងល្អិតល្អន់ ពីបញ្ហាទទួលបានវិញតំលៃដើមក្នុងសេវាស្តារនិតិសម្បទា។ ជាទូទៅ ជន រងគ្រោះដោយសារមីនច្រើនតែជាក្រុមមនុស្ស ស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចទាបដែលនេះជាបញ្ហា ដែលពួកគេត្រូវប្រឈម។

### ២.៩.៥ ក្របខ័ណ្ឌការងារ ដើម្បីជំនះបញ្ហាប្រឈមសំខាន់ៗ និងសំរេចឱ្យបាននូវចំណុចដៅ គអសក៩

- ការបង្កើតក្របខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ចៈ ម្ចាស់ជំនួយដែលមានបំណងគាំទ្រសកម្មភាពបោសសំអាតមីន ទទួលបានការស្នើសុំដ៏សំបើមពីសំណាក់ប្រទេសនានាលើពិភពលោក។ ពួកគេចង់ឃើញលទ្ធផលការងារ ចេញជាតំលៃក្នុងមួយម៉ែត្រក្រឡានៃផ្ទៃដីបោសសំអាតមីន ផលប៉ះពាល់ដល់ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ដល់អ្នកទទួលផល និងចំនួនគ្រាប់មីនដែលបានដោះ។ ប្រទេសកម្ពុជាពុំមានទិន្នន័យសេដ្ឋកិច្ចគ្រប់គ្រាន់ ដែលអាចអោយម្ចាស់ជំនួយធ្វើការកំណត់ជាផលចំណេញផ្នែកសេដ្ឋកិច្ច ចេញពីសកម្មភាពបោសសំអាត មីនបាន។ គេបានស្នើដល់ CMAA អោយបង្កើតឡើងនូវក្របខ័ណ្ឌការងារមួយ ដែលម្ចាស់ជំនួយអាច ប្រើប្រាស់ ដើម្បីវាស់វែងផលចំណេញផ្នែកសេដ្ឋកិច្ច និងធានាថាលុយរបស់ពួកគេមានតំលៃខ្ពស់។

- ការបញ្ច្រាបទៅក្នុងកម្មវិធីអភិវឌ្ឍន៍នានាៈ បញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍ជំនួយឧបត្ថម្ភ សំរាប់ជនរងគ្រោះតាមរយៈការបញ្ច្រាបកម្មវិធីនេះ ទៅក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្រ គឺទាមទាអោយមានការបង្កើតយុទ្ធសាស្ត្រសហការគ្នាជាមួយនឹងបណ្តាអង្គការមិនមែនរដ្ឋាភិបាលនានា។ ដោយផ្អែកជនពិការនៅកម្ពុជាតំរូវអោយមានវិធីសាស្ត្រអភិវឌ្ឍន៍ ដោយផ្អែកលើសិទ្ធិនោះ ជំនួយឧបត្ថម្ភដល់ជនរងគ្រោះត្រូវតែធ្វើសមាហរណកម្មទៅក្នុងសង្គម ជាជាងការដាក់អោយនៅដាច់ពីគេ។
- ការពង្រឹងសមត្ថភាពរបស់កងយោពលខេមរៈភូមិន្ទៈ កងកំលាំងប្រដាប់អាវុធកម្ពុជា នឹងដើរតួនាទីឱ្យបានច្រើនក្នុងសកម្មភាពមីននៅពេលអនាគត។ មានន័យថា ការប្រឈមទៅនឹងសមត្ថភាពនេះ នឹងត្រូវការពង្រឹងបន្ថែមទៀត។ មានជំរើសជាច្រើនដែលត្រូវការស្វែងយល់ ដើម្បីធ្វើឱ្យចំណុចដៅនៃការបោសសំអាតមីនអាចសំរេចបាន។ សំណើរសុំថវិកាត្រូវបានដាក់ជូន សេវាសកម្មភាពមីនសំរាប់សហប្រជាជាតិ។
- ការសម្របសម្រួល/ការគាំទ្រនៃអង្គការមិនមែនរដ្ឋាភិបាល លើយុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ៈ ត្រូវការបង្កើតយុទ្ធសាស្ត្រភាពជាអ្នកដឹកនាំជាតិឡើង ដើម្បីពង្រីកសកម្មភាពកាត់បន្ថយគ្រោះថ្នាក់។ ភាគីដែលដើរតួសំខាន់ៗ បានបង្កើតម៉ូដែលសហការគ្នាល្អមួយ ដែលអាចជួយគ្នាទៅវិញទៅមកនៅទូទាំងប្រទេស។ បណ្តាញអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា គឺជាអ្នកអនុវត្តន៍នៅថ្នាក់កណ្តាល ហើយការជាប់ពាក់ព័ន្ធរបស់ស្ថាប័ននេះនឹងជាការសំខាន់ណាស់។ លើសពីនេះទៅទៀតកម្មវិធីថ្មីៗនឹងត្រូវ បង្កើតឡើងសំដៅចំពោះក្រុមគោលដៅជាក់លាក់ ឧទាហរណ៍ កុមារ និងគ្រាប់មិនទាន់ផ្ទុះ។

### **២.៩.៦ ភាពខុសគ្នាតាមតំបន់ក្នុងការសំរេចចំណុចដៅនៃ គអសក៩**

រូប ២.៩.៣ បង្ហាញការបែងចែកតាមខេត្ត/ក្រុង សំរាប់តំបន់ដែលសង្ស័យថាមានចំការមីន។ ពណ៌ក្រហមតំណាងអោយតំបន់ដែលមានការសង្ស័យកំរិតធ្ងន់ធ្ងរ និងខ្ពស់ រីឯពណ៌លឿង និងបៃតង ជាតំបន់ដែលមានការសង្ស័យកំរិតមធ្យម និងទាបរៀងគ្នា។ CMAA បានធ្វើចំណាត់ថ្នាក់នេះផ្អែកទៅលើលទ្ធផល នៃការធ្វើអង្កេតជាតិកំរិតមួយ។ តំបន់ដែលមានការសង្ស័យកំរិតខ្ពស់ គឺខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ក្រុងប៉ៃលិន និងខេត្តពោធិ៍សាត់។

## រូប ២.៩.៣: សន្ទស្សន៍រួមនៃ គអសក៩ តាមខេត្ត/ក្រុង




## តារាង ២.៩.២: សន្ទស្សន៍រួមនៃ គអសក៩ តាមខេត្ត/ក្រុង

| លេខកូដ | ខេត្ត/ក្រុង | គអសក៩ | លេខកូដ | ខេត្ត/ក្រុង | គអសក៩ | លេខកូដ | ខេត្ត/ក្រុង | គអសក៩ |
|---|---|---|---|---|---|---|---|---|
| ១៤ | ព្រៃវែង | ១,០០០ | ១០ | ក្រចេះ | ០,៩៧០ | ១៣ | ព្រះវិហារ | ០,៨៥៦ |
| ១២ | ភ្នំពេញ | ០,៩៩៩ | ២០ | ស្វាយរៀង | ០,៩៦៤ | ២៤ | ក្រុងប៉ៃលិន | ០,៧៨៥ |
| ១៨ | ក្រុងព្រះសីហនុ | ០,៩៩៨ | ១៦ | រតនគិរី | ០,៩៥៧ | ២២ | ឧត្តរមានជ័យ | ០,៦៤២ |
| ២៣ | ក្រុងកែប | ០,៩៩៦ | ០៥ | កំពង់ស្ពឺ | ០,៩៤០ | ០១ | បន្ទាយមានជ័យ | ០,៦៤១ |
| ១១ | មណ្ឌលគិរី | ០,៩៩៣ | ០៧ | កំពត | ០,៩១៥ | ១៧ | សៀមរាប | ០,៥៥៣ |
| ០៤ | កំពង់ឆ្នាំង | ០,៩៩២ | ១៩ | ស្ទឹងត្រែង | ០,៨៩៩ | ១៥ | ពោធិ៍សាត់ | ០,៥៤៧ |
| ០៨ | កណ្ដាល | ០,៩៨៥ | ០៣ | កំពង់ចាម | ០,៨៩៧ | ០២ | បាត់ដំបង | ០,០០០ |
| ២១ | តាកែវ | ០,៩៧៣ | ០៦ | កំពង់ធំ | ០,៨៩៥ | | | |
| | | | ០៩ | កោះកុង | ០,៨៧៣ | | | |

ប្រភព: អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការ ឆ្នាំ២០០៣។

# ផ្នែកទី៣

# វិធីសាស្ត្រតាមដាន និងវាយតម្លៃ

# លើភាពជឿនលឿននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

## ៣.១ ការតាមដានលើភាពជឿនលឿននៃ គអសក

ការវាស់វែងភាពជឿនលឿនរបស់ គអសក តំរូវឱ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃ។ ការតាមដានសំដៅលើ ១) ការរកឱ្យឃើញជាបន្ទាន់នូវការងាករេដ៏គួរឱ្យកត់សំគាល់ពីករិត ដែលគេរំពឹងទុកចំពោះធនធាន សកម្មភាព និងលទ្ធផល ដែលទាក់ទិននឹងគោលនយោបាយសំខាន់ៗ និងគំរោងទាំងឡាយដែលសំដៅសំរេចឱ្យបាននូវចំណុចដៅ គអស ទៅតាមលំដាប់ឆ្នាំដែលបានកំណត់ និង ២) វាយតម្លៃនិន្នាការនៃសូចនាករលទ្ធផល និងសូចនាករផលប៉ះពាល់របស់ គអស។ ដូច្នេះ ការតាមដានរួមមាន កំណត់ត្រាទុកជាទ្បេងទាត់នូវការវាស់វែងពីគំលាត និងការធ្វើរបាយការណ៍វិភាគជាមូលដ្ឋាន និងរក្សាទុកនូវទិន្នន័យអំពីសូចនាករសំខាន់ៗ។ ទិន្នន័យដែលចាំបាច់សំរាប់សកម្មភាពតាមដានបែបនេះរួមមាន ពតិមានជារូបវ័ន្ត និងហិរញ្ញវត្ថុអំពីធនធាន ដែលត្រូវបានប្រើប្រាស់ សកម្មភាពដែលបានធ្វើ និងលទ្ធផលដែលបានសំរេច (ទិន្នន័យដែលមានស្រាប់បានមកពីប្រភពគំរោង) ក៏ដូចជាទិន្នន័យដែលចាំបាច់សំរាប់គណនាសូចនាករលទ្ធផល និងផលប៉ះពាល់ដែលបានមកពីប្រភពការងាររដ្ឋបាលជាប្រចាំ និងពីការធ្វើអង្កេត។

ការតាមដានសូចនាករ គអស បានត្រូវបញ្ចូលក្នុងបញ្ជីសូចនាករភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាពនៃប្រព័ន្ធតាមដាន និងវិភាគភាពក្រីក្រនៅកម្ពុជា។ បញ្ជីសូចនាករភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាពនេះរួមមាន សូចនាករមួយចំនួនស្តីពី គអស យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទីពីរ ផែនការតាមវិស័យ និងការវាយតម្លៃប្រទេសរួម (Common Country Assessment) សំរាប់ការតាមដានភាពក្រីក្រ និងការវាយតម្លៃផលប៉ះពាល់នៅកម្ពុជា។ ដូច្នេះការតាមដាន គអស នឹងក្លាយជាចំណែកនៃយន្តការរួមមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការតាមដានភាពក្រីក្រ និងវាយតម្លៃផលប៉ះពាល់។

កម្ពុជាបានប្រឹងប្រែងយ៉ាងខ្លាំង ក្នុងទសវត្សរ៍កន្លងមកនេះ ដើម្បីកសាងឡើងវិញនូវប្រព័ន្ធស្ថិតិរបស់ខ្លួន ប៉ុន្តែកម្ពុជាត្រូវជំនះលើបញ្ហាប្រឈមមួយចំនួន ដើម្បីតាមដាន គអសក ប្រកបដោយប្រសិទ្ធភាព។ គុណភាពទិន្នន័យ គឺជាកង្វល់ដ៏ចំបងមួយ ពីព្រោះទិន្នន័យដែលមិនសូវមានគុណភាព នឹងធ្វើអោយតម្លៃសូចនាករមិនសូវត្រឹមត្រូវទៅតាមតថភាព ដែលជាហេតុនាំអោយការផ្តល់អនុសាសន៍ផ្នែកគោលនយោបាយមិនសូវបានល្អ។ តារាង ៣.១ ផ្តល់នូវការវាយតម្លៃខាងគុណភាពលើពតិមានដែលមាន ដើម្បីតាមដាន និងវាយតម្លៃភាពជឿនលឿននៅក្នុង គអសក។ តាមការវាយតម្លៃបានបង្ហាញថា មានភាពខុសគ្នាទាំងខាងបរិមាណ គុណភាព និងលទ្ធភាពអាចមានទិន្នន័យក្នុងចំណោម គអសក។ មានតែ គអសក មួយចំនួនប៉ុណ្ណោះ ដែលមានប្រព័ន្ធពតិមានអាចយកជាការបានក្នុងការធានានូវការតាមដានប្រកបដោយប្រសិទ្ធភាព។

ទិន្នន័យដែលរកបាននៅមានលក្ខណៈមធ្យម និងមានករិត ហើយប្រការនេះបានក្លាយជាផ្នែកមួយដែលជាក្តីបារម្ភក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ការលំបាកកើតឡើងពីការប្រមូលទិន្នន័យនៅមូលដ្ឋាន ពាក់ព័ន្ធនឹងកង្វះការសហការ

ក្នុងការផ្តល់ពត៌មាន និងការសំរបសំរួលនៅក្នុងការធ្វើអង្កេតធំៗ ដែលបណ្តាលឱ្យមានទិន្នន័យមិនគ្រប់គ្រាន់ចំពោះសូចនាករសំខាន់ៗ ឬមានទិន្នន័យច្រើន និងមិនច្បាស់លាស់ ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការបកស្រាយ ។ គុណភាពទិន្នន័យរដ្ឋបាល ក៏ជាក្តីបារម្ភដ៏ចំបងមួយផងដែរ ។ ក្នុងករណីភាគច្រើន ទិន្នន័យអង្កេត និងទិន្នន័យរដ្ឋបាលធម្មតាមានការប្រើប្រាស់មិនទាន់ទូលំទូលាយ ដោយសារធនធានមនុស្សនៅមានកំរិតក្នុងការគ្រប់គ្រង ការកែច្នៃ និងការវិភាគទិន្នន័យ ។ ម្យ៉ាងទៀត មូលដ្ឋានទិន្នន័យដែលបានមកពីការធ្វើអង្កេត ដែលចំណាយច្រើនមានការទុកដាក់ ឬការរក្សាទុកមិនទាន់បានល្អ និងមិនទាន់បានផ្តល់ឱ្យដល់អ្នកប្រើប្រាស់ទូលំទូលាយនៅឡើយ ។ មានតំរូវការជាបន្ទាន់នូវប្រព័ន្ធផ្សព្វផ្សាយមួយ ដែលមានតម្លៃថោក និងងាយស្រួលប្រើដែលសំរួលដល់ការទុកដាក់ឯកសារ ការទាញយកទិន្នន័យមកប្រើ និងការប្រើប្រាស់ដោយប្រើបច្ចេកវិទ្យាពតិមាន ។

## ៣.២ ការវាយតំលៃជំរើសគោលនយោបាយនានាដើម្បីសំរេចបាន គអសក

បន្ថែមលើបទដ្ឋានក្នុងការតាមដាន និងវាយតំលៃសកម្មភាពនានា ការវាយតំលៃជាប្រចាំលើផលប៉ះពាល់នៃគោលនយោបាយសាធារណៈ និងកម្មវិធី ជាប្រការមួយដ៏សំខាន់។ ការវាយតំលៃលើផលប៉ះពាល់ ប្រើប្រាស់ឧបករណ៍ផ្សេងៗលើសពីការតាមដាន និងការវាយតំលៃ ដើម្បីផ្តល់នូវការយល់ដឹងស៊ីជំរៅមួយលើទំនាក់ទំនងរវាងលទ្ធផលនៃកម្មវិធី និងផលប៉ះពាល់លើសុខុមាលភាព។ មានតំរូវការចាំបាច់ក្នុងការវាយតំលៃលើផលប៉ះពាល់ដោយរួមបញ្ចូលទាំងវិធីសាស្ត្របរិមាណ និងគុណភាព ដើម្បីផ្តល់នូវពតិមានដែលអាចយកជាការបានជូនដល់អ្នកធ្វើសេចក្តីសំរេចចិត្ត។ គោលដៅជាគន្លឹះ គឺការកសាងសមត្ថភាពជាតិ ដោយធានាឱ្យបានប្រាកដថាដៃគូជាតិត្រូវបានពាក់ព័ន្ធយ៉ាងជិតស្និទ្ធក្នុងការងារវាយតំលៃនេះ។ សកម្មភាពវាយតំលៃបែបនេះ ទាមទារមិនត្រឹមតែពតិមានដែលមានស្រាប់ប្រើប្រាស់រួច ហើយដើម្បីគោលបំណងតាមដានប៉ុណ្ណោះទេ ប៉ុន្តែក៏ទាមទារទាំងការប្រមូលទិន្នន័យនៅមូលដ្ឋានដោយពាក់ព័ន្ធជាមួយអ្នកទទួលផលពីកម្មវិធីក្នុងដំណើរការនេះផងដែរ។ រាជរដ្ឋាភិបាលនឹងចូលរួមនៅក្នុងសកម្មភាពទាំងឡាយ ដើម្បីវាយតម្លៃលើផលប៉ះពាល់នៃគោលនយោបាយសាធារណៈ និងកម្មវិធីផ្សេងៗ ស្តីពីគអសក។

## តារាង ៣.១: សមត្ថភាពសំរាប់ការតាមដាន និងធ្វើរបាយការណ៍ពីភាពជឿនលឿននៃ គអសក

| គអសក | បរិមាណ & ប្រក្រតីភាព ពត៌មានអង្កេត | | | គុណភាពពត៌មាន | | | ការវិភាគស្ថិតិ | | | ស្ថិតិក្នុងការធ្វើ គោលនយោបាយ | | | របាយការណ៍ និង ការផ្សព្វផ្សាយពត៌មាន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខ្លាំង | មធ្យម | ខ្សោយ | ខ្លាំង | មធ្យម | ខ្សោយ | ខ្លាំង | មធ្យម | ខ្សោយ | ខ្លាំង | មធ្យម | ខ្សោយ | ខ្លាំង | មធ្យម | ខ្សោយ |
| ១. ភាពក្រីក្រ និងការអត់ឃ្លាន | | ✓ | | | ✓ | | | ✓ | | ✓ | | | ✓ | | |
| ២. ការអប់រំកំរិតបឋមសិក្សាជាសកល | ✓ | | | | ✓ | | ✓ | | | ✓ | | | ✓ | | |
| ៣. សមភាពយេនឌ័រ | | ✓ | | | ✓ | | | ✓ | | | | ✓ | | | ✓ |
| ៤. អត្រាមរណភាពកុមារ | ✓ | | | | ✓ | | ✓ | | | | ✓ | | | ✓ | |
| ៥. សុខភាពមាតា | | ✓ | | | ✓ | | | ✓ | | | ✓ | | | ✓ | |
| ៦ក. មេរោគអេដស៍/ជម្ងឺអេដស៍ | | ✓ | | | ✓ | | | ✓ | | ✓ | | | | ✓ | |
| ៦ខ. ជម្ងឺគ្រុនចាញ់ គ្រុនឈាម និងរបេង | | | ✓ | | | ✓ | | ✓ | | | | ✓ | | ✓ | |
| ៧ក. ចីរភាពបរិស្ថាន | | | ✓ | | ✓ | | | ✓ | | | ✓ | | | | ✓ |
| ៧ខ. ទឹក និងអនាម័យ | | ✓ | | | ✓ | | | ✓ | | | ✓ | | | | ✓ |
| ៨. ភាពដៃគូជាសកលសំរាប់កិច្ចអភិវឌ្ឍន៍ | | | | | | | | | | | | | | | |
| ៩. សកម្មភាពមីន | ✓ | | | ✓ | | | | ✓ | | | ✓ | | | ✓ | |

## ៣.៣ ក្របខ័ណ្ឌស្ថាប័នសំរាប់ការតាមដាន និងការវាយតម្លៃលើ គអសក

ក្របខ័ណ្ឌស្ថាប័នដែលមានប្រសិទ្ធភាពមួយ មានសារៈសំខាន់បំផុតចំពោះការតាមដាន និងការវាយតំលៃលើភាពជឿនលឿននៃ គអសក។ ការតាមដានលើកម្មវិធី និងគំរោងតាមវិស័យនឹងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធ និងភ្នាក់ងារអនុវត្តនីដទៃទៀត។ ការយកចិត្តទុកដាក់របស់គេ នឹងផ្តោតទៅលើសូចនាករធនធាន សូចនាករដំណើរការ និងសូចនាការលទ្ធផល។ ភារកិច្ចចំបងរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៏សង្គមកិច្ច និងអង្គភាពបច្ចេកទេសតាមដាន និងវិភាគភាពក្រីក្រ របស់ក្រុមប្រឹក្សានេះ នឹងផ្តោតលើការតាមដានលទ្ធផល និងការវាយតំលៃផលប៉ះពាល់។ ដើម្បីសំរេចជោគជ័យបាន ភ្នាក់ងារផ្សេងៗចាំបាច់ត្រូវធ្វើជាដៃគូនៅក្នុងប្រព័ន្ធនេះ។ ការទទួលខុសត្រូវរួមនៅក្នុងកំរិតធ្វើគោលនយោបាយ ស្ថិតនៅក្រោមក្រុមប្រឹក្សាអភិវឌ្ឍន៏សង្គមកិច្ច។ រូប ៣.១ បង្ហាញនូវការរៀបចំស្ថាប័នសំរាប់ការតាមដាន និងការវាយតម្លៃ។

**រូប ៣.១: រចនាសម្ព័ន្ធស្ថាប័ន សំរាប់តាមដាន និងវាយតំលៃលើភាពក្រីក្រនៅកម្ពុជា**



ការតាមដាននៅក្នុងកំរិតមូលដ្ឋានលើកម្មវិធី និងគោលនយោបាយទាំងឡាយក៏នឹងត្រូវអនុវត្តផងដែរ។ ក្នុងខណៈដែលវិមជ្ឈការត្រូវបានពង្រឹង ហើយសមត្ថភាពត្រូវបានកសាងនៅក្នុងកំរិតមូលដ្ឋាន ធនធានហិរញ្ញវត្ថុកាន់តែកើនឡើង នឹងត្រូវបែងចែកដល់កំរិតមូលដ្ឋាន។ ជាផ្នែកមួយនៃសកម្មភាពក្នុងក្របខ័ណ្ឌកម្មវិធីសិលាមូលដ្ឋានទិន្នន័យមួយត្រូវបានបង្កើតឡើងថ្មីៗនេះ ដែលត្រូវបានពង្រឹងដោយដាក់បន្ថែមនូវពត៌មានលើសូចនាករនៅថ្នាក់ឃុំ/សង្កាត់។

## ៣.៤ ប្រព័ន្ធគ្រប់គ្រងពត៌មាន ស្តីពីភាពក្រីក្រកម្ពុជា

សេចក្តីព្រាងច្បាប់ស្ថិតិ ផ្តល់នូវការទទួលខុសត្រូវដល់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការប្រមូល ការផ្ទៀងផ្ទាត់ ការកែច្នៃ ការផលិត និងការផ្សព្វផ្សាយទិន្នន័យនៅថ្នាក់ជាតិ។ ប៉ុន្តែច្បាប់នេះក៏បានអនុញ្ញាតិឱ្យអង្គភាពស្ថិតិ និងភ្នាក់ងារផ្សេងៗទៀតធ្វើការប្រមូល និងផលិតទិន្នន័យរបស់គេផ្ទាល់សំរាប់ប្រើប្រាស់ផ្ទៃក្នុង។ ដូចមានចែងក្នុងច្បាប់នេះ អង្គភាពជាន់ខ្ពស់ពីរត្រូវបានស្នើឱ្យគ្រប់គ្រងការងារស្ថិតិរួមមាន ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិតិ (Statistics Advisory Council) ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងផែនការ និងគណៈកម្មាធិការសំរបសំរួលស្ថិតិ (Statistics Coordination Committee) ដែលដឹកនាំដោយអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ។

មកដល់ពេលនេះទិន្នន័យ និងពត៌មានដែលចាំបាច់សំរាប់ការតាមដាន និងវាយតំលៃត្រូវបានរាយប៉ាយនៅតាមអង្គភាពរដ្ឋាភិបាលផ្សេងៗ និងអ្នកពាក់ព័ន្ធដទៃទៀត។ ការទុកដាក់ ការគ្រប់គ្រង និងការផ្សព្វផ្សាយពត៌មាន តាមរយៈប្រព័ន្ធពត៌មានមួយដែលងាយស្រួលប្រើប្រាស់ គឺជាអាទិភាពចំបង។ ទិន្នន័យទាំងអស់ដែលបានពីប្រភពមូលដ្ឋាន និងដែលមានស្រាប់ នឹងត្រូវបានចងក្រងទុកដាក់ រួចឱ្យប្រើប្រាស់ជាបន្តបន្ទាប់នៅក្នុងទំរង់បែបផែនផ្សេងៗ ដោយអ្នកធ្វើសេចក្តីសំរេចចិត្ត និងអ្នកប្រើប្រាស់ដទៃទៀត។ ការបង្កើតឡើងនូវឃ្លាំងទិន្នន័យជាតិនឹងកាត់បន្ថយការលំបាកក្នុងការទទួលយកបាននូវទិន្នន័យ ការវិភាគទិន្នន័យ និងការធ្វើរបាយការណ៍ ទិន្នន័យនៅក្នុងបែបផែនផ្សេងៗគ្នា។ កម្ពុជាបានសំរេចចិត្តបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងពត៌មាន ស្តីពីភាពក្រីក្រមួយនៅក្នុងរូបភាពជាឃ្លាំងទិន្នន័យជាតិ ដែលនឹងត្រូវបានបញ្ចូលទៅក្នុងរចនាសម្ព័ន្ធស្ថិតិជាតិដែលមានស្រាប់។ ទិន្នន័យ និងពត៌មានដែលត្រូវបានប្រើប្រាស់ ដើម្បីគណនាតំលៃសូចនាករភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព នឹងត្រូវបានប្រមូល បញ្ចូល និងរក្សាទុកដាក់នៅក្នុងឃ្លាំងទិន្នន័យជាតិ។ ប្រព័ន្ធគ្រប់គ្រងពត៌មានស្តីពីភាពក្រីក្រកម្ពុជា ជាប្រព័ន្ធពត៌មានដ៏ពេញលេញមួយ ដែលមានឃ្លាំងទិន្នន័យជាតិមួយ ដែលស្ថិតនៅក្នុងវិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ និងឃ្លាំងទិន្នន័យតូចៗផ្សេងទៀត ដែលស្ថិតនៅតាមបណ្តាក្រសួងពាក់ពន្ធ័ និងស្ថាប័នដទៃទៀត។ គួរកត់សំគាល់ថាប្រព័ន្ធគ្រប់គ្រងពត៌មានស្តីពីភាពក្រីក្រកម្ពុជា នឹងមិនជំនួសឱ្យប្រព័ន្ធគ្រប់គ្រងពត៌មានដទៃទៀត នៅតាមបណ្តាក្រសួងពាក់ព័ន្ធ និងនៅកន្លែងផ្សេងៗទៀតឡើយ ប៉ុន្តែវានឹងអនុញ្ញាតិឱ្យមានការភ្ជាប់គ្នានិងតជាបណ្តាញក្នុងចំណោមប្រព័ន្ធគ្រប់គ្រងពត៌មានទាំងនោះ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច នឹងតំណាងឱ្យអ្នកប្រើប្រាស់ទិន្នន័យ ហើយក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិតិ (SAC) នឹងតំណាងឱ្យអ្នកគ្រប់គ្រងទិន្នន័យ/ផលិតទិន្នន័យ។ រចនាសម្ព័ន្ធស្ថាប័នទាំងពីរនេះនឹងរួមគ្នាបង្កើត

ឡើងនូវក្រុមការងារបច្ចេកទេសមួយ នៃប្រព័ន្ធគ្រប់គ្រងពត៌មានស្ដីពីភាពក្រីក្រកម្ពុជា ដែលមានសមាជិកជាអ្នកតំណាងនៃអ្នកប្រើប្រាស់ទិន្នន័យ និងអ្នកគ្រប់គ្រង/ផលិតទិន្នន័យដទៃៗទៀត។

ក្រុមការងារបច្ចេកទេសនៃប្រព័ន្ធគ្រប់គ្រងពត៌មាន ស្ដីពីភាពក្រីក្រកម្ពុជា នឹងធ្វើការសហការជាមួយក្រុមការងារស្ថិតិនៃវិជ្ជាស្ថានជាតិស្ថិតិ អង្គភាពស្ថិតិ និងភ្នាក់ងារផ្សេងៗទៀត ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នានៃកិច្ចការស្ថិតិ និងកិច្ចការគ្រប់គ្រងប្រចាំថ្ងៃ ចំពោះឃ្លាំងទិន្នន័យជាតិ។ រូប ៣.២ បង្ហាញពីការបង្កើតស្ថាប័នប្រព័ន្ធគ្រប់គ្រងពត៌មានស្ដីពីភាពក្រីក្រកម្ពុជា។

**រូប ៣.២: រចនាសម្ព័ន្ធស្ថាប័នសំរាប់ប្រព័ន្ធគ្រប់គ្រងពត៌មានស្ដីពីភាពក្រីក្រកម្ពុជា**



# ឯកសារយោង


១. Abbasi Zia (ឆ្នាំ២០០៣) *ភាពជាដៃគូនៅក្នុងការកសាងសមត្ថភាពស្ថិតិ ឆ្នាំ១៩៩៣-២០០៣* បទពិសោធន៍ ប្រទេសកម្ពុជា (ពង្រាងចុងក្រោយ) មូលនិធិរូបិយវត្ថុអន្តរជាតិ នាយកដ្ឋានស្ថិតិ ។

២. ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច (ឆ្នាំ២០០២) *ឯកសារយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥* ភ្នំពេញ ។

៣. ក្រសួងផែនការ និងក្រសួងសុខាភិបាល (ឆ្នាំ២០០១) *អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០០០* ភ្នំពេញ ។

៤. _____ (ឆ្នាំ២០០០) *របាយការណ៍ស្តីពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៩* ភ្នំពេញ ។

៥. វិទ្យាស្ថានជាតិស្ថិតិ (ឆ្នាំ១៩៩៨) *របាយការណ៍ស្តីពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៧* ភ្នំពេញ ។

៦. _____ (ឆ្នាំ១៩៩៥) *របាយការណ៍ស្តីពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៣-៩៤* ភ្នំពេញ ។

៧. _____ (ឆ្នាំ២០០០) *ជំរឿនប្រជាជនកម្ពុជា ឆ្នាំ១៩៩៨: លទ្ធផលចុងក្រោយ* ភ្នំពេញ ។

៨. _____ (ឆ្នាំ២០០០ក) *ចំណោលប្រជាជន: ការវិភាគលទ្ធផលជំរឿន (របាយការណ៍ ៦)* ភ្នំពេញ ។

៩. _____ (ឆ្នាំ២០០៣) គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០២ ព្រឹត្តិប័ត្រលេខ៧ ភ្នំពេញ ។

១០. _____ (ឆ្នាំ២០០៣ក) កំរងស្ថិតិកម្ពុជា ឆ្នាំ២០០២ (ពង្រាង) ភ្នំពេញ ។

១១. រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០០២) *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទីពីរ ២០០១-២០០៥* ភ្នំពេញ ។

១២. រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ១៩៩៧) *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទីមួយ ១៩៩៦-២០០០* ភ្នំពេញ ។

១៣. អង្គការសហប្រជាជាតិ (ឆ្នាំ២០០៣) *សូចនាករសំរាប់តាមដានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍* ញូវយ៉ក ។

១៤. កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (ឆ្នាំ២០០៣) របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០៣ ញូវយ៉ក ។


**ទាក់ទងនឹង គអសក១**


១. ក្រសួងផែនការ (ឆ្នាំ១៩៩៩) *ស្ថានភាពនៃភាពក្រីក្ររបស់ប្រទេសកម្ពុជា* ភ្នំពេញ ។

២. ក្រសួងផែនការ (ឆ្នាំ១៩៩៧) *របាយការណ៍ស្តីពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា* ភ្នំពេញ ។

៣. Prescott, Nicholas and Menno, Pradhan (ឆ្នាំ១៩៩៧) *ស្ថានភាពនៃភាពក្រីក្ររបស់ប្រទេសកម្ពុជា* ឯកសារពិភាក្សាលេខ ៣៧៣ វិទ្យាស្ថានធនាគារពិភពលោក វ៉ាស៊ីនតោនឌីស៊ី ។

៤. កម្មវិធីស្បៀងអាហារពិភពលោក និងក្រសួងផែនការ (ឆ្នាំ២០០២) *ការប៉ាន់ស្មានអត្រាភាពក្រីក្រនៅក្នុងកំរិតឃុំនៅប្រទេសកម្ពុជា* ភ្នំពេញ ។

**ទាក់ទងនឹង គអសក២**

១. ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ១៩៩៨ ១៩៩៩ ២០០០ ២០០១ ២០០២ក) *ស្ថិតិ និងសូចនាករអប់រំ* ភ្នំពេញ។

២. ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០០២ខ) *កម្មវិធីគាំទ្រវិស័យអប់រំ ២០០២-២០០៦* ភ្នំពេញ។

៣. ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០០៣) *របាយការណ៍បំពេញការងារវិស័យអប់រំ ការពិនិត្យឡើងវិញនូវកម្មវិធីគាំទ្រវិស័យអប់រំ* ភ្នំពេញ។

៤. រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០០៣) *ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ២០០៣-២០១៥* ភ្នំពេញ។

៥. អង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ (ឆ្នាំ១៩៩៨) *ការអភិវឌ្ឍន៍សូចនាករអប់រំពិភពលោក* ប៉ារីស។

**ទាក់ទងនឹង គអសក៣**

១. អគ្គលេខាធិការដ្ឋាននៃរដ្ឋសភាជាតិនៃប្រទេសកម្ពុជា *បញ្ជីសមាជិករដ្ឋសភានៃអាណត្តិទីមួយ ឆ្នាំ១៩៩៣ និងអាណត្តិទីពីរ ឆ្នាំ១៩៩៨ និងបញ្ជីសមាជិកសភាក្នុងឆ្នាំ២០០២* ភ្នំពេញ។

២. ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ១៩៩៨ ១៩៩៩ ២០០០ ២០០១ និង២០០២) *សូចនាករ និងស្ថិតិការអប់រំ* ភ្នំពេញ។

៣. ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ១៩៩៧ ១៩៩៨ក ១៩៩៩ក ២០០០ក ២០០១ក) *ស្ថិតិការអប់រំ ឆ្នាំ ១៩៩៦/៩៧ ១៩៩៧/៩៨ ១៩៩៨/៩៩ ១៩៩៩/២០០០ ២០០០/២០០១* ភ្នំពេញ។

៤. វិទ្យាស្ថានជាតិស្ថិតិ (ឆ្នាំ២០០២) *របាយការណ៍អង្កេតកំលាំងពលកម្មនៃប្រទេសកម្ពុជា ឆ្នាំ២០០១* ភ្នំពេញ។

៥. វិទ្យាស្ថានជាតិស្ថិតិ (ឆ្នាំ២០០១) *របាយការណ៍អង្កេតកំលាំងពលកម្មនៃប្រទេសកម្ពុជា ឆ្នាំ២០០០* ភ្នំពេញ។

**ទាក់ទងនឹង គអសក៤ និង៥**

១. ក្រសួងសុខាភិបាល (ឆ្នាំ២០០៣) *ការពិនិត្យឡើងវិញប្រចាំឆ្នាំ នូវការអនុវត្តន៏វិស័យសុខាភិបាល ឆ្នាំ ២០០៣* ភ្នំពេញ។

២. ______ (ឆ្នាំ២០០២ក) *ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ភាគ១ ឆ្នាំ២០០៣-២០០៧* ភ្នំពេញ។

៣. ______ (ឆ្នាំ២០០២ខ) *ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ភាគ២ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ឆ្នាំ២០០៣-២០០៧* ភ្នំពេញ។

៤. ______ (ឆ្នាំ២០០២) *ក្របខ័ណ្ឌសំរាប់ការតាមដាន និងវាយតំលៃ ភាគ៣ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ឆ្នាំ២០០៣-២០០៧* ភ្នំពេញ។

៥. ______ (ឆ្នាំ២០០២) *ក្របខ័ណ្ឌសំរាប់ផែនការប្រតិបត្តិការប្រចាំឆ្នាំ ភាគ៤ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ឆ្នាំ២០០៣-២០០៧* ភ្នំពេញ។

៦. ______ (ឆ្នាំ១៩៩៨) *អង្កេតសុខភាពជាតិ* ភ្នំពេញ។

៧.	______ (ឆ្នាំ១៩៩៤) *សុខភាពមាតា និងកុមារ ផែនការសុខាភិបាលជាតិ ឆ្នាំ១៩៩៤-១៩៩៦ របស់ប្រទេសកម្ពុជា* ភ្នំពេញ។

៨.	______ (ឆ្នាំ១៩៩៤ក ១៩៩៥ ១៩៩៦ ១៩៩៧ ១៩៩៨ក និង១៩៩៩) *របាយការណ៍ស្ថិតិសុខាភិបាល* ភ្នំពេញ។

៩.	ធនាគារពិភពលោក (ឆ្នាំ២០០២) *មូលដ្ឋានទិន្នន័យនៃសូចនាករអភិវឌ្ឍន៍ពិភពលោក*។

១០.	http://www.unicef.org/statis/Country_1Page92.html

**ទាក់ទងនឹង គអសក៦**

១.	មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (ឆ្នាំ២០០១) *ផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ សំរាប់គ្រប់គ្រងជម្ងឺរបេង ឆ្នាំ២០០១-២០០៥* ភ្នំពេញ។

២.	មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (ឆ្នាំ២០០១ក) *គោលនយោបាយ និងយុទ្ធសាស្ត្រសុខាភិបាលជាតិ សំរាប់គ្រប់គ្រងជម្ងឺរបេង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១-២០០៥* ភ្នំពេញ។

៣.	Christopher D. et al. (ឆ្នាំ១៩៩៩) អង្គការសុខភាពពិភពលោក គំរោងអង្កេតតាមដានជាសកល។ បន្ទុកជំងឺរបេងជាសកលៈ ការប៉ាន់ស្មានអត្រាឆ្លងថ្មី អត្រាប្រេវ៉ាឡង់ និងអត្រាស្លាប់ តាមប្រទេស។ ទស្សនាវដ្តីសមាគមន៍វេជ្ជសាស្ត្រអាមេរិកាំង លេខ២៨២ៈ ៦៧៧-៦៨៦។

៤.	ក្រសួងសុខាភិបាល (ឆ្នាំ២០០២) *កម្មវិធីជាតិកំចាត់ជម្ងឺរបេងៈ ស្ថិតិប្រចាំឆ្នាំស្តីពីជម្ងឺរបេងនៅប្រទេសកម្ពុជា* ភ្នំពេញ។

៥.	ក្រសួងសុខាភិបាល (ឆ្នាំ១៩៩៤ ១៩៩៥ ១៩៩៦ ១៩៩៧ ១៩៩៨ ១៩៩៩ និង២០០០) *របាយការណ៍ស្ថិតិសុខាភិបាលជាតិ* ភ្នំពេញ។

៦.	ក្រសួងសុខាភិបាល (ឆ្នាំ១៩៩៦ក) *គោលនយោបាយ និងយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ១៩៩៦-២០០០* ភ្នំពេញ។

៧.	ក្រសួងផែនការ (ឆ្នាំ២០០១) *របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជា របាយការណ៍ស្តីពីទិដ្ឋភាពសង្គមនៃការរាតត្បាតមេរោគអេដស៍/ជម្ងឺអេដស៍នៅកម្ពុជា* ភ្នំពេញ។

៨.	អាជ្ញាធរជាតិប្រយុទ្ធជម្ងឺអេដស៍ (ឆ្នាំ២០០៣) *របាយការណ៍កម្ពុជាស្តីពីការអនុវត្តន៍នូវសេចក្តីថ្លែងការណ៍លើការប្តេជ្ញាចំពោះមេរោគអេដស៍/ជម្ងឺអេដស៍* (UNGASS) ភ្នំពេញ។

៩.	អាជ្ញាធរជាតិប្រយុទ្ធជម្ងឺអេដស៍ (ឆ្នាំ២០០១) *ផែនការយុទ្ធសាស្ត្រជាតិសំរាប់ការយល់ដឹង និងការឆ្លើយតបជាពហុវិស័យ ចំពោះមេរោគអេដស៍/ជម្ងឺអេដស៍ ឆ្នាំ២០០១-២០០៥* ភ្នំពេញ។

១០.	មជ្ឈមណ្ឌលជាតិប្រយុទ្ធមេរោគអេដស៍/ជម្ងឺអេដស៍ សើស្បែកនិងកាមរោគ (ឆ្នាំ២០០២) *ការផ្សព្វផ្សាយនៃអង្កេតតាមដានប្រេវ៉ាឡង់មេរោគអេដស៍* ភ្នំពេញ។

១១.	មជ្ឈមណ្ឌលជាតិប្រយុទ្ធមេរោគអេដស៍/ជម្ងឺអេដស៍ សើស្បែក និងកាមរោគ (ឆ្នាំ២០០២ក) *ការអង្កេតតាមដានការប្រព្រឹត្ត* ភ្នំពេញ។

១២.	មជ្ឈមណ្ឌលជាតិប្រយុទ្ធមេរោគអេដស៍/ជម្ងឺអេដស៍ សើស្បែក និងកាមរោគ (ឆ្នាំ១៩៩៩) *របាយការណ៍ស្តីពីការអង្កេតអត្រាប្រេវ៉ាឡង់មេរោគអេដស៍* ភ្នំពេញ។

១៣. មជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់ (ឆ្នាំ២០០៣) *របាយការណ៍ប្រព័ន្ធពត៌មានសុខាភិបាល* ភ្នំពេញ។
១៤. មជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់ (ឆ្នាំ២០០២) *របាយការណ៍ប្រចាំឆ្នាំ២០០២ និងផែនការប្រតិបត្តិឆ្នាំ២០០៣* ភ្នំពេញ។
១៥. មជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺគ្រុនចាញ់ (ឆ្នាំ២០០០) *របាយការណ៍ពត៌មានសុខាភិបាល* ភ្នំពេញ។

**ទាក់ទងនឹង គអសក៧**

១. ព្រះរាជាណាចក្រកម្ពុជា *ការបង្កើត និងការរៀបចំតំបន់ការពារៈ ព្រះរាជក្រិត្យប្រកាសថ្ងៃ ១ វិច្ឆិកា ឆ្នាំ១៩៩៣ ដោយព្រះមហាក្សត្រ* ភ្នំពេញ។
២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានរុក្ខាប្រមាញ់ (ឆ្នាំ២០០៣) *វិធីសាស្ត្រថ្មី គណនាផ្ទៃគ្របដន្តប់ដោយព្រៃឈើនៅកម្ពុជា* ភ្នំពេញ។
៣. ______ (២០០៣ក) *របាយការណ៍ប្រចាំឆ្នាំ ២០០២/២០០៣* ភ្នំពេញ។
៤. ______ (១៩៩៨) *ការវាយតំលៃគំរបព្រៃឈើនៅប្រទេសកម្ពុជា* ភ្នំពេញ។
៥. ក្រសួងអភិវឌ្ឍន៍ជនបទ (ឆ្នាំ២០០៣) *គោលនយោបាយទឹក* ភ្នំពេញ។
៦. អង្គការសុខភាពពិភពលោក/មូលនិធិកុមារអង្គការសហប្រជាជាតិ (ឆ្នាំ២០០១) *កម្មវិធីតាមដានរួមចំពោះការប៉ាន់ស្មានការផ្គត់ផ្គង់ទឹក និងអនាម័យ ឆ្នាំ១៩៩៨-២០០០: លទ្ធភាពទទួលបាននូវសេវាអនាម័យ* ភ្នំពេញ។

**ទាក់ទងនឹង គអសក៩**

១. អាជ្ញាធរជាតិកំចាត់មីន និងសង្គ្រោះជនពិការកម្ពុជា (ឆ្នាំ២០០៣) *របាយការណ៍នៃដំណើរការសិក្ខាសាលាស្តីពីការកសាងកិច្ចសហប្រតិបត្តការទៅថ្ងៃមុខ សំរាប់សកម្មភាពមីននៅក្នុងអាស៊ីអគ្នេយ៍* ភ្នំពេញ។
២. អាជ្ញាធរជាតិកំចាត់មីន និងសង្គ្រោះជនពិការកម្ពុជា (ឆ្នាំ២០០៣) *យុទ្ធសាស្ត្រជាតិស្តីពីសកម្មភាពមីន* ភ្នំពេញ។
៣. អាជ្ញាធរជាតិកំចាត់មីន និងសង្គ្រោះជនពិការកម្ពុជា (ឆ្នាំ២០០៣) *ផែនការប្រាំឆ្នាំស្តីពីសកម្មភាពមីន (២០០៣-២០០៧)* ភ្នំពេញ។
៤. ប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីននៅកម្ពុជា (ឆ្នាំ២០០២) *ឆ្ពោះទៅរកអត្រាគ្រោះថ្នាក់សូន្យ ជំរឿនស្តីពីជនរងគ្រោះដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះនៅក្នុងប្រទេសកម្ពុជា* ភ្នំពេញ។
៥. កាកបាទក្រហមកម្ពុជា និងអង្គការជនពិការអន្តរជាតិប៊ែលហ្សិច (ឆ្នាំ២០០៣) *ជំរឿនស្តីពីជនរងគ្រោះដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះនៅក្នុងប្រទេសកម្ពុជា* ភ្នំពេញ។

# ឧបសម្ព័ន្ធ ក
## សទ្ទានុក្រមបច្ចេកទេស

### និយមន័យនៃពាក្យបច្ចេកទេសទូទៅ

**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា:** គអសក ពោលគឺឆ្លុះបញ្ចាំងនូវតថភាពនៃប្រទេសកម្ពុជា និងអាទិភាពរបស់អ្នកពាក់ព័ន្ធសំខាន់ៗ (រាជរដ្ឋាភិបាល និងក្រសួង សង្គមស៊ីវិលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងអ្នកផ្តល់ជំនួយ)។

**សូចនាករនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា:** អថេរដែលឆ្លុះបញ្ចាំងនូវលទ្ធផល ឬផលប៉ះពាល់សំខាន់ៗ ដែលសមស្របទៅនឹង គអសក ណាមួយ។ វាមានលក្ខណៈជាបរិមាណដើម្បីវាស់វែងដោយមិនលំអៀងលើភាពជឿនលឿន។

**តម្លៃឆ្នាំមូលដ្ឋាននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា:** តម្លៃនៃសូចនាករ គអសក ណាមួយនៅក្នុងឆ្នាំយោងជាចំណុចគោល (អាស្រ័យលើទិន្នន័យដែលមាន)។

**ចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា:** កំរិតមួយដែលគេចង់បាននៃសូចនាករ គអសក ណាមួយនៅក្នុងពេលវេលាជាកំណត់មួយ (ឆ្នាំ២០០៥ ២០១០ និង ២០១៥)។

**ពេលវេលាតាមលំដាប់ឆ្នាំ:** បណ្តាឆ្នាំដែលក្នុងនោះភាពជឿនលឿនលើចំណុចដៅនៃ គអសក ត្រូវបានវាយតម្លៃ។

**ប្រជុំជន និង ជនបទ ក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា:** គ្រប់ទីរួមខេត្ត ទីរួមស្រុកទាំងអស់ត្រូវបានចាត់ទុកថាជាតំបន់ប្រជុំជន។ ក្រុងព្រះសីហនុ កែប និង ប៉ៃលិន ត្រូវបានចាត់ទុកថាជាទីប្រជុំជនទាំងអស់។ ក្នុងរាជធានីភ្នំពេញ ខ័ណ្ឌទាំងបួន ដូនពេញ ចំការមន ប្រាំពីរមករា និងទួលគោក ត្រូវបានចាត់ថ្នាក់ជាខ័ណ្ឌប្រជុំជន។ ផ្នែកដែលនៅសេសសល់ផ្សេងទៀតនៅទូទាំងប្រទេស ត្រូវបានចាត់ទុកថាជាទីជនបទ។

### ពាក្យបច្ចេកទេសទាក់ទងនឹង គអសក១

**សន្ទស្សន៍ចំនួនអ្នកក្រីក្រ:** ភាគរយនៃចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។

**ការប្រើប្រាស់ចំណាយនៃអ្នកក្រីក្រជាងគេបំផុត ២០%នៃប្រាក់ចំណូល/ប្រាក់ចំណាយរបស់ជាតិ:** ការវាស់វែង ពីសមាមាត្រនៃប្រាក់ចំណូល/ចំណាយរបស់ប្រជាជន ដែលមានកំរិតទាបជាងគេបំផុត ២០% នៃប្រាក់ចំណូល/ចំណាយសរុបរបស់ជាតិ។

**ខ្សែបន្ទាត់ភាពក្រីក្រ:** បន្ទាត់ផ្នែកខាងក្រោមដែលកំណត់ប្រជាជនរស់នៅក្នុងភាពក្រីក្រ។ វាជាបន្ទាត់បញ្ជាក់ពីចំនួលជាក់លាក់មួយសំរាប់បុគ្គលម្នាក់ ដើម្បីចំណាយទៅលើអាហារដែលអាចផ្គត់ផ្គង់តិចបំផុត ២១០០កាឡូរីនៃថាមពលប្រចាំថ្ងៃ គួបផ្សំនិងចំណាយបន្តិចបន្តួចទៅលើផ្នែកមិនមែនម្ហូបអាហារ ដូចជាផ្ទះសំបែង និងសំលៀកបំពាក់ ជាដើម។

**សមាមាត្រកុមារធ្វើការដែលមានអាយុពី ៥ ទៅ ១៧ឆ្នាំ:** កុមារដែលធ្វើការងារត្រូវបានអោយនិយមន័យថាជាការចូលរួមរបស់កុមារនៅក្នុងសកម្មភាពសេដ្ឋកិច្ច ដើម្បីកំរៃ ប្រាក់ចំណេញ និងផលចំណេញប្រចាំគ្រួសារ។

**អត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទំងន់ (អាយុក្រោមប្រាំឆ្នាំ):** ភាពមិនគ្រប់ទំងន់ (ទំងន់មិនសមនឹងអាយុ) គឺជាសមាមាត្ររវាងកុមារមិនគ្រប់ទំងន់ អាយុក្រោមប្រាំឆ្នាំ និងចំនួនកុមារដែលមានអាយុដូចគ្នា។

**សមាមាត្រប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារ:** បន្ទាត់ភាពក្រីក្រម្ហូបអាហារ តំណាងឱ្យចំណាយអប្បបរមា ដែលត្រូវការ ដើម្បីចំណាយទៅលើតំរូវការម្ហូបអាហារជាមូលដ្ឋានរបស់បុគ្គលណាម្នាក់។ ខ្សែបន្ទាត់នេះផ្អែកទៅលើតំរូវការថាមពល ដែលគិតជាកាឡូរី (២១០០ កាឡូរី) សំរាប់មនុស្សម្នាក់ៗ ក្នុងមួយថ្ងៃ។

**អត្រាប្រេវ៉ាឡង់នៃកុមារក្រិនក្រោមអាយុ៥ឆ្នាំ:** ភាពក្រិន-ការលូតលាស់យឺត (ដោយសារភាពក្រីក្រ) បណ្តាលមកពីការផ្តល់អាហារមិនបានគ្រប់គ្រាន់ និង សុខភាពទន់ខ្សោយ។ សន្ទស្សន៍កំពស់ដែលត្រូវនឹងអាយុបានបង្ហាញអំពីទំនាក់ទំនងនៃការធៀបកំពស់ របស់កុមារ ទៅនឹងអាយុរបស់គេ។ ក្នុងករណីដែលមានកង្វះផ្អែកអាហារូបត្ថម្ភ ល្បឿននៃការរីកធំធាត់ ត្រូវចុះថយ។

**អត្រាប្រេវ៉ាឡង់នៃកុមារស្គមក្រោមអាយុក្រោម៥ឆ្នាំ:** ភាពស្គម (ទំងន់ស្រាលមិនសមត្រូវនឹងកំពស់) គឺជាអត្រានៃកុមារស្គមដែលមានអាយុក្រោម៥ឆ្នាំ និងនិយាយអំពីការបាត់បង់ទំងន់យ៉ាងច្រើនរបស់កុមារ ជាធម្មតាដោយសារភាពអត់ឃ្លានរ៉ាំរ៉ៃ ឬដោយសារមានជំងឺធ្ងន់ធ្ងរ។

**សមាមាត្រគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ:** ភាគរយនៃគ្រួសារ ដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ ក្នុងចំណោមប្រជាជនទាំងអស់។

## ពាក្យបច្ចេកទេសទាក់ទងទៅនឹង គអសក២

**ការអប់រំមូលដ្ឋាន:** ជាវដ្តពេញលេញនៃរយៈពេល ៩ឆ្នាំសំរាប់ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយចាប់ផ្តើមពីថ្នាក់ទី១ និងបញ្ចប់នៅថ្នាក់ទី៩។

**អត្រាអក្ខរកម្ម:** ចំនួនប៉ាន់ស្មាននៃអក្ខរជន ដែលមានអាយុជាក់លាក់ណាមួយ ដោយបញ្ជាក់ជាភាគរយនៃចំនួនប្រជាជនសរុបដែលមានអាយុដូចគ្នា។

**អក្ខរកម្ម:** សមត្ថភាពក្នុងការអាន និងសរសេរសារងាយៗ។

**អត្រាពិតចូលរៀនថ្មី:** ចំនួនសិស្សចូលរៀនថ្នាក់ទី១ នៅអាយុចូលរៀនសាលាជាផ្លូវការ (អាយុ៦ឆ្នាំ) ដែលបញ្ជាក់ជាភាគរយនៃចំនួនប្រជាជនសរុបដែលមានអាយុត្រូវចាប់ផ្តើមចូលរៀន (អាយុ៦ឆ្នាំ)។

**អត្រាពិតនៃការសិក្សា:** ចំនួនសិស្សគ្រប់អាយុចូលរៀនជាផ្លូវការ ដែលបានចុះឈ្មោះចូលរៀននៅក្នុងសាលា ដោយបញ្ជាក់ជាភាគរយនៃចំនួនប្រជាជនសរុបដែលមានអាយុដូចគ្នា។

**សមាមាត្រចំនួនកុមារដែលមិនបានចូលរៀនក្នុងសាលា:** ចំនួនកុមារដែលមានអាយុត្រូវចូលរៀន តែមិនបានទៅរៀននៅសាលា ដោយសារតែ (i)ពួកគេមិនដែលបានចូលរៀន ឬក៏ (ii)បានចូលរៀនហើយក៏បោះបង់ការសិក្សាវិញ ដោយគិតជាភាគរយនៃចំនួនប្រជាជនសរុបដែលមានអាយុដូចគ្នា។

**ផលធៀបចំនួនកុមារីជាមួយចំនួនកុមារា:** ចំនួនកុមារីក្នុងចំណោមកុមារាចំនួន ១០០នាក់ នៅក្នុងស្ថានភាពជាក់លាក់ណាមួយ។

**អត្រាគង់វង្សនៃសិស្ស:** ភាគរយនៃសិស្សមួយជំនាន់ ដែលបានរៀនដល់ថ្នាក់ចុងបញ្ចប់នៃកំរិតណាមួយ ដោយមិនអាស្រ័យទៅលើចំនួនឆ្នាំ ដែលគេបានចំណាយក្នុងការរៀននៅសាលានោះទេ។

**ការអប់រំមូលដ្ឋានជាទូទៅ:** ការចូលរៀនទាំង ១០០% នៃកុមារដែលស្ថិតនៅក្នុងក្រុមអាយុត្រូវទទួលការអប់រំមូលដ្ឋាន។

**សាលារៀននៅតំបន់ទីក្រុង តំបន់ជនបទ និងតំបន់ដាច់ស្រយាល:** កំនត់ដោយការិយាល័យអប់រំស្រុក/ខ័ណ្ឌ និង/ឬ មន្ទីរអប់រំខេត្ត/ក្រុង។ តាមធម្មតាសាលារៀនដែលមានទីតាំងនៅទីរួមខេត្តឬទីក្រុង ត្រូវបានចាត់ទុកជាសាលាតំបន់ទីក្រុង។ ចំណែកសាលាទាំងឡាយណា ដែលស្ថិតក្នុងតំបន់ដាច់ស្រយាលដែលមានការលំបាកក្នុងការធ្វើទំនាក់ទំនង និងដឹកជញ្ជូនទៅកាន់សាលានោះ គឺចាត់ទុកថាជាសាលាតំបន់ដាច់ស្រយាល។ សាលាក្រៅពីនេះ គឺជាសាលាតំបន់ជនបទ។ សាលាតំបន់ទីក្រុង គឺជាសាលាដែលមានទីតាំងនៅក្នុងក្រុងទាំង ៤ នៃក្រុងភ្នំពេញ ក្រុងកែប ក្រុងព្រះសីហនុ និងក្រុងប៉ៃលិន ហើយនិងនៅតាមទីរួមខេត្តទាំងអស់។ នៅពេលណាដង់ស៊ីតេប្រជាជន នៅក្នុងតំបន់ណាមួយតិចជាង ១០នាក់ ក្នុង១គីឡូម៉ែត្រក្រឡា នោះសាលាដែលនៅក្នុងតំបន់នោះត្រូវបានចាត់ទុកជាសាលាតំបន់ដាច់ស្រយាល។ សាលាក្រៅពីនេះចាត់ទុកថាជាសាលាជនបទ។

## ពាក្យបច្ចេកទេសទាក់ទងនៅនឹង គអសក៣

**ផលធៀបរវាងសិស្សស្រី និងសិស្សប្រុសនៅកំរិតមធ្យមសិក្សាទុតិយភូមិ:** ជាភាគរយនៃអត្រាសិស្សស្រីធៀប និងសិស្សប្រុស ដែលបានរៀននៅកំរិតមធ្យមសិក្សាទុតិយភូមិដោយរាប់បញ្ចូលទាំងនៅក្នុងសាលារដ្ឋ និងឯកជន។

**ផលធៀបរវាងនិស្សិតស្រី និងនិស្សិតប្រុសនៅកំរិតឧត្តមសិក្សា:** ជាភាគរយនៃអត្រានិស្សិតស្រីធៀប និងនិស្សិតប្រុស ដែលបានសិក្សានៅកំរិតឧត្តមសិក្សា ដោយរាប់បញ្ចូលទាំងនៅក្នុងគ្រឹះស្ថានសាធារណៈ និងឯកជន។

**ផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរស:** ជាភាគរយនៃអត្រាអក្ខរកម្មស្ត្រីធៀប និងបុរស ដែលមានអាយុពី ១៥-២៤ឆ្នាំ និង ២៥-៤៤ឆ្នាំ ដែលអាចអាន និងសរសេរលិខិតស្មាមងាយយល់ខ្លីៗនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។

**សមាមាត្រនៃស្ត្រីធ្វើការមានប្រាក់បៀវត្សរ៍នៅក្នុងវិស័យកសិកម្ម:** ចំនួនស្ត្រីដែលធ្វើការទទួលប្រាក់ឈ្នួល/ប្រាក់បៀវត្សរ៍នៅក្នុងវិស័យកសិកម្ម (ផលិតកម្មចំបង) គិតជាភាគរយ ធៀបទៅនឹងនិយោជិកសរុប។ វិស័យកសិកម្មរួមមាន: ការដាំដុះ និងចិញ្ចឹមសត្វ ការប្រមាញ់ ការទាញយកអនុផលព្រៃឈើ ការកាប់ឈើ និងសេវាសកម្មភាពដែលទាក់ទងនឹងការនេសាទ ការភ្ញាស់ត្រី ការចិញ្ចឹមត្រី និងសេវាសកម្មភាពដែលពាក់ព័ន្ធ។

**សមាមាត្រនៃស្ត្រីធ្វើការមានប្រាក់បៀវត្សរ៍ នៅក្នុងវិស័យឧស្សាហកម្ម:** ចំនួនស្ត្រីដែលធ្វើការមានប្រាក់ឈ្នួល/ប្រាក់បៀវត្សរ៍នៅក្នុងវិស័យឧស្សាហកម្ម គិតជាភាគរយធៀបទៅនឹងនិយោជិកសរុប។ វិស័យឧស្សាហកម្មរួមមានការរុករ៉ែ និងការវាយថ្ម កម្មន្តសាល សំណង់ អគ្គីសនី ឧស្ម័ន និងការផ្គត់ផ្គង់ទឹក ដែលស្ថិតក្នុងផ្នែក ២-៥ នៃនិយាមអន្តរជាតិនៃចំណាត់ថ្នាក់តាមវិស័យ (ISIC Revision 2) ឬប្រភេទតារាង C-F (ISIC Revision 3)។

**សមាមាត្រនៃស្ត្រីធ្វើការមានប្រាក់បៀវត្សរ៍នៅក្នុងវិស័យសេវាកម្ម:** ចំនួនស្ត្រីដែលធ្វើការទទួលប្រាក់ឈ្នួល/ប្រាក់បៀវត្សរ៍ នៅក្នុងវិស័យសេវាកម្ម គិតជាភាគរយធៀបទៅនឹងនិយោជិកសរុប។ វិស័យសេវាកម្មរួមមានពាណិជ្ជកម្មលក់ដុំ និងលក់រាយ ភោជនីយដ្ឋាន និងសណ្ឋាគារ ការដឹកជញ្ជូន ការលើកដាក់/រក្សាទុក និងទូរគមនាគមន៍

ហិរញ្ញវត្ថុ ធានារ៉ាប់រង ការទិញ/លក់អចលនទ្រព្យ សេវាកម្មពាណិជ្ជកម្ម និងសេវាកម្មសង្គម ព្រមទាំងសេវាផ្ទាល់ខ្លួនដទៃទៀត ដែលស្ថិតក្នុងផ្នែក ៦-៩ របស់និយាមអន្តរជាតិនៃចំណាត់ថ្នាក់តាមវិស័យ (ISIC Revision 2) ឬប្រភេទតារាង G-P (ISIC Revision 3) ។

**សមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ:** ភាគរយនៃអសនៈដែលកាន់កាប់ដោយស្ត្រីនៅក្នុងរដ្ឋសភា ធៀបទៅនឹងចំនួនអសនៈសរុបនៃរដ្ឋសភា។ ចំនួនអសនៈដែលកាន់កាប់ដោយស្ត្រីនៅក្នុងរដ្ឋសភា ត្រូវបានរាប់បញ្ចូលទាំងចំនួនសមាជិកដែលបានជាប់ឆ្នោត និងចំនួនសមាជិកដែលបានតែងតាំង។

**សមាមាត្រស្ត្រីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការ អភិបាលខេត្ត និងអភិបាលខេត្តរង:** ភាគរយនៃស្ត្រីដែលមានមុខតំណែងជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលខេត្ត និងអភិបាលខេត្តរង ធៀបទៅនិងចំនួនសរុបនៃមន្ត្រីដែលមានមុខតំណែងជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលខេត្ត និងអភិបាលខេត្តរង។ មុខតំណែងនិមួយៗសំដៅទៅលើចំនួនសមាជិក ដែលត្រូវបានជ្រើសរើស និងចំនួនសមាជិកដែលត្រូវបានតែងតាំងជំនួស។

**សមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់:** ភាគរយនៃស្ត្រីដែលមានមុខតំណែង នៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ ធៀបទៅនឹងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់សរុប។ ចំនួនសមាជិកដែលមានមុខតំណែងនៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ សំដៅទៅលើសមាជិកដែលបានជាប់ឆ្នោត និងចំនួនសមាជិកដែលត្រូវបានតែងតាំង។

## ពាក្យបច្ចេកទេសទាក់ទិននឹង គអសក៤ និង៥

**មរណភាពកុមារក្រោមអាយុ ៥ឆ្នាំ:** ចំនួនកុមារដែលស្លាប់ចន្លោះពីការកើតរហូតដល់មុនអាយុ ៥ឆ្នាំ របស់ខ្លួនដែលត្រូវបានកំណត់ក្នុងកំណើតរស់ចំនួន ១០០០នាក់។

**មរណភាពទារក:** ចំនួនកុមារដែលស្លាប់ចន្លោះពីការកើតរហូតដល់មុនអាយុ ១ឆ្នាំ របស់ខ្លួន ដែលត្រូវបានកំណត់ក្នុងកំណើតរស់ចំនួន ១០០០នាក់។

**ភាគរយនៃកុមារក្រិន:** ភាគរយនៃកុមារដែលមានទម្ងន់លើសខុសប្លែកពីគំលាតគំរូ (Standard Deviation) ចំនួនពីរដងក្រោមស្តង់ដារយោងមធ្យម (Median Reference Standard) សំរាប់អាយុកុមារនោះ។

**កុមារដែលបានចាក់ថ្នាំការពារគ្រប់:** ភាគរយឬចំនួនទារកដែលមានអាយុរហូតដល់ ១ឆ្នាំ ដែលបានចាក់ថ្នាំកាពារគ្រប់ចំនួនការពារជម្ងឺខាន់ស្លាក់ តេតាណូស ក្អកមាន់ កញ្រ្ជិល ស្វិតដៃជើង និងរបេង។

**ជម្ងឺរលាកទងសួតធ្ងន់ធ្ងរ:**

- *ប្រេវ៉ាឡង់:* ភាគរយនៃកុមារក្រោមអាយុ ៥ឆ្នាំ ដែលក្អកនិងដកដង្ហើមញាប់ក្នុងរយៈពេលពីរសប្តាហ៍មុនពេលធ្វើអង្កេតតាមការពន្យល់ និងរាយការណ៍របស់ម្តាយ។
- *ការព្យាបាល:* ភាគរយនៃកុមារ ដែលក្អកនិងដកដង្ហើមញាប់ក្នុងរយៈពេលពីរសប្តាហ៍កន្លងមក ហើយត្រូវបានយកទៅកាន់សេវាព្យាបាលណាមួយ និងភាគរយកុមារដែលត្រូវបានយកទៅមន្ទីរពេទ្យរដ្ឋ។

**មរណភាពមាតា:** ចំនួននៃការស្លាប់ម្តាយក្នុង ១០០០០០ កំណើតកូន។ ការស្លាប់ម្តាយ គឺជាការស្លាប់របស់ស្ត្រីនៅពេលមានគភ៌ ឬនៅក្នុងអំឡុងពេល ៤២ថ្ងៃ នៃការបញ្ចប់ការមានផ្ទៃពោះ ដោយមិនគិតពីរយៈពេល និងទី

កន្លែងនៃការមានផ្ទៃពោះ ដោយសារមូលហេតុណាក្តីដែលទាក់ទិននឹង ឬដែលត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើង ដោយសារការមានផ្ទៃពោះ ឬការគ្រប់គ្រងពេលមានផ្ទៃពោះ ប៉ុន្តែមិនមែនដោយសារមូលហេតុគ្រោះថ្នាក់ ឬឧប្បត្តិហេតុឡើយ។

**បុគ្គលិកសុខាភិបាលជំនាញ:** វេជ្ជបណ្ឌិត (អ្នកឯកទេស ឬអ្នកមិនឯកទេស) ឬអ្នកទាំងឡាយណាដែលមានជំនាញខាងឆ្មបដែលអាចចាត់ចែងការសំរាលកូន និងធ្វើរោគវិនិច្ឆ័យចាត់ចែង ឬបញ្ជូនការសំរាលកូនដែលមានបញ្ហា។ ទាំងឆ្មបបុរាណ ដែលបានទទួលការហ្វឹកហាត់ និងពុំបានទទួលការហ្វឹកហាត់ពុំត្រូវបានរាប់បញ្ចូលទេ។

**អត្រាលទ្ធភាពផ្តល់កំណើតសរុប:** ចំនួនកូនជាមធ្យមដែលស្ត្រីម្នាក់អាចបង្កើតក្នុងជីវិតរបស់គាត់ តាមអាយុជាក់លាក់ ដែលអាចផ្តល់កំណើតក្នុងពេលបច្ចុប្បន្ន។

**ការថែទាំមុនពេលសំរាលកូន:** ភាគរយនៃកំណើតនៅក្នុងរយៈពេល ៥ឆ្នាំ មុនពេលធ្វើអង្កេត ដែលក្នុងនោះស្ត្រីបានទទួលនូវការពិគ្រោះយ៉ាងតិចបំផុតមួយដង លើការថែទាំមុនពេលសំរាលកូន ជាមួយអ្នកជំនាញសុខាភិបាល ដែលជាវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ឬឆ្មប។

**ការប្រើមធ្យោបាយពន្យារកំណើតទំនើប:** ភាគរយនៃស្ត្រី និងបុរសដែលរៀបការ ហើយបានរាយការណ៍ពីការប្រើមធ្យោបាយទំនើបការពារមិនឱ្យមានកូន ដែលមានន័យថា ការធ្វើលែងឱ្យមានកូនចំពោះបុរស/ស្ត្រី ថ្នាំគ្រាប់ការពារមិនឱ្យមានកូន ថ្នាំចាក់ការពារមិនឱ្យមានកូន កងដាក់ក្នុងស្បូន ស្រោមអនាម័យបុរស/ស្ត្រី សន្ទះការចងដៃស្បូន ឬថ្នាំលាបការពារមិនឱ្យមានកូន (Contraceptive Jelly)។

**ភាគរយនៃម្តាយដែលមានផលធៀបទំងន់ទៅនឹងកំពស់ទាប:** ភាគរយនៃស្ត្រី ដែលមានផលធៀបទំងន់ ទៅនឹងកំពស់ក្រោម ១៨,៥គីឡូក្រាម/ម៉ែត្រការ៉េ ដែលផលធៀបទំងន់ទៅនឹងកំពស់ (BMI) ជាសូចនាករនៃស្ថានភាពអាហារូបត្ថម្ភមនុស្សពេញវ័យ ដែលត្រូវបានកំណត់ដោយទម្ងន់ គិតជាគីឡូក្រាមចែកនឹងការ៉េ នៃកំពស់គិតជាម៉ែត្រ។

## ពាក្យបច្ចេកទេសទាក់ទិននឹង គអសក៦

### មេរោគអេដស៍/ជម្ងឺអេដស៍:

**អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥-៤៩ឆ្នាំ:** ភាគរយនៃមនុស្សពេញវ័យអាយុ ១៥-៤៩ឆ្នាំ ដែលឆ្លងមេរោគអេដស៍។ ប្រេវ៉ាឡង់នេះ គឺជាការបូកបណ្តាក់នូវចំនួនអ្នកឆ្លងមេរោគនេះតាំងពីឆ្នាំដំបូងនៃការរាតត្បាតជាមួយនឹងអត្រាឆ្លងថ្មីរាល់ឆ្នាំ។

**អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ ដែលមានអាយុពី ១៥-២៤ឆ្នាំ បានពិនិត្យផ្ទៃពោះមុនសំរាល:** ភាគរយនៃគំរូសំណាកឈាមបានពីស្ត្រីមានផ្ទៃពោះអាយុ ១៥-២៤ឆ្នាំ ដែលមានផ្ទុកមេរោគអេដស៍។

**អត្រាប្រើស្រោមអនាម័យនៃអត្រាប្រេវ៉ាឡង់ការពារមិនឱ្យមានកូន:** ចំនួនស្ត្រីអាយុ ១៥-៤៩ឆ្នាំ ដែលរួមសេពសន្ថវៈជាមួយប្តីប្រពន្ធ ឬមិនជាមួយប្តីប្រពន្ធ ដោយប្រើស្រោមអនាម័យជាមធ្យោបាយការពារមិនឱ្យមានកូន គិតជាសមាមាត្រនៃអ្នកដែលប្រើទាំងអស់ ឬអ្នកដែលមានដៃគូជាអ្នកប្រើប្រភេទ នៃមធ្យោបាយការពារមិនឱ្យមានកូន របស់ក្រុមអាយុដូចគ្នា និងស្ថានភាពគូស្រករ។ (មិនបានដាក់បញ្ចូលក្នុងបញ្ជីសូចនាករទេ)។

**អត្រាប្រើស្រោមអនាម័យ ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ ក្នុងពេលរួមភេទចុងក្រោយៈ** ភាគរយស្ត្រីរកស៊ីផ្លូវភេទ ដែលប្រើស្រោមអនាម័យជាមួយអតិថិជន ក្នុងពេលរួមភេទចុងក្រោយ។

**ភាគរយនៃយុវជនអាយុពី ១៥-២៤ឆ្នាំ ដែលបានរាយការណ៍ពីការប្រើស្រោមអនាម័យ ក្នុងពេលរួមភេទជាមួយដៃគូមិនទៀងទាត់ៈ** ចំនួនយុវជនអាយុពី ១៥-២៤ឆ្នាំ ដែលបានប្រើស្រោមអនាម័យក្នុងពេលរួមភេទជាមួយដៃគូផ្សេងពីប្រពន្ធ ឬសង្សាររបស់ខ្លួន ក្នុងចំណោមយុវជន ១០០នាក់។

**សមាមាត្រនៃការប្រើស្រោមអនាម័យ ដែលបានរាយការណ៍ដោយស្ត្រីមានប្តី ដែលដឹងថាខ្លួនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ៈ** ភាគរយស្ត្រីមានប្តី ដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដោយមេរោគអេដស៍ ដែលប្រើស្រោមអនាម័យក្នុងពេលរួមភេទជាមួយប្តីរបស់ខ្លួន។

**ភាគរយនៃស្ត្រីពិនិត្យផ្ទៃពោះមុនសំរាល ដែលមានផ្ទុកមេរោគអេដស៍ ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្តាយទៅកូនៈ** ចំនួនស្ត្រីពិនិត្យផ្ទៃពោះមុនសំរាល ដែលមានផ្ទុកមេរោគអេដស៍ ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្តាយទៅកូន ក្នុងចំណោមស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ១០០នាក់។

**ភាគរយនៃអ្នកជំងឺអេដស៍ ដែលបានទទួលថ្នាំ ARV ប្រឆាំងនឹងមេរោគអេដស៍ៈ** ចំនួនក្នុងចំណោមអ្នកជំងឺអេដស៍ ១០០នាក់ ដែលបានទទួលការព្យាបាលដោយ ARV ប្រឆាំងនឹងមេរោគអេដស៍ ដើម្បីទប់ស្កាត់ការវិវត្តន៍នៃជម្ងឺអេដស៍។

## ជម្ងឺគ្រុនចាញ់ និងគ្រុនឈាមៈ

**អត្រាស្លាប់ដោយសារជម្ងឺគ្រុនចាញ់ ដែលបានរាយការណ៍ដោយវិស័យសុខាភិបាលសាធារណៈ** ចំនួនអ្នកស្លាប់ដោយសារគ្រុនចាញ់ ក្នុងចំណោមអ្នកស្លាប់ទាំងអស់ ដែលបានរាយការណ៍ដោយវិស័យសុខាភិបាលសាធារណៈ។

**សមាមាត្រនៃប្រជាជន នៅតំបន់មានជំងឺគ្រុនចាញ់ខ្ពស់ ដែលប្រើមុងជ្រលក់ថ្នាំកាលពីយប់កន្លងមកៈ** ចំនួនក្នុងចំណោមប្រជាជន ១០០នាក់ នៃតំបន់គ្រោះថ្នាក់ខ្ពស់ដោយជំងឺគ្រុនចាញ់ ដែលប្រើមុងជ្រលក់ថ្នាំកាលពីយប់កន្លងមក ដើម្បីការពារមូសខាំ។

**ចំនួនអ្នកជម្ងឺគ្រុនចាញ់ ដែលបានទទួលការព្យាបាល នៅក្នុងវិស័យសុខាភិបាលសាធារណៈ ក្នុង ១០០០ នាក់ៈ** ចំនួនអ្នកជម្ងឺគ្រុនចាញ់ ដែលត្រូវបានព្យាបាលនៅក្នុងវិស័យសុខាភិបាលសាធារណៈក្នុង ១០០០នាក់ ធៀបនឹងអ្នកជំងឺទាំងអស់។

**សមាមាត្រ នៃសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់ ពីរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់ ៩៥% តាមរូបមន្តជាតិៈ** ចំនួនសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់រោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់ ៩៥% តាមរូបមន្តជាតិ ក្នុងចំណោម ១០០សេវាសុខភាពសាធារណៈ។

**ចំនួនអ្នកជម្ងឺគ្រុនឈាម ដែលបានទទួលការព្យាបាល នៅក្នុងវិស័យសុខាភិបាលសាធារណៈ ក្នុង ១០០០ នាក់ៈ** ចំនួនអ្នកជម្ងឺគ្រុនឈាម ដែលត្រូវបានព្យាបាលនៅក្នុងវិស័យសុខាភិបាលសាធារណៈ ក្នុង ១០០០នាក់ ធៀបនឹងអ្នកជំងឺទាំងអស់។

**អត្រាស្លាប់ដោយសារជម្ងឺគ្រុនឈាម ដែលបានរាយការណ៍ពីវិស័យសុខាភិបាលសាធារណៈ:** ចំនួនអ្នកស្លាប់ដោយសារជម្ងឺគ្រុនឈាម ក្នុងចំណោមអ្នកស្លាប់ទាំងអស់ ដែលបានរាយការណ៍ដោយវិស័យសុខាភិបាលសាធារណៈ។

**ជម្ងឺរបេងៈ**

**អត្រាប្រេវ៉ាឡង់នៃជម្ងឺរបេងសួតវិជ្ជមាន BK ក្នុង ១០០ ០០០នាក់:** ចំនួនអ្នកជម្ងឺរបេង ក្នុងប្រជាជន ១០០០០០ នាក់។

**អត្រាស្លាប់ដោយសារជម្ងឺរបេងក្នុង ១០០ ០០០នាក់:** ចំនួនអ្នកស្លាប់ដោយសារជម្ងឺរបេង ក្នុងប្រជាជន ១០០០០០ នាក់។

**សមាមាត្រនៃអ្នកដែលបានប៉ាន់ស្មានថា មានករណីជម្ងឺរបេងសួតវិជ្ជមាន BKថ្មី បានរកឃើញក្រោម ការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS):** ភាគរយនៃអ្នកទើបឆ្លងជម្ងឺរបេងថ្មីៗ ដែលបានប៉ាន់ស្មានក្រោមយុទ្ធសាស្ត្រនៃការព្យាបាល ដោយមានការត្រួតពិនិត្យផ្ទាល់ (DOTS) (អង្គការសុខភាពពិភពលោក)។

**សមាមាត្រនៃអ្នកជម្ងឺរបេងសួតវិជ្ជមាន BK ដែលបានកត់ត្រា ហើយបានព្យាបាលប្រកបដោយជោគជ័យ ក្រោមការព្យាបាល ដោយមានការត្រួតពិនិត្យផ្ទាល់** (DOTS): ភាគរយនៃអ្នកជម្ងឺ ដែលត្រូវបានព្យាបាលជាសះស្បើយ និងភាគរយនៃអ្នកដែលបានទទួលការព្យាបាលពេញលេញ ធៀបនឹងអ្នកជំងឺទាំងអស់ដែលបានកត់ត្រា។

**ពាក្យបច្ចេកទេសទាក់ទិននឹង គអសក៧**

**គំរបព្រៃ:** សមាមាត្រនៃផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ គឺជាចំណែកមួយនៃព្រៃឈើនៅក្នុងផ្ទៃដីសរុប។

**ប្រភេទព្រៃឈើ:** ព្រៃស្រោងក្រាស់ ព្រៃស្រោងស្តើង ព្រៃស្រោងដុះដោយដុំ ព្រៃពាក់កណ្តាលស្រោងក្រាស់ ព្រៃពាក់កណ្តាល ស្រោងស្តើង ព្រៃពាក់កណ្តាលស្រោងដុះដោយដុំ ព្រៃល្បោះ ព្រៃល្បោះដុះដោយដុំ ព្រៃដុះឡើងវិញ ព្រៃលិចទឹក ដុះឡើងវិញ ព្រៃលិចទឹក ព្រៃកោងកាង ព្រៃដាំ ព្រៃលិចទឹកដុះដោយដុំ។

**ប្រភេទមិនមែនព្រៃ:** ព្រៃគម្ពោចបៃតងជានិច្ច វាលស្មៅ ឬស្សី ព្រៃគម្ពោតស្ងួត ព្រៃគម្ពោចលិចទឹក កសិកម្មពនេចរ (<30%) កសិកម្មពនេចរ (>30%) ដីកសិកម្ម ដីទំនេរគំរបរុក្ខជាតិ ថ្ម ទីក្រុង/ប្រជុំជន ដីសើម ពពក និងផ្សេងៗទៀត។

**តំបន់អភិរក្ស:** ភាគរយនៃផ្ទៃដីសរុបនៃប្រទេស។ វាជាផ្ទៃដីនិង/ឬផ្ទៃសមុទ្រ ដែលត្រូវបានប្រគល់ជូនជាពិសេសដល់ការការពារ និងថែរក្សាជីវសាស្ត្រចំរុះ និងធនធានទាក់ទិននឹងធម្មជាតិ និងវប្បធម៌។

**ឧទ្យានជាតិ (ប្រភេទ IUCN ទី២):** តំបន់ធម្មជាតិនិងមានទស្សនីយភាពល្អដែលមានសារៈសំខាន់សំរាប់ តម្លៃខាងវិទ្យាសាស្ត្រ អប់រំ និង កំសាន្ត។

**ជម្រកសត្វព្រៃ (ប្រភេទ IUCNទី ៤):** តំបន់ធម្មជាតិដែលនៅទីនោះប្រភេទរុក្ខជាតិ និងសត្វសំខាន់ៗ សហគមន៍ធម្មជាតិ ឬលក្ខណៈពិសេស តំរូវអោយមានអន្តរាគមន៍ជាក់លាក់ដើម្បីការស្ថិតស្ថេររបស់ខ្លួន។ តំបន់លិចទឹកកោះកាពិ និងប្រជុំកោះ នៅជំរកសត្វព្រៃពាម ក្រសោប (១២ ០០០ ហិកតា) ត្រូវបានកំណត់ជាតំបន់រ៉ាំសារ។

**ទេសភាពអភិរក្ស (ប្រភេទ IUCNទី ៥):** ទេសភាពធម្មជាតិ និងពាក់កណ្តាលធម្មជាតិ ដែលមានសារៈសំខាន់ក្នុងលក្ខណៈជាតិដែលត្រូវតែថែរក្សា ដើម្បី ផ្តល់ឱកាសដល់ការកំសាន្ត។

**តំបន់ពហុផលប្រយោជន៍ (ប្រភេទ IUCN ទី ៨):** តំបន់ដែលទុកបំរុងសំរាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានទឹក ឈើ សត្វព្រៃ ត្រី ទីចំណីសត្វ និងការកំសាន្ត ដោយមានអភិរក្សធម្មជាតិ ដែលសំដៅជាសំខាន់លើការគាំទ្រនូវសកម្មភាពសេដ្ឋកិច្ចទាំងនេះ។ តំបន់ពហុផលប្រយោជន៍ទន្លេសាបបាន ត្រូវចាត់ទុកជាតំបន់បំរុងដែនជីវៈទីមួយរបស់ប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩៧។ ចំណែកបឹងឆ្មារនៃតំបន់ពហុប្រយោជន៍ទន្លេសាប (២៨០០០ ហិកតា) គឺត្រូវបាន ចាត់ទុកជាតំបន់រ៉ាំសារ។

**តំបន់រ៉ាំសារៈ** ទីកន្លែងពីរនៅក្នុងប្រភេទ IUCN ទី ៤ និងទី ៨ ខាងលើនិងទីកន្លែងមួយនៅចំពាក់កណ្តាលបណ្តោយទន្លេមេគង្គ ក្នុងចន្លោះខេត្តស្ទឹងត្រែង និងព្រំប្រទល់ដែនជាមួយឡាវ។

**ជំរកត្រីៈ** តំបន់ផ្ទៃលើនៃអភិរក្សសំរាប់ប្រភេទត្រីទឹកសាប និងត្រីសមុទ្រ។

**សមាមាត្រនៃប្រជាជន ដែលមានលទ្ធភាពប្រើប្រាស់ប្រកបដោយនិរន្តរភាព នូវប្រភពទឹកដែលត្រូវបានកែលំអ (ទីប្រជុំជន និងជនបទ):** ភាគរយនៃប្រជាជន ដែលប្រើប្រាស់ប្រភេទផ្គត់ផ្គង់ទឹកសំរាប់ផឹកណាមួយ ដូចតទៅនេះ: ទឹកម៉ាស៊ីន ទឹកម៉ាស៊ីនសាធារណៈ អណ្តូងស្នប់ អណ្តូងដែលមានការការពារ ទឹកចេញពីក្រោមដីដែលមានការការពារ និងទឹកភ្លៀង។ ប្រភពទឹកកែលំអដែលមិនត្រូវបានរាប់បញ្ចូលរួមមានទឹកលក់ ទឹកដប ទឹកដឹកតាមរថយន្ត និងអណ្តូង ដែលមិនមានការការពារ និងទឹកចេញពីក្រោមដី។

**សមាមាត្រនៃប្រជាជនដែលមានលទ្ធភាពទទួលបង្គន់អនាម័យប្រសើរឡើង (ទីប្រជុំជន និងជនបទ):** ភាគរយនៃប្រជាជន ដែលមានលទ្ធភាពទទួលបង្គន់ ដែលដាក់របាំងប្រកបដោយអនាម័យចំពោះលាមកមនុស្ស មិនឱ្យមានការប៉ះពាល់ដោយមនុស្សសត្វ និងសត្វល្អិត។ បង្គន់ទាំងនេះគឺជាប្រព័ន្ធលូបង្ហូរ ឬជាប្រព័ន្ធអាងបង្គន់ចាក់ទឹក បង្គន់រណ្តៅសាមញ្ញ ឬបង្គន់រណ្តៅសាមញ្ញដែលត្រូវបានកែលំអឱ្យមានខ្យល់ចេញចូល ហើយបង្គន់ទាំងអស់នេះមិនមែនជារបស់សាធារណៈ ឬចែកគ្នាប្រើឡើយ។

**សមាមាត្រនៃគ្រួសារដែលមានលទ្ធភាពកាន់កាប់ដីប្រកបដោយសុវត្ថិភាពៈ** គ្រួសារដែលជាម្ចាស់ ឬដែលកំពុងទិញផ្ទះ និងមានកម្មសិទ្ធិដីធ្លី។

**តំបន់ "ជនបទ" និង "ទីប្រជុំជន":** និយមន័យផ្លូវការនៃ "ទីប្រជុំជន" របស់ជំរឿនប្រជាជន ឆ្នាំ១៩៩៨ លើកឡើងថាដង់ស៊ីតេប្រជាជនដែល លើស ២០០នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ឬចំនួនប្រជាជនសរុបក្នុងឃុំលើសពី ២០០០ នាក់ (ពន្លឺថ្មីស្តីពីនគរូបនីយកម្មក្នុងឆ្នាំ ២០០៣ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ២០០៣)។ តំបន់ជនបទមានន័យ ថាជាតំបន់ដែលមានប្រជាជនតិចជាង ឬស្មើ ២០០ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។

## ពាក្យបច្ចេកទេសទាក់ទិននឹង គអសក៨

**ការសំរាលបំណុលដែលបានប្តេជ្ញាធ្វើនៅក្រោមគំនិតផ្តួចផ្តើមនៃបណ្តាប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរៈ** ការបោះបង់ចោលប្រាក់កំចី ដែលជាផ្នែកមួយនៃជំនួយអភិវឌ្ឍន៍ផ្លូវការនៅក្រោមគំនិតផ្តួចផ្តើមស្តីពីបំណុល សំរាប់បណ្តា

ប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ។ គំនិតផ្តួចផ្តើមនេះគឺជាវិធីសាស្ត្រដ៏ទូលំទូលាយដំបូងមួយ ដើម្បីកាត់បន្ថយបំណុលពីខាងក្រៅរបស់បណ្តាប្រទេសក្រីក្របំផុតនៅលើពិភពលោកដែលជាប្រទេសជំពាក់បំណុលដ៏ធ្ងន់ធ្ងរ។

**សេវាកម្មបំណុលសរុប:** ផលបូកនៃការទូទាត់សងវិញសរុប និងការប្រាក់ដែលត្រូវសងជារូបិយវត្ថុបរទេស សងជាទំនិញ ឬសេវាកម្មសំរាប់បំណុលរយៈពេលវែង (មានរយៈពេលច្រើនជាងមួយឆ្នាំ) ការប្រាក់ត្រូវសងលើបំណុលរយៈពេលខ្លី និងការទូទាត់សងទៅឱ្យមូលនិធិរូបិយប័ណ្ណអន្តរជាតិ។

**គណៈកម្មាធិការជំនួយអភិវឌ្ឍន៍:** គណៈកម្មាធិការរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ដែលដោះស្រាយពីកិច្ចការសហប្រតិបត្តិការអភិវឌ្ឍន៍។

**ចំនូលជាតិសរុប:** ផលបូកនៃតំលៃបន្ថែម ដោយអ្នកផលិតក្នុងស្រុកទាំងអស់នៃសេដ្ឋកិច្ច បូកនិងពន្ធលើផលិតផលណាមួយ (ដកឧបត្ថម្ភកធន) មិនបញ្ចូលការបញ្ចុះតំលៃប្រាក់នៃលទ្ធផល បូកនិងចំនូលសុទ្ធនៃចំណូលដំបូង (ការទូទាត់សងនិយោជិក និងចំនូលពីទ្រព្យសម្បិត្ត) ពីបរទេស។ តំលៃបន្ថែម គឺជាលទ្ធផលសុទ្ធនៃឧស្សាហកម្មមួយក្រោយពីបូករួមនៃលទ្ធផលទាំងអស់ ហើយដកចេញនូវធនធានអន្តរការី។

**ចំនុចសំរេចចិត្តនៃបណ្តាប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ:** កាលបរិច្ឆេទនៅពេលបណ្តាប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ បានបង្កើតការកត់ត្រាឃ្លាំមើលពីស្នាដៃល្អក្រោមកម្មវិធីកែតំរូវ ដែលប្តេជ្ញាគាំទ្រដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ក្រោមគំនិតផ្តួចផ្តើមស្តីពីបំណុលសំរាប់បណ្តាប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ ដើម្បីធ្វើកំណែទំរង់ថែមទៀត និងដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។

**ការបំពេញលក្ខខ័ណ្ឌនានានៃបណ្តាប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ (HIPC):** កាលបរិច្ឆេទដែលប្រទេសណាមួយដោយរួមមានគំនិតផ្តួចផ្តើមស្តីពីបំណុលសំរាប់ HIPCs ដែលបំពេញលក្ខខ័ណ្ឌកំណែទំរង់សំខាន់ៗ ប្រកបដោយជោគជ័យដូចដែលបានយល់ព្រមលើចំនុចនៃការសំរេចចិត្ត HIPCs ដោយរួមមានការរៀបចំ និងការអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ ពេលនោះប្រទេសនេះទទួលបាននូវកញ្ចប់នៃការសំរាលបំណុលនៅក្រោមគំនិតផ្តួចផ្តើម HIPCs ដោយគ្មានលក្ខខ័ណ្ឌគោលនយោបាយផ្សេងទៀត។

**ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA):** ប្រាក់ផ្តល់ឱ្យ ឬកំចីទៅឱ្យបណ្តាប្រទេសនិងដែនដី ដែលមាននៅក្នុងផ្នែកទី១នៃបញ្ជីរបស់គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ស្តីពីអ្នកទទួលជំនួយ (បណ្តាប្រទេសកំពុងអភិវឌ្ឍន៍) ដែល: (ក) ប្រកាន់យកវិស័យផ្លូវការ (ខ) លើកតំកើងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសុខុមាលភាពជាគោលបំណងសំខាន់ (គ) យល់ព្រមលើលក្ខខ័ណ្ឌសម្បទានហិរញ្ញវត្ថុ [បើកំចីមានលក្ខណៈជាប្រាក់ផ្តល់ឱ្យ (q.v.) យ៉ាងតិចបំផុត២៥%]។ លើសពីនេះទៅទៀត ចំពោះលំហូរហិរញ្ញវត្ថុ កិច្ចសហប្រតិបត្តិការខាងបច្ចេកទេស (q.v.) ត្រូវបានដាក់បញ្ចូលទៅក្នុងជំនួយ។ ប្រាក់ផ្តល់ឱ្យ កំចី និងឥណទាននានាសំរាប់ គោលបំណងយោធាមិនត្រូវគិតបញ្ចូលទេ។

**កូតា:** ការដាក់កំរិតលើបរិមាណផលិតផល ដែលសហគ្រាសមួយត្រូវបានអនុញ្ញាតិឱ្យលក់ ឬប្រទេសនោះ ត្រូវបានអនុញ្ញាតិឱ្យនាំចូល។

**ឧបត្ថម្ភកធន:** ការសងប្រាក់ដោយរដ្ឋាភិបាលទៅឱ្យផលិតករផលិតទំនិញនិងសេវាកម្មនានា។

**ពន្ធជាមធ្យមលើផលិតផលកសិកម្មវាយនភ័ណ្ឌ និងសំលៀកបំពាក់ពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍:** អត្រាពន្ធមធ្យមលើការនាំចូល ផលិតផលកសិកម្ម (ផលិតផលកសិកម្មធ្វើពីសត្វ និងរុក្ខជាតិ រួមមាន ដំណាំរុក្ខជាតិ ប៉ុន្តែមិនបញ្ចូល ឈើនិងផលិតផលត្រីទេ) វាយនភ័ណ្ឌ និងសំលៀកបំពាក់ (រួមមាន ផលិតផលសសៃធម្មជាតិ និងធ្វើដោយមនុស្ស សំភារៈធ្វើពីសូត្រ និងផ្នែកនៃសំលៀកបំពាក់ធ្វើពីសូត្រ) ពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ អត្រាពន្ធបន្ថែមដែលបានប្រើ ដោយរួមមានប្រទេសទទួលការអនុគ្រោះបំផុត និងអត្រាសំរាប់ប្រទេសមិនទទួលការអនុគ្រោះបំផុត។

**អត្រាពន្ធ:** ពន្ធលើការនាំចូលដោយរដ្ឋាភិបាលដែលដាក់ទៅលើប្រទេសនាំចូល។

## ពាក្យបច្ចេកទេសទាក់ទិននឹង គអសក៩

**គ្រាប់មីន:** ជាគ្រាប់រំសេវដែលគេគ្រោងឡើង ដើម្បីដាក់ពីក្រោម ពីលើ ឬក្បែរដី ឬកន្លែងដែលមានផ្ទៃរាបស្មើដទៃទៀត ដើម្បីអោយផ្ទុះឡើងនៅពេលមានវត្តមាន ការចូលទៅជិត ឬការប៉ះពាល់ពីមនុស្ស ឬរថយន្ត។

**គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO):** ជាគ្រាប់យុទ្ធភ័ណ្ឌដែលបានបាញ់ បានឆេះដោយមិនផ្ទុះ ត្រៀមផ្ទុះ ឬត្រៀមសំរាប់ប្រើប្រាស់ ឬត្រូវបានគេប្រើប្រាស់។ គ្រាប់ទាំងនេះអាចត្រូវបានបាញ់ចេញពីកាណុង ទំលាក់ពីយន្តហោះ គ្រវែង គប់ ឬចោល ប៉ុន្តែ នៅមិនទាន់ផ្ទុះបណ្តាលមកពីគាំង មិនដំណើរការទៅតាមការគ្រោងទុក ឬដោយហេតុផលផ្សេងៗទៀត។

**ការដោះមីន:** ជាសកម្មភាពដែលឈានទៅរកការយកចេញនូវគ្រាប់មីន និងUXO ដែលមានគ្រោះថ្នាក់ ការស្រាវជ្រាវ ការគូសប្លង់ផែនទី ការបោសសំអាត ការដាក់ផ្លាកសញ្ញា ការរៀបចំឯកសារក្រោយការបោសសំអាត ការទំនាក់ទំនងសកម្មភាពកំចាត់មីនតាមសហគមន៍ និងការប្រគល់ដីដែលបានបោសសំអាតមីនរួច។ ការដោះមីនអាចត្រូវបានអនុវត្តដោយអង្គការផ្សេងៗដូចជា អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនពាណិជ្ជកម្ម ក្រុមសកម្មភាពកំចាត់មីនរបស់ជាតិ ឬអង្គភាពយោធា។ ការដោះមីនអាចផ្អែកលើគោលការណ៍ចាំបាច់បន្ទាន់ និងគោលការណ៍អភិវឌ្ឍន៍។

**សកម្មភាពកំចាត់មីន:** សកម្មភាពកំចាត់មីននៅប្រទេសកម្ពុជា សំដៅទៅលើសកម្មភាពទាំងឡាយ ដែលមានបំណងកាត់បន្ថយផលប៉ះពាល់ដល់សង្គម សេដ្ឋកិច្ច និងបរិយាកាស ដែលបង្កឡើងដោយគ្រាប់មីន និងUXO។ វត្ថុបំណងនៃសកម្មភាពកំចាត់មីន គឺដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន អោយដល់កំរិតមួយ ដែលប្រជាជនអាចរស់នៅដោយសុវត្ថិភាព ហើយការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខាភិបាល អាចអភិវឌ្ឍន៍ឡើងដោយពុំមានការព្រួយបារម្ភអំពីគ្រាប់មីន និងជាបំណងប្រាថ្នារបស់ជនពិការ។

**ជនរងគ្រោះដោយសារមីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ:** មនុស្សដែលរបួសដោយផ្ទាល់ ឬប្រយោល ស្លាប់ ឬមិនស្លាប់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះនៅប្រទេសកម្ពុជា នៅចន្លោះឆ្នាំ១៩៧៩ មកទល់បច្ចុប្បន្ន រួមទាំងអ្នកទាំងឡាយដែលរងរបួសនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែ បានព្យាបាលនៅប្រទេសថៃ ឡាវ ឬប្រទេសវៀតណាម។

**ការជួយសង្គ្រោះជនពិការ:** និយាយសំដៅលើជំនួយគ្រប់ប្រភេទ មានជំនួយដើម្បីជួយសំរាលការលំបាក ការលួងលោមលើកទឹកចិត្ត និងគាំទ្រដល់ជនរងគ្រោះ (រួមទាំងអ្នកមានជីវិតនៅរស់) ក្នុងគោលបំណងដើម្បីកាត់បន្ថយជាបន្ទាន់ និងការព្យាបាលរយៈពេលយូរ និងប្រើចិត្តសាស្ត្រ ដែលទាក់ទងដល់មុខរបួសរបស់ពួកគេ។

# ឧបសម្ព័ន្ធ ២

## វិធីសាស្ត្រនៃការជ្រើសរើសសូចនាករ និងចំណុចដៅ

## ការជ្រើសរើសសូចនាករ និងចំណុចដៅនៃ គអសក

សូចនាករនៃ គអសក សំដៅប្រែក្លាយ គអស ឱ្យមានលក្ខណៈកម្ពុជា ពោលគឺដើម្បីឆ្លុះបញ្ចាំងពីតថភាព និងអាទិភាពក្នុងស្រុក ។ សូចនាករនៃ គអសក ត្រូវបានកំណត់ដោយប្រើវិធីសាស្ត្រដូចខាងក្រោម:

១. ទីមួយ: ចំណុចចាប់ផ្តើម ផ្អែកទៅលើប្រភេទនៃចំណុចដៅចំនួន ១៨ និងសូចនាករចំនួន ៤៨ ដែលត្រូវបានស្នើឡើងដោយអង្គការសហប្រជាជាតិសំរាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ ចំណុចដៅ និងសូចនាករទាំងនេះមានលក្ខណៈសមហេតុផលបំផុត ដោយសារវាត្រូវបានជ្រើសរើសដោយសហគមន៍អន្តរជាតិ ដើម្បីឆ្លុះបញ្ចាំងនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ នៅក្នុងប្រទេសភាគច្រើន ហើយវាអនុញ្ញាតិឱ្យមានការប្រៀបធៀបជាអន្តរជាតិ ។

២. ទីពីរ: បញ្ជីសូចនាករ ឬចំណុចដៅចំនួនបួនទៀតបានត្រូវពិចារណា ដើម្បីសំរេចថាតើសូចនាករ ដែលមាននៅក្នុងបញ្ជីទាំងនេះគួរត្រូវបានបន្ថែម កែប្រែ ឬលុបចោល: (១) បញ្ជីសូចនាករនៃភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព (PVI) ដែលសូចនាករទាំងនេះ តំណាងឱ្យកិច្ចប្រឹងប្រែងដោយអង្គភាពបច្ចេកទេសតាមដាន និងវិភាគភាពក្រីក្រ ដើម្បីធ្វើឱ្យមានលក្ខណៈសមស្របក្នុងស្រុក នូវសូចនាករទាំងឡាយដែលទាក់ទិននឹងភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព (២) បញ្ជីសូចនាករ ដែលត្រូវបានប្រើក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទីពីរ (SEDPII), (៣) បញ្ជីសូចនាករដែលត្រូវបានប្រើក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) (៤) បញ្ជីសូចនាករដទៃទៀត ដែលត្រូវបានប្រើនៅក្នុងផែនការតាមវិស័យពាក់ព័ន្ធ ។

៣. ទីបី: ការពិគ្រោះយោបល់ ត្រូវបានធ្វើឡើងជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមមានក្រសួងពាក់ព័ន្ធ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល និងអ្នកផ្តល់ជំនួយ ។ ការពិគ្រោះយោបល់ទាំងនោះ ត្រូវបានធ្វើឡើងនៅភ្នំពេញ និងខេត្តចំនួនបី ។

ការជ្រើសរើសសូចនាករមិនមែនជាការងាយស្រួលឡើយដោយត្រូវធ្វើឡើងយ៉ាងលំបាកបំផុត ។ លក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើសំរាប់ការជ្រើសរើសសូចនាករ មានដូចខាងក្រោម:

- ពាក់ព័ន្ធទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។
- ឆ្លុះបញ្ចាំងនូវស្ថានភាពជាក់ស្តែង ជាគន្លឹះរបស់កម្ពុជា ។
- ជាសូចនាករលទ្ធផល និងផលប៉ះពាល់ ។ សូចនាករធនធាន សូចនាករដំណើរការ និងសូចនាករលទ្ធផល មិនត្រូវបានជ្រើសរើសឡើយ ។
- ការប្រើប្រាស់ដោយផ្អែកលើឯកសារសំខាន់ៗដូចជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ៥ឆ្នាំ លើកទីពីរ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ យុទ្ធសាស្ត្រចំបងៗ និងផែនការជាគន្លឹះតាមវិស័យ ។

- ទទួលបានការគាំទ្រភាគច្រើន ពីភាគីពាក់ព័ន្ធសំខាន់ៗ ។
- ចំនួនសូចនាករនៅមានកំរិត ដែលផ្តោតលើអាទិភាពមួយចំនួន និងដើម្បីគិតគូរពីការលំបាកខាងបច្ចេកទេស ស្ថាប័ន និងហិរញ្ញវត្ថុ នៃការតាមដាន គអស នៅក្នុងប្រទេស ។
- ការមានទិន្នន័យខាងបរិមាណ ដែលអាចទុកចិត្តបានសំរាប់ការគណនាសូចនាករ ។ ចំពោះទស្សនៈនៃគុណភាព ឬស្ថាប័ន អថេរតំណាងបរិមាណត្រូវបានកំណត់ឡើងហើយវានឹងអាស្រ័យលើរបាយការណ៍ គអស ពេលអនាគត ដើម្បីដាក់លទ្ធផលខាងបរិមាណ ទៅក្នុងទស្សនៈវិស័យដ៏ទូលំទូលាយមួយ ដើម្បីកំណត់នូវភាពជឿនលឿនឆ្ពោះទៅសំរេច គអស ។

ក្នុងការជ្រើសរើសសូចនាករ គអសក ផ្តើមចេញឡើងដោយការកំណត់តំលៃ និងចំណុចដៅជាមូលដ្ឋានពោលគឺកំរិតដែលចង់បានសូចនាករ គអសក តាមលំដាប់ឆ្នាំ។ ទិន្នន័យនៃសូចនាករឆ្នាំមូលដ្ឋាន ភាគច្រើនចាប់ផ្តើមនៅឆ្នាំ១៩៩៧ ឬឆ្នាំណាមួយ ដែលមានទិន្នន័យសំរាប់សូចនាករភាគច្រើនរបស់ គអសក។ ពេលវេលាបីត្រូវបានកំណត់យក គឺឆ្នាំ២០០៥ ២០១០ និង២០១៥។ ឆ្នាំ២០១៥ គឺជា ពេលវេលាកំណត់ចុងក្រោយសំរាប់ គអស។ ឆ្នាំ២០០៥ គឺជារយៈពេលកំណត់ របស់ផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទីពីរ និងយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពកីក្រ ។ ឆ្នាំ២០១០ ផ្តល់នូវចំណុចជាមធ្យមមួយ ។

ចំណុចដៅរឹតតែមានលក្ខណៈលំបាកក្នុងការកំណត់ ដោយសារវាអាចឆ្លុះបញ្ចាំងនូវផលប្រយោជន៍ផ្ទុយគ្នា និងមានកំរិត ដោយសារពតិមានមិនសុក្រិត។ គួរចងចាំថា (១)ទោះបីវាលំបាកក្តី ការកំណត់ចំណុចដៅ គឺជាប្រការចាំបាច់ ដើម្បីកំណត់យ៉ាងច្បាស់នូវអាទិភាពសំរាប់សកម្មភាព និងដើម្បីវាស់វែងភាពជឿនលឿនឆ្ពោះទៅកាន់គោលដៅដែលចង់បាន (២)ការអនុវត្តន៏នេះ គឺជាផ្នែកមួយនៃវិធីសាស្រ្តតាមវិស័យ (Sector-wide-Approach) ដែលក្នុងនោះចំណុចដៅអាចត្រូវបានកែប្រែ នៅពេលដែលពតិមានត្រូវបានកែលំអ។ ក្នុងខណៈនេះ ចំណុចដៅត្រូវបានកំណត់ដោយមានការពិចារណាលើកត្តាមួយចំនួនដូចខាងក្រោម:

- ចំណុចដៅដែលត្រូវបានកំណត់ក្នុងបញ្ជីសូចនាករនៃ គអស ដែលបានស្នើឡើងដោយអង្គការសហប្រជាជាតិ ។
- ចំណុចដៅដែលត្រូវបានកំណត់ក្នុងយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាគន្លឹះ (ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទីពីរ យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ យុទ្ធសាស្រ្ត និងផែនការតាមវិស័យ) ។
- ភាពប្រាកដនិយមនៃចំណុចដៅ ដែលត្រូវបានវាយតម្លៃលើមូលដ្ឋាននៃ ១)ការប្រៀបធៀបចំណុចដៅ និងការវិវត្តន៏នៃនិន្នាការសូចនាករ ២)ការវាយតម្លៃលើកំរិតនៃកិច្ចប្រឹងប្រែងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកែសំរួលនិន្នាការអំពីការឆ្លុះបញ្ចាំងទៅលើកម្មវិធីគោលនយោបាយ និងថវិកា (៣)យោបល់របស់អ្នកឯកទេសតាមវិស័យ ដែលមានការយល់ដឹងពីភាពជាក់ស្តែងរបស់កម្ពុជា ។
- ភាពស៊ីគ្នាចំពោះចំណុចដៅ និងតាមលំដាប់ឆ្នាំ ។
- ការមានទិន្នន័យដែលអាចទុកចិត្តបាន ។

ក្រៅពីទិដ្ឋភាពខាងគុណភាព ឬស្ថាប័ន ចំណុចដៅដែលតំណាងឱ្យអថេរខាងបរិមាណត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាន នៃការវិនិច្ឆ័យដោយប្រយ័ត្នប្រយែង របស់អ្នកឯកទេសតាមវិស័យ និងទិន្នន័យដែលមាន។ សេចក្ដីវិនិច្ឆ័យប្រកបដោយការប្រុងប្រយ័ត្ន នឹងត្រូវធ្វើឡើង ដើម្បីវាយតម្លៃទៅលើភាពជឿនលឿនដែលសំរេចបានរបស់សូចនាករ គអសក។

បន្ថែមលើការជ្រើសរើសសូចនាករ និងការកំណត់ចំណុចដៅ និន្នាការសំរាប់អនាគត ត្រូវបានប៉ាន់ប្រមាណចំពោះសូចនាករទាំងឡាយ ដោយផ្អែកលើដំណើរការនៃការគណនាលីនេអ៊ែរ (Linear Extrapolation) ពីនិន្នាការកន្លងមក។ វាជាប្រការច្បាស់លាស់ណាស់ ដែលថាមានចំណុចខ្វះខាតជាច្រើន ទាក់ទិននឹងការគណនាពន្លាតទិន្នន័យស្ថិតិដោយបំព្រួញ ហើយដែលជួនកាលមិនអាចទុកចិត្តបាន។ ម្យ៉ាងវិញទៀត វាទំនងជាមានផ្នែកមិនលីនេអ៊ែរសំខាន់ៗមួយចំនួនទៀត ចំពោះនិន្នាការនានា ដែលស្ថិតក្នុងភាពមិនប្រាកដ ដែលស្នើឱ្យមានការប្រុងប្រយ័ត្នខ្ពស់នៅពេលដែលធ្វើការវិភាគ។ ទោះជាយ៉ាងនេះក្ដី ក៏ការគណនាលីនេអ៊ែរនេះ ត្រូវផ្ដល់នូវតម្លៃប្រហាក់ប្រហែល និងអាចប្រែប្រួលតាមទិសដៅដែលធ្វើឡើង ដោយក្រុមបច្ចេកទេសជាតិនៅកម្ពុជា។ លើសពីនេះទៀត ការកំណត់គំលាតរវាងនិន្នាការ និងចំណុចដៅ វាបានផ្ដល់នូវគំនិតអំពីបរិមាណនៃធនធានដែលត្រូវការ ដើម្បីសំរេចឱ្យបាននូវចំណុចដៅដែលបានកំណត់។

# ឧបសម្ព័ន្ធ គ

## វិធីសាស្ត្រគណនាសន្ទស្សន៍នៃ គអសក

សន្ទស្សន៍រួមទាំងឡាយបានត្រូវគណនាសំរាប់ គអសក នីមួយៗដើម្បីវាយតម្លៃលើការបែងចែកតាមខេត្ត/ក្រុង។ តម្លៃសន្ទស្សន៍ទាំងនេះ តំណាងឱ្យសន្ទស្សន៍ដែលត្រូវបានថ្លឹងថ្លែងស្មើៗគ្នា នៃគ្រប់សូចនាករទាំងអស់សំរាប់ គអសក ដែលមានទិន្នន័យ។

សន្ទស្សន៍រួមជាលទ្ធផលតំណាងឱ្យរូបភាពបំបែកមួយ (Disaggregate Picture) របស់ស្ថានភាពប្រទេសទាក់ទិននឹងការកំណត់សូចនាករណាមួយសំរាប់ គអសក។ លទ្ធផលនៃការធ្វើបែបនេះអនុញ្ញាតិឱ្យមានការធ្វើចំណាត់ថ្នាក់ខេត្ត/ក្រុងជាបីប្រភេទ ដែលតំណាងអោយស្ថានភាពប្រសើរ មធ្យម និងអន់ជាងគេ ដែលយោងទៅតាមស្ថានភាពជាក់ស្តែងរបស់ខេត្តទាំងនោះ។

ការគណនាសន្ទស្សន៍សំរាប់ គអសក មានដូចខាងក្រោមៈ

### ១. ប្រក្រតីនីយកម្មនៃតម្លៃសូចនាករ ($NIV_i$)

សូចនាករទាំងអស់ត្រូវបានធ្វើប្រក្រតីនីយកម្ម ដោយប្រើរូបមន្តដូចខាងក្រោមៈ

$$NIV_i = \frac{(VI_{ij} - MinVI_{ij})}{(MaxVI_{ij} - MinVI_{ij})}$$

ដែល
- i: ចំនួនសូចនាករ, i = 1 ….n
- j: ចំនួនខេត្ត/ក្រុង, j = 1 …24
- NIV : ប្រក្រតីនីយកម្មនៃតម្លៃសូចនាករ
- VI: តម្លៃនៃសូចនាករ (i) នៅក្នុងខេត្ត/ក្រុង (j)
- MinVI: តម្លៃអប្បបរមានៃសូចនាករ (i) នៅក្នុងខេត្ត/ក្រុង (j)
- MaxVI: តម្លៃអតិបរមានៃសូចនាករ (i) នៅក្នុងខេត្ត/ក្រុង (j)

ចំនួននៃសូចនាករ (i) មានលក្ខណៈខុសៗគ្នាតាមខេត្ត/ក្រុងយោងតាមទិន្នន័យដែលមាន។

សន្ទស្សន៍ទាំងនេះត្រូវបានគណនាលើខេត្ត-ក្រុងចំនួន ២៤ (j)

### ២. ផលបូកសូចនាករទាំងអស់ដែលត្រូវបានធ្វើប្រក្រតីនីយកម្ម ($NIV_i$) និងការចែកតាមចំនួនរបស់សូចនាករ

តម្លៃសន្ទស្សន៍ប្រែប្រួលពី 0 (ស្ថានភាពអាក្រក់បំផុត) ទៅ ១ (ស្ថានភាពល្អបំផុត)។ នៅពេលដែលសូចនាករតំណាងឱ្យស្ថានភាព "អវិជ្ជមាន" (ឧទាហរណ៍ ភាពក្រីក្រ) តម្លៃដែលត្រូវបានធ្វើប្រក្រតីនីយកម្ម ត្រូវបានដាក់បញ្ច្រាសមកវិញ ដើម្បីអាចធ្វើការបូកសរុបជាមួយនិងសូចនាករដទៃទៀត ($1 - NIV_i$)។

ឧទាហរណ៍ ក្នុងករណី គអសក៤ ស្តីពីមរណភាពរបស់កុមារ សូចនាករចំនួនបួន ដូចតទៅនេះ ត្រូវបានប្រើនៅក្នុងការគណនាសន្ទស្សន៍រួមៈ (១) អត្រាមរណភាពកុមារក្រោមអាយុ៥ឆ្នាំ (២) អត្រាមរណភាពទារក

(៣) សមាមាត្រនៃកុមារអាយុ ៦-៥៩ខែ ដែលបានទទួលថ្នាំវីតាមីនអា (៤) សមាមាត្រនៃម្តាយ ដែលចាប់ផ្តើមបំបៅដោះទារកដែលទើបនឹងកើត ក្នុងរយៈពេល១ម៉ោងនៃកំណើត។ ក្នុងករណីសូចនាករទាំងពីរចុងក្រោយ ដែលតំណាងឱ្យស្ថានភាព "វិជ្ជមាន" ខេត្ត/ក្រុងនិមួយៗ ត្រូវបានកំណត់តម្លៃក្នុងចន្លោះរវាងលេខ 0 និង ១ ដោយផ្អែកលើសមិទ្ធិផលរបស់ខេត្ត/ក្រុងនិមួយៗ ធៀបនឹងខេត្ត/ក្រុងដទៃទៀត (ត្រូវបានគណនាតាមរូបមន្ត ដែលបានបង្ហាញខាងលើ) ។ ក្នុងករណីសូចនាករពីរខាងដើម "(១) និង (២)" ដែលតំណាងឱ្យស្ថានភាព "អវិជ្ជមាន" តម្លៃត្រូវបានកំណត់តាមរូបមន្តដូចគ្នា ប៉ុន្តែបន្ទាប់មកត្រូវបានដាក់បញ្ច្រាស់ ដោយយក ១ ដកចេញនូវតម្លៃទាំងនោះ ($1-NIV_i$) ។ ការចាំបាច់ក្នុងការធ្វើដូច្នេះ គឺដើម្បីឱ្យខេត្តទាំងឡាយណាដែលមានតម្លៃខ្ពស់បំផុត ឧទាហរណ៍ ចំពោះមរណភាពកុមារ ទទួលតម្លៃទាបបំផុតមកវិញនៅក្នុងសន្ទស្សន៍រួម។ បន្ទាប់ពីការដាក់បញ្ច្រាស់តាមវិធីនេះ គេអាចបូកសរុប និងធ្វើមធ្យមភាគលើសូចនាករទាំងបួន។